# តន្ត្រី របាំ និង ល្ខោនខ្មែរ





និពន្ធដោយៈ អេងផុន ពេជ្រតុំក្រវិល

២០០៦

www.elibraryofcambodia.org

ទទួលអំណោយបានពីលោក ខ្មៅ ឈុនសិរី ដល់ក្រុមការងារខ្មែរ
ដើម្បីទុកដាក់ក្នុង elibrary of Cambodia
៩ តុលា ២០១៥

# តន្ត្រី របាំ និងល្ខោនខ្មែរ

ពេជ្រ ទុំក្រវិល

គ្រឹះស្ថានបោះពុម្ពផ្សាយសាស្ត្រា

www.elibraryofcambodia.org

នាយកបោះពុម្ពផ្សាយ ៖ លោកខេង ពិទូកេត្យា

និពន្ធដោយ ៖ ព្រឹទ្ធាចារ្យ ពេជ្រ ទុំក្រវិល

បណ្ណាធិការអក្ខរាវិរុទ្ធ ៖ លោកឃឹម ច័ន្ទសុអហំ

អ្នករចនាទំព័រ ៖ កញ្ញាយ៉ែម ខេមចិត្តនា

ការបោះពុម្ពផ្សាយសៀវភៅនេះចូលរួមឧបត្ថម្ភដោយមូលនិធិ មេគង្គ

The publication of this book was partially

funded by the Mekong Press Foundation

ISBN-13: 978-99950-961 – 4 - 4

បោះពុម្ពនៅភ្នំពេញ ដោយរោងពុម្ព ពន្លឺខ្មែរ

www.elibraryofcambodia.org

# មាតិកា


| | |
|---|---|
| បទឧទ្ទិស | ០៩ |
| សេចក្តីថ្លែងអំណរគុណ | ១១ |
| វាចាអ្នកស្រាវជ្រាវ | ១៣ |
| កថាមុខ | ១៥ |
| តន្ត្រីនៅប្រទេសកម្ពុជា | ១៧ |
| ១- តន្ត្រីខ្មែរ | ១៩ |
| ២- តន្ត្រីខ្មែរលើ | ៣៨ |
| ៣- តន្ត្រីរបស់ខ្មែរឥស្លាម | ៥០ |
| ៤- តន្ត្រីសម័យ | ៥១ |
| របាំនៅប្រទេសកម្ពុជា | ៥៩ |
| ១- របាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យ | ៦២ |
| ២- របាំប្រពៃណី | ៧៩ |
| ៣- របាំប្រជាប្រិយ | ៨៦ |
| ទម្រង់ល្ខោនខ្មែរ | ៩៥ |
| ១- ស្បែកធំ | ៩៨ |
| ២- ស្បែកពណ៌ | ១០៣ |
| ៣- ស្បែកតូច ឬអាយ៉ង | ១០៧ |
| ៤- ល្ខោនតុក្កតា | ១១២ |
| ៥- ល្ខោនខោល ឬភាណី | ១១៨ |
| ៦- ល្ខោនយីកេ | ១៣៨ |
| ៧- ល្ខោនបាសាក់ | ១៤៤ |
| ៨- ល្ខោនមហោរី | [illegible] |


www.elibraryofcambodia.org

៩-ល្ខោនកំណាព្យ ១៥៧
១០-ល្ខោនពាលស្រី ១៦៦
១១-ល្ខោនគែន ១៧០
១២-ល្ខោនបើកបទ ១៧៤
១៣-ល្ខោនបាមោជ្ជទ័យ ១៧៧
១៤-អាយៃ ១៨១
១៥-ល្ខោនភ្លេងការ ១៨៥
១៦-ល្ខោននិយាយ ១៩០
១៧-ល្ខោនចម្រុះ ១៩៥
១៨-ការនិទានរឿង ២០០
១៩-ចម្រៀងខ្សែមួយ ឬចម្រៀងសាដៀវ ២០៧
២០-ចម្រៀងចាប៉ី ២១២
២១-សៀកខ្មែរ ២១៧
សៀវភៅបោះពុម្ពរួច ២២១
ស្នាដៃរឿងល្ខោន ២២២
ប្រវត្តិរូប ២២៤
ឯកសារពិគ្រោះ ២២៦



www.elibraryofcambodia.org



ព្រះមហាក្សត្រិយានី

ស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា

ព្រះមហាវីរក្សត្រី ជាតិសង្គារៈ

www.elibraryofcambodia.org



សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ

ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ

ព.ស. ២៤២៧ - ២៥១៣

www.elibraryofcambodia.org

# បទឧទ្ទិស

ទូលព្រះបង្គំយើងខ្ញុំ សូមលើកហត្ថប្រណម្យអញ្ជលី បង្គំផ្ចង់កម្សាន្តដាក់លើសិរសីឧទ្ទិសស្នាដៃ **«តន្ត្រី របាំ និងល្ខោនខ្មែរ»** ថ្វាយចំពោះដួងព្រះវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រជាទីសក្ការៈ និងព្រះវិញ្ញាណក្ខន្ធព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរតនសិរីវឌ្ឍនា ព្រះមហាវីរក្សត្រីនៃមាតុភូមិ និងប្រជាជនជាទីសក្ការៈ កាលព្រះអង្គទ្រង់គង់ព្រះជន្មនៅឡើយ ព្រះអង្គទ្រង់បានបំពេញមហាពលិកម្មដ៏ធំធេងដោយបង្ហាញបំណាយព្រះកាយពលគ្មានគិតការនឿយហត់ និងទ្រង់បានបរិច្ចាគព្រះរាជទ្រព្យដ៏ច្រើនសន្ធឹកសន្ធាប់ ជុំវិញ និងណែនាំការបង្កើតស្នាដៃការសិក្សាស្រាវជ្រាវចងក្រង និងកត់ត្រាទុកលើកតម្កើងវប្បធម៌ជាតិកម្ពុជាទាំងវប្បធម៌សិល្បៈ ដែលមានចរន្តចេញពីអ្នកប្រាជ្ញរាជបណ្ឌិត ទាំងសិល្បៈដែលមានចរន្តចេញពីគំនិតច្នៃប្រឌិតរបស់ប្រជាជន មហាជនអ្នកស្រែចម្ការឲ្យមានកម្រិតខ្ពស់សម្បូរបែប និងរីកចម្រើនឡើងគួរជាទីមោទនៈយ៉ាងក្រៃលែងៗ

ព្រះមហាវីរភាពរបស់ព្រះអង្គ ក្នុងការបង្កើតសាមគ្គីផ្ទៃក្នុងជាតិ តាមរយៈការកសាងវប្បធម៌សិល្បៈ ការលើកស្ទួយវប្បធម៌ជាតិឲ្យថ្កុំថ្កើងរុងរឿងល្បីរន្ទឺ ធ្វើឲ្យខ្មែរមានកេរ្តិ៍ឈ្មោះពីរោះក្នុងលោក និងជាពុម្ពគំរូដ៏ថ្លៃថ្លាកាត់ថ្លៃពុំបាន ដែលកុលបុត្រកុលធីតាខ្មែរគ្រប់ជំនាន់ សូមកត់ត្រាទុកក្នុងក្រអៅបេះដូងរបស់ខ្លួនជានិច្ចៗ

សូមឧទ្ទិសស្នាដៃសៀវភៅ **«តន្ត្រី របាំ និងល្ខោនខ្មែរ»** ដែលកើតឡើងដោយក្រុមប្រឹក្សានេះ ថ្វាយចំពោះដួងវិញ្ញាណក្ខន្ធសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ដែលជាអតីតព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ ព្រះមហាវីរបណ្ឌិតជាតិកម្ពុជា ដែលក្នុងមួយព្រះជន្មព្រះអង្គ ព្រះអង្គទ្រង់បានបំពេញមហាពលិកម្មដ៏ធំធេង

www.elibraryofcambodia.org

ដើម្បីជាតិមាតុភូមិកម្ពុជា ពិសេសក្នុងវិស័យព្រះពុទ្ធសាសនា វិស័យវប្បធម៌ សិល្បៈ អក្សរសាស្ត្រជាតិ និងលើកកម្ពស់សីលធម៌សង្គមឲ្យខ្ពស់ត្រដែតតាមរយៈព្រះសកម្មភាព ព្រះរាជបន្ទូលទូន្មានប្រៀនប្រដៅ និងស្នាមព្រះហស្តដែលព្រះអង្គទ្រង់បានរៀបរៀងនិពន្ធឡើង ដ៏ច្រើនសន្ធឹកសន្ធាប់ជាប្រទីបបំភ្លឺផ្លូវដល់កុលបុត្រកុលធីតាកម្ពុជាគ្រប់ជំនាន់ៗ

ព្រះរាជបន្ទូល ដែលជាព្រះបណ្តាំចែងជាកំណាព្យថា ៖

រីរូបនៃសព្វសត្វ តែងវិបត្តិចាស់ជរា
ឯនាមនិងគោត្តា ឥតជរាដូចរូបឡើយ
សូន្យបាត់តែរូបទៅ កេរ្តិ៍ឈ្មោះនៅជិតបង្កើយ
បើគេមិនតោះតើយ គេអាចស្គាល់យូរអង្វែង។

គឺជាថាមពលដ៏ខ្លាំងក្លា ជំរុញដួងចិត្តខ្មែរគ្រប់រូបឲ្យវៀរចាកអំពើបាប អកុសល កសាងតែអំពើល្អ កេរ្តិ៍ល្អ ដំណែលល្អ ឈ្មោះល្អ គំរូល្អតកូនតចៅតៅសន្តាន ដើម្បីបានជាផលប្រយោជន៍ដល់ជាតិមាតុភូមិ និងប្រជាជនកម្ពុជាព្រមទាំងមនុស្សជាតិទូទៅ ឲ្យបានរីកចម្រើនរុងរឿង និងសុខដុមរមនា។

សូមដួងព្រះវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ ព្រះមហាវីរក្សត្រជាទីសក្ការៈ និងសម្តេចព្រះមហាសុមេធាធិបតី ទ្រង់បានយាងទៅសោយសុខនៅសុគតិភពដោយស្ងប់រំងាប់ ហើយសូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសន្តោសត្រាប្រណី ជួយជាកបែរប្រែក្រោយប្រសិទ្ធពរជ័យដល់មាតុភូមិកម្ពុជា និងជនជាតិខ្មែរទាំងអស់ សូមឲ្យបានរួចរំដោះផុតអស់គ្រោះភ័យ បានសុខសន្តិភាព និងស្ថិតស្ថេរគង់វង្សជាអមតៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

ពេជ្រ ជុំត្រាវុល



www.elibraryofcambodia.org

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណជាពន្ទឹក ចំពោះគ្រូឧបជ្ឈាយាចារ្យទាំងអស់ ទាំងគ្រហស្ថ ទាំងព្រះសង្ឃ ពិសេសចំពោះភរិយាខ្ញុំ និងបុត្រាបុត្រីទាំងអស់ ដែលបានធ្វើពលិកម្មដ៏ធំធេងក្នុងការជួយជំរុញ និងបង្កការងាយស្រួលសព្វបែបយ៉ាងដើម្បីឲ្យខ្ញុំមានឱកាស និងលទ្ធភាពធ្វើការងារសិក្សាស្រាវជ្រាវក្នុងរយៈកាលច្រើនឆ្នាំ រហូតអាចចងក្រង និងបោះពុម្ពជាឯកសារទុកជាផលប្រយោជន៍សម្រាប់កុល-បុត្រកុលធីតាខ្មែរជំនាន់ក្រោយៗ បានទៀតផង។

ក្នុងន័យនេះផងដែរ ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគ្រឹះស្ថានបោះពុម្ពផ្សាយសាស្ត្រា ដែលទទួលការឧបត្ថម្ភបោះពុម្ពពីមូលនិធិមេគង្គ (Mekong Press Foundation) ក៏ដូចជាការចូលរួមចំណែកក្នុងការជួយជ្រោមជ្រែងឲ្យសៀវភៅ **«តន្ត្រី របាំ និងល្ខោនខ្មែរ»** នេះ អាចបោះពុម្ពផ្សាយជារូបរាងឡើង។

សូមលោក លោកស្រី លោកគ្រូ អ្នកគ្រូដ៏មានគុណទាំងអស់ ភរិយាសំណព្វចិត្ត និងបុត្រាបុត្រីទាំងអស់ បានសមប្រកបតែនឹងសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ប្រការ៕

ពេជ្រ ទុំក្រវិល

www.elibraryofcambodia.org

# វាចាអ្នកស្រាវជ្រាវ

ក្នុងមនសិការភ្ញាក់រលឹកនឹកខ្មាសអៀន ខ្លាចក្រែងវិប្បដិសារី ដេរស្តីបន្ទោសថា **«មានមាសហើយឥតក្រដាសខ្ចប់»** ដោយមិនបានយកចិត្តទុកដាក់ និងបណ្តែតបណ្តោយឲ្យមរតក ដែលជាគំនិតច្នៃប្រឌិតរបស់បុព្វបុរសជូនតាខ្លួន ដ៏សម្បូរបែបត្រូវលំលាយ ឬវិនាសទៅដោយងាយៗនោះ ដែលអាចបង្កើតឲ្យមានពាក្យដំណៀលថា ជាអ្នករមិលគុណចំពោះបុព្វបុរស ឬមាតុភូមិដ៏មានគុណនោះ ទើបខ្ញុំបាទជាអ្នកស្រាវជ្រាវដែល÷

- មានសមត្ថភាពតិចតួចស្តួចស្តើង
- ក្នុងលទ្ធភាពក្រីក្រលំបាកលំបិនខ្សត់ខ្សោយ
- ឯកសារយោងខ្វះខាតអត់ខាត់ ដូចសំពត់ទើចខ្ចីមុខយូរ ក្រោយព្យាយាមចំណាយពេលអស់ច្រើនឆ្នាំ ដើម្បីកត់ត្រាទុកនូវមរតក វប្បធម៌សិល្បៈអរូបី ដែលជាចម្រៀកដ៏តូចមួយ នៃអត្តសញ្ញាណជាតិកម្ពុជា ជាដៃគូនឹងសិល្បៈរូបីយមានសំណង់ប្រាសាទបុរាណ សិលាចារឹកកប់ពាន់ ដែលពាយស្ទើរពាសពេញដែនដីឥណ្ឌូចិនទាំងមូល ពោលគឺនៅប្រទេសសៀម (ថៃ) ក៏មានប្រាសាទខ្មែរ នៅប្រទេសលាវក៏មាន ប្រាសាទខ្មែរ នៅប្រទេសវៀតណាមខាងត្បូងអតីតៈដែនដីកម្ពុជាក្រោម ក៏មានប្រាសាទខ្មែរ និងនៅលើទឹកដីកម្ពុជាដ៏តូច ដែលយើងកំពុងរស់រានមានជីវិតសព្វថ្ងៃនេះ ក៏មានប្រាសាទយ៉ាងច្រើនសន្ធឹកសន្ធាប់ស្ទើរគ្រប់ខេត្តខណ្ឌដែរៗ

យើងខ្ញុំក្រុមអ្នកកត់ត្រាទាំងអស់យល់ច្បាស់ណាស់ថា ការកត់ត្រារបស់យើងនេះមិនទាន់បានល្អគ្រប់សព្វនៅឡើយទេ ព្រោះវាជាបេការដែលរែងរេកពាក

www.elibraryofcambodia.org

បទពិសោធផ្ទាល់ខ្លួន និងការចេះចាំតៗគ្នា រួមផ្សំនឹងការសិក្សាស្រាវជ្រាវប៉ុណ្ណោះ ប៉ុន្តែវាគ្រាន់តែ **«គ្រាន់បើជាងគ្មាន»** ប៉ុណ្ណោះៗ ហេតុនេះសូមអស់លោកអ្នកប្រាជ្ញ រាជបណ្ឌិត អ្នកស្នេហាជាតិ ស្នេហាវប្បធម៌សិល្បៈជាតិ មេត្តាកុំមើលបំណាំ សូមជួយកែលម្អ ជួយលាបក្រែម ផាត់ម្សៅបន្ថែម ធ្វើយ៉ាងណាឲ្យការកត់ត្រាទាំងនេះបានជាព័ត៌មានដ៏សម្បើម និងមានប្រយោជន៍ដល់កុលបុត្រកុលធីតាខ្មែរក្នុងគ្រប់ជំនាន់ ដោយក្ដីអនុគ្រោះផងចុះៗ

ពេជ្រ ជុំក្រវិល

អ្នកនិពន្ធ និងដឹកនាំរឿងល្ខោន

www.elibraryofcambodia.org

# អារម្ភកថា

ដំណើរបោះជំហាន ទៅក្នុងសហស្សវត្សថ្មី នៃយុគសម័យសកលភាវូបនីយកម្ម និងទំនើបកម្មសង្គម ទោះចង់ ឬមិនចង់ ពិតជាជៀសមិនផុតពីការជះឥទ្ធិពល ដល់អតីតកាលដ៏រុងរឿងនៃវប្បធម៌ អរិយធម៌ និងអត្តសញ្ញាណជាតិខ្មែរដ៏ចំណាស់ ក្នុងតំបន់អាស៊ីអាគ្នេយ៍ឡើយ។

ភាពចំណាស់ និងកិត្តិសព្ទដ៏ល្បីល្បាញ នៃតម្លៃវប្បធម៌សិល្បៈខ្មែរ ពិតជាបានបង្ហាញឲ្យពិភពលោកទាំងមូលទទួលស្គាល់ និងកោតស្ញប់ស្ញែង នូវទេពកោសល្យដ៏ប៉ិនប្រសប់ របស់ស្នាដៃបុព្វស្ថាបត្យករ និងសិល្បករខ្មែរ ដែលប្រកបដោយគំនិតសិល្បៈច្នៃប្រឌិតកម្រិតខ្ពស់ តាមរយៈសំណង់ស្ថាបត្យកម្ម ចម្លាក់ ប្រាសាទតន្ត្រី របាំជាដើម ដែលទាំងនេះ បាននាំមកនូវវិសាលភាពដ៏ធំធេង ចំពោះសង្គមជាតិ ដ៏ដូចជាមោទនភាពរបស់ប្រជាជាតិខ្មែរយើងផងដែរ។ ប៉ុន្តែគួរឲ្យស្ដាយ សំណល់នៃតម្លៃសោភ័ណវប្បធម៌សិល្បៈខ្មែរនាអតីតកាល កំពុងប្រឈមទៅនឹងភាពស្រុតចុះ និងសាបរលាបបន្តិចម្តងៗ ក្នុងពេលបច្ចុប្បន្ននេះ។ ទាំងនេះ មកពីយើងម្នាក់ៗភ្លេចខ្លួន ដោយកំពុងតែលង់លក់ ក្នុងសុបិននៃអតីតកាលដ៏រុងរឿង ដែលប្រាសចាកពីសច្ចភាព ក្នុងការទទួលខុសត្រូវ គោរព និងថែរក្សាខ្ពស់ នូវតម្លៃជាសកលចំពោះព្រលឹងវប្បធម៌ និងអត្តសញ្ញាណសិល្បៈជាតិដែលមានស្រាប់។

ភាពអន់ខ្សោយ និងមោទនភាពជ្រុលហួសហេតុនេះហើយ ដែលបណ្ដាលឲ្យប្រជាជាតិខ្មែរមួយចំនួន មិនយល់ពីតម្លៃ និងព្រលឹងពិតនៃវប្បធម៌សិល្បៈជាតិ បន្ថែមលើគំនិតដែលមិនយល់ច្បាស់ និងទស្សនៈស្រពិចស្រពិល ឬភាន់ច្រឡំ ដែលខ្លួនមានស្រាប់ហើយនោះ ដែលជាហេតុមកបំផ្លាញលក្ខណៈពិត និងទម្រង់ដើមនៃវប្បធម៌សិល្បៈរបស់ជាតិស្ទើរសូន្យបង់។

ក្នុងសេចក្ដីនានេះហើយ ទើបគ្រឹះស្ថានបោះពុម្ពផ្សាយសារសោ ធើការ

បោះពុម្ពចំពោះស្នាដៃ «**តន្ត្រី របាំ និងល្ខោនខ្មែរ**» ព្រោះដោយយើងមើលឃើញយ៉ាងច្បាស់នៃគុណសម្បត្តិ និងឧត្តមភាពនៃវប្បធម៌ សិល្បៈបុរាណខ្មែរ ដែលប្រកបដោយឧត្តមគតិជាតិនិយមពិតៗ និងចង់បង្ហាញឲ្យកូនខ្មែរជំនាន់ក្រោយ ស្គាល់ពីកិត្យានុភាព នៃវប្បធម៌សិល្បៈជាតិ ក៏ដូចជាការរួមចំណែក ក្នុងការលើកស្ទួយនូវតម្លៃនៃគំនិតច្នៃប្រឌិតរបស់បុព្វសិល្បករខ្មែរ និងបន្ថែមការយកចិត្តទុកដាក់មួយកម្រិតទៀត ក្នុងសម័យទំនើបនិយម នៃសកលភាវូបនីយកម្ម ។

សូមឲ្យព្រលឹងនៃមរតកវប្បធម៌ សិល្បៈបុរាណជាតិខ្មែរ ឋិតក្នុងសញ្ចេតនារបស់ជាតិខ្មែរគ្រប់ៗរូប...!

គ្រឹះស្ថានបោះពុម្ពផ្សាយសាស្ត្រា

www.elibraryofcambodia.org

# តន្ត្រីនៅប្រទេសកម្ពុជា



ជនជាតិខ្មែរ គឺជាជនជាតិមួយដែលមានចំណាស់ និងវត្តមានច្រើនពាន់ឆ្នាំមកហើយនៅលើទឹកដីនៃមាតុភូមិរបស់ខ្លួនសព្វថ្ងៃ ហើយជនជាតិខ្មែរនេះធ្លាប់បានកសាងអារ្យធម៌មួយឲ្យរីកចម្រើនរុងរឿងត្រចះត្រចង់ល្បីរន្ទឺពាសពេញពិភពលោកនៅក្នុងប្រវត្តិសាស្ត្រជាតិរបស់ខ្លួន ពិសេសនៅក្នុងសម័យអាណាចក្រ

www.elibraryofcambodia.org

ខ្មែរដ៏ធំធេងនៅចន្លោះសតវត្សរ៍ទី ៩ និងសតវត្សរ៍ទី ១៤ នៃគ.ស ម្យ៉ាងទៀតជន
ជាតិខ្មែរជាជនជាតិដែលមានឈាមជ័រជាអ្នកច្នៃប្រឌិត ធ្លាប់បានកសាងដោយសទ្ធា
ជ្រះថ្លានូវមហាប្រាសាទរាប់ពាន់ ដែលគេសង្កេតឃើញមានសេសសល់ជា
សំណល់ ស្ទើរពាសពេញផ្ទៃប្រទេសទាំងឡាយនៃឥណ្ឌូចិនទាំងមូល ហើយមាន
ប្រាសាទខ្លះដូចជាប្រាសាទអង្គរវត្តជាដើម បានត្រូវមនុស្សជាតិចាត់ទុកថា ជា
អច្ឆរិយវត្ថុក្នុងលោកថែមទៀតផង។

ក្រៅពីប្រាសាទ និងផ្ទាំងសិលាចារឹកដ៏ច្រើនសន្ធឹកសន្ធាប់ ជនជាតិខ្មែរនេះ បានបន្សល់ទុកនូវបទភ្លេង និងចម្រៀងច្រើនពាន់បទ និងវង់តន្ត្រីជាច្រើនវង់ ដែលមានតួនាទីខុសៗគ្នា ឯទស្សនីយភាពល្ខោនវិញ ក៏មានច្រើនទម្រង់ដែលស្ថិតក្នុងរូបភាពខុសៗគ្នាដូចជា ៖

# ១– តន្ត្រីខ្មែរ



www.elibraryofcambodia.org

**វង់ភ្លេងអារក្ខ** (សម្រាប់ពិធីខាងជំនឿអារក្ខអ្នកតា)។

ដែលមានឧបករណ៍ដូចតទៅនេះ ៖

- ស្គរដៃ ពីពីរឡើងទៅ
- ប៉ីពក (ប្រគំដាច់តែឯងពិសេសបទប្រគំ) ១
- ប៉ីបបុស ឬប៉ីអ ១
- ទ្រខ្មែរ ឬទ្រខ្សែបី ១
- ចាប៉ីដងវែង ១
- សាដៀវ ឬខ្សែមួយ ១
- ឈិង — អ្នកច្រៀង

ហើយមានបទដែលបានរកឃើញហើយចំនួន ៥៦ បទសម្រាប់ប្រារព្ធពិធីខាងជំនឿអារក្ខ អ្នកតា ដូចជាពិធីលៀងអារក្ខ បញ្ជាន់អារក្ខ ឡើងអ្នកតា ជារលាន



ខេត្ត បាត់ដំបង

www.elibraryofcambodia.org

ៗលៗ ដែលជាជំនឿដើមរបស់ប្រជាជនកម្ពុជា ដែលមានអាយុច្រើនពាន់ឆ្នាំមក ហើយ ពោលគឺតាំងពីមុនពេលដែលព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាហូរចូលមកក្នុងតំបន់ជ្រោយសុវណ្ណភូមិមកម្ល៉េះៗ

## វង់ភ្លេងអារក្ស



## ខ_វង់ភ្លេងប្រពៃណី ឬភ្លេងការ (សម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍)

ដែលមានឧបករណ៍ដូចគ្នានេះបំរើនីងវង់ភ្លេងអារក្ខគឺ

- ស្គរដៃ ២
- ទ្រខ្សែបី ឬទ្រខ្មែរ ១
- តាប៉ីដងវែង ១
- សាដៀវ ឬខ្សែមួយ ១
- ប៉ីបបុស ឬប៉ីអ ១
- ឈិង
- អ្នកច្រៀង

ហើយមានបទដែលបានរកឃើញហើយចំនួន ១៣៣ បទ សម្រាប់ប្រារព្ធពិធីអាពាហ៍ពិពាហ៍កូនប្រុស-ស្រី ដែលជាពិធីធំមានសារៈសំខាន់បំផុតសម្រាប់ជីវិតកុលបុត្រ និងកុលធីតាខ្មែរ ។ គឺជាចំណងចងភ្ជាប់គ្នារវាងគូស្វាមី និងភរិយាផង ចង



www.elibraryofcambodia.org

ភ្ជាប់គ្នាបានញាតិសាលោហិតផង និងចំណងចងជនជាតិខ្មែរ ទៅនឹងទឹកដីនៃមាតុភូមិរបស់ខ្លួនផងៗ ប្រពៃណីអាពាហ៍ពិពាហ៍នេះ កំមានអាយុយូរយារណាស់មកហើយ ដោយចម្លងយកតាមព្រះរាជពិធីអភិសេករាជព្រះថោង និងនាងនាគព្រះបឋមមហាក្សត្រខ្មែរ ដែលបានកើតមានឡើងតាំងពីកាលខាងដើមសតវត្សរ៍ទី១ នៃគ.ស នោះៗ

## វង់ភ្លេងប្រពៃណី ឬភ្លេងការ



## គ_វង់ភ្លេងពិណពាទ្យ (សម្រាប់ពិធីខាងសាសនា)

ភ្លេងពិណពាទ្យ ជាវង់ភ្លេងដែលមានប្រជាប្រិយភាពជាងគេ នៅប្រទេសកម្ពុជាៗ ជាប្រភេទតន្ត្រីបម្រើខាងសាសនា ហើយជាទូទៅគេច្រើនចែកវង់ភ្លេងពិណពាទ្យនេះជាពីរបែបគឺ ភ្លេងពិណពាទ្យវង់ធំ និងភ្លេងពិណពាទ្យវង់តូច ទៅតាមចំនួនឧបករណ៍ដែលមានៗ

**វង់ធំមានឧបករណ៍ច្រើនមុខ គឺ៖**

- រនាតឯក ១ — រនាតធុង ១
- រនាតដែក ១ (សំឡេងស្រួយ)
- រនាតថោង ១ (រនាតដែកដែរ តែសំឡេងគ្រលរជាំ)
- ស្រឡៃតូច ១ — ស្រឡៃធំ ១
- គងវង់តូច ១ — គងវង់ធំ ១
- សម្ភោរ ១ — ស្គរធំមួយគូ
- ឈិង



www.elibraryofcambodia.org

**វង់តូចមានឧបករណ៍ ៥ មុខគឺ**

- រនាតឯក ១
- ស្រឡៃ ១
- ស្គរធំមួយគូ ១
- គងវង់ធំមួយ ១
- សម្ភោរ ១

# ភ្លេងពិណពាទ្យ

## វង់ធំ




www.elibraryofcambodia.org

# ភ្លេងពិណពាទ្យ
## វង់តូច




ដែលមានបទភ្លេងគេឃើញហើយមានចំនួន ២៥០ បទ សម្រាប់កំដរពិធីផ្សេងៗខាងសាសនាផង សម្រាប់ជូនទម្រង់ល្ខោនក្បាច់បុរាណ ឬល្ខោនព្រះរាជទ្រព្យផង ជូនទម្រង់ល្ខោនពោលស្រីផង ជូនល្ខោនស្រមោលស្បែកធំផង ស្បែកតូចផង ល្ខោនបើកបទ និងល្ខោនភាណី ឬល្ខោនខោល ដែលសុទ្ធតែជាទម្រង់ល្ខោនខ្មែរ ដែលមានអាយុច្រើនសតវត្សរ៍មកហើយផង។

www.elibraryofcambodia.org

**ឃ-វង់ភ្លេងមហោរី** (សម្រាប់ប្រគុំកំដរបរិយាកាសសប្បាយរីករាយ)

ដែលវង់តូចមានឧបករណ៍ដូចតទៅនេះ ÷

- រនាតឯក ១ - រនាតធុង ១
- ខ្លុយ ១ - តាខេ ឬក្រពើ ១
- ទ្រអ៊ូ ១ - ទ្រសោតូច ១
- ស្គរថូនរមនា - ឈិង - អ្នកច្រៀង

ហើយបើជាវង់ធំ គេមានថែមឧបករណ៍ខ្លះបន្ថែមទៀតដូចជា ÷

- ទ្រសោធំ ១ - ទ្រធេ-អ៊ូ ១ (ដើរផ្លូវទ្រអ៊ូ)
- ទ្រធេ-សោ ១ (ដើរផ្លូវទ្រសោតូច)

មិនត្រឹមតែប៉ុណ្ណោះឡើយ នៅពេលក្រោយមកទៀត គេបានច្នៃដោយបន្ថែមឧបករណ៍តន្ត្រីបស្ចិមប្រទេសខ្លះដូចជាបង់ហ្សូ ម៉ង់ដូលីន អាម៉ូនីញ៉ូម ឬកុំអកដែលគេនិយមហៅថា «មហារីច្នៃ» ថែមទៀតផង។



www.elibraryofcambodia.org

វង់ភ្លេងមហោរី ដែលអាចក្លាយមកពីពាក្យសំស្ក្រឹតថា មនោហារ (ប្រុស) មនោហារី (ស្រី) ដែលសុទ្ធតែជាអ្នកបម្រើដំគាប់ព្រះទ័យ ខាងប្រគំតន្ត្រី និងចម្រៀងថ្វាយព្រះអាទិទេព នៅតាមប្រាសាទនានា ក្នុងសម័យបុរាណនោះ មានបទដែលយើងបានរកឃើញហើយចំនួន ៦៦៤ បទ សម្រាប់កំដរតាមការសប្បាយរីករាយ ក្នុងពិធីបុណ្យគ្រួសារ ឬបុណ្យតាមភូមិ-ស្រុក ពិធីជប់លៀង និងសម្រាប់ជូនល្ខោនមហោរីផង។

## វង់ភ្លេងមហោរី




www.elibraryofcambodia.org

## ខ. វង់ភ្លេងពន្រ្ទីគងស្គរ (សម្រាប់ពិធីខាងសាសនា)

ដែលមានឧបករណ៍ ÷

- ស្គរធំ ១ ដាក់តម្កល់លើជើងស្គរយ៉ាងខ្ពស់
- គងដោះធំ ១ ព្យួរនឹងរនង ដែលមានឆ្លាក់ជាក្បាច់រូបនាគ
- ទ្រខ្សែបី ឬទ្រខ្មែរ ១
- ប៉ីអ ឬប៉ីបបុស ១
- ចាប៉ីដងវែង ១
- ស្គរដៃ ២
- អ្នកចម្រៀង

សព្វថ្ងៃនេះ គេសង្កេតឃើញវង់ភ្លេងគងស្គរនេះ មានសេសសល់នៅក្នុងខេត្តកំពត ខេត្តតាកែវ និងខេត្តកំពង់ចាម សម្រាប់ប្រគំក្នុងពិធីបុណ្យខាងព្រះពុទ្ធសាសនា និងពិធីបុណ្យផ្សេងៗទៀតផង។



www.elibraryofcambodia.org

# វង់ភ្លេងគងស្គរ




www.elibraryofcambodia.org

## ច_វង់ឆៃយ៉ាំ (សម្រាប់ពិធីដង្ហែក្បួននានា)

មានឧបករណ៍÷

- ស្គរឆៃយ៉ាំមួយចំនួន
- ឆាប ២
- គងម៉ង់ ១
- ពេលខ្លះមានឈិង និងទ្រថែមទៀតផង ហើយនិងចម្រៀងច្រៀង

វង់ឆៃយ៉ាំនេះសម្រាប់ពិធីដង្ហែក្បួននានា ដែលសប្បាយរីករាយ និងខាងផ្នែកសាសនា ឬពិធីបុណ្យទានធម្មតាដូចជា÷ ដង្ហែផ្កា ដង្ហែអង្គកឋិន ពិធីបំបួននាគ ឬពិធីសម្ពោធសមិទ្ធិថ្មីផ្សេងៗ



www.elibraryofcambodia.org

# ទង់ភ្លេងឆៃយ៉ាំ




www.elibraryofcambodia.org

## ឆ-វង់តន្ត្រីទ្រៀមមឹង ឬធម្មំ តន្ត្រីម៉ូង ឬម៉ងគ្រុំ (សម្រាប់កំដរសព)

ជាវង់តន្ត្រីដែលសម្ដែងអនិច្ចាពីជីវិត «វាលវដ្ដសង្សារ» មានតួនាទីសម្រាប់កំដរសពៗ ពិសេសក្នុងពេលតម្កល់សពមាតា បិតា ឬគ្រូបាធ្យាយ គ្រូចៅអធិការវត្តជាដើមៗ ឯឧបករណ៍មាន÷

-គងវង់ចំណិតខែ ដែលមានផ្លែ ៨ ឬ ៩ (មានរូបចម្លាក់នៅអង្គរ) ជាតំណាងតំណក់ទឹកភ្លៀង

-ស្រឡៃតូចមួយ (ជាតំណាងខ្យល់ធម្មជាតិ)

-ស្គរធំមួយ និងគងដោះធំ ២ (ជាតំណាងផ្គររន្ទះ)

-ក្រាប់ដើមឫស្សីមួយកំណាត់

-ចម្រៀងយ៉ាងកម្សត់



www.elibraryofcambodia.org

វង់តន្ត្រីទាំងមូល ជានិមិត្តនៃការវិលកើត វិលស្លាប់ ក្នុងវដ្តសង្សារ ដូចទឹកសមុទ្រ និងទឹកទន្លេ ស្ទឹង ត្រូវកម្ដៅហួតជាពពកអណ្ដែតឡើងលើអាកាសវេហាស៍ រួចត្រូវខ្យល់ត្រជាក់បក់បោកឲ្យបែកធ្លាក់ ជាតំណក់ទឹកភ្លៀងស្រក់ចុះមកលើផែនដីជ្រាបចូលក្នុងបឹង ស្ទឹង ទន្លេ សមុទ្រវិញៗ

ក្នុងពេលប្រគំដើម្បីជានិមិត្តនៃការ «បែកកាយ រំលាយខន្ធ» នោះតាមទំនៀមទម្លាប់ តន្ត្រីករទាំងអស់ត្រូវអង្គុយងាកចេញពីគ្នា ឬកំអង្គុយទល់ខ្នងគ្នាៗ

## វង់តន្ត្រី ឆ្នាមមឹង ឬម៉ុងគ្រី




www.elibraryofcambodia.org

## ៥-វង់តន្ត្រីស្គរឈ្នះ ឬស្គរយោន (សម្រាប់ពិធីដង្ហែសព)

មានឧបករណ៍ ៖

-ស្គរយោន ១ ជាមេ វាយដោយដៃទាំងសងខាង «ដើរសាច់បទ»

-ស្គរយោន ២ វាយដោយអន្ទង បញ្ចប់សង្វាក់នីមួយៗ ស្គរនេះមានខ្សែពាក់ស្ពាយនឹងក ឬគំបន្ទាក់ស្គរចំពីមុខ

-ស្រឡៃតូចមួយ

វង់តន្ត្រីស្គរឈ្នះ ឬស្គរយោននេះ មានតួនាទីសម្រាប់ដង្ហែសពទៅកប់ ឬបូជា ជាការកិច្ចចុងក្រោយសម្រាប់ជីវិតមនុស្សៗ



www.elibraryofcambodia.org

# វង់តន្ត្រី ស្គរឈ្នះ ឬស្គរយោន



ក្រៅពីវង់តន្ត្រីដែលរៀបរាប់ដោយសង្ខេបខាងលើនេះ យើងនៅមានវង់ភ្លេង ដែលស្ថិតនៅជាប់តាមទម្រង់ល្ខោននីមួយៗ ហើយជាសញ្ញាសម្គាល់លក្ខណៈពិសេសរបស់ទម្រង់ល្ខោនទាំងនោះផង ដូចជាវង់ភ្លេងសម្រាប់ទម្រង់ «យីកេ» ដែលមានស្គរយីកេពី ២ ដល់ ១៣ ស្គរ និងទ្រអ៊ូ ១ ព្រមទាំងស្រឡៃមួយផង ហើយមានបទភ្លេង និងចម្រៀងជាង ៨០ បទៗ

ចំណែកឯតន្ត្រីសម្រាប់ «ល្ខោនបាសាក» វិញមានឧបករណ៍ជាច្រើន ដូចជា÷

- ទ្រអ៊ូចំហៀង ១
- ទ្រជេ ១
- ឃឹមតូច ១
- ឃឹមធំ ១
- ឈិង, ប៉ោ, ឡោ, គា (ឆាប, ប៉ាន់, ឃ្មោះគង)
- ស្គរឡុក ១ (ស្គរតូចវាយដោយកូនអន្ទូង)
- ស្គរធំ ១
- ខ្លុយ ១

ហើយមានបទដែលបានគេឃើញហើយ រហូតដល់១៨៥បទឯណោះ។

www.elibraryofcambodia.org

# ២–តន្ត្រីខ្មែរលើ



www.elibraryofcambodia.org

## ក-ចង់គងស្ពាន់ ឬសំរិទ្ធ

(ជនជាតិ ទំពួន-គ្រឹង-ព្នង-ព្រៅ-ចារ៉ាយ)



ដែលមានចំនួនគងតិច ឬច្រើនទៅតាមពិធី៖

-គង ១៣ -គង ១២

-គង ៨ -គង ៦

-គង២ (ផ្សំផ្គុំកូនចៅ)

www.elibraryofcambodia.org

## ខ-ចង់តន្ត្រី ហ្គង ប. ប្រគងបុស្សី





www.elibraryofcambodia.org

## គ-ធីចប៊ុត ប្ប៊ុចប៊ុ (ស្គរបំពាច់ប្រស្សៀនះ)





www.elibraryofcambodia.org

# ឃ-ហ្គួចណោត (ទនាតបំពង់ឫស្សី)





www.elibraryofcambodia.org

# ៦_ម៉ុម



ឧបករណ៍តន្ត្រី ម៉ុម
(រូបចម្លាក់ប្រាសាទបាយ័ន)



ការប្រគំឧបករណ៍ ម៉ុម
(ខេត្តរតនគិរី)

www.elibraryofcambodia.org

## ច_ហ្គងរិង (គងរិង) និងន្លូម (ខ្លុយ)



ហ្គងរិង (គងរិង)



ន្លូម (ខ្លុយ)

www.elibraryofcambodia.org

# ឆ-ហេតហូត



ឧបករណ៍តន្ត្រី ហេតហូត

www.elibraryofcambodia.org

# ៥_ជីងរាង (ចាប៉ីឃ្លោក)





www.elibraryofcambodia.org

## ឈ-តន្ត្រីជនជាតិស្ទួយ (ត៌ំពង់ស្លឹ)



ញ-តន្ត្រីភ្លុយ ជនជាតិពារ៍ ភ្នំក្រវាញ




ដ-ចង់តន្ត្រីស្គរលរបស់ជនជាតិស្មៀង



(ខេត្តក្រចេះ)

www.elibraryofcambodia.org

## ឋ-តន្ត្រីជនជាតិកួយ (វង់ភ្លេងលប៉េងលប៉ង)





www.elibraryofcambodia.org

# ៣-តន្ត្រីអារក្ខខ្មែរឥស្លាម





www.elibraryofcambodia.org

# ៤- តន្ត្រីសម័យ

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

## បទភ្លេង និង ទំនុកច្រៀង

ចំនួន ១៦



ដែលព្រះរាជនិពន្ធ ដោយស្នាព្រះហស្ដ
នៃ សម្ដេចព្រះឧបយុវរាជ
នរោត្តម-សីហនុ
ក្នុង ឆ្នាំ ១៩៤៥-១៩៥០

www.elibraryofcambodia.org

# RECUEIL de CHANTS



RECUEIL de CHANTS


| | Pages |
|---|---|
| *Phnom-Penh* | 4 |
| *Monica* | 6 |
| *La Forêt Enchantée* | 8 |
| *Passion* | 10 |
| *Le soir où je t'ai rencontrée* | 12 |
| *Chérie* | 14 |
| *Brise de Novembre* | 16 |
| *Phnom Koulen* | 18 |
| *Séduction* | 20 |
| *Amour sans Espoir* | 22 |
| *Prière dans la Nuit* | 24 |
| *Nouvel An* | 26 |
| *Si je pouvais t'aimer* | 28 |
| *Complainte* | 30 |
| *Evanescence* | 32 |
| *Regret* | 34 |
| *Nuit Froide* | 36 |
| *Love Star* | 38 |
| *Ironie* | 40 |
| *Nostalgie* | 42 |
| *Beauté de Kep* | 44 |
| *Charmante* | 46 |
| *Rose de Phnom-Penh* | 48 |
| *Ne vous moquez pas de mon Amour* | 50 |
| *Sakrava* | 52 |
| *Luang Prabang* | 54 |
| *Fleur de Vientiane* | 56 |
| *Revoir Java* | 58 |
| *Good bye, Bogor* | 60 |
| *Nostalgie de la Chine* | 62 |


## ប្រវត្តិតន្ត្រីសម័យ

ប្រវត្តិតន្ត្រីសម័យនៅប្រទេសកម្ពុជា បើតាមឯកសារមហាបុរសខ្មែរបានឲ្យដឹងថា តន្ត្រីសម័យនេះបានហូរចូលមកប្រទេសខ្មែរពីបស្ចិមប្រទេស ពិសេសក្នុងរជ្ជកាល ព្រះបាទ នរោត្តម (១៨៥៩-១៩០៤?) ពោល គឺក្នុងពេលដែលមានវត្តមានអាណា

www.elibraryofcambodia.org

ព្យាបាលបារាំង។

ក្នុងពេលដែលគេចូលមកត្រួតត្រាលើប្រទេសកម្ពុជានេះ ក្រៅពីអ្នកធ្វើការរដ្ឋបាល និងកម្លាំងទ័ព ពួកបារាំងបាននាំទាំងទាហានខាងភ្លេងត្រែ សម្រាប់ពិធីផ្សេងៗ ខាងទ័ពរបស់គេមកជាមួយផង។ ប៉ុន្តែពេលនោះខ្មែរហាក់ដូចជាមិនទាន់បានទទួលយកនូវឥទ្ធិពលនៃភ្លេងនោះនៅឡើយ។

រហូតមកដល់ គ.ស ១៨៧២ ក្នុងព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះអង្គទៅកាន់ក្រុងហុងកុង ក្រុងម៉ាកាវ ដែលកាន់កាប់ដោយកម្លាំងទ័ពចក្រភពអង់គ្លេស និងក្រុងម៉ានីលនៃប្រទេសហ្វីលីពីន ដែលកាន់កាប់ដោយអេស្ប៉ាញ៉ុល នោះទើបខ្មែរបានចាប់ផ្តើមទទួលយកឥទ្ធិពលនៃតន្ត្រីបស្ចិមប្រទេសនេះ។ ដោយមុនពេលយាងនិវត្តន៍មកកាន់មាតុភូមិកម្ពុជាវិញ ព្រះបាទនរោត្តមទ្រង់បានទទួលនូវតង្វាយជាកងទ័ពម៉ានីល ដែលក្នុងនោះមានទាំងទ័ពភ្លេងត្រែនោះផង ពីលោក Gouverneur អេស្ប៉ាញ៉ុល ហើយនាំឲ្យមករស់នៅក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា ដែលព្រះអង្គ សព្វព្រះរាជហឫទ័យផ្គត់ផ្គង់ និងប្រទានបណ្តាសក្តិឲ្យបានគ្រប់ៗគ្នាផង ហើយចាត់ចែងលំនៅដ្ឋានក្នុងភូមិមួយដាក់ឈ្មោះថា ភូមិម៉ានីលស្ថិតនៅជាប់នឹងរបងព្រះបរមរាជវាំង ប៉ែកខាងក្រោយ។ គឺចាប់ពីពេលនោះមកហើយ ដែលខ្មែរបានទទួលយកដោយផ្ទាល់ នូវឥទ្ធិពលតន្ត្រីបស្ចិមប្រទេសនេះ។

ក្រោយពីបានមករស់នៅប្រទេសកម្ពុជា ក្រោមព្រះរាជកិច្ចឧបត្ថម្ភរបស់ព្រះមហាក្សត្រខ្មែរ ពួកទ័ព និងតន្ត្រីករម៉ានីល ក៏បានបំពេញភារកិច្ច ក្នុងវង់ភ្លេងត្រែសម្រាប់ព្រះរាជពិធីនានា និងបានកសាងគ្រួសារជាមួយជនជាតិខ្មែរ ហើយបានបង្រៀនបន្តនូវចំណេះដឹងតូរ្យតន្ត្រីខាងបស្ចិមប្រទេសនេះ មកឲ្យកូនខ្មែរថែមទៀតផង។

នៅក្នុងប្រវត្តិដ៏យូរលង់ ពោលគឺតាំងពីរាជព្រះបាទនរោត្តម (១៨៥៩-១៩០៤) រាជព្រះបាទស៊ីសុវត្ថិ (១៩០៤-១៩២៧) រាជ ព្រះបាទ ស៊ីសុវត្ថិមុនីវង្ស (១៩២៧-

www.elibraryofcambodia.org

១៩៤០) រាជព្រះបាទនរោត្តម សីហនុវរ្ម័ន (១៩៤១-១៩៥៥) ព្រះបាទនរោត្តម សុរាម្រិត និងព្រះមហាក្សត្រិយានី កុសុមៈនារីរតន៍ (១៩៥៥-១៩៦០) និងសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) យើងឃើញថា តន្ត្រីសម័យដែលមានដើមកំណើតមកពីបស្ចិមប្រទេសនេះ បានរីកចម្រើនយ៉ាងខ្លាំងនៅប្រទេសកម្ពុជា ព្រោះព័ត៌មានខ្លះបានបញ្ជាក់ប្រាប់យើងថា នៅក្នុងអំឡុងឆ្នាំ១៩៤០មិនត្រឹមតែភ្លេងត្រែដែលខ្មែរនិយមឲ្យឈ្មោះថាភ្លេងម៉ានីលប៉ុណ្ណោះទេ យើងបង្កើតបានជាវង់តន្ត្រីសម័យសម្រាប់កែកម្សាន្ត ដែលខ្មែរនិយមហៅថា ភ្លេងអាកេស ហើយប្រគំក្នុងរង្គសាលពិកម្សាន្តនានាដូចជា បាអារ៉ែក (Bar Arec) ដែលមានទីតាំងនៅមាត់ទន្លេចំពីមុខ ព្រះសក្យមុនីចេតិយក្រុងភ្នំពេញសព្វថ្ងៃ និងបាឡុបនិល ដែលមានទីតាំងនៅម្តុំពេងឡោនថ្ម ស្ពានកូនកាត់ម្តុំវត្តលង្កាសព្វថ្ងៃ ដែលជារង្គសាលដ៏ល្បីល្បាញ និងពេញនិយមនៅរាជធានីភ្នំពេញ ដែលមានក្រុមតន្ត្រីសម័យ លាយចម្រុះ និងឧបករណ៍តន្ត្រីបុរាណខ្មែរ (រង់មហោរីថ្មែ) ប្រគំជូនការរាំរែក និងកំដរការកម្សាន្តសប្បាយនានាផងៗ ឯទម្រង់ល្ខោនខ្លះដូចជាល្ខោនបាសាក់ ក៏បានទទួលយកឥទ្ធិពលភ្លេងនេះទៅប្រើប្រាស់ក្នុងទម្រង់សិល្បៈរបស់ខ្លួនដែរ ពិសេសគឺសម្រាប់ «**ឡុកម៉ាដាម**»ៗ ចំណែកឯទម្រង់ល្ខោនបាមោជ្ឈទ័យ ដែលបានកើតមានឡើងក្នុងរយៈកាលនោះដែរ ក៏បានយកតន្ត្រីអកកេស "Orchestre" នេះធ្វើជាគ្រឹះឲ្យទម្រង់របស់ខ្លួនតែម្តងៗ

គឺចាប់ពីពេលនោះមកដែរ ដែលខ្មែរយើងចាប់ផ្តើមមានអ្នកនិពន្ធបទភ្លេងនិងទំនុកច្រៀងខាងផ្នែកតន្ត្រីសម័យយ៉ាងល្បីល្បាញ ទាំងក្នុងព្រះញាតិវង្សានុវង្សក៏ដូចជារាស្ត្រប្រជាសាមញ្ញដែរ មានព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ដែលទ្រង់ជាកវីនិពន្ធដ៏ឆ្នើមជាកស្តុតាងស្រាប់ៗ

មិនត្រឹមតែប៉ុណ្ណោះឡើយ មុខវិជ្ជាខាងតន្ត្រីបស្ចិមប្រទេសនេះបានត្រូវពង្រីកឲ្យកាន់តែរីកចម្រើនឡើង ពិសេសនៅក្នុងសម័យសង្គមរាស្ត្រនិយមៗ រាជរដ្ឋា

www.elibraryofcambodia.org

ភិបាលក្នុងសម័យនោះ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ ព្រះប្រមុខរដ្ឋ **«ព្រះបិតាឯករាជ្យជាតិ»** បានបើកឲ្យមានសាលាតូរ្យតន្ត្រី (១៩៥៩) ដែលមានទីតាំងដំបូង នៅម្តុំវិទ្យាល័យព្រះយុគន្ធរ (ពេទ្យចិន) រួចប្តូរមកទួលគោក ហើយទីបំផុតក៏ក្លាយទៅជាមហាវិទ្យាល័យសិល្បៈតូរ្យតន្ត្រី ស្ថិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ហើយបានអប់រំបណ្តុះបណ្តាល សិស្សនិស្សិតជាច្រើនក្នុងមុខជំនាញនេះរហូតដល់អាចបង្កើតបានជាក្រុម តន្ត្រីសំឡេងស្រាល Orchestre de Chambre និងក្រុមតន្ត្រីសាំងហ្វូនី "Orchestre Symphonie" ដ៏ធំសម្បើម ព្រមទាំងក្រុមចម្រៀងជាពួក "Choral" ដែលមានលក្ខណៈជាអន្តរជាតិថែមទៀតផង។

សូមបញ្ជាក់ថា ក្នុងរយៈពេលនោះ ការហូរចូលនូវប្រភេទតន្ត្រីសម័យពីបរទេសមកក្នុងប្រទេសកម្ពុជា ក៏មានច្រើនទាំងថាសចម្រៀង ទាំងក្រុមតន្ត្រីដែលជាកត្តាគួបផ្សំ និងជួយជំរុញឲ្យតន្ត្រីកាន់តែរីកចម្រើនឡើង ទាំងក្នុងអង្គភាពរដ្ឋ ទាំងក្រុមឯកជនជាច្រើននៅរាជធានីភ្នំពេញ ក៏ដូចជានៅគ្រប់ខេត្ត-ខណ្ឌផង។

ម្យ៉ាងទៀត គឺក្នុងរយៈពេលនេះផងដែរ ដែលអ្នកចម្រៀងមាននិស្ស័យខ្ពស់ និងទេពកោសល្យល្អៗ បានផុសឡើងព្រោងព្រាតដូចជាអ្នកស្រី ម៉ៅ សារ៉េត, អ្នកស្រី កែវ មណ្ឌា, អ្នកស្រី ហួយ មាស, អ្នកស្រី ប៉ែន រ៉ន, អ្នកស្រី ប៉ែន រ៉ម, លោក សុស ម៉ាត់, លោក មាស សាម៉ន, លោក មាស ហុកសេង, លោក អ៊ិង យ៉េង ព្រមទាំងអ្នកស្រី រស់ សិរីសុទ្ធា និងលោក ស៊ិន ស៊ីសាមុត ដែលមានឈ្មោះល្បីល្បាញជាងគេបំផុតក្នុងប្រទេសកម្ពុជា។

រហូតមកដល់សព្វថ្ងៃ ថ្វីត្បិតតែលោកស្រី និងអស់លោកជាអ្នកចម្រៀងទាំងអស់នេះបានលាចាកលោកក្តី ក៏សំឡេងដ៏ពីរោះរណ្តំរបស់លោកស្រី អស់លោក នៅតែលាន់រងំនៅក្នុងសោតិន្ទ្រីយារម្មណ៍ និងបេះដូងខ្មែរជារៀងរហូត តាំងពីមុនរហូតពេលបច្ចុប្បន្ន ទាំងនៅក្នុងមាតុភូមិកម្ពុជាទាំងនៅឯបរទេស ពិសេសនៅប្រទេសទាំងឡាយក្នុងពិភពលោកដែលមានប្រជាជនខ្មែររស់នៅ។

www.elibraryofcambodia.org

ចំណុចមួយដ៏សំខាន់ទៀត ទាក់ទងទៅនឹងដំណើរវិវឌ្ឍន៍នៃតន្ត្រីសម័យនៅប្រទេសកម្ពុជាក្នុងដំណាក់កាលចុងក្រោយនេះ យើងសង្កេតឃើញថា ចាប់ពីពេលដែលប្រទេសយើងដើរមកដល់បេត់នយោបាយមួយថ្មី គឺបង្រួបបង្រួមផ្សះផ្សាជាតិ ហើយប្រទេសកម្ពុជាបានបើកទ្វារទំទូលាយក្នុងយុគសម័យសកលភាវូបនីយកម្ម និងសេដ្ឋកិច្ចទីផ្សារសេរី ការហូរចូលនៃវប្បធម៌បរទេសពីគ្រប់ទិសទីនៃពិភពលោកតាមមធ្យោបាយដ៏មានប្រសិទ្ធភាព គឺទូរទស្សន៍ធម្មតា ទូរទស្សន៍ខ្សែកាប និងមធ្យោបាយទំនើបផ្សេងៗទៀតជាច្រើន បានធ្វើឲ្យវប្បធម៌ខ្មែរជួបនូវផលពិបាកយ៉ាងខ្លាំងពីគ្រាដំបូង ពិសេសគឺផ្នែកសិល្បៈទស្សនីយភាព ដែលមានទ្រង់ទ្រាយបុរាណៗ ផុយទៅវិញក្នុងពេលជាមួយគ្នានោះតន្ត្រីសម័យនៅប្រទេសកម្ពុជាហាក់ហក់ទៅមុខយ៉ាងខ្លាំង ដែលពីដំបូង យើងមើលឃើញហាក់ដូចជាច្រើនតែចម្លងរបស់បរទេសមកធ្វើជារបស់ខ្លួន? ទាំងរូបភាព ទាំងខ្លឹមសារក៏ពិតមែន ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃ យើងឃើញមានការវិវឌ្ឍមករកពណ៌សម្បុរជាតិរបស់ខ្លួន ហើយមានការរីកចម្រើនទាំងបរិមាណ និងគុណភាពផងៗ ម្យ៉ាងទៀត ដោយមធ្យោបាយផ្សព្វផ្សាយទំនើប និងសម្បូរបែបមានទូរទស្សន៍ ខារ៉ាអូខេ កាសែតសំឡេងស៊ីឌី (CD) វីស៊ីឌី (VCD) ឌីវីឌី (DVD) រួមផ្សំនឹងតន្ត្រី សម័យក្នុងពេលសព្វថ្ងៃនេះបានក្លាយជាទីពេញនិយមរបស់ប្រជាជនខ្មែរយើងនៅទូទាំងប្រទេសផងៗ យើងសង្ឃឹមថា បទពិសោធនានាក្នុងការងារអាជីព នឹងក្លាយជាមេរៀនដ៏ធំជំរុញសមត្ថភាពអ្នកនិពន្ធបទភ្លេង និងទំនុកច្រៀងខ្មែរយើង ក៏ដូចជាតន្ត្រីករនិងអ្នកចម្រៀង យុវវ័យដ៏ច្រើន ក្នុងសម័យដើមសតវត្សរ៍ទី ២១ នេះឲ្យកាន់តែមានកម្រិតខ្ពស់ឡើង និងជំរុញមុខជំនាញរបស់ខ្លួនឲ្យកាន់តែល្អប្រសើរក្នុងកាលអនាគតមិនខានៗ

www.elibraryofcambodia.org



លោក ស៊ិន ស៊ីសាមុត



អ្នកស្រី រស់ សិរីសុទ្ធា

អ្នកចម្រៀងល្បីល្បាញក្នុងទសវត្សរ៍ឆ្នាំ ៦០



www.elibraryofcambodia.org





ក្រុមចម្រៀងជាពួក

www.elibraryofcambodia.org

# របាំនៅប្រទេសកម្ពុជា



របាំក៏ដូចជាល្ខោន តន្ត្រី ចម្រៀង កំណាព្យ ចម្លាក់ និងទម្រង់សិល្បៈដទៃទៀតទាំងអស់ដែរ គឺសុទ្ធតែជាតម្រូវការរបស់ជីវិតខ្មែរទាំងអស់ ។ ដោយហេតុហ្នឹងហើយ ទើបខ្មែរកើតទម្លាប់ប្រើពាក្យថា **«ជីវិតគឺសិល្បៈ ហើយសិល្បៈគឺជាជីវិត»** រៀងៗ

www.elibraryofcambodia.org

តាំងពីថ្ងៃកើតដល់ថ្ងៃស្លាប់ ជីវិតខ្មែរត្រូវការសិល្បៈជាចាំបាច់ៗ ម្តាយបំពេរកូនតាំងពីនៅជាទារក... រហូតដល់ពេលស្លាប់សំឡេងសូត្រព្រះធម៌មកជំនួសវិញៗ

- ពេលរស់ឆ្លាក់តាំងពីក្បាលដំណើរ ស៊ុមតែ ក្បាក់តែ វែក ត្រលោក ហិបស្លា អកកំពោរ... ដល់ពេលស្លាប់ ឆ្លាក់ក្តារមឈូសប៊ិទ ក្រដាស់ពណ៌ មេរុលម្អចាក់ចេកៗ
- តន្ត្រីកំដរជីវិត តន្ត្រីព្យាបាលរោគ (ភ្លេងអារក្ខ បញ្ជាន់អារក្ខ) ភ្លេងសម្រាប់ពិធីកោរជុក ទុកកំពោយ... ភ្លេងសម្រាប់ពិធីបំបួសនាគ ភ្លេងសម្រាប់ពិធីអាពាហ៍ពិពាហ៍... រហូតដល់ថ្ងៃស្លាប់មានតន្ត្រីកំដរសព ពេលតម្កល់សព (វង់តន្ត្រីទ្រាមមីង ឬឈម្មីង) និងតន្ត្រីដង្ហែសព យកទៅកប់ ឬបូជាជាគ្រាចុងក្រោយ) វង់តន្ត្រីស្គរជ័យ ឬស្គរយោន)ៗ

ចំណែកខាងរបាំក៏មិនខុសគ្នាប៉ុន្មានពីទម្រង់សិល្បៈទាំងអស់ដូចបានរៀបរាប់ខាងលើនេះដែរ ព្រោះរបាំក៏ជាតម្រូវការរបស់ជីវិតខ្មែរដូចគ្នាដែរៗ យ៉ាងណាមិញខ្មែរត្រូវការរបាំដើម្បីរាំថ្វាយអារក្ខ អ្នកតា សុំសេចក្តីសុខ រាំបួងសួងសុំទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការ រាំបន់ស្រន់សុំឲ្យវត្ថុស័ក្តិសិទ្ធិជួយបំបាត់ឧបទ្រពចង្រៃ រាំដើម្បីសុំសុខសប្បាយក្នុងពេលប្តូរភូមិមករស់នៅក្នុងភូមិថ្មី រហូតដល់រាំដើម្បីកែកម្សាន្ត ឬបំបាត់ការនឿយហត់ក្រោយពេលធ្វើពលកម្មនានា ក្នុងជីវិតថែមទៀតផងៗ ជាទូទៅនៅប្រទេសកម្ពុជា យើងសង្កេតឃើញមានរបាំជាច្រើនដែលមានលក្ខណៈខុសៗគ្នាទាំងប្រភពកំណើត ទាំងរូបភាពពណ៌សម្បុរ ទាំងតួនាទីក្នុងសង្គមផងដូចជា៖

- របាំខ្លះមានប្រភពចេញមកពីសាសនាព្រាហ្មណ៍ រួចធ្វើដំណើរឆ្លងកាត់ដំណាក់កាលជាច្រើនមកដល់សម័យពុទ្ធសាសនាមហាយាន រួមថេរវាទ ជាប្រភេទសិល្បៈទេវៈ ដែលគេប៉ាន់ស្មានថា ជាស្នាដៃច្នៃប្រឌិតរបស់អ្នកប្រាជ្ញ

www.elibraryofcambodia.org

រាជបណ្ឌិតរួចក្រោយមកដិតជាប់ក្នុងពិធីនានា នៃព្រះបរមរាជវាំងៗ
-ឯរបាំខ្លះទៀត មានប្រភពចេញមកពីជំនឿអារក្ខអ្នកតា (ជំនឿខ្មែរដើម) ហើយជារបាំដែលត្រូវបានថែបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ដែលគេរាប់ថាជាមរតក «បន្តត្រកូល» របស់ជនជាតិខ្មែរ និងរបស់គ្រប់ជនជាតិភាគតិចដែលរស់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជាតាមតំបន់ខុសៗគ្នា និងមានទម្លាប់ខុសៗគ្នាខ្លះផង ដែលអ្នកស្រាវជ្រាវច្រើនយល់ថា គឺជាស្នាដៃច្នៃប្រឌិតដែលចេញមកពីប្រភពមហាជន ប្រជាជន អ្នកស្រែចម្ការៗ
- និងមានរបាំមួយប្រភេទទៀត ជារបាំដែលមានប្រជាប្រិយជាងគេនៅក្នុងប្រទេសកម្ពុជាទាំងមូល ពោលគឺនៅទីណាកន្លែងណា ក៏មានរបាំនេះដូចគ្នាទាំងអស់ ទោះជានៅទីក្រុង ឬជនបទតំបន់ភ្នំ តំបន់វាលទំនាប ឬក៏តំបន់មាត់សមុទ្រក្តី ហើយលក្ខណៈពិសេសមួយទៀត គឺប្រជាជនទូទាំងប្រទេសទាំងក្មេងទាំងចាស់ ទាំងប្រុស ទាំងស្រី ចេះរាំរបាំនេះទាំងអស់គ្នាៗ ចំណែកឯតួនាទីរបាំនេះនៅក្នុងសង្គមវិញ គឺសម្រាប់កែកម្សាន្ត ឬប្រភេទរបាំសម្រាប់លំហែកាយ និងធ្វើឲ្យសប្បាយចិត្តបំបាត់ការនឿយហត់ពីពលកម្មនានាៗ

អាស្រ័យដោយប្រទេសកម្ពុជា ជាប្រទេសដែលសម្បូរទៅដោយរបាំដែលមានប្រភេទខុសៗគ្នា ដូចបានរៀបរាប់ជូនខាងលើ ទើបរហូតមកដល់បច្ចុប្បន្ននេះ ខ្មែរមានការនិយមចែករបាំទាំងនោះជាបីក្រុម ហើយឈ្មោះខុសៗគ្នា ទៅតាមលក្ខណៈពិសេសរបស់ក្រុមរបាំនីមួយៗនោះផងគឺ ÷

- របាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យ
- របាំប្រពៃណី
- របាំប្រជាប្រិយ

www.elibraryofcambodia.org

# ១-របាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យ



www.elibraryofcambodia.org

ខ្មែរយើងមានពាក្យពីរម៉ាត់ សម្រាប់សម្គាល់ទម្រង់សិល្បៈ ទស្សនីយភាពក្បាច់បុរាណនេះគឺ ១-របាំ ឬល្ខោនក្បាច់បុរាណខ្មែរ និង ២-របាំ ឬល្ខោនព្រះរាជទ្រព្យ ។ ឯពាក្យថារបាំ និងល្ខោនក្នុងទីនេះ ក៏សម្រាប់គូសបញ្ជាក់ពីភាពខុសគ្នាខ្លះៗ នៃទម្រង់សិល្បៈនេះក្នុងឱកាសសម្តែងម្តងៗផងដែរ។ ឧទាហរណ៍ដាក់ស្តែងកាលណាទម្រង់ក្បាច់បុរាណនេះសម្តែងជាទ្រង់ទ្រាយរបាំដាច់ៗតែឯង ដូចជារបាំជូនពរ របាំអប្សរា របាំទេពមនោរម្យជាដើមនោះគេច្រើននិយមប្រើពាក្យថារបាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យៗ ប៉ុន្តែបើទម្រង់ដដែលនេះ សម្តែងជាសាច់រឿងផ្សេងៗដូចជារឿងរាមកេរ្តិ៍ រឿងព្រះជិនវង្ស រឿងព្រះកេតុមាលា ឬរឿងព្រះថោងនាងនាគជាដើមនោះ គេច្រើននិយមហៅថា ល្ខោនព្រះរាជទ្រព្យ ឬល្ខោនក្បាច់បុរាណខ្មែរទៅវិញៗ

ចំពោះប្រភព និងកាលបរិច្ឆេទកំណើតនៃទម្រង់សិល្បៈរបាំ ឬល្ខោននេះនៅលើទឹកដីកម្ពុជាវិញ មិនមានឯកសារណានិយាយប្រាប់យើង ឲ្យបានច្បាស់ប្រាកដប្រជាថាកើតនៅខែណា ឬឆ្នាំណាទេ?ៗ ប៉ុន្តែតាមការសិក្សាស្រាវជ្រាវដោយពឹងផ្អែកទៅលើការគាស់កកាយរកវត្ថុបុរាណ សិក្សាពីរូបចម្លាក់តាមប្រាសាទបុរាណនានា ការសិក្សាសិលាចារឹក និងការសិក្សាអំពីទំនៀមទម្លាប់ប្រពៃណីផ្សេងៗ នាំឲ្យយើងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយសាកល្បងសន្និដ្ឋានថាទម្រង់សិល្បៈក្បាច់បុរាណនេះប្រហែលជាយានយកកំណើត នៅលើទឹកដីនៃប្រទេសកម្ពុជាតាំងពីសម័យនគរភ្នំ (ស.វ ទី ១ ដល់ទី ៦ នៃគ.ស) មកម្ល៉េះពីព្រោះ÷

ក-នៅចន្លោះឆ្នាំ ១៩៧៩-១៩៩០ ពិតមែនតែបរិយាកាសក្នុងប្រទេស បានប្រសើរជាងមុនខ្លះ ដោយរបបប្រល័យពូជសាសន៍ ខ្មែរក្រហម ប៉ុល ពត, អៀង សារី បានដួលរលំផុតទៅហើយ ប៉ុន្តែសង្គ្រាមរវាងខ្មែរ នៅតាមតំបន់ផ្សេងៗ ពិសេសគឺតាមព្រំដែនខ្មែរ-ថៃនៅបន្តនៅឡើយៗ ធ្លៀតឱកាសដែលមាតុភូមិ និងប្រជាពលរដ្ឋយើងកំពុងតែជួបការលំបាកនេះឈ្មួញទុច្ចរិតទាំងខ្មែរ ទាំងបរទេស

ដែលមានគំនិតទិលខូច ពិសេសគឺចង់បំផ្លាញឲ្យអស់នូវសម្បត្តិវប្បធម៌ខ្មែរនោះ បានបំផុសចលនាដោយអាថ៌កំបាំងគឺទិញយកវត្ថុបុរាណ ដែលលួចបានពីកម្ពុជាក្នុងតម្លៃថ្លៃបង្គួរៗ គាប់ជួនពេលនោះជីវភាពរបស់ប្រជាពលរដ្ឋខ្មែរយើងនៅក្រីក្រលំបាកតោកយ៉ាក រួមផ្សំនឹងការយល់ដឹងនៅមានកម្រិតទាបនៅឡើយ ជនជាតិខ្មែរមួយចំនួន ទាំងជនសាមញ្ញទាំងអ្នកមានអំណាច ក៏បានធ្លាក់ចូលក្នុងអន្ទាក់នៃការបំផ្លាញវប្បធម៌ជាតិរបស់ខ្លួនដោយមិនដឹងខ្លួន ឬក៏ដោយបំពានៗ នៅគ្រប់ទីកន្លែងដែលមានប្រាសាទបុរាណ ឬក៏តំបន់ប្រវត្តិសាស្ត្រ ទោះនៅក្នុងព្រៃជ្រៅ ឬក៏ក្នុងស្រុកភូមិទីប្រជុំជនក្តី គេឃើញមានការលួចគាស់កកាយយកបដិមា រូបចម្លាក់ ឬវត្ថុបុរាណផ្សេងៗយ៉ាងសកម្មបំផុតនៅទូទាំងផ្ទៃប្រទេស ដូចជានៅខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ ព្រះវិហារ កំពង់ធំ កំពង់ចាម កំពង់ស្ពឺ កណ្តាល តាកែវ ។ល។ ក្នុងនោះ អង្គរបុរី ដែលមានទីតាំងនៅស្រុកព្រៃកប្បាសខេត្តតាកែវ ដែលជារាជធានីដ៏ចាស់មួយ របស់រាជាណាចក្រនគរភ្នំ ពីចន្លោះស.វទី ១ ដល់ ស.វទី ៦ នៃគ.ស ត្រូវបានប្រជាពលរដ្ឋយើងជីកគាស់កកាយរកវត្ថុបុរាណយ៉ាងអនាធិបតេយ្យ ទិងគគ្រឹកគគ្រេងផងដែរ។

ក្នុងការគាស់កកាយនេះ វត្ថុបុរាណដែលមានអាយុរាប់ពាន់ឆ្នាំមក ហើយរាប់សិបមុខបានក្លាយទៅជាមុខទំនិញ ដែលត្រូវបញ្ជូនបន្តគ្នាពីដៃអ្នកគាស់ទៅដៃឈ្មួញកណ្តាល ហើយទីបំផុតក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃឈ្មួញធំ ដែលភាគច្រើនវត្ថុទាំងនោះ ត្រូវដឹកចេញដោយលួចលាក់ទៅលក់ឯបរទេសៗ ក្រៅពីនេះ មានវត្ថុបុរាណតិចតួចប៉ុណ្ណោះ ដែលក្រសួងមានសមត្ថកិច្ចបានឃាត់ទុក ក្នុងនោះក៏សុទ្ធតែជាវត្ថុបុរាណដែលមានអាយុរាប់ពាន់ឆ្នាំមកហើយដែរ ដូចជាចម្លាក់លើមាសសន្ទឹក សំរិទ្ធ ក្រឡ ពួច រូបបដិមាផ្សេងៗ គ្រឿងតុបតែងលម្អកាយ ការពាក់ត្របៀក ក្រវិល ទុំហូ អង្គាំដ៏ គងដៃ គងជើង ចិញ្ចៀន ប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗ ក្នុងសម័យនគរភ្នំ ក្នុងនោះយើងបានជួបប្រទះនឹងរូបស្រីរបាំ ដែលជាចម្លាក់ដ៏ផុត

www.elibraryofcambodia.org

ហើយនិងរូបស្វាដែលទំនងជារូប (ហនុមាន) កាន់ដំបងយ៉ាងវែងផងដែរ ។

បើតាមព័ត៌មានរូបស្រីរបាំ និងរូបហនុមានកាន់ដំបងនេះ ត្រូវគេគាស់យកបានពីក្នុងបរិវេណវត្ត «គំនូរ» ដែលស្ថិតនៅចំកណ្ដាលទីតាំង នៃរាជធានីរាជាណាចក្រនគរភ្នំនោះឯង។ ដោយសារតឹកតាងនេះហើយ ដែលនាំឲ្យយើងមានការសង្ស័យថា របាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យប្រហែលជាបានចាប់កំណើតលើទឹកដីកម្ពុជាតាំងពីសម័យនគរភ្នំមកម៉្លេះ ពោលគឺការចម្លងតាមបែបផែនរបាំឥណ្ឌា ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងលទ្ធិព្រាហ្មណ៍ ហើយទំនងជាហូរចូលមកតាមរយៈពួកព្រាហ្មណ៍នោះឯង ដូចជារឿងរាមកេរ្តិ៍ដូច្នេះដែរ។

ប៉ុន្តែ បើយើងសាកល្បងពិនិត្យពីរូបភាព ស្រីរបាំនៃរូបចម្លាក់ដ៏ផុតនោះ យើងឃើញហាក់ឃ្លាតឆ្ងាយគ្នាណាស់ពីរបាំបុរាណខ្មែរសព្វថ្ងៃ ព្រោះថាទ្រង់ទ្រាយ ឬកាយវិការនៃស្រីរបាំនោះ មានលក្ខណៈដូចគ្នាបេះបិទនឹងរបាំឥណ្ឌាខ្លះ ដែលយើងធ្លាប់ឃើញគេរាំរហូតមកដល់សព្វថ្ងៃនេះ ពិសេស គឺកាយវិការជើងកន្ទែកហាក់សង្កត់ទម្ងន់លើជើងទាំងពីរ ក្នុងលក្ខណៈបន្ទាត់កាច់ ហើយចុងជើងទាំងពីរកន្ទែងចេញក្រៅ។ ឯដៃទាំងពីរលើកឡើងលើខ្ពស់អមសងខាងក្បាលបញ្ចុចកែងដៃ កន្ទែកម្រាមដៃខាងឆ្វេងចេញក្រៅ ឯម្រាមដៃខាងស្ដាំចូលក្នុង ក្នុងកាយវិការប្រើបន្ទាត់កាច់ដូចគ្នាដែរ។

លក្ខណៈខុសប្លែកគ្នារវាងរូបចម្លាក់ «ស្រីរបាំ» ផ្ញើពីដ៏ផុត ដែលយើងបានស្មានថា ជាស្នាដៃដែលកើតឡើងក្នុងសម័យនគរភ្នំ ស.វ ទី១ ដល់ ស.វ ទី៦ នៃគ.ស និងរូបភាពរបាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យដែលមានបច្ចុប្បន្ននេះ ហើយដែលភាគច្រើនប្រើកាយវិការដោយបន្ទាត់កោង នាំឲ្យយើងនឹកឃើញដល់ការរៀនសាងប្រាសាទរបស់ជនជាតិខ្មែរ ដែលទទួលមេរៀនជាដំបូងវមកពីឥណ្ឌា ហើយពីមួយថ្ងៃទៅមួយថ្ងៃច្រើនសតវត្សរ៍ទៅ ខ្មែរបានស្វែងរកបុគ្គលិកលក្ខណៈពិសេសរបស់ខ្លួន រហូតដល់អាចសាងប្រាសាទអង្គរវត្ត ដែលអគ្គជំនាញខាង

www.elibraryofcambodia.org

បុរាណវិទ្យាឥណ្ឌាពោលថា ប្រហែលជាប្រាសាទខាងព្រហ្មញ្ញសាសនា ដែលធំជាងគេក្នុងពិភពលោកបានថែមទៀតផង ៦ទំនាក់ទំនងរបស់ទម្រង់ល្ខោនក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យ ដែលបានយកកំណើតដោយចម្លងតាមគំរូនៃរបាំខាងព្រហ្មញ្ញសាសនាឥណ្ឌា ក៏គង់មានលម្អានវិវឌ្ឍន៍កែច្រើនមិនខុសអ្វីពីដំណើរវិវឌ្ឍន៍ នៃប្រាសាទបុរាណខ្មែរដូច្នេះឡើយៗ

១-ចំណុចមួយយ៉ាងសំខាន់ទៀត គឺការសិក្សាសិលាចារឹករបស់អ្នកឯកទេសខាងភាសាសំស្ក្រឹត និងខ្មែរបុរាណ ដែលបានរកឃើញឯកសារ ដ៏មានសារៈសំខាន់ជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រ ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ សិល្បៈ ល្ខោន របាំ តន្ត្រី សព្វបែបយ៉ាង ដែលមានអាយុពីយូរលង់ច្រើនសតវត្សរ៍មកហើយ ហើយសុទ្ធតែជាស្នាដៃរបស់បុព្វបុរសដូនតាខ្មែរបានបន្សល់ទុក ជាក់ស្តែងនៅក្នុងអត្ថបទសិក្សាដែលមានចំណងជើងថា *Music and Dance in Ancient Cambodia as Evidenced by old Khmer Epigraphy* របស់អ្នកស្រី ពៅ សាវរស់ បានដកស្រង់នូវភស្តុតាងជាក់លាក់ជាពាក្យសម្តី ឬឈ្មោះជាសំស្ក្រឹត និងខ្មែរបុរាណ ដែលមានចារទុកក្នុងផ្ទាំងសិលាចារឹក មានកាលបរិច្ឆេទត្រឹមត្រូវ ទៅតាមរជ្ជកាលសោយរាជ្យនៃព្រះមហាក្សត្រខ្មែរនានា ច្បាស់លាស់ស្តីអំពីល្ខោនភាណីដែលប្រហែលជាទម្រង់ល្ខោន «**ខោល**» សព្វថ្ងៃៗ ត្នោងភាណី តន្ត្រីករ ប្រគំគ្រឿងដំ សម្រាប់កំដរល្ខោនភាណី ដែលមានសុទ្ធតែប្រុសៗ វង់ភ្លេងមហោរី ដែលប្រហែលក្លាយមកពីពាក្យថា **មនោហារា មនោហារី** ៗ សិល្បៈការិនី សម្តែង សិល្បៈតុក្កតា តួតុក្កតា ។ល។ ហើយក្នុងនោះក៏មានសិលាចារឹកលេខ K-៥៥៧, K-៦០០ និង សិលាចារឹក លេខ K-១៣៧ រកឃើញក្នុងវត្តគំនូរអង្គរបុរី ជាសិលាចារឹកក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ ដែលបានរៀបរាប់នូវតន្ត្រាយ ជាអ្នកចម្រៀង ឧបករណ៍ភ្លេង និងរបាំចំពោះទេវស្ថាននៅទីនោះៗ ប្រហែលជាព្រះបាទជ័យវរ្ម័ន ទី ១ ព្រះអង្គឯងទ្រង់បានឧទ្ទិសក្រុមសិល្បៈស្រីថ្វាយចំពោះអាទិទេព

www.elibraryofcambodia.org

ថែមទៀតផង ។

ចំណុចនេះយើងជឿថា ៖ បើព្រះបាទជ័យវរ្ម័នទី១ (៦៥៥-៦៨១) ជាព្រះរាជឥស្សរនិយមបានឧទ្ទិស «**ក្រុមសិល្បៈស្រី**» ដល់អាទិទេព ពិសេសគឺព្រះឥសូរក្នុងរាជព្រះអង្គនោះ នោះទម្រង់សិល្បៈរបាំស្រីនេះ គង់មានកំណើតយ៉ាងយូរតាំងពីមុនពេលនោះមិនខាន មុននឹងក្លាយជាតង្វាយដ៏គាប់ព្រះទ័យរបស់ព្រះអាទិទេពនោះ ។

គ-រឿងរ៉ាវមួយទៀត ដែលកើតឡើងក្នុងសម័យអាណាចក្រចេនឡា គឺការកកើតជាខ្សែស្ទួបវង្ស ឬអាទិច្ចវង្សគឺវង្សស្រីកម្ពុ ដោយមានការចងសម្ព័ន្ធរបស់ឥសីកម្ពុស្វយម្ភូ និងនាងអប្សរាមេរា ដូចមានកត់ត្រាទុក ក្នុងសិលាចារឹកបក្សីចាំក្រុង (ស.វ ទី ១០) ដែលបាននិទានថាស្តេចខ្មែរយើងមានកំណើតមកពីឥសីកម្ពុស្វយម្ភូ និងនាងអប្សរាមេរា ដែលព្រះឥសូរបានប្រទានឲ្យជាមហេសី ។

ព្រឹត្តការណ៍វាយលុកយកនគរហ្វូណន (នគរភ្នំ) ឆ្នាំ ៥០០ ដើម្បីបង្កើតជារាជាណាចក្រខ្មែរ រហូតដល់មានព្រឹត្តការណ៍ចងភ្ជាប់គ្នា រវាងកូនចៅឥសីកម្ពុ ខ្សែស្ទួបវង្ស ខាងផ្នែកចេនឡាព្រះនាមព្រះបាទភវវរ្ម័ន ទៅនឹងខាងសោមវង្ស ផ្នែកខាងនគរភ្នំ គឺព្រះនាងកម្ពុជលក្ស្មី ថែមទៀតនោះ តើមានទាក់ទងអ្វីនឹងកំណើតនៃរបាំស្រីនេះទេ ? តើអប្សរាមេរា ដែលព្រះ ឥសូរ ប្រទានជាមហេសីដល់ឥសីកម្ពុស្វយម្ភូ ក្នុងទីនេះ មានទាក់ទងអ្វីនឹងដើមកំណើតទម្រង់សិល្បៈល្ខោនក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យ ដែលមានសេសសល់រហូតដល់ថ្ងៃនេះឬទេ? ម្យ៉ាងទៀតយើងក៏បានជួបប្រទះផងដែរ នូវគំនិតរបស់អ្នកប្រាជ្ញ អ្នកស្រាវជ្រាវដែលបានពន្យល់ថា ពាក្យថាកម្ពុជា ឬខ្មែរដែលយើងប្រើសព្វថ្ងៃនេះក៏គឺជាហេតុផលដែលបានមកពីការចងសម្ព័ន្ធរវាងឥសីកម្ពុ និងអប្សរាមេរានេះដែរ ព្រោះបើយើងអានប្រមៀលពាក្យកម្ពុមេរានេះបន្តិចម្តងៗ ក៏នឹងបានទៅជាពាក្យខ្មែរ ដូច ៖ កម្ពុ+មេរា --> កម្ពុ +មេរ--> កម៑ + មេរ--> កមេរ -->ក្មេរ -->ខ្មែរនេះឯង ។

ការដែលយើងលើកយកចំណុច ៖

www.elibraryofcambodia.org

១- ចម្លាក់រូបស្រីកំ និងហនុមានកាន់ដំបង ធ្វើអំពីដីឥដ្ឋដុតរកឃើញនៅក្នុងបរិវេណវត្តគំនូរអង្គរបុរី

២-ការសិក្សាអំពីសិលាចារឹក លេខ K-៥៥៧ និង K-៦០០ជា សិលាចារឹកអង្គរបុរី និងសិលាចារឹក K-១៣៧ ដែលបានថែងថា ប្រហែលជាព្រះបាទជ័យវរ្ម័នទី១ (៦៥៥-៦៨១) បានឧទ្ទិសរបាំស្រីថ្វាយព្រះឥស្វរ។

. ៣-ព្រឹត្តការណ៍ចងភ្ជាប់គ្នារវាងខ្សែស្ឡូប្រវង្សខាងចេនឡា និងខ្សែសោមវង្សខាងនគរភ្នំ ដែលយើងយល់ថា ជាព្រឹត្តការណ៍ដែលមានទាក់ទងទៅនឹងការកកើតទម្រង់សិល្បៈរបាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យខ្មែរនេះ ព្រោះយើងមានការសង្ស័យផង និងមានជំនឿផងថា ទម្រង់សិល្បៈនេះប្រហែលជាបានយោនយកកំណើតនៅលើទឹកដីកម្ពុជា ដោយចម្លងតាមរបាំនៃព្រហ្មញ្ញសាសនាឥណ្ឌានៅក្នុងសម័យហ្វូណន ឬនគរភ្នំ (ស.វទី១ ដល់ ស.វទី ៦) ឬយ៉ាងហោចណាស់ក៏ប្រហែលជាកើតនៅសម័យចេនឡា (ស.វ ទី ៧-ទី ៨ នៃគ.ស) ពោលគឺមុនសម័យអង្គរជាក់ជាមិនខាន។ ម្យ៉ាងទៀតយើងមានជំនឿផងដែរថា ក្រោយពីកំណើតនៃទម្រង់សិល្បៈរបាំ ឬល្ខោនស្រីនេះក៏ដូចជាទម្រង់សិល្បៈដទៃទៀតដែរ បានវិវឌ្ឍន៍រីកចម្រើនរុងរឿងឧត្តុង្គឧត្តម ឬក៏ទ្រុឌទ្រោមរហូតដល់ពេលខ្លះអាប់ឱនស្ទើរលោយបាត់រូប ស្របគ្នាតាមដំណើរវិវឌ្ឍន៍នៃប្រវត្តិសាស្ត្រជាតិកម្ពុជាថែមទៀតផង។ ជាក់ស្តែងមកដល់សម័យអង្គរ ដែលចាប់ផ្តើមឡើងពីរាជព្រះបាទជ័យវរ្ម័នទី ២ (៨០២-៨៥០) ព្រះមហាក្សត្រដែលទ្រង់បានរំដោះកម្ពុជទេស គឺប្រទេសខ្មែរឲ្យរួចផុតពីចំណុះរាជវង្សសៃលេន្ទ្រៈនៃកោះជ្វា ដោយបានប្រារព្ធពិធី **«ទេវរាជ»** លើភ្នំមហេន្ទ្របព៌ត (ភ្នំគូលែន)។ ព្រះអង្គបានសាងប្រាសាទភ្នំ ជាដំបូងបង្អស់នៅទីនោះគឺ **«ព្រះអារាមរោងចិនសព្វថ្ងៃ»**? ដោយព្រះអង្គមានជំនឿមុតមាំលើព្រះឥស្វរ ដល់ពេលព្រះអង្គទ្រង់សោយទិវង្គតទៅនៅហរិហរាល័យ (រលួស) ព្រះអង្គទ្រង់ទទួលព្រះមរណនាមថា បរមេស្វរៈ។ រហូតដល់ព្រះមហាក្សត្រក្រោយៗ

www.elibraryofcambodia.org

ព្រះអង្គជាច្រើនអង្គ ដែលមានជំនឿដូចគ្នាក្ដី ឬខុសគ្នាក្ដីតែងសាងប្រាសាទជាច្រើន សាងទំនប់ ប្រឡាយ និងអាងទឹកធំសម្បើមៗ កសាងសង្គម និងសាងវប្បធម៌ ពោលគឺកសាងអារ្យធម៌ខ្មែរឲ្យរីកសុះសាយល្បីរន្ទឺលើពិភពលោក នោះយើងជឿថា ទម្រង់សិល្បៈរបាំស្រី **«របាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យ»** របស់ជនជាតិខ្មែរនេះក៏បានរីកចម្រើនលូតលាស់ស្របគ្នា និងដំណើររីករុងរឿងនៃអារ្យធម៌អង្គរទាំងមូលនេះដែរ ព្រោះបើយើងពិនិត្យមើលរូបចម្លាក់ទាំងឡាយនៅជញ្ជាំងប្រាសាទខ្លះ ដូចជាប្រាសាទបន្ទាយស្រី (ត្រីភូវនមហេស្វរៈ) ដែលកសាងឡើងដោយព្រាហ្មណ៍ព្រះគ្រូយជ្ញវរាហៈ (Yajñavaraha) ក្នុង គ.ស ៩៦៧ ឬក៏ជញ្ជាំងប្រាសាទ«**អង្គរវត្ត**» ស្នាព្រះហស្ដរបស់ព្រះបាទសុរិយាវរ្ម័នទី២(១១១៣-១១៥២) ដែលគេជឿថាព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ គោរពសាសនាព្រាហ្មណ៍គណៈវិស្ណុ ហើយទ្រង់បានលើកតម្កើងសាសនាព្រាហ្មណ៍នេះ ឲ្យមានឋានៈជាសាសនាសម្រាប់រដ្ឋ ។ ក្នុងពេលដែលព្រះអង្គទ្រង់សោយទិវង្គតទៅ ព្រះអង្គទ្រង់ទទួលព្រះមរណនាមថា បរមវិស្ណុលោក នោះគេឃើញមានរូបចម្លាក់ទេពអប្សរ គឺស្រីរបាំនៃឋានសួគ៌តាំងពីអគារប្រាង្គកំផែងទិសទាំងបួនខាងក្រៅ រហូតដល់បណ្ណាល័យខាងក្នុងបរិវេណកំផែង រហូតដល់តួប្រាសាទ ដែលមានរូបចម្លាក់ទេពអប្សរនេះ តាំងពីផ្នែកខាងក្រោមរហូតដល់ផ្នែកកំពូលនៃប្រាសាទ ហើយមានចំនួនច្រើនស្ទើររាប់មិនអស់ ដែលអាចបញ្ជាក់ថា សិល្បៈរបាំស្រី ជាប្រភេទសិល្បៈទេវៈ ឬរបាំនៃព្រះវិហារនេះមានការរីកចម្រើនរុងរឿងអស្ចារ្យណាស់ ក្នុងកាលវេលានោះៗ

មិនត្រឹមតែប៉ុណ្ណោះទេ រហូតមកដល់ពេលដែលព្រះពុទ្ធសាសនាមហាយានបានឡើងជាសាសនាធំនៅក្នុងប្រទេសកម្ពុជា ពិសេសរាជព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២១៨) ដែលជាព្រះមហាក្សត្រដ៏មានមហិទ្ធិឫទ្ធិបំផុត ក្នុងរាជពង្សាវតារនៃប្រទេសកម្ពុជា ហើយក៏ជាព្រះមហាក្សត្រ ដែលបានសាងសាលាសំណាក់ មន្ទីរ

www.elibraryofcambodia.org

ព្យាបាលរោគ និងប្រាសាទជាច្រើនមានប្រាសាទបាយ័ន តាព្រហ្ម ព្រះខ័ន បន្ទាយក្តី នាគព័ន្ធ តាសោម បន្ទាយឆ្មា(បាត់ដំបង)វត្តនគរ(កំពង់ចាម) តាព្រហ្មបាទី (តាកែវ) ប្រាសាទបានថ្ម ប្រាសាទកុដិមហាឫសី (ខេត្តបុរីរម្យ) ប្រាសាទគូកែវ (ខេត្តឧត្តរដែនី) ប្រាសាទវត្តមហាធាតុ (ខេត្តលពបុរី)ប្រាសាទតាមន្ត (ខេត្តសុរិន្ទ) ប្រាសាទពិមាយ (ខេត្តនគររាជសីមា) ប្រាសាទកំផែងតូច (ខេត្តស៊ីសាកេត) ប្រាសាទកំផែងលែង (ខេត្តពេជ្របុរី) ។ល។ ជាដើមនោះ របាំក្បាច់បុរាណ ឬទម្រង់ល្ខោនស្រីនេះ ទំនងជាកាន់តែរុងរឿង និងរីកចម្រើនថែមទៀតផង ព្រោះថ្វីដ្បិតតែមានការដោះដូរជំនឿសាសនានៅក្នុងព្រះនគរមែន ប៉ុន្តែរបាំក្បាច់បុរាណដែលជាកេរដំណែលរបស់បុព្វបុរសដូនតាខ្មែរត្រូវបានគេថែរក្សាទុកយ៉ាងល្អប្រពៃហើយប្រហែលជាបានបង្កើន ឬបន្ថែមតួនាទីឲ្យទម្រង់សិល្បៈនេះពីអ្នកបម្រើដំគាប់ព្រះទ័យ **«ទេវទាសី»** របស់អាទិទេពខាងព្រាហ្មណ៍សាសនា **«ទេវរាជ»** មកជាអ្នកបម្រើខាងវិហារ ព្រះពុទ្ធសាសនា **«ពុទ្ធរាជ»** ថែមទៀតផង ? ជាក់ស្តែងដូចមានសិលាចារឹក នៅប្រាសាទតាព្រហ្ម ឬរាជវិហារដែលព្រះអង្គចាត់ចែងកសាងឡើងនៅឆ្នាំ ១១៨៣ ដើម្បីឧទ្ទិសចំពោះព្រះមាតា និងព្រះរាជគ្រូឈ្មោះ **«ជ័យមង្គលាថ»** នោះបានបញ្ជាក់ថា ក្នុងប្រាសាទនេះមានស្រីរបាំចំនួន៦១៥នាក់ ។ ចំណែកខាងប្រាសាទព្រះខ័ន ឬជ័យស្រីកសាងឡើងក្នុងឆ្នាំ ១១៩១ ដើម្បីឧទ្ទិសចំពោះព្រះបិតាព្រះអង្គវិញ មានអ្នករបាំរហូតដល់ ១.០០០ នាក់ ឯណោះ សម្រាប់រៀបចំកំដរថ្វាយក្នុងពិធីសក្ការៈបូជាផ្សេងៗ នៅក្នុងប្រាសាទនេះ ។

មិនត្រឹមតែប៉ុណ្ណោះទេ ព្រះនាងឥន្ទ្រទេវីដែលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានអភិសេកជាមហេសី បន្ទាប់ពីព្រះនាងជ័យរាជទេវីព្រះអនុជរបស់ព្រះនាង និងជាអគ្គមហេសីទ្រង់សោយវិលាល័យទៅ ព្រះបាទជ័យវរ្ម័នទី ៧ តែងតាំងជាបរិនាយកាចារ្យនៅមហាវិទ្យាល័យជ័យស្រីនេះ ហើយទ្រង់ថែមទាំងបាននាំពួកស្រី ដែលជាព្រះរាជបរិពាររបស់ព្រះនាង ឲ្យសម្តែងរឿងជាតកផ្សេងៗថែមទៀតផង ។

ក្រោយពីព្រះបាទជ័យវរ្ម័នទី ៧ សោយទិវង្គតទៅ ព្រះបាទឥន្ទ្រវរ្ម័នទី ២ ជាព្រះរាជបុត្រទ្រង់ បានឡើងសោយរាជ្យបន្តពីព្រះបិតា (១២១០ ឬ ១២១៨?ដល់ ១២៤៣) ព្រឹត្តការណ៍ចម្លែកៗ កើតមានឡើងនៅក្នុងរាជនេះដូចជា ប្រគល់ឯករាជ្យឲ្យនគរចម្ប៉ា ដោយលើកព្រះអង្គរាជ ស្ដេចចាម ឲ្យឡើងសោយរាជ្យនៅចម្ប៉ានោះ និងព្រឹត្តការណ៍រាយលុកទឹកដីខ្មែររបស់ជនជាតិសៀម «ថៃ» ដំបូងនៅរាលទំនាបទន្លេមេណាមត្រង់តំបន់សុខោទ័យៗ

ប៉ុន្តែដែលជាអកុសលបំផុតនោះ ថែមលើការរាយលុករបស់បរទេស គឺវិបត្តិសាសនា ស្នាមបែកបាក់ផ្ទៃក្នុង ដែលអូសបន្លាយយូរអង្វែងនៅសម័យអង្គរតាំងពីរាជជ័យវរ្ម័នទី ៨ (១២៤៣-១២៩៥) ព្រះបាទស្រីឥន្ទ្រវរ្ម័នទី៣ (១២៩៥-១៣០៧) ព្រះបាទស្រីន្ទ្រជ័យវរ្ម័ន ឬឥន្ទ្រជ័យវរ្ម័ន (១៣០៨-១៣២៧) និងព្រះបាទជ័យវរ្ម័នទី ៩ (១៣២៧-១៣៣៦) ដែលមានប្រតិកម្ម ជះកំសួលជាអំពើអាក្រក់ទៅលើគ្នាទៅវិញទៅមកៗ ជួនកាលព្រះពុទ្ធសាសនាប៉ះពារទៅលើព្រហ្មញ្ញសាសនា ហើយភាគច្រើនខាងព្រហ្មញ្ញសាសនា បានបំផ្លាញព្រះពុទ្ធសាសនា ដែលមានអ្នកគោរពបូជាកាន់តែច្រើនលើសលប់ណាស់ទៅហើយនៅក្នុងទូទាំងប្រទេសនោះ ដែលបាំនជំរុញប្រទេសកម្ពុជា ឲ្យធ្លាក់ចូលក្នុងវិបត្តិមួយយ៉ាងធំ ដោយប្រវត្តិសាស្ត្រប្រទេសកម្ពុជាត្រូវកាត់ផ្ដាច់មួយរយៈកាល ហើយភ្ជាប់មកវិញដោយព្រឹត្តការណ៍ប្ដូររាជវង្សពីវង្សវរ្ម័ន មកវង្សត្រសក់ផ្អែម (ជាកសិករកាន់ព្រះពុទ្ធសាសនាថេរវាទ) ដែលប្រវត្តិវិទូ និងអ្នកស្រាវជ្រាវភាគច្រើនយល់ថា នេះជាបដិវត្តន៍ខាងនយោបាយ និងសាសនារបស់នាយត្រសក់ផ្អែមៗ ហើយចំណុចមួយសំខាន់ទៀត ដែលត្រូវកត់សម្គាល់នោះគឺថា តាំងពីការប្ដូររាជវង្សពីវង្សវរ្ម័នមកវង្សត្រសក់ផ្អែម ហើយចាប់ពីរាជត្រសក់ផ្អែមមករាជព្រះនិព្វានបាទជាព្រះរាជបុត្ររបស់ព្រះអង្គនេះហើយ ពេលប្រទេសខ្មែរហាក់បាត់បង់ភាពជាម្ចាស់ទាំងស្រុង លើទឹកដីភាគខាងលិចរបស់ខ្លួនដែលត្រូវជនជាតិសៀម «ថៃ» ចូលមកលុកលុយរុករានទន្ទ្រានយកនោះៗ

www.elibraryofcambodia.org

ជនជាតិសៀម «ថៃ» ជាកុលសម្ព័ន្ធមួយនៅប្រទេសចិនភាគខាងត្បូង បានច្រាលចុះមកក្រោមកាន់តែច្រើនឡើងៗ ហើយទីបំផុតក៏បានវាយខ្មែរម្ចាស់ស្រុកនៅសុខោទ័យ រួចប្រកាសជារដ្ឋសៀមដំបូងនៅអំឡុងឆ្នាំ ១២២០។ បន្ទាប់មក ពួកនេះបានបន្តរុករានទន្ទ្រានយកទឹកដីខ្មែររហូតដល់តំបន់អយុធ្យា ចុងក្រោយបានវាយបែកអង្គរក្នុងអំឡុងឆ្នាំ ១៣៥៣? ក្នុងរាជស្ដេចខ្មែរមួយអង្គនាម លំពង់រាជា ដែលមានជំនោរអំនួតអួតអាង ដោយសារឃើញសៀមដែលពីដំបូងចូលមកវាយក្រុងអង្គរមិនបាន ហើយទទួលបរាជ័យយ៉ាងដំណំៗ ព្រះអង្គទ្រង់គិតថា គ្មានសត្រូវណាអាចឈ្នានពានរាជធានីនៃមហានគរបានឡើយ ក៏ទ្រង់រំសាយទ័ពឲ្យវិលត្រឡប់ទៅស្រុកភូមិវិញអស់។ ចុងបញ្ចប់ មហានគរក៏ត្រូវលំដោយសាមហិច្ឆិតានៃសត្រូវជំក្នែងខ្វីដែលខ្មែរមាក់ងាយនេះ។

នៅក្នុងជោគជ័យរបស់គេ ជាបន្តបន្ទាប់សៀមបានឆក់ប្លន់ និងរឹបអូសយកសម្បត្តិដ៏មានតម្លៃ ឯកសារសព្វបែបយ៉ាង ទាំងធនធានមនុស្សថែមទៀតផងៗ ចុះចំណែករបាំបុរាណ ដែលយើងឃើញមាននៅប្រទេសសៀមសព្វថ្ងៃដែលមានលំនាំប្រហាក់ប្រហែលគ្នានឹងរបាំខ្មែរ ដែលមានប្រភពជាសិល្បៈទេវៈនៅគ្រប់ប្រាសាទទេវស្ថានរបស់ខ្មែរ ពិសេសនៅក្នុងប្រាសាទទាំងឡាយទៅលើទឹកដីដែលសៀមវាយដណ្ដើមបានយកទៅកាន់កាប់នោះ តើពួកសៀមមានបានបង្ខិតបង្ខំរឹបអូសយក ឬចម្លងយកឬទេ? ពិសេសក្នុងពេលដែលពួកសៀមវាយបែកក្រុងអង្គរអំឡុងឆ្នាំ ១៣៥៣? ដែលឯកសារជាច្រើនបានរៀបរាប់ប្រាប់យើង ពីការដឹកជញ្ជូនប្លន់យកសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌របស់ខ្មែរដ៏ច្រើនសន្ធឹក និងកៀរគ្រូខ្មែរពលសែនត្រូវនោះ តើអ្នកប្រាជ្ញរាជបណ្ឌិតខ្មែរលើគ្រប់វិស័យត្រូវសៀមកៀរយកទៅឬទេ? តើគ្រូរបាំនិងសិល្បការិនី (ទេវទាសី) គ្រូតន្ត្រី និងសិល្បករដ៏ចំណាញៗ លើគ្រប់វិស័យត្រូវសៀមបង្ខំចាប់យកទៅស្រុកគេដែរឬក៏អត់?។

ចំណែកខាងប្រទេសលាវវិញ ឯកសារមួយចំនួនបានរៀបរាប់ប្រាប់យើងថា

ដោយសារចំណងមិត្តភាពផង និងជាសាច់សារលោហិតផង សំណល់វប្បធម៌នៃប្រទេសទាំងពីរគឺលាវ និងកម្ពុជាមានទំនាក់ទំនងនឹងគ្នាតាំងពីយូរលង់មកហើយ ពោលគឺតាំងពីសម័យមហានគរមកម៉្លេះ។ យ៉ាងណាមិញព្រះចៅហ្វាង៉ូម ដែលជាព្រះរាជាដំបូងហើយល្បីល្បាញជាងគេក្នុងប្រវត្តិនៃអាណាចក្រឡានសាង គឺជាបុត្រពីតុបតី (កូនប្រសារប្រុស) របស់ព្រះចៅក្រុងកម្ពុជានាសម័យអង្គរ ដោយកាលនៅពីកុមារ ព្រះអង្គត្រូវបានគេបណ្តែតពោងពាយតាមដងទន្លេមេគង្គ មកទើរនៅត្រង់តំបន់ចម្ប៉ាសាក់ ហើយត្រូវបានព្រះចៅអធិការវត្តមួយនៅចម្ប៉ាសាក់រើសយកមកបីបាច់ថែរក្សា រួចនាំទៅថ្វាយព្រះរាជានាទីក្រុងអង្គរ។ ព្រះរាជាខ្មែរនៅអង្គរទ្រង់សព្វព្រះរាជហឫទ័យយ៉ាងខ្លាំង កំផុតផ្គង់ទំនុកបម្រុងហើយផ្តុងផ្តើមឲ្យចៅហ្វាង៉ូមសាងផ្នួស បួសរៀនទូវវិជ្ជាសព្វសារពើ រហូតមានការចេះដឹងកម្រិតខ្ពស់ៗ លុះលាចាកសិក្ខាបទ ព្រះរាជាខ្មែរនាសម័យអង្គរនេះរៀបអភិសេកបុត្រីសំណប់ព្រះទ័យរបស់ព្រះអង្គព្រះនាមកែវឡតហ្វា និងបានជួយផ្តល់កម្លាំងទ័ពយ៉ាងច្រើន ដើម្បីឲ្យចៅហ្វាង៉ូមយាងទៅដោះទឹកដីកំណើត (ទំនងជាសាមន្តរដ្ឋ)ដែលសត្រូវឈ្លានពានយកទៅនោះមកវិញ។ ក្នុងដំណើរវិលត្រឡប់នេះ ចៅហ្វាង៉ូមបាននាំទៅជាមួយនូវទំនៀមទម្លាប់ប្រពៃណីសិល្បៈមួយចំនួន និងទាំងផ្នែកសាសនាផងៗ ទីបំផុតព្រះអង្គទ្រង់បានទទួលជោគជ័យ និងឡើងសោយរាជនៅហ្លួងព្រះបាង (ហ្លួងព្រះបង) ក្នុងអំឡុងឆ្នាំ១៣៥៣? គឺជំណាលគ្នា និងកាលបរិច្ឆេទនៃការបែកក្រុងអង្គរនេះឯង។ តាមរយៈឯកសារទាំងនេះគួបផ្សំដោយការពិនិត្យជាក់ស្តែងផង យើងអាចយល់បានថាវប្បធម៌លាវ និងកម្ពុជាមួយភាគធំ ដែលសេសសល់ដល់សព្វថ្ងៃ ជាបងប្អូននឹងគ្នាយ៉ាងពិតប្រាកដៗ ម្យ៉ាងទៀត យើងពិនិត្យមើលរបាំក្បាច់បុរាណដែលសព្វថ្ងៃលាវក៏មាន ខ្មែរក៏មានក្នុងរូបភាពប្រហាក់ប្រហែលគ្នាទាំងតន្ត្រី ជួនសិល្បៈរបាំនេះក៏ដូចគ្នាទៀតផង ហើយដែលនៅប្រទេសឡាវគេមានការនិយមឲ្យឈ្មោះថា «ណាងកែវ» និង «ពាងកែវ» ...

www.elibraryofcambodia.org

ដល់សព្វថ្ងៃនេះៗ ឈ្មោះនាងកែវនេះ គំប្រហែលអាចជាភស្តុតាងបញ្ជាក់បន្ថែមពីទំនាក់ទំនងរវាងទម្រង់សិល្បៈរបាំ ឬល្ខោនក្បាច់បុរាណលាវទៅនឹងសិល្បៈទេវៈរបស់មហានគរដែរ?ៗ ឯក្សត្រីកែវឡតហ្វា បុត្រីព្រះចៅក្រុងកម្ពុជានាសម័យអាណាចក្រអង្គរ ដែលបានក្លាយទៅជាមហេសីរបស់ព្រះចៅហ្វាងុំ គំប្រហែលអាចជាសិល្បការិនីនៃទម្រង់សិល្បៈរបាំបុរាណខ្មែរជំនាញ «Star» ថែមទៀតផងៗ

ចំណែកនៅឯកម្ពុជាឯណេះវិញ ក្រោយពីបែកអង្គរ ឬគំចាប់តាំងពីមានវិបត្តិសាសនាពោលគឺពីរាជព្រះបាទជ័យវរ្ម័នទី ៨ មក ម៉្លេះដែលរបាំស្រី (ទេវទាសី) នៃប្រាសាទនានា ហាក់ត្រូវខ្ចាត់ខ្ចាយបោះបង់ចោលព្រះវិហារ (ប្រាសាទ)? រិលត្រឡប់មករស់ក្បែរព្រះរាជាវរហូតមកដល់ ព្រះបាទពញាយ៉ាត (១៣៩៣-១៤៦៣) ទ្រង់ប្តូររាជធានីពីក្រុងអង្គរមកនៅទួលបាសាន (១៤៣១)? រួចមកភ្នំពេញចតុមុខ (១៤៣២)? ប្រហែលពីពេលនោះមកហើយ ដែលខ្មែរនិយមហៅរបាំស្រី ដែលជាប្រភេទសិល្បៈទេវៈនេះថាជារបាំ ឬល្ខោនព្រះរាជទ្រព្យជារៀងរហូតមកៗ

យើងមិនបានដឹងពិតប្រាកដទេ អំពីការវិវឌ្ឍរីកចម្រើន ឬស្រុតចុះរបស់ទម្រង់ល្ខោនក្បាច់បុរាណនេះ នៅក្នុងសម័យក្រោយរាជព្រះបាទពញាយ៉ាត តែបើតាមឯកសារមហាបុរសខ្មែរ យើងអាចដឹងបានថា ទម្រង់សិល្បៈរបាំស្រី ឬល្ខោនព្រះរាជទ្រព្យនេះ ត្រូវបានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទរាជា ឬអង្គច័ន្ទទី ១ (គ.ស ១៥១៦-១៥៦៦) ដែលជាព្រះរាជាដ៏ខ្លាំងពូកែមួយអង្គក្រោយសម័យអង្គរៗ ព្រះអង្គទ្រង់គង់នៅព្រះរាជវាំងបន្ទាយលង្វែកៗ ទ្រង់បានខិតខំការពារមាតុភូមិឲ្យបានសុខសន្តិភាពយ៉ាងយូរ សត្រូវទាំងឆ្វេងស្តាំមិនហ៊ានឈ្លានពានឡើយ ហើយទ្រង់បានរៀបចំប្រទេសជាតិឲ្យរីកចម្រើនលើគ្រប់វិស័យ ទាំងវិស័យវប្បធម៌ សាសនា និងសេដ្ឋកិច្ច ក្នុងនោះសិល្បៈគ្រប់ផ្នែកគំបានរីកចម្រើនយ៉ាងខ្លាំងក្លាណាស់ដែរៗ ឯកសារបានរៀបរាប់ថា ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់សម្អិតសម្អាងសិល្បៈមហោស្រព របាំតន្ត្រី ទម្រង់ល្ខោនប្រុសល្ខោន

www.elibraryofcambodia.org

ស្រី ដើម្បីទុកជាគ្រឿងសម្ដែងក្នុងពិធីការ ជូនជាកិត្តិយសចំពោះមន្ត្រីជាន់ខ្ពស់ទាំងឡាយ ដែលបានទទួលជោគជ័យធំធេង ក្នុងការបម្រើជាតិមាតុភូមិរបស់ខ្លួនៗ ឯកសារក៏បានកត់ត្រាទុកយ៉ាងច្រើនផងដែរ ពីទំនាក់ទំនងយ៉ាងស្និទ្ធស្នាល សន្ដោសប្រណីរវាងព្រះរាជា និងសិល្បករសំណប់ព្រះទ័យរបស់ព្រះអង្គៗ

ប៉ុន្តែជាអកុសលមិនបានយូរប៉ុន្មាន ក្រោយពីរាជ្យព្រះអង្គចន្ទរាជា រាជធានីលង្វែកដែលជាបន្ទាយដ៏រឹងមាំចុងក្រោយរបស់កម្ពុជា ក៏ត្រូវរលំរលាយដោយសៀមប្រើល្បិច យកប្រាក់ដួងធ្វើជាគ្រាប់កាំភ្លើងបាញ់ចូលក្នុងគុម្ពឫស្សី ដំរុញចិត្តខ្មែរដែលលោភលន់ និងល្ងង់ខ្លៅមួយចំនួន ឲ្យកាប់គ្នារអស់កំពែងឫស្សីដ៏ក្រាស់របស់បន្ទាយលង្វែក ហើយទីបំផុតរាជធានីនេះក៏ត្រូវរលាយជាផេះផង់ដោយស្នាដៃសត្រូវសៀមសារជាថ្មី នៅឆ្នាំ ១៥៩៣ នៃគ.សៗ

ក្រោយសម័យលង្វែក សិល្បៈព្រះរាជទ្រព្យនេះ ក៏នៅតែមានវត្តមានជានិច្ចនៅក្នុងព្រះបរមរាជវាំងៗ រហូតមកដល់រជ្ជកាល ព្រះរាជសម្ភារ«ពញាតូ» ដែលជាព្រះមហាក្សត្រ និងជាកវីនិពន្ធដ៏ឆ្នើម (១៦២៩-១៦៣៤) ដែលទ្រង់គង់នៅឧត្តុង្គ ហើយមានវិបត្តិជាមួយ នឹងព្រះឧទ័យរាជា (បិតុលា) ពីរឿងស្នេហាលើស្រីតែម្នាក់ ហើយព្រះអង្គទ្រង់ផ្លាស់មកគង់នៅវាំងកោះឃ្លោក ដោយប្រហែលជានាំមកនូវក្រុមសិល្បៈព្រះរាជទ្រព្យ មួយក្រុមមកជាមួយផងៗ ព្រោះក្រោយពីការសិក្សាស្រាវជ្រាវអំពីទម្រង់ល្ខោនខ្មែរ យើងឃើញទំនងដូចជាមានត្រូវដែលសេសសល់ពីកោះឃ្លោក បានទៅបង្រៀនល្ខោនស្រីនៅម្ដុំកៀនស្វាយកោះស្លាកែត ? ស្ថិតនៅខាងត្បូងឈៀងខាងកើតរាជធានីភ្នំពេញ ដែលល្ខោនពោលស្រីនេះនៅមានវត្តមានរហូតមកដល់សព្វថ្ងៃនេះៗ បើយើងគិតពីបែកលង្វែករហូតមកដល់រាជព្រះឧទ័យរាជា ឬអង្គចន្ទទី ២ (១៨០៦-១៨៣៤)រាជ្យក្សត្រីអង្គម៉ី (១៨៣៤-១៨៤០) ប្រទេសជាតិខ្មែរត្រូវចុះដុនដាបស្ទើររលាយបាត់រូបដោយសារទំនាស់រាជវង្ស ... ទាស់ផ្ទៃក្នុង និងសង្គ្រាមឈ្លានពានពីខាងក្រៅមកផងៗ ...

www.elibraryofcambodia.org

ល្អមហាជ័យជម្នះដ៏ត្រចះត្រចង់ របស់ព្រះហរិរក្សរាមាធិបតីព្រះអង្គដួង (១៨៤០-១៨៥៩) ក្នុងសង្គ្រាមសង្គ្រោះប្រទេសជាតិ ដោយមានប្រជារាស្ត្រទូទាំងនគរបានស្ម័គ្រចិត្តក្រោកឈរដង្ហែព្រះអង្គផងនោះ ហើយដែលធ្វើឲ្យសៀម និងយួនព្រមទទួលស្គាល់ព្រះអង្គ ជាព្រះមហាក្សត្រនៃប្រទេសកម្ពុជាព្រមគ្នា និងបានបង្អាក់មហិច្ឆិតាលោភលន់នៃសត្រូវទាំងសងខាងមិនឲ្យយកទន្លេមេគង្គ ធ្វើជាព្រំប្រទល់នៃប្រទេសទាំងពីរបានៗ ប៉ុន្តែ គឺចាប់តាំងពីពេលមុននោះមកម្ល៉េះ ដែលខ្មែរបានទទួលឥទ្ធិពលពីសៀមខាងផ្នែកវប្បធម៌ ដោយខ្មែរបានចម្លងយកមរតកកេរដូនតាខ្លួន ដែលសៀមបានឆក់ប្លន់យកទៅមកវិញៗ ហើយភាគច្រើនគឺប្រើពាក្យឬឈ្មោះជាសៀមដែលបានបកប្រែ ពីឈ្មោះដើមរបស់ខ្មែរទៅដូចជា ឈ្មោះបទភ្លេងជាច្រើន ដែលយើងបានរៀបរាប់ក្នុងសៀវភៅល្ខោនខោល (បោះពុម្ពឆ្នាំ ២០០០ ដោយជំនួយមូលនិធិតូយូតា Toyota Foundation ជប៉ុន) ជាកស្តុតាង រហូតដល់មានខ្មែរខ្លះយល់ច្រឡំហៅភ្លេងពិណពាទ្យរបស់ខ្លួនថា ជាភ្លេងសៀមថែមទៀតផង ?ៗ ប៉ុន្តែ ក្រោយពីការកាត់បន្ថយបាននូវការឈ្លានពានរបស់សត្រូវទាំងសងខាង ឥទ្ធិពលនេះក៏ត្រូវសាបរលាបទៅៗជារៀងរាល់ថ្ងៃ ដោយប្រជាជនខ្មែរមានឱកាសស្វែងយល់កាន់តែច្បាស់ អំពីវប្បធម៌ជាតិរបស់ខ្លួនឡើងវិញ ហើយខំកសាងវប្បធម៌សិល្បៈជាតិរបស់ខ្លួនបន្តពីដូនតាឲ្យបានរីកចម្រើនយ៉ាងខ្លាំងក្លា ពិសេសគឺការរីកចម្រើននៅក្នុងរជ្ជកាលព្រះបាទនរោត្តម សីហនុវរ្ម័ន (១៩៤១-១៩៥៥) និងសម័យសង្គមរាស្ត្រនិយម (១៩៥៦-១៩៧០) ដែលធ្វើឲ្យពិភពលោកចាប់អារម្មណ៍ និងស្ងើចសរសើរវប្បធម៌សិល្បៈជាតិកម្ពុជាយ៉ាងខ្លាំងៗ ក្នុងរយៈកាលនេះក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រិយានី កុសុមៈនារីរតន៍សិរីវឌ្ឍនា ជាព្រះមាតាព្រះបាទសម្តេច នរោត្តម សីហនុវរ្ម័ន មិនថាឡើយតែសិល្បៈរបាំ ឬល្ខោនព្រះរាជទ្រព្យ ដែលជាប្រភេទសិល្បៈសក្ការៈ សិល្បៈនៃប្រាសាទទេវស្ថាន ដែលមានប្រភពចេញពីអ្នកប្រាជ្ញរាជបណ្ឌិត ដែលបានរីកចម្រើនយ៉ាងខ្លាំងក្លា

www.elibraryofcambodia.org

ទាំងបច្ចេកទេសសិល្បៈ ទាំងប្រណីតភាព និងសោភណភាពទាំងអលង្ការតុបតែងលម្អដូចជាមកុដធ្វើអំពីមាសសុទ្ធដាំត្បូងពេជ្រដ៏មានតម្លៃ (ពិសេសគឺមកុដសម្រាប់តួនាង និងនាយរោង) ទម្រង់សិល្បៈដទៃទៀតទាំងអស់ដែលជាសិល្បៈប្រពៃណី សិល្បៈប្រជាប្រិយ សិល្បៈជនជាតិ ដែលមានប្រភពចេញមកពីប្រជាជន មហាជនក៏ត្រូវបានព្រះអង្គជំរុញលើកស្ទួយធ្វើការសិក្សាស្រាវជ្រាវចងក្រង ឲ្យបានរីកចម្រើនខ្លាំងក្លាដូចគ្នាផងដែរ នៅទូទាំងប្រទេសកម្ពុជាគួរជាទីមោទនៈយ៉ាងក្រៃលែង។

ប៉ុន្តែជាអកុសល មោទនភាពនេះបានក្លាយទៅជាសុបិនរបស់ខ្មែរ គ្រប់ៗរូបយ៉ាងឆាប់រហ័សទៅវិញ ដោយសារសង្គ្រាមបំផ្លាញជាតិដ៏សាហាវបានចាប់ផ្តើមនៅឆ្នាំ ១៩៧០។

គ្រាន់តែមួយរយៈពេលខ្លីល្មមប៉ុណ្ណោះ ការបែកបាក់ផ្ទៃក្នុងរបស់ខ្មែរបានជំរុញប្រទេសកម្ពុជា ឲ្យប្តូររបបនយោបាយច្រើនលើកច្រើនសារហូតដល់ខ្មែរម្នាក់ៗស្ទើរតែចាំពុំបាននូវរូបភាពទង់ជាតិ និងភ្លេងជាតិក្នុងរបបនីមួយៗដែលខ្លួនធ្លាប់បានច្រៀងកាត់នោះផង។ ឯវប្បធម៌សិល្បៈដែលជាអត្តសញ្ញាណជាតិវិញបានត្រូវទ្រុឌទ្រោមរលាយរលត់បត់បែន ទៅតាមដំណាក់កាលនីមួយៗនោះដែរ យ៉ាងណាមិញនៅចន្លោះឆ្នាំ ១៩៧០-១៩៧៥ ក្នុងរបបសាធារណៈរដ្ឋខ្មែររបស់លន់ នល់ ដែលបានផ្តួលរំលំរបបរាជានិយម របាំព្រះរាជទ្រព្យដែលធ្លាប់ហៅពីមុន និងដែលស្ថិតជាប់នឹងព្រះរាជាត្រូវគេប្តូរមកហៅថា របាំ បុរាណ ល្ខោនក្បាច់បុរាណវិញ ហើយបង្វែរការទទួលខុសត្រូវឲ្យមកនៅក្រោមសាកលវិទ្យាល័យវិចិត្រសិល្បៈ ប៉ុន្តែទីតាំងហាត់រៀនផ្នែកបច្ចេកទេសរក្សាទុកនៅដដែល គឺហាត់នៅប្រាសាទ ...ធោយាក្នុងព្រះបរមរាជវាំង។

ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ពេលដែលរបបសាធារណៈខ្មែរដួលរលំទៅ ...បុលយ័ពួកសាសន៍ «កម្ពុជាប្រជាធិបតេយ្យ» ក៏ឡើងមកកាន់អំណាច ។ពេល

www.elibraryofcambodia.org

នោះរបាំក្បាច់បុរាណក៏ដូចជាទម្រង់សិល្បៈដទៃទៀត ត្រូវគេលុបបំបាត់ចោលទាំងស្រុងដោយយកលេសថា ជាមរតកសិល្បៈសក្តិភូមិៗ សិល្បករ សិល្បការិនីភាគច្រើនត្រូវកាប់សម្លាប់ អ្នកខ្លះត្រូវគេធ្វើទារុណកម្មសម្លាប់នៅគុកទួលស្លែង មានឯកសារនៅជាភស្តុតាងផងៗ ឆ្នាំ១៩៧៩-១៩៨៣ ក្រោយពីរបបប្រល័យពូជសាសន៍ដួលរលំទៅ ប្រទេសជាតិ និងប្រជាជនកម្ពុជា ត្រូវបានសង្គ្រោះដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាៗ ក្នុងរយៈកាលនេះសិល្បករ និងគ្រូចាស់ៗបន្តិចបន្តួចលើគ្រប់មុខជំនាញដែលសេសសល់ពីស្លាប់ បានខិតខំពីបាតដៃទទេដោយក្តីលំបាកលំបិនជាទីបំផុត ដោយប្រឹងធ្វើឲ្យរស់ឡើងវិញ នូវសិល្បៈគ្រប់ប្រភេទ ក្នុងនោះក៏មានរបាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យផងដែរ ដែលគេនិយមហៅឈ្មោះថារបាំ ឬល្ខោនក្បាច់បុរាណខ្មែរៗ

ក្រោយឆ្នាំ១៩៩៣ ពោលគឺពេលដែលសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ដោយមានការបោះឆ្នោតគាំទ្រ ដោយអង្គការសហប្រជាជាតិ ហើយប្រទេសជាតិត្រូវសម្រេចឲ្យស្ថិតក្នុងរបបរាជានិយម **«ព្រះរាជាណាចក្រកម្ពុជា»** ជាលើកទីពីរឡើងវិញ នោះរបាំក្បាច់បុរាណនេះ ក៏ត្រូវបានគេនិយមហៅឈ្មោះទាំងពីរ គឺល្ខោន ឬរបាំក្បាច់បុរាណខ្មែរ និងល្ខោន ឬរបាំព្រះរាជទ្រព្យ រហូតមកដល់សព្វថ្ងៃនេះ។

www.elibraryofcambodia.org

# ២-របាំប្រពៃណី



www.elibraryofcambodia.org

ពាក្យប្រពៃណី ឬប្រវេណី ឬបវេណីមានន័យថា ទំនៀមពូជពង្ស តំណវង្សត្រកូល ដូចជាការខិតខំថែរក្សាបវេណីនៃត្រកូលរបស់ខ្លួន ឬការនិយមធ្វើបុណ្យទានតាមប្រពៃណីជាដើម។ ឯរបាំប្រពៃណីវិញ គឺសម្គាល់របាំទាំងឡាយដែលស្ថិតជាប់នឹងពិធីប្រពៃណី ឬពិធីតំណត្រកូលដ៏យូរលង់មកហើយរបស់ជនជាតិខ្មែរ ឬក៏ជនជាតិដទៃទៀតទាំងអស់ ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ខុសៗគ្នា ទាំងមានការនិយមដូចគ្នាក្ដី ឬការនិយមខុសគ្នាក្ដី នៅតំបន់ភ្នំខ្ពង់រាបតំបន់វាលទំនាបទន្លេមេគង្គ និងតំបន់មាត់សមុទ្រ។ ដូចជារបាំគាប់ក្របីផឹកស្រារបស់បងប្អូនជនជាតិខ្មែរព្នង ខ្មែរគ្រឹង ខ្មែរទំពួន ដែលជឿលើជំនឿអារក្ខអ្នកតា។ របាំនេះនៅភូមិកាតញៀសាន បានស្ថិតនៅជាប់ជាមួយនឹងពិធីប្រពៃណីគាប់ក្របីសែនអ្នកតា ក្នុងពេលដែលអ្នកភូមិជួបគ្រោះអាសន្ន និងដើម្បីបំបាត់ឧបទ្រពចង្រៃ សុំសេចក្ដីសុខសប្បាយឲ្យកើតមានដល់ស្រុកភូមិ ហើយពេលខ្លះគេរាំសុំទឹកភ្លៀងផងដែរ។ របាំស្នែងទន្សោង របាំសែនព្ធយ និងរបាំក្លាក ពោធិ៍សាត់របស់បងប្អូនជនជាតិខ្មែរពរ៍ នៅតំបន់ភ្នំក្រវាញ ដែលគេតែងតែរាំថ្វាយអ្នកតាម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃភ្នំ សុំឲ្យបានសុខសប្បាយ ក្នុងពេលទៅប្រកបរបរផ្សេងៗ ដូចជាបេះក្រវាញ រកជ័រ ឬមុខរបរប្រមាញ់ជាដើម ហើយសូមឲ្យប្រមូលផលបានច្រើនថែមទៀត។ របាំអារក្ខ របស់បងប្អូនជនជាតិខ្មែរស្ទាមនៅខេត្តកំពង់ឆ្នាំងសម្រាប់រាំក្នុងពិធីលៀងអារក្ខលាបំណន់ ក្រោយពីការបន់ស្រន់ឲ្យអ្នកជំងឺដែលគេជឿថាឈឺដោយបានប្រព្រឹត្តខុសឆ្គងចំពោះពូជពង្សវង្សត្រកូលបានសះស្បើយ ហើយចាត់ទុកពិធីនោះជាការលាមាត់ លាក សុំខមាទោស ចំពោះកំហុសឆ្គង ដែលបានប្រព្រឹត្តរួចមកហើយចំពោះដូនតានោះផង។

របាំក្លាករបស់បងប្អូនជនជាតិកូឡា ដែលច្រើនមានមុខរបរ ជាអ្នករកត្បូងពេជ្រ។ របាំនេះ ច្រើនរាំក្នុងថ្ងៃសីល ឬក៏ក្នុងពិធីបុណ្យផ្សេងៗខាងព្រះពុទ្ធសាសនា ដើម្បីសុំសេចក្ដីសុខ និងរកទទួលទានមានបានផង។

www.elibraryofcambodia.org

របាំគោះត្រឡោក និងរបាំកណ្ដូបសេះនៅខេត្តស្វាយរៀង ដែលជាប់នឹងពិធីអាពាហ៍ពិពាហ៍កូនប្រុសស្រី ពិសេសក្នុងពិធីហែកូនកម្លោះៗ ឯរបាំបុកល័ក្កវិញគឺបានដកស្រង់ចេញពីទំនៀមទម្លាប់ អាពាហ៍ពិពាហ៍របស់ជនជាតិខ្មែរដែលជាមរតករបស់ព្រះថោងនាងនាគ ព្រះមហាក្សត្រខ្មែរនៅសតវត្សរ៍ទី ១ នៃគ.សៗ របាំខែល ឬរបាំរាយគួយ របស់បងប្អូនជនជាតិគួយ នៅខេត្តស្ទឹងត្រែងដែលជារបាំមានប្រភពមកពីកីឡាដែលជាទំនៀមទម្លាប់សប្បាយរីករាយរបស់ជនជាតិនេះក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិៗ របាំពន្ធ័រ៉ុង នៅខេត្តកោះកុងដែលទាក់ទងនឹងទំនៀមទម្លាប់បួងសួងបន់ស្រន់ កំថ្វាយអ្នកតាមុនពេលចេញទៅកេងវ័រង្គ ដើម្បីសុំសេចក្ដីសុខ និងបានជោគជ័យក្នុងការកេងវ័រង្គនេះៗ

របាំពួយស្ទួយ និងរបាំជាច្រើនទៀតរបស់ជនជាតិស្ទួយ នៅខេត្តកំពង់ស្ពឺដែលមានជំនឿលើអារក្សអ្នកតាដែរៗ របាំត្រុដិនៅខេត្តសៀមរាប និងនៅម្តុំតំបន់ផ្លូវភ្នំដងរែករាំក្នុងពិធីបុណ្យចូលឆ្នាំថ្មី ដើម្បីបំបាត់ឧបទ្រពចង្រៃនៃឆ្នាំចាស់និងសុំឲ្យមានមង្គលសិរីសួស្ដី សុកមង្គលក្នុងឆ្នាំថ្មីថែមទៀតផងៗ របាំនាងម៉េវ ឬរបាំត្រុដិនាងម៉េវ ដែលសិល្បករ នាំគ្នាសែងឆ្មាដើររាំកាត់ស្រុកភូមិជាច្រើន ដើម្បីសុំទឹកភ្លៀង ពិសេសក្នុងពេលដែលស្រុកទេសជួបគ្រោះរាំងស្ងួតនោះៗ

ក្រៅពីនេះនៅមានរបាំប្រពៃណីជាច្រើនទៀត ដែលនៅរាយប៉ាយពេញទាំងផ្ទៃប្រទេសកម្ពុជាៗ តាមការស្រាវជ្រាវរួចមកហើយ យើងសង្កេតឃើញថាភាគច្រើនលើសលប់នៃរបាំប្រពៃណីនៅប្រទេសកម្ពុជា គឺសុទ្ធតែទាក់ទងទៅនឹងជំនឿអារក្សអ្នកតា ដែលជាជំនឿរបស់ខ្មែរដើមៗ ប៉ុន្តែក៏មានរបាំខ្លះទាក់ទងនឹងព្រះពុទ្ធសាសនាផងដែរ ដូចជារបាំក្ងោកប៉ៃលិន ឬរបាំត្រុដិជាដើមៗ

ម្យ៉ាងទៀតដោយសង្កេតឃើញថាមានរបាំ និងពិធីប្រពៃណីខ្លះមានលក្ខណៈដូចគ្នាទាំងនៅកម្ពុជា និងនៅប្រទេសដទៃទៀត ស្ថិតនៅក្នុងតំបន់ជាមួយគ្នាដូចជារបាំគោះត្រឡោក របាំគោះអង្រែ ល្បែងប្រពៃណី ចាប់កូនខ្លែង បុលាក់កន្ទុង

www.elibraryofcambodia.org

ជាដើមនោះ ទើបអស់លោកអ្នកប្រាជ្ញ អ្នកស្រាវជ្រាវទាំងឡាយយល់ថា របាំប្រពៃណី ឬពិធីប្រពៃណីទាំងនេះជាមរតកវប្បធម៌រួមគ្នា របស់ជនជាតិទាំងឡាយដែលស្ថិតក្នុងអម្បូរអូស្រ្តូអាស៊ី (វប្បធម៌អាស៊ីភាគខាងត្បូង) ដែលបានយោនយកកំណើតច្រើនពាន់ឆ្នាំមកហើយនៅអាស៊ីភាគខាងត្បូង ពិសេសនៅតាមដូរភ្នំនានា ឬតាមកោះនានាដែលស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍នេះតែម្តងៗ

ចំពោះការសិក្សាស្រាវជ្រាវ របាំប្រពៃណីនៅប្រទេសកម្ពុជាវិញ យើងទើបតែបានចាប់ផ្តើមធ្វើឡើង នៅក្នុងអំឡុងឆ្នាំ ១៩៦០ ប៉ុណ្ណោះ ក្រោមព្រះតម្រិះ និងព្រះរាជកិច្ចឧបត្ថម្ភរបស់ព្រះមហាក្សត្រិយានី កុសុមៈនារីរតន៍ សិរីវឌ្ឍនា ដែលទ្រង់សព្វព្រះរាជហឫទ័យ ថែរក្សាការពារ និងលើកតម្កើងវប្បធម៌ អត្តសញ្ញាណជាតិឲ្យខ្ពស់ត្រដែតឡើងៗ

ក្រុមអ្នកស្រាវជ្រាវនេះ ដឹកនាំដោយលោកព្រឹទ្ធាចារ្យ ឆេង ផុន ដែលកាលណោះលោកបាននាំក្រុមស្រាវជ្រាវ ទៅធ្វើការសិក្សារបាំប្រពៃណីជាតិ និងជនជាតិជាច្រើនទឹកខ្មែរ ដូចជាភូមិភាគពាយ័ព្យ ភូមិភាគនិរតី និងឦសាននៃប្រទេសដែលមានជនជាតិរស់នៅច្រើនៗ

លទ្ធផលនៃការស្រាវជ្រាវនោះ គឺបានលទ្ធផលល្អប្រសើរដោយយើងអាចហាត់រៀនចម្លងពីប្រជាជនបាននូវរបាំប្រពៃណីជាច្រើន ដូចដែលយើងបានថែរក្សាទុកនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងនាយកដ្ឋានសិល្បៈនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌តាមខេត្តនានាផងៗ ម្យ៉ាងទៀតគឺចេញពីការចាប់ផ្តើមស្រាវជ្រាវដំបូងនោះហើយ ដែលបង្កើត ឬប្រមូលបាននូវបទពិសោធសម្រាប់អ្នកស្រាវជ្រាវជំនាន់បន្តមកទៀត ដែលពេលខ្លះបានធ្វើការសិក្សាចងក្រង និងដំឡើងរបាំប្រពៃណីថ្មីៗ ខ្លះទៀតផងដែរៗ

ឯរបាំប្រពៃណីដែលយើងបានទៅរៀនសូត្រ ហើយចម្លងមកពីប្រជាជនបានមានដូចតទៅនេះ ÷

www.elibraryofcambodia.org

| | |
|---|---|
| ០១- របាំត្រុដិ | ខេត្តសៀមរាប និងផ្លូវភ្នំដងរែក |
| ០២- របាំត្រុដិនាងម៉េវ | ខេត្តសៀមរាប និងផ្លូវភ្នំដងរែក |
| ០៣- របាំក្ងោកប៉ៃលិន | ក្រុងប៉ៃលិន |
| ០៤- របាំបក់ស្រូវ | ខេត្តបាត់ដំបង |
| ០៥- របាំក្ងោកពោធិ៍សាត់ | ខេត្តពោធិ៍សាត់ |
| ០៦- របាំបេះក្រវាញ | ខេត្តពោធិ៍សាត់ |
| ០៧- របាំសែនកួយ | ខេត្តពោធិ៍សាត់ |
| ០៨- របាំស្នែងទន្សោង | ខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង |
| ០៩- របាំព័ទ្ធរត្ត | ខេត្តកោះកុង |
| ១០- របាំកួយសួយ | ខេត្តកំពង់ស្ពឺ |
| ១១- របាំកន្ត្រៃ | ខេត្តកំពង់ស្ពឺ និងកំពង់ធំ |
| ១២-របាំប្រម | ខេត្តតាកែវ |
| ១៣-របាំភយក្រាប់ | ខេត្តតាកែវ-កណ្ដាល |
| ១៤-របាំអន្ទង់ហែន | ខេត្តកណ្ដាល |
| ១៥-របាំគោះត្រឡោក និងកណ្ដូបសេះ | ខេត្តស្វាយរៀង |
| ១៦-របាំគោះអង្រែ | ខេត្តកំពង់ចាម កណ្ដាល និងផ្លូវភ្នំដងរែក |
| ១៧-របាំតូណៃទីន | ខេត្តរតនគិរី មណ្ឌលគិរី |
| ១៨-របាំកាប់ក្របីផឹកស្រា | ខេត្តរតនគិរី មណ្ឌលគិរី |
| ១៩-របាំកំរង់ភូមិថ្មី(កំរង់ស្រុកហាន់ទឹម) | ខេត្តរតនគិរី |
| ២០-របាំគែន | ខេត្តស្ទឹងត្រែង |
| ២១- របាំភ្ញាយកួយ | ខេត្តស្ទឹងត្រែង |
| ២២- របាំចាក់គ្រើល | ខេត្តកំពង់ធំ |
| ២៣- របាំត្បាល់កាប់ ឬត្បាល់ក្បៀង | ខេត្តកំពង់ធំ . |

www.elibraryofcambodia.org

២៤- របាំអារក្ខតាម ខេត្តកំពង់ឆ្នាំង
២៥- របាំស្វា
២៦- របាំនេសាទ
២៧- របាំកង្កែប
២៨- របាំអាពាហ៍ពិពាហ៍បក្សី
២៩- របាំស្គរគ្នាត
៣០- របាំក្អម ខេត្តកំពង់ឆ្នាំង
៣១- របាំបរគោ ខេត្តកំពង់ឆ្នាំង
៣២- របាំច្រូតស្រូវ
៣៣- របាំបុកល័ក្ខ
៣៤- របាំកន្សែងស្នេហ៍
៣៥- របាំចាក់អន្ទ្រង ខេត្តសៀមរាប
៣៦- របាំឆៃយ៉ាំ
៣៧- របាំដាល់អំបុក ខេត្តកំពង់ស្ពឺ
៣៨- របាំស្គរ ខេត្តកំពង់ស្ពឺ
៣៩- របាំគងស្នួយ ខេត្តកំពង់ស្ពឺ
៤០- របាំជួសទឹកប៉ូស្រា
៤១- របាំស្គូល (ជនជាតិស្មៀង)
៤២- របាំត្រុមាៗលៗ

ហើយនៅមានរបាំប្រពៃណីជាច្រើនទៀត ដែលស្ថិតនៅក្នុងដៃប្រជាជន ដែលយើងមិនទាន់បានរៀនសូត្រកត់ត្រាទុក ឬដំឡើងជាផ្ទាំងទស្សនីយភាពដើម្បីផ្សព្វផ្សាយជាទូលាយនៅឡើយ ពិសេសគឺរបាំ ដែលជាប់នឹងពិធីទំនៀមទម្លាប់

www.elibraryofcambodia.org

ប្រពៃណីរបស់ខ្មែរ និងជនជាតិនានា ដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាលទាំងតំបន់ព្រៃភ្នំ ទាំងតំបន់ទំនាប និងទាំងតំបន់មាត់សមុទ្រផង ដែលយើងត្រូវតែមានទិសដៅធ្វើការសិក្សាស្រាវជ្រាវចងក្រង កត់ត្រាទុក និងដំឡើងជាបន្តទៅទៀត។

www.elibraryofcambodia.org

# ៣-របាំប្រជាប្រិយ



www.elibraryofcambodia.org

មិនខុសអ្វីពីល្បែងប្រជាប្រិយ៍ចោលឈូង លាក់កន្សែង ចាប់កូនខ្លែង បោះអង្គញ់ ស្តេចចង់ ឬល្បែងឯទៀតដែលខ្មែរនិយមនាំគ្នាលេងកម្សាន្ត ក្នុងពិធីបុណ្យនានា ពិសេសគឺបុណ្យចូលឆ្នាំប្រពៃណីជាតិនោះឡើយៗ របាំប្រជាប្រិយ រាំវង់ រាំក្បាច់ គឺជាប្រភេទរបាំដែលមានការនិយមជាទូទៅ នៅក្នុងទូទាំងប្រទេសទោះនៅទីក្រុងក៏ដូចជាជនបទ នៅតំបន់ភ្នំក៏ដូចនៅវាលទំនាប ឬក៏តំបន់មាត់សមុទ្រៗ របាំប្រជាប្រិយខ្មែរនេះជាប្រភេទរបាំដែលងាយចាំងាយចេះ ហើយងាយក្នុងការរៀបចំសម្តែងទៀតផងៗ អាស្រ័យហេតុនេះទើបគេសង្កេតឃើញប្រជាជនខ្មែរតាំងពីព្រះរាជា នាម៉ឺនសព្វមុខមន្ត្រីរហូតដល់ប្រជារាស្ត្រ ទាំងក្មេង ទាំងចាស់ ប្រុសស្រី ចេះរាំរបាំនេះគ្រប់ៗគ្នា

ឯពាក្យថារាំវង់ គឺជាលក្ខណៈពិសេសសម្រាប់សម្គាល់រូបភាពនៃរបាំនេះ ពោល គឺពេលរាំគេនាំគ្នារាំបន្តគ្នាជារង្វង់មូលៗ ហើយជារបាំសម្រាប់រាំលេងកម្សាន្ត ឬក៏រាំដើម្បីបំបាត់ការនឿយហត់ ក្រោយពីការបំពេញពលកម្មនានារួចៗ



ចំពោះប្រវត្តិកំណើតនៃរបាំរាំវង់នេះវិញ បើយើងពឹងផ្អែកលើឯកសារសរសេរដែលមានបន្តិចបន្តួច និងផ្អែកលើភាពជាក់ស្តែងក្នុងជីវិត ដែលបានប្រព្រឹត្តដល់យើងសព្វថ្ងៃនេះ យើងជឿថា សិល្បៈរាំវង់នេះមានអាយុច្រើនសតវត្សរ៍ណាស់មកហើយនៅលើមាតុភូមិកម្ពុជានេះ។

ព្រោះតាំងពីបុព្វេជំយូរលង់ ទាំងជនជាតិខ្មែរ និងជនជាតិឯទៀត ដែលស្ថិតក្នុងអម្បូរជាមួយគ្នាដូចជាព្នង គ្រឹង ទំពួន ព្រៅ មានការទាក់ទង និងការរាំវង់ ឬជារង្វង់មូលនេះជាច្រើន។

-បងប្អូនជនជាតិខ្មែរលើភូមិភាគឦសាននៃប្រទេស ឬតំបន់ព្រៃភ្នំនៃភូមិភាគដទៃទៀត និយមរាំលេងកម្សាន្តនៅជុំវិញភ្នក់ភ្លើងនាពេលរាត្រី។ ទម្លាប់រាំវង់ជុំវិញភ្នក់ភ្លើងនេះ មានអាយុច្រើនពាន់ឆ្នាំមកហើយ ហើយក៏នៅមានសេសសល់រហូតដល់សព្វថ្ងៃនេះ។

-ក្នុងពិធីលៀងអារក្ខ ឬឡើងអ្នកតា (ជំនឿខ្មែរដើមមានតាំងពីយូរលង់មុន



www.elibraryofcambodia.org

សម័យដែលព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ហូរចូលមកក្នុងតំបន់ស្រាយសុវណ្ណភូមិ ពោលគឺតាំងពីមុន ៣០៩ ឆ្នាំមុន គ.ស (ព្រះសោណ ព្រះឧត្តរ ចាំង ខាត់) ជនជាតិខ្មែរតែងតែនាំគ្នាសង់រោងតូចមួយដោយធ្វើរោងវត្តពុទ្ធជុំវិញ ហើយរូបមេមត់ (អ្នកចូលរូប) តែងតែរាំជារង្វង់មូលជុំវិញរោងនោះក្នុងពេលប្រារព្ធពិធីលៀងអារក្ខនេះ។

- ឯពិធីគាប់ក្របីថ្វាយអ្នកតារបស់បងប្អូនជនជាតិព្នង គ្រឹង ទំពួន ដែលមានអាយុច្រើនពាន់ឆ្នាំមកហើយ ហើយដែលគេឃើញមានរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន ដែលកសាងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២១៨) ដែលបងប្អូនយើងថែរក្សាឲ្យគង់វង្សរហូតមកដល់សព្វថ្ងៃនេះផងនោះ ក៏មានទម្លាប់រាំជាវង់ ឬជារង្វង់មូលផងដែរ។

លើសពីនេះទៅទៀត បងប្អូនជនជាតិព្រៅ ព្នង គ្រឹង ទំពួននៅប្រកាន់ភ្ជាប់ទំនៀម «រាំវង់ភូមិថ្មី» ដែលភាសាជនជាតិនិយមថា **«រាំវង់ ស្រុកបាន់ទើម»**។ របាំរាំវង់ភូមិថ្មី គេមានទម្លាប់ធ្វើនៅក្នុងពេលប្តូរភូមិ ពីភូមិចាស់ទៅរស់នៅក្នុងភូមិថ្មីតាមធម្មតា ក្នុងរយៈពេលពីបីទៅប្រាំពីរឆ្នាំ មុននឹងប្តូរភូមិ ឬចាកចេញពីភូមិចាស់ មេកន្រ្ទាញ និងចាស់ទុំក្នុងភូមិ តែងនាំគ្នាធ្វើពិធីផ្សងទៅតាមជំនឿរបស់ខ្លួនដើម្បីរកកន្លែងដីថ្មី ដែលមានលក្ខណៈភូមិសាស្រ្តល្អ មានទឹកគ្រប់គ្រាន់ និងជាកន្លែងដែលអាចការពារសន្តិសុខជូនញាតិមិត្ត ក្នុងស្រុកភូមិបានល្អ។ ពេលផ្សងរើសរកដីថ្មីបានហើយ ទើបគេនាំគ្នាធ្វើពិធីកំណត់ឆ្នាំសម្រាប់រស់នៅ គឺឲ្យដឹងថាតើពួកគេអាចរស់នៅបានប៉ុន្មានឆ្នាំ នៅនឹងភូមិថ្មីនោះ?។ ពិធីកំណត់ឆ្នាំ សម្រាប់រស់នៅនេះប្រព្រឹត្តទៅដោយមេកន្រ្ទាញ និងចាស់ទុំភូមិធ្វើពិធីផ្សង ដោយយកប្រទាលបកចិតទម្លាក់មកលើដីចំនួនប្រាំពីរចំណិត។ បើប្រទាលនោះក្រឡាប់ប៉ុន្មានចំណិតនោះគេជឿថា គេអាចរស់នៅក្នុងភូមិថ្មីនោះបានប៉ុណ្ណឹងឆ្នាំដែរ ពោលគឺតាមចំនួនចំណិតប្រទាលដែលក្រឡាប់នោះ។ ដូចជា បើប្រទាលក្រឡាប់បី ឬប្រាំចំណិតនោះ

www.elibraryofcambodia.org

គេអាចរស់នៅទីនោះបានបី បួនឆ្នាំដែរ ហើយជំនឿនេះមានរឿងរហូតតាំងពីបុរាណយូរលង់ណាស់មកហើយ រហូតដល់សព្វថ្ងៃនេះៗ ពេលធ្វើពិធីផ្សងរកដីថ្មីបានហើយ មេកន្ទ្រាញក៏ប្រកាសឲ្យអ្នកស្រុក អ្នកភូមិរុះរើពីភូមិចាស់ទៅរៀបចំផ្ទះសំបែងនៅភូមិថ្មីៗ ពេលនាំគ្នាចូលទៅភូមិថ្មីជាដំបូង គេនាំគ្នាប្រារព្ធពិធីសម្តែងរបាំ រាំវង់ភូមិថ្មីនេះមុនគេបង្អស់ៗ អ្នកស្រុក អ្នកភូមិមានស្រី មានប្រុសនាំគ្នារាំជាគូ (តាមប្រពៃណីដូនតា) តៗគ្នារហូតដល់បច្ចុប្បន្ននេះ ដែលមានជំនឿថា នឹងនាំឲ្យគេគ្រប់គ្នាបានសេចក្តីសុខចម្រើនៗ

ការរៀបរាប់ខាងលើនេះបញ្ជាក់ថា របាំរាំវង់នៅប្រទេសកម្ពុជា មានតាំងពីយូរយារណាស់មកហើយ ជារបាំដែលជាប់នឹងពិធីប្រពៃណី តែលុះចំណេរក្រោយមកទើបក្លាយជារបាំប្រជាប្រិយដែលមានការនិយមចូលចិត្ត ពីគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិកម្ពុជាទាំងមូលៗ ហើយក្រោយមកទៀត ក្នុងពេលដែលប្រទេសជិតខាងមាន សៀម និងលាវ បានចាប់កំណើតឡើង របាំរាំវង់នេះក៏ដូចទម្រង់សិល្បៈឯទៀតដែរ បានហូរចុះហូរឡើង ឬក៏ជះឥទ្ធិពលឆ្លងគ្នាទៅវិញទៅមករវាងខ្មែរ និងលាវ ខ្មែរ និងសៀម ពិសេសគ្រប់តំបន់ជាយដែន និងតំបន់ដែលមានប្រជាជនខ្មែរ លាវ ឬខ្មែរសៀមរស់នៅលាយឡំគ្នាច្រើននោះៗ

បើតាមឯកសារខ្លះៗដែលនៅសល់ និងតាមព័ត៌មានដែលយើងទទួលបានពីចាស់ទុំជាច្រើនបានបញ្ជាក់ថា នៅប្រទេសកម្ពុជា របាំប្រជាប្រិយ រាំវង់ រាំក្បាច់នេះបានរីកចម្រើនយ៉ាងខ្លាំងនៅសតវត្សរ៍ទី ២០ ពិសេសគឺតាំងពីពេលដែលខ្មែរឥស្សរៈកើតមាននៅគ្រប់តំបន់ក្នុងប្រទេស និងជីវពលនារីក្លាហានក្រោកឡើងបណ្តេញអាណានិគមបារាំង ដើម្បីទាមទារឯករាជ្យជូនជាតិមាតុភូមិនោះមកហើយ ដែលគេអាចឃើញមាន សល់នៅបទចម្រៀងរាំវង់មួយចំនួន ដែលអាចជាតឹកតាង ឬជាអនុស្សាវរីយ៍នៃសម័យកាលនោះផងៗ ហើយក៏ប្រហែលនៅក្នុងពេលនោះដែរ ដែលឥទ្ធិពលនៃពាក្យបរទេសដូចជាពាក្យថា រាំ «ឡាំថុន» ឬឡែក

www.elibraryofcambodia.org

«ឡាំថូន» (ថូនគឺស្គរ) ត្រូវខ្មែរយកមកប្រើ ព្រោះពេលនោះគងទ័ពខ្មែរឥស្សរៈ ដែលបោះទីតាំងក្នុងព្រៃជ្រៅតំបន់ភ្នំដងរែក តំបន់ជ្រាវឱរ៉ាល់ ភ្នំក្រវាញ តំបន់ភាគឦសាននៃប្រទេស (ដែលអាចចងសម្ព័ន្ធជាមួយឥស្សរៈលាវ) ឬតំបន់មាត់សមុទ្រក្ដី ច្រើននាំគ្នាលេងរាំវង់ដោយប្រើស្គរដៃមួយប៉ុណ្ណោះ និងចម្រៀងដែលមានលក្ខណៈងាយស្រួលក្នុងការកម្សាន្តទៅតាមកាលៈទេសៈនៃការតស៊ូ និងការរស់នៅដោយយកព្រៃជ្រៅជាមូលដ្ឋានបង្អែក។ សូមបញ្ជាក់ថា ស្គរដៃនេះជាស្គរនៃរាំវង់ភ្លេងអារក្ខ ឬរាំវង់ភ្លេងប្រពៃណី ភ្លេងការរបស់ជនជាតិខ្មែរដែលមានកំណើតរាប់ពាន់ឆ្នាំមកហើយ។

ចាប់តាំងពីពេលស្រុកខ្មែរបានឯករាជ្យ ក្រោមព្រះរាជកិច្ចដឹកនាំនៃព្រះករុណាព្រះបាទ នរោត្តមសីហនុវរ្ម័ន ៩ វិច្ឆិកា ឆ្នាំ ១៩៥៣ មក ប្រទេសជាតិ និងប្រជារាស្ត្រមានសេរីភាពគ្រប់គ្រាន់ របាំប្រជាប្រិយរាំវង់ រាំក្បាច់ក៏បានរីកចម្រើនយ៉ាងខ្លាំងក្លា ពេលគឺនៅកន្លែងខ្លះ គេរាំជាមួយស្គរដៃ ពេលខ្លះគេរាំជាមួយវង់



www.elibraryofcambodia.org

ភ្លេងខ្មែរដែលមានឧបករណ៍ស្គរ ទ្រ រនាត និងឧបករណ៍ច្រើនផ្សេងៗទៀត រហូតដល់វង់តន្ត្រីសម័យយ៉ាងទំនើប ដែលយើងឃើញរហូតដល់សព្វថ្ងៃនេះផងៗ

## របៀបសម្តែង

ដូចបានជម្រាបខាងលើមកហើយថា រាំវង់ រាំក្បាច់ ជារបាំប្រជាប្រិយខ្មែរនេះ មានលក្ខណៈងាយស្រួលចាំ ងាយចេះទាំងក្បូរក្បាច់ ប្រើដៃ ជើង ក ចង្កេះទៀតសោតក៏សាមញ្ញណាស់ដែរៗ ចង្វាក់វិញ មិនយឺតពេក ក៏មិនញាប់ពេកដែរ គឺបើស្តាប់សំឡេងស្គរដៃ ឬ **«ប៉ាក់ពើងប៉ាក់ (ៗ)»** ឬក៏ **«តាក់ទីងតាក់(ៗ)»** យ៉ាងនេះៗ ក្នុងពេលរាំទាំងស្រី ទាំងប្រុស ត្រូវបោះជំហានឆ្វេងស្តាំទៅមុខ ដោយស្រីរាំទៅខាងមុខប្រុសរាំពីក្រោយបន្តគ្នា ឬពេលខ្លះរាំកៀងគ្នា ឬជុំរុញឲ្យប្តូរគូក៏មានៗ ឯដៃត្រូវ **«ជីប»** ពីក្រោម ហើយលើកចំពីមុខទៅ **«លា»** ខាងលើ បញ្ច្រាសគ្នាឆ្វេងម្តងស្តាំម្តងហើយលៃដៃ និងជើងនោះ ក៏ឲ្យបញ្ច្រាសគ្នាផងដែរ គឺបើឈានជើងស្តាំទៅមុខត្រូវលើកដៃឆ្វេង ហើយបើឈានជើងឆ្វេងទៅមុខវិញ ត្រូវលើកដៃស្តាំៗ រួចជួនកាលគេរាំធ្វើដំណើរទៅមុខបីជំហានរួចគោះជើងមកខាងក្រោយ **«មួយ»** ក៏មានហើយចេះតែបន្តយ៉ាងនេះ ជាវគ្គដ៏មូលរហូតទៅៗ

ឯចង្វាក់ភ្លេងរាំវង់វិញ ជាទូទៅពេលចាប់ផ្តើម ច្រើនតែស្ថិតនៅក្នុងចង្វាក់ទីង ឬស្មើធម្មតា លុះដិតចប់បទនីមួយៗ ក្រុមតន្ត្រីច្រើនតែប្រគំរន្ទីនឡើងៗ **«ញាប់ឡើងៗ»** រហូតដល់ចប់ៗ

ចំណែកខាងរាំក្បាច់វិញ ក៏មានលំនាំប្រហាក់ប្រហែលគ្នានឹងក្បាច់រាំវង់ដែរ គឺដៃត្រូវ **«ជីប»** ពីក្រោម ហើយលើកខ្ពស់ឡើងលើរួចទៅ **«លា»** នៅខាងលើ ខាងឆ្វេងម្តង ខាងស្តាំម្តង ប្តូរវេនគ្នាដោយលៃឲ្យបញ្ច្រាសគ្នានឹងជើង ដែលបោះខ្វែងគ្នាឈានទៅមុខនោះផងៗ ពោល គឺបើបោះជើងស្តាំឈានទៅមុខ ខ្វែងជើងឆ្វេងដែលទ្រទម្ងន់ដងខ្លួន ដៃឆ្វេងដែល **«ជីប»** ពីក្រោម ត្រូវរាសលើកខ្ពស់ឡើងលើ

www.elibraryofcambodia.org

ត្រឹមចុងចិញ្ចឹម ហើយ «ឈា» នៅខាងឆ្វេងៗ លុះដល់ឈានជើងឆ្វេងទៅមុខខ្វែងនឹងជើងស្ដាំដែលទ្រទម្ងន់ដងខ្លួនវិញនោះ ដៃស្ដាំដែល «ជីប» នៅខាងក្រោមត្រូវលើកខ្ពស់ឡើងរួច «ឈា» នៅខាងស្ដាំវិញម្ដងៗ ធ្វើចលនាយ៉ាងនេះ ក្នុងដំណើររាំឈានទៅមុខជាផ្លូវមូលដូចជារាំវង់ដែរ ខុសតែចង្វាក់នោះយឺតជាង គឺបើស្ដាប់ជើងស្គរឃើញ **«តាក់តាក់ទីងទីង(១)»** ឬ**«ប៉ាក់ប៉ាក់ពើងពើង(១)»** យ៉ាងនេះៗ ឯការតុបតែងលម្អទីសម្រាប់រាំវិញ មានលក្ខណៈសាមញ្ញបំផុត គឺមានតែទីលានស្អាត និងតុដាក់ផ្កាមួយថូ ឬមួយផើងដែលគេចាត់ទុកជាស្នូលកណ្ដាលប៉ុណ្ណោះៗ ប៉ុន្តែសម័យថ្មីនេះ គេឃើញមានតុបតែងលម្អភ្លើង ឬអ្វីផ្សេងៗទៀត ទៅតាមភាពសម្បូរបែបរបស់កន្លែងនីមួយៗទៀតផងៗ

សូមជម្រាបថា នៅក្នុងប្រភេទសិល្បៈរបាំប្រជាប្រិយ នៅប្រទេសកម្ពុជាយើងនេះក្រៅពីរាំវង់ និងរាំក្បាច់ដែលជារបាំមូលដ្ឋានរបស់ជនជាតិខ្មែរមានចម្រៀងនិងរបាំច្រើន និងកន្ត្រឹមដែលមានប្រជាប្រិយភាពដ៏ធំធេងនៅតំបន់ចំនៀរភ្នំដងរែកនោះ និងនៅមានរបាំ **«ឡាំលាវ»** និង**«សារ៉ាវ៉ាន់»** ថែមទៀត ដែលមានប្រជាប្រិយភាពធំធេង ហើយមានការនិយមរាំឆ្លុកគ្នាជាមួយរាំវង់ និងរាំក្បាច់ជានិច្ចនោះផងៗ ចំពោះរបាំឡាំលាវ ដែលមានចង្វាក់ញាប់រន្ទឹន និងរបាំក្បាច់សារ៉ាវ៉ាន់នេះ យើងត្រូវតែទទួលស្គាល់ថា នេះគឺពិតជាឥទ្ធិពលរបស់សិល្បៈលាវ ដែលបានហូរចូលមកប្រទេសកម្ពុជា ក្នុងឋានៈជាមិត្តភក្តិ និងជាបងប្អូន និងជាអ្នកភូមិផងរបងជាមួយ ហើយត្រូវបានជនជាតិកម្ពុជានិយមរាប់អានយ៉ាងក្រៃលែងៗ ដូច្នេះគួរជ្រាបថា ខ្មែររាំឡាំលាវនោះគឺមានសេចក្ដីថា ខ្មែររាំបែបលាវ ឬចម្លងរបៀបរាំតាមជនជាតិលាវ ថ្វីត្បិតតែមិនបានចម្លងឲ្យដូចគ្នាបេះបិទ ឬក៏ដូចលាវសុទ្ធសាធក្ដីៗ ឯសារ៉ាវ៉ាន់វិញ គឺជាឈ្មោះខេត្តមួយរបស់ប្រទេសលាវ ជាប់នឹងខេត្តអាត់តៈពើ ហើយដែលស្ថិតមិនឆ្ងាយប៉ុន្មានពីខេត្តស្ទឹងត្រែងរបស់ប្រទេសកម្ពុជាយើងនេះឡើយៗ ក្បាច់សារ៉ាវ៉ាន់នេះក៏ជាភស្តុតាងគួរសបញ្ជាក់ថា មានប្រភពដើមចេញមក

www.elibraryofcambodia.org

ពីខេត្តសារ៉ាវ៉ាន់នេះយ៉ាងឯងពិតប្រាកដៗ

អាស្រ័យដោយហេតុផល និងតឹកតាងដូចបានជម្រាបខាងលើតាមយោបល់ ឬសំណូមពររបស់ខ្ញុំបាទផ្ទាល់ថា ខ្មែរយើងគួរតែកុំប្រើពាក្យថា ឡាំលាវ សារ៉ាវ៉ាន់ ប្រពៃណីខ្មែរ? ទើបជាការប្រសើរៗ

ចំណែកខាងពេលវេលា ឬពិធីដែលរបាំប្រជាប្រិយសម្តែងវិញ គឺមានលក្ខណៈទូលំទូលាយណាស់ ជាទូទៅគេច្រើនរាំក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ នៅទូទាំងប្រទេស ហើយមានកន្លែងខ្លះ ឬស្រុកខ្លះរាំលេងសប្បាយរាប់ខែមុនពេលចូលឆ្នាំ និងរាំលេងរាប់ខែក្រោយពេលចូលឆ្នាំទៀតផង ដូចជានៅភូមិអន្លង់រមៀត ក្នុងខេត្តកណ្តាល ស្ថិតមិនឆ្ងាយប៉ុន្មានពីរាជធានីភ្នំពេញនេះជាដើមៗ គេរាំលេងកម្សាន្តក្នុងអាពាហ៍ពិពាហ៍មង្គលការកូនប្រុសស្រី ពិធីជប់លៀង ពិធីបុណ្យតាមគ្រួសារ ឬក៏រាំកែកម្សាន្តពេលជួបជុំញាតិមិត្តជិតឆ្ងាយ ឬរាំដើម្បីបំបាត់ការនឿយហត់ ក្រោយពេលបំពេញពលកម្មនានាថែមទៀតផងៗ រហូតមកដល់សព្វថ្ងៃនេះគេសង្កេតឃើញរបាំប្រជាប្រិយរាំវង់ រាំក្បាច់ ឡាំលាវ សារ៉ាវ៉ាន់ត្រូវបានគេនិយមរាំលេងនៅតាមរង្គសាលនានា លាយចម្រុះ និងក្បាច់របាំបរទេសនានាជារាល់រាត្រីផងៗ

រីឯទស្សនៈយល់ឃើញអំពីសិល្បៈរបាំប្រជាប្រិយខ្មែរ ដែលរាំជារង្វង់មូល ហើយប្រើកាយវិការ និងក្បាច់ដៃ «ជីប» ពីក្រោមហើយលើកឡើង «លា» នោះវិញមានមតិភាគច្រើនយល់ថា នោះជាការបង្កើតសាមគ្គីភាពរវាងគ្នានឹងគ្នាផង ការបង្ហាញពីសុខមង្គលក្នុងជីវិតខ្មែរផង និងជានិមិត្តរង្វង់នៃជីវិត ដែលត្រូវតែមានពលកម្មដាំដុះផលដំណាំ សារចុះសារឡើងបន្តជានិរន្តន៍មិនចេះចប់ ដើម្បីទ្រទ្រង់ជីវិត និងការចាំបាច់ នៃការបន្តពូជពង្សវង្សត្រកូល (បន្តវេន) នៃធម្មជាតិ និងមនុស្សពិសេស គឺពូជពង្សវង្សត្រកូលខ្មែរនេះតែម្តងៗ

www.elibraryofcambodia.org

# ជម្រង់ល្ខោនខ្មែរ



www.elibraryofcambodia.org

ចំណែកខាងទម្រង់ល្ខោននៅប្រទេសកម្ពុជា ក៏មានច្រើនណាស់ (ដាង៤០ ទម្រង់) ក្នុងនោះល្ខោនខ្លះនៅរស់រានមានជីវិតនៅឡើយៗ ទម្រង់ខ្លះកំពុងត្រូវបានទ្រុឌទ្រោមឈានទៅបាត់បង់រួចទៅហើយ នៅសល់តែឈ្មោះ និងព័ត៌មានដែលទាក់ទងនឹងទម្រង់នេះតែបន្តិចបន្តួចប៉ុណ្ណោះៗ ទម្រង់ល្ខោនទាំងនោះមាន ÷

- ល្ខោនស្រមោល «ស្បែកធំ»
- ល្ខោនស្រមោល «ស្បែកតូច»
- ស្បែកពណ៌ (ដាស្បែកសម្តែងពេលថ្ងៃ)
- ល្ខោនខោល (ល្ខោនប្រុស ល្ខោនពាក់មុខ)
- ល្ខោនព្រះរាជទ្រព្យ
- ល្ខោនមហោរី
- ល្ខោនបាសាក់
- យីកេ
- ល្ខោនពោលស្រី
- ល្ខោនបាមោឌ្គទ័យ ឬប្រាមោទ្យ
- ល្ខោនអាម៉ៃ
- ល្ខោនគែន
- ល្ខោនបើកបទ
- ល្ខោនគ្រឿងការ
- ល្ខោនតុក្កតា
- ល្ខោននិយាយ
- ល្ខោនចម្រុះ
- ល្ខោនកំណាព្យ
- ចាប៉ីរឿង, និទានរឿង, ខ្សែរដៀវរឿង

www.elibraryofcambodia.org

- អាយ៉ៃរឿង
- សៀកសម្តែង

បន្ទាប់ទៅទៀតនេះ ខ្ញុំសូមជូនប្រវត្តិសង្ខេប និងលក្ខណៈពិសេសខ្លះ នៃទម្រង់ល្ខោននីមួយៗរបស់ខ្មែរយើងមានដូចតទៅ ៖

www.elibraryofcambodia.org

# ១–ស្បែកធំ



www.elibraryofcambodia.org

## ប្រវត្តិសិល្បៈស្បែកធំ

ស្បែកធំជាទស្សនីយភាពប្រភេទស្រមោល ដែលបានមកពីការយកចម្លាក់លើស្បែកគោដែលដាប់ទម្ងន់មានទំហំធំ ជារូបនិងថ្កល់មិនអាចកម្រើកបាន (I) យកទៅដើតផ្ទប់នឹងផ្ទាំងសំពត់សយ៉ាងធំ ដែលត្រូវបញ្ចាំងដោយពន្លឺភ្លើង គំនរឧសភ្លើងចន្លុះ ឬភ្លើងលលាដ៍ដូង ដែលត្រូវគេដុតឲ្យឆេះសន្ធោសន្ធៅលើកនដោយមានក្រាលដើមចេកពីខាងក្រោយសំពត់ស ដើម្បីត្រូវយកស្រមោលរូបចម្លាក់ទាំងឡាយនោះ (សព្វថ្ងៃគេប្រើចង្កៀងបញ្ចាំងអគ្គិសនីជំនួសវិញ) (Projecteur)។ ជាទូទៅគេសង្កេតឃើញសិល្បៈល្ខោនស្រមោលនេះទាំងតូចទាំងធំមាននៅច្រើនប្រទេស ដូចជា អ៊ីរ៉ង់ ទួរគី ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី កម្ពុជា ថៃ។ល។

សិល្បៈស្បែកធំនៅប្រទេសកម្ពុជាជាប្រភេទសិល្បៈសក្ការៈ ព្រោះទម្រង់នេះសម្ដែងតែរឿងរាមកេរ្តិ៍មួយប៉ុណ្ណោះ ដែលជាទេវកថាបង្ហាញពីមហិទ្ធិឫទ្ធិព្រះរាមជាអវតាររបស់ព្រះនារាយណ៍ ហើយមិនមានសម្ដែងរឿងអ្វីក្រៅពីនេះឡើយ នេះបើរាប់មកដល់ឆ្នាំ ២០០២ នេះ។ ឯកាលវេលាសម្ដែងវិញ គឺច្រើនសម្ដែងក្នុងពិធីបូជាព្រះសពព្រះមហាក្សត្រ គ្រូបាធ្យាយ ឬសពមាតាបិតា ឬពេលខ្លះសម្ដែងដើម្បីសុំទឹកភ្លៀង ក្នុងពេលដែលស្រុកទេសជួបប្រទះគ្រោះរាំងស្ងួត។

ក្នុងការសម្ដែង អ្នកដើត ឬអ្នករាំត្រូវលើករូបដើតវិលជុំវិញផ្ទាំងសំពត់សយ៉ាងធំតាមក្រុមតួខុសៗគ្នា គឺដំណើរយក្ស ដំណើរមនុស្ស និងស្វាហោះលើអាកាស អណ្ដែតទឹក ឬកំចលនាចម្បាំង ទៅតាមចង្វាក់ភ្លេងខុសៗគ្នា ដែលអ្នកប្រគុំត្រូវប្រគុំទៅតាម «ការហៅ» របស់អ្នកពោលដែលភាគច្រើន ច្រើនតែជាគ្រូធំនៃវង់សិល្បៈស្បែកធំនេះ។

ពិតមែនតែសិល្បៈស្បែកធំសម្ដែងតែរឿងរាមកេរ្តិ៍មែន ប៉ុន្តែគេមិនបានសម្ដែងរឿងនេះពីដើមដល់ចប់ទេ ភាគច្រើនគឺសម្ដែងតែអន្ទើចម្បាំង ឥន្ទជិត(កូនប្រុស រាពណ៍) ជាមួយនិងព្រះលក្ស្មណ៍ (ប្អូនព្រះរាម) តែប៉ុណ្ណោះ។ ម៉្យាងទៀតនៅ

www.elibraryofcambodia.org

ក្នុងអន្ទ្រី ចម្បាំងឥន្ទជិតនេះ គេច្រើនចែកជាឈុតតូចៗទៅតាមឈ្មោះសរ គឺ «អាវុធដ៏មានឫទ្ធិ» របស់តួសត្រូវទាំងសង ខាងដូចតទៅ ÷

-ឈុតសរនាគបាស គឺជាសរមួយរបស់អសុរឥន្ទជិត ផ្លែងទៅក្លាយជាសត្វនាគជាច្រើន ហើយត្រូវព្រះលក្ស្មណ៍ និងពលសេនារបួសគ្រប់គ្នាៗ តែបាន ក្រុងសិម្ពលីគ្រុឌជាព្រះធម្មបិតារបស់ព្រះរាមទៅជួយឆាបឆក់សម្លាប់អស់ពួកនាគរំដោះព្រះលក្ស្មណ៍ និងពួកពលសេនាឲ្យបានរស់មកវិញៗ

-ឈុតសរព្រហ្មាស្ត្រ គឺជាសរមួយរបស់ឥន្ទជិតដែរ ដែលផ្លែងទៅត្រូវព្រះលក្ស្មណ៍ ហើយក្លាយជាដើមឈើដុះមែកបែកសាខាៗ ប៉ុន្តែ សរនេះត្រូវបន្លាត់ (ដកបាន) មុនពេលព្រះអាទិត្យរះ ដោយការទំប្រឹងប្រែងផ្សងទិសថរបស់ពិភេកហោរា និងដែលមានហនុមានជាអ្នកទំស្វះស្វែងរកថ្នាំនោះបាន មកពីភ្នំនន្ទចក្រយកទឹកម៉ូត្រគោឧសភរាជ ពីព្រៃហេមពាន្តៗ យកថ្មដុសពីឋានព្រះព្រហ្មមិធុតា និងឃាត់ដំណើរព្រះអាទិត្យតាមបញ្ជាព្រះរាមៗ

-ឈុតសរពាន់ គឺជាសរមួយរបស់ព្រះលក្ស្មណ៍ដែលផ្លែងចេញទៅកើតជាព្រួញរាប់ពាន់ត្រូវអសុរឥន្ទជិត ធ្វើឲ្យឥន្ទជិតឈឺចុកចាប់ក្រៃលែងៗ ឥន្ទជិតខិតខំដកសរ ប៉ុន្តែសល់សរមួយដកមិនរួចសោះ ឥន្ទជិតក៏ហោះទៅសុំទឹកដោះនាងមណ្ឌោគីរី ជាព្រះមាតាទៅបន្លាត់សរនេះបាន ដូចក្តីប្រាថ្នាៗ ប៉ុន្តែទីបំផុតឥន្ទជិតត្រូវស្លាប់ ដោយការផ្លែងសរព្រហ្មាស្ត្ររបស់ព្រះរាម ដើម្បីផ្តាច់ក្បាលឥន្ទជិតៗ ក្បាលនេះត្រូវស្វាអង្គទទ្រដាក់លើគោក ដែលនាំមកពីឋានព្រហ្ម ហើយត្រូវព្រះរាមផ្លែងសរបញ្ជូនទៅស្ថានតុសិត នៅទីបញ្ចប់នៃសង្គ្រាមនោះៗ

ចំណែកវង់តន្ត្រីដែលប្រគំជូនសិល្បៈល្ខោនស្រមោលស្បែកធំនេះវិញ ក៏ជាប្រភេទតន្ត្រីដែលជាប់នឹងពិធីខាងសាសនាផងដែរ គឺវង់ភ្លេងពិណពាទ្យ ដែលក្នុង

www.elibraryofcambodia.org

វង់តូចមានឧបករណ៍៥ មុខគឺ ៖

- រនាតឯក
- គងវង់ធំ
- ស្រឡៃ
- សម្ភោរ
- ស្គរធំមួយគូ

២

ហើយបើវង់ធំវិញ មានឧបករណ៍ជាច្រើនគឺ ៖

- រនាតឯក
- រនាតធុង
- គងវង់តូច
- គងវង់ធំ
- ស្រឡៃតូច
- ស្រឡៃធំ
- រនាតដែក
- រនាតថោង
- សម្ភោរ
- ស្គរធំមួយគូ
- ឈិង

ហើយបទភ្លេងទៀតសោត ត្រូវអនុវត្តច្បាប់ផងតន្ត្រីដែល ដូចបានរៀបរាប់ខាងលើនេះ មានចំនួនប្រមាណតែជាងម្ភៃបទប៉ុណ្ណោះ ហើយបទនីមួយៗហាក់ត្រូវសបញ្ជាក់នូវដំណើរមួយ ឬមនោសញ្ចេតនាមួយយ៉ាងច្បាស់លាស់ ទៅតាមក្រុម

www.elibraryofcambodia.org

គ្នាផ្សេងគ្នា សម្គាល់ដាច់ស្រឡះពីគ្នា ពុំលាយឡំគ្នាឡើយដូចជា៖

| | |
|---|---|
| បទសាធុការ | សម្រាប់ពិធីហោមរោង |
| បទដើត | សម្រាប់ដំណើរ ឬច្បាំង ឬហោះ |
| បទដើតឈឹង | សម្រាប់ផ្លែងសរ |
| បទដើតចាប់ | សម្រាប់ច្បាំង ឬស្វាប្រចាំប់ |
| បទដំណើរក្នុង | សម្រាប់ដំណើរកងទ័ពយក្ស |
| បទដំណើរក្រៅ | សម្រាប់ដំណើរកងទ័ពមនុស្ស-ស្វា (ព្រះរាម)ៗ |
| បទផ្ទិ | សម្រាប់ដំណើរសត្វត្រុឌ |
| បទលោ | សម្រាប់អន្ទើបុញ្ញកាយអណ្តែតទឹក |
| បទត្រាក់ | សម្រាប់ប្រែកាឡា |
| បទពេទ្យមួយជាន់ | ដំណើរចូលច្បាំង |
| បទពេទ្យបីជាន់ | សម្រាប់ផ្លែងសរសម្តែងឫទ្ធិ |
| បទអូតតូច និងអូតធំ | សម្រាប់អន្ទើកម្សត់-យំសោក |
| បទនាងលោត | សម្រាប់អន្ទើកំប្លុកកំប្លែង |
| បទក្លុំ | សម្រាប់ពិធីតាំងស៊ីល ឬដំណើរ |

ពួកទេវតាជាដើមៗលៗ

www.elibraryofcambodia.org

# ២-ស្បែកពណ៌



www.elibraryofcambodia.org

## ប្រវត្តិសិល្បៈស្បែកពណ៌

សិល្បៈស្បែកពណ៌ ក៏ជាប្រភេទសិល្បៈចម្លាក់ដាប់ទម្លុះលើស្បែកគោដែរ ប៉ុន្តែ មិនមែនជាសិល្បៈល្ខោនស្រមោលដូចស្បែកធំ និងស្បែកតូច ឬអាយ៉ងឡើយ គឺជារូបចម្លាក់ស្បែកលាបពណ៌ ដូចគំនូរលាបពណ៌បែបបុរាណរបស់ខ្មែរ Dessin Traditionel Khmer ហើយសម្រាប់សម្តែងក្នុងពេលថ្ងៃ ដោយប្រើផ្ទាំងសំពត់ពណ៌ខ្មៅ ឬពណ៌ស្រគាំ ជាផ្ទាំងសំពត់ សម្រាប់ដើត (ដូចយករូបគំនូរលាបពណ៌មកនិទានរឿងរួមផ្សំ និងសិល្បករសម្តែងផង)។

សិល្បៈស្បែកពណ៌នេះបានបាត់បង់អាក់ខាន លែងបានសម្តែងជាយូរឆ្នាំមកហើយ គឺប្រហែលតាំងពីឆ្នាំ ១៩៣០ ឬ ១៩៤០ មកម៉្លេះ នេះបើតាមព័ត៌មានដែលយើងប្រមូលបាន។

ក្រោយដែលរបបខ្មែរក្រហមដួលរលំទៅ ទើបយើងបានរកឃើញដោយចៃដន្យ នូវផ្ទាំងគំនូរស្បែកលាបពណ៌ប្រមាណជាងម្ភៃសន្លឹក នៅក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ។




www.elibraryofcambodia.org

ក្រោយពីការត្រួតពិនិត្យដោយហ្មត់ចត់នូវរូបចម្លាក់ស្បែកដ៏ល្អប្រណីតទាំងនេះ ដោយអ្នកជំនាញសំខាន់ៗទាំងព្រះសង្ឃ ទាំងគ្រហស្ថ នាំឲ្យយើងប៉ាន់ស្មានបានថា ស្បែកដែលសេសសល់ទាំងនេះ គឺប្រហែលជាស្នាដៃរបស់សិល្បករជំនាញៗនៃរោងជាងព្រះបរមរាជវាំងជាក់ជាមិនខាន ។ ម្យ៉ាងទៀត ថ្វីត្បិតតែស្បែកទាំងនោះនៅសេសសល់តិចតួចប៉ុណ្ណោះ ក៏គង់អាចធ្វើឲ្យយើងដឹងបានដែរថា ស្បែកពណ៌នេះអាចសម្តែងរឿងរាមកេរ្តិ៍ រឿងឥណាវបុស្សបា និងរឿងដទៃទៀតបានទៀតផង។

ក្រោយពេល ដែលយើងបានរកឃើញស្បែកលាបពណ៌នេះមក យើងមានបំណងចង់ឲ្យសកម្មភាពសម្តែងជូនទស្សនិកជនជាតិ និងភ្ញៀវអន្តរជាតិ ឲ្យបានឃើញ និងស្គាល់ច្រើនគ្នាផង ប៉ុន្តែជាប្រការគួរឲ្យសោកស្តាយណាស់ ភាពក្រីក្រខ្វះខាតរបស់យើង ទាំងការយល់ដឹង ទាំងសម្ភារៈព្រមទាំងមានព្រឹត្តិការណ៍ផ្សេងៗទៀតជាច្រើនរំខានផង បានធ្វើឲ្យបំណងយើងខ្ញុំនេះជួបផលវិបាកយ៉ាងខ្លាំងៗ

និយាយជារួម គឺរហូតមកដល់ឆ្នាំ ២០០០ គិតទៅជាងមួយឆ្នាំ ទើបយើងអាចបោះពុម្ពសៀវភៅស្តីពីស្បែកពណ៌នេះបាន ដោយសារជំនួយដ៏សប្បុរសរបស់មូលនិធិតូយ៉ូតាជប៉ុន ហើយក្នុងឆ្នាំ ២០០០ នោះដែរ នៅក្នុងពេលប្រារព្ធពិធីទិវាវប្បធម៌ជាតិថ្ងៃ ៣ មេសា នៅសាលមហោស្រពចតុមុខដោយសារជំនួយរបស់អង្គការ Slawson សហរដ្ឋអាមេរិកតាមរយៈលោកបណ្ឌិត សំ សំអាង ដែលគណៈកម្មការស្រាវជ្រាវសិល្បៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាំងមូលបានធ្វើឲ្យរស់ឡើងវិញនូវទម្រង់ស្បែកពណ៌ ដោយបានលើកយករឿងទេវកថា **«កួរសមុទ្រទឹកដោះ»** តាមចម្លាក់ជាច្រើន នៅប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទឯទៀតយកមកសម្តែងជូនភ្ញៀវជាតិ និងអន្តរជាតិឲ្យបានឃើញជាលើកដំបូងក្នុងឱកាសនោះៗ

ឯរបៀបសម្ដែងស្បែកពណ៌ ដែលនាំស្បែកសម្ដែងក្នុងពេលថ្ងៃនេះវិញ មានលក្ខណៈខុសគ្នាខ្លះៗ ពីការសម្ដែងល្ខោនស្រមោលស្បែកធំ ដែលអ្នកដើរ ដើររូបដើរជុំវិញផ្ទាំងសំពត់ពណ៌ស «Ecran» ឬក៏ស្បែកតូច ដែលអ្នកដើរ អង្គុយ ដើររូបពីក្រោយផ្ទាំងសំពត់ស ដោយពឹងលើពន្លឺភ្លើង ឆុះយកស្រមោលៗ

ចំណែកខាងការសម្ដែងស្បែកពណ៌វិញ យើងសង្កេតឃើញមានលក្ខណៈ ពាក់កណ្ដាលសម្ដែងល្ខោន ពាក់កណ្ដាលសម្ដែងស្បែក ពោល គឺអ្នកដើរស្បែក មានស្រី មានប្រុស ក្នុងសម្លៀកបំពាក់ និងគ្រឿងអលង្ការស្អាតៗ តាមតួអង្គ (រូបស្បែក) រួចគេដើរស្បែកចេញមកខាងមុខផ្ទាំងសំពត់ខ្មៅ ឬពណ៌ស្រគុំពេល ខ្លះគេបញ្ឈរស្បែក និងផ្ទាំងក្រណាត់ រួចគេសម្ដែងជាល្ខោន ដោយមានច្រៀង និយាយរៀបរាប់ ជជែកពិភាក្សា ឬឆ្លងឆ្លើយស្នេហា ថែមទៀតផង រួចទើបគេ ចាប់ស្បែករបស់គេ ដើម្បីដើរបន្តទៅទៀតៗ

ឯវង់តន្ត្រីប្រគុំសិល្បៈស្បែកពណ៌នេះវិញ គឺវង់ភ្លេងពិណពាទ្យវង់តូច ដែល មានឧបករណ៍ប្រាំមុខគឺ ៖

- រនាតឯក
- សម្ភោរ
- គងវង់ធំ
- ស្គរធំ
- ស្រឡៃតូច

ហើយបទភ្លេងភាគច្រើន គឺខ្ចីមកពីវង់ភ្លេងមហោរី ។

(១) មានឯកសារបោះពុម្ពហើយ ដោយមូលនិធិ តូយ៉ូតាជប៉ុន ឆ្នាំ ២០០០

www.elibraryofcambodia.org

# ៣- ស្បែកតូច ឬអាយ៉ង



www.elibraryofcambodia.org

## ប្រវត្តិល្ខោនស្រមោលស្បែកតូច

ស្បែកតូច ជាប្រភេទសិល្បៈស្ថិតក្នុងក្រុមល្ខោនស្រមោល ដូចស្បែកធំដែរ ប៉ុន្តែជាចម្លាក់ ដែលឆ្លាក់នៅលើស្បែកគោមានទំហំតូចៗ ហើយមិនមែនជាចម្លាក់នឹងថ្កល់ (immobile) ដូចសិល្បៈស្បែកធំ ឬស្បែករបាំពណ៌ឡើយ។ ផ្ទុយទៅវិញ ជាចម្លាក់ដែលអាចធ្វើចលនាកម្រើកបាន ដូចជាលើកដៃ លើកជើង ឬក៏ហាមាត់និយាយ និងច្រៀងបានៗ ម៉្យាងទៀត សិល្បៈស្បែកធំជាប្រភេទសិល្បៈសក្ការៈ ការសម្ដែងមានលក្ខណៈហ្មត់ចត់ ស្រគត់ស្រគំ សម្ដែងរឿងសាសនា(សម្ដែងតែរឿងរាមកេរ្តិ៍មួយគត់)។ ប៉ុន្តែស្បែកតូចវិញ ជាប្រភេទសិល្បៈប្រជាប្រិយមានលក្ខណៈកំប្លុកកំប្លែងងាយមើលងាយយល់ ព្រមទាំងអាចសម្ដែងរឿងជាច្រើន ដូចជារឿងព្រេងនិទាន រឿងប្រវត្តិសាស្ត្រ ឬរឿងទាក់ទងនឹងបច្ចុប្បន្នភាពរបស់សង្គមថែមទៀតផង។

នៅប្រទេសកម្ពុជាមានពាក្យបីម៉ាត់សម្រាប់សម្គាល់ ឬក៏ដាក់ជាឈ្មោះឱ្យដល់ទម្រង់សិល្បៈនេះគឺ ១-ស្បែកតូច, ២-អាយ៉ង, ៣-ណាំង តាលុង ឬណាំងតាលុង ទៅតាមការនិយមរបស់តំបន់នីមួយៗខុសគ្នា។ ម៉្យាងទៀត បើយើងពឹងផ្អែកទៅលើការនិយមរបស់ជនជាតិខ្មែរដែលយល់ថា ពាក្យតុក្កតា និងពាក្យអាយ៉ងមានន័យដូចគ្នា គឺសម្រាប់សម្គាល់វត្ថុឥតវិញ្ញាណទាំងឡាយ ទោះបីមានទំហំមាឌ ឬក៏សំប៉ែត ដូចជារូបចម្លាក់ធ្វើអំពីឈើ អំពីក្រណាត់ញាត់សំឡី រូបចម្លាក់ធ្វើពីដីឥដ្ឋរូបចម្លាក់ធ្វើអំពីស្បែក ហើយសព្វថ្ងៃមានធ្វើពីក្រដាស និងជ័រប្លាស្ទិកទៀតផងដែល វត្ថុទាំងនេះត្រូវគេដឹក ឬញាក់ ឬជំរុញឱ្យធ្វើសកម្មភាពដោយអ្នកដទៃ«**សិល្បករអ្នកដឹក**» នោះយើងជឿថាសិល្បៈប្រភេទនេះប្រាកដជាមានចំណាស់ច្រើនសតវត្សរ៍ណាស់មកហើយ នៅលើទឹកដីកម្ពុជានេះ។

ចំពោះកាលបរិច្ឆេទកំណើតវិញ យើងបានជួបប្រទះនូវឯកសារជាច្រើនដែលរបស់លោកអ្នកប្រាជ្ញរាជបណ្ឌិតទាំងជនជាតិកម្ពុជា ទាំងបរទេស បានបន្សល់ទុកឱ្យ

www.elibraryofcambodia.org

ដោយមតិខ្លះបានស្មានថា ស្បែកតូច ឬអាយ៉ងខ្មែរ ប្រហែលជាបានមានកំណើតមកពី Wayangម៉ាឡេស៊ី ?។ ឯមតិខ្លះទៀត បានសន្និដ្ឋានថា អាយ៉ងខ្មែរប្រហែលជាមានដើមកំណើតនៅភូមិម៉ាល់យ៉ង់ ទឹកដីកាតទាងលិចខេត្តបាត់ដំបង ។ ខ្លះមានយោបល់ថា អាយ៉ងប្រហែលជាមានដើមកំណើតនៅម្តុំខួបតាយ៉ងគឺវត្តបទុមវតី រាជធានីភ្នំពេញសព្វថ្ងៃតាំងពីយូរលង់ណាស់មកហើយ ដោយសំអាងទៅលើការសិក្សាស្រាវជ្រាវពីឈ្មោះអាយ៉ងនេះ ដែលសម្គាល់ដល់តួអង្គតុក្កតាដ៏ល្បីល្បាញរបស់ទម្រង់សិល្បៈនេះនៅភ្នំពេញ ហើយដែលប្រជាជនទូទាំងប្រទេសមានការនិយមរាប់អាន និងមានមតិខ្លះទៀតបានផ្តោតទៅលើភូមិកំពង់ត្រយ៉ងស្ថិតក្នុងឃុំពួក ស្រុកពួកខេត្តសៀមរាប ដែលស្ថិតមិនឆ្ងាយប៉ុន្មានពីទីក្រុងអង្គរដែលបាយទំនៀមផលិត និងសម្តែងតុក្កតាធ្វើអំពីឈើ តាំងពីយូរល.ង់ណាស់មកហើយផង ឯតំបន់ដទៃទៀតដែលមានស្បែកតូចដែរ ប៉ុន្តែគ្មានតួកឈ្មោះអាយ៉ងដូច្នេះទេ?។

រីឯចំណុចដ៏សំខាន់មួយទៀត ដែលទាក់ទងដល់ដើមកំណើតតុក្កតា ឬអាយ៉ងនោះ គឺការសិក្សាសិលាចារឹកខ្មែររបស់អ្នកស្រី ពៅ សាវរស់ ដែលបានបញ្ជាក់ឲ្យយើងដឹងថា នៅក្នុងសិលាចារឹកមុនសម័យអង្គរលេខ K-១៥៥ មានចែងអំពីសិល្បការិនីសម្តែងតុក្កតា (KU TUKTAR) ក្នុងពិធីបូជាថ្វាយចំពោះព្រះអាទិទេព «សរស្វតី SARASVATI» ដែលជាអាទិទេពតំណាងឲ្យសំនួនវោហារដ៏ពីរោះ និងសិល្បៈ (The goddess of Eloquence and Arts)។ នេះជាភស្តុតាងដែលធ្វើឲ្យយើងដឹងថា ទម្រង់សិល្បៈនេះមានកំណើតតាំងពីមុនសម័យកសាងប្រាសាទអង្គរម៉្លេះ។ ហើយអ្នកស្រីបានបន្ថែមទៀតថា 4-3-4.

ខ្ញុំមិនដកពាក្យ ទុកទារ ដែលខ្ញុំបានរៀកាស្រួចមកហើយក្នុងឆ្នាំ ១៩៨៦ និងក្នុង Sup, 1.2 ចេញនោះទេ។ ពាក្យនេះមានន័យថា «Puppet» ហើយបន្ទាប់មកទៅជា «Puppeter»។ អ្នកបម្រើស្រីមួយចំនួនហៅថា «Ku Tuktar»ត្រូវបានគេថ្វាយចំពោះទេពសរស្វតី។ គេមិនចាំបាច់សង្កត់ធ្ងន់ទៅលើអត្ថន័យនៃល្ខោនអាយ៉ង

www.elibraryofcambodia.org

នៅក្នុងវប្បធម៌ខ្មែរនោះទេ។

ដោយឡែកក្នុងពេលថ្មីៗនេះ យើងទើបតែទទួលបានទូវព័ត៌មាន បុកឯកសារដ៏មានសារៈសំខាន់មួយទៀត ដែលទាក់ទងនឹងសិល្បៈល្ខោនស្រមោលស្បែកតូចនៅកម្ពុជានេះដែរ ដោយនៅឆ្នាំ ២០០០ នេះលោក Hamzah Awang Amat ជាសាស្ត្រាចារ្យដឹកនាំសិល្បៈល្ខោនស្រមោល Wayang Kulit ដ៏ល្បីល្បាញរបស់ប្រទេសម៉ាឡេស៊ី លោកបានទទួលពានរង្វាន់ជ័យលាភីសិល្បៈ និងវប្បធម៌ «Arts and Culture prize» របស់ The "Fokuoka Asian Culture prizes ២០០០។ នៅក្នុងអត្ថបទរបស់លោក លោកបានបញ្ជាក់ថា ល្ខោនស្រមោល Wayang Kulit ខេត្តកេឡាន់តាន់ក្នុងប្រទេសម៉ាឡេស៊ី មានប្រភពនៅក្នុងប្រទេសកម្ពុជា ហើយបានហូរចូលទៅជ្រោយម៉ាឡេតាមប្រទេសថៃភាគខាងត្បូង។

Wayang Kul:: Kalatan ដែលមាននៅក្នុងប្រទេសម៉ាឡេស៊ី មានប្រភពនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានគេនាំយកមកជ្រោយម៉ាឡេ ពីប្រទេសថៃភាគខាងត្បូង ។ ការសម្ដែងរៀបចំឡើងដោយប្រើសាច់រឿងរាមាយណៈរបស់ឥណ្ឌា ដោយវាក៏មានវត្តមាននៅក្នុងសិល្បៈបុរាណ នៅប្រទេសឥណ្ឌូណេស៊ី ថៃ និងកម្ពុជា។ តួអង្គសំខាន់របស់ Wayang Kulit គឺ Hikaya Seri Rama ដែលគេបានចាត់ទុកថាជារឿងរាមាយណៈ បែបម៉ាឡេស៊ី។

ចំណុចសំខាន់មួយទៀត រហូតដល់សព្វថ្ងៃនេះ គេសង្កេតឃើញមានក្រុមសិល្បៈស្បែកតូច បុរាណយ៉ាងនេះមានវត្តមាននៅច្រើនខេត្តក្រុងក្នុងផ្ទៃប្រទេសទាំងមូល ដូចជា នៅខេត្តសៀមរាប (មានស្បែកតូចច្រើនវង់) នៅខេត្តបន្ទាយ-មានជ័យ នៅខេត្តបាត់ដំបង និងនៅរាជធានីភ្នំពេញ (ក៏មានច្រើនវង់ដែរ)។

ចំណែកខាងវង់តន្ត្រីជូនស្បែកតូចទាំងអស់នោះវិញ ក៏ឃើញមានលក្ខណៈមិនដូចគ្នាទាំងអស់ដែរ ពោលគឺវង់ស្បែកតូចនៅខេត្តសៀមរាប និងវង់ស្បែកតូចនៅភ្នំពេញ ប្រើវង់ភ្លេងពិណពាទ្យសម្រាប់ជូនការសម្ដែង ហើយភាគច្រើនៗតែជា

www.elibraryofcambodia.org

ភ្លេងពិណពាទ្យវង់តូច ដែលមានឧបករណ៍ប្រាំមុខគឺ រនាតឯក គងវង់ធំ ស្រឡៃ សម្ភោរ និងស្គរធំ ឯបទភ្លេងវិញ គឺកាត់ច្រើនខ្ទីពីវង់ភ្លេងមហោរី។

ដោយឡែកក្រុមស្បែកតូច នៅខេត្តបាត់ដំបងវិញ គេមិនមានប្រើវង់ភ្លេងពិណពាទ្យទេ ផ្ទុយទៅវិញសម្រាប់ជូនសិល្បៈស្បែកតូច ឬអាយ៉ងនេះ អ្នកបាត់ដំបងប្រើវង់ភ្លេងមួយវង់ ដែលមានឧបករណ៍ដូចជា៖

១-ស្គរតូចមួយ (រាងដូចស្គរធំភ្លេងពិណពាទ្យ វាយដោយអន្លូងតូចៗមួយគូ)

២-ស្គរដៃមួយគូ (ស្គរអារក្ស)

៣-ស្រឡៃតូចមួយ

៤-គងដោះតូចមួយ (គងម៉ង់)

៥-ហើយពេលខ្លះមានគ្រាប់កំណាត់ដើមឫស្សីផង ។

www.elibraryofcambodia.org

# ៤-ល្ខោនតុក្កតា



www.elibraryofcambodia.org

# ប្រវត្តិល្ខោនតុក្កតា

មិនខុសគ្នាប៉ុន្មានពីប្រវត្តិសិល្បៈស្បែក ដែលមានរូបចម្លាក់ដ៏ច្រើនសន្ធឹកសន្ធាប់ នៅតាមជញ្ជាំងប្រាសាទនានា ដូចជាប្រាសាទបាពួន ប្រាសាទបាយ័ន ព្រះលាន ផល់ដំរី ។ល។ បង្ហាញយើងជាភស្តុតាងថា ខ្មែរមានសិល្បៈស្បែកៗ ប៉ុន្តែរូបភាពជាក់ស្តែងពិតប្រាកដនៅក្នុងសង្គម និងជាផ្លូវការ ស្ទើរតែគ្មានសោះតាំងពីយូរលង់ណាស់មកហើយ គឺទើបតែត្រូវបានយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ និងបង្កើតសិល្បៈស្បែកជាផ្លូវការនៅក្នុងអំឡុងឆ្នាំ ១៩៨០ ប៉ុណ្ណោះនៅប្រទេសកម្ពុជានេះ។

ដោយឡែកសិល្បៈល្ខោនតុក្កតា បើយើងយោងតាមឯកសារសិលាចារឹក ដែលដូនតាយើងបានសាងទុកមក និងតាមការសិក្សាស្រាវជ្រាវដោយហ្មត់ចត់ ដោយអ្នកស្រី ពៅ សាវរស់ បញ្ជាក់ថា ខ្មែរមានសិល្បៈតុក្កតានេះតាំងពីសម័យមុនកសាងប្រាសាទអង្គរវត្តមកម្ល៉េះ នេះបើយើងផ្អែកលើឯកសារសិលាចារឹកលេខ K-១៥៥ ជាសិលាចារឹកនៅប្រាសាទលលៃចុះកាលបរិច្ឆេទចុងសតវត្សរ៍ទី ៩ (៨៩៣)ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន និងជំនឿលើព្រហ្មញ្ញសាសនា ដែលបានថែងពីសិល្បការិនីសម្តែងសិល្បៈតុក្កតា«គូតុក្កតា KU TUKTAR» ឧទ្ទិសថ្វាយចំពោះអាទិទេពសូរៈស្វតិ អាទិទេព តំណាងវោហារពីរោះ និងសិល្បៈនោះៗ គ្រាន់តែយើងមិនបានដឹងប្រាកដថា តើតុក្កតានោះធ្វើអំពីអ្វី? មានរូបភាពយ៉ាងណា? ជាតុក្កតាដែលដើតដោយដងសន្ទូច (ដូចស្បែកតូច ឬអាយ៉ង) ឬក៏តុក្កតាដែលប្រើខ្សែព្យួរសម្រាប់ញាក់ ឬក៏មានលក្ខណៈផ្សេងពីនេះៗ

ក្នុងការសិក្សាស្រាវជ្រាវរកព័ត៌មានជាច្រើនឆ្នាំ ស្តីអំពីទស្សនីយភាពល្ខោនតុក្កតានេះកាលពីច្រើនឆ្នាំមុនសង្គ្រាមឆ្នាំ ១៩៧០ បានផ្ទុះឡើងនោះយើងខ្ញុំធ្លាប់ សួរលោកសាស្ត្រាចារ្យ ប៉ុល សំអឿន ជាសាស្ត្រាចារ្យសាលាល្ខោនជាតិរួចក្រោយមកលោកបង្រៀននៅមហាវិទ្យាល័យសិល្បៈ នាដសាស្ត្របានមានប្រសាសន៍ថា កាលនៅពីតូច លោកធ្លាប់បានមើលល្ខោនតុក្កតា [illegible]

និយមហៅថា «ហ៊ីដុំដី» នៅឯស្រុកកំណើតរបស់លោកក្នុងខេត្តបាត់ដំបងហើយក្រោយមកតុក្កតាហ៊ីដុំដី នេះក៏បាត់បង់ទៅដោយមិនដឹងមកពីមូលហេតុអ្វីឡើយ។

មួយទៀត ក្រោយពីរបបប៉ុល ពត ដួលរលំទៅ យើងបានទទួលដំណឹងថា មានភូមិមួយឈ្មោះភូមិកំពង់ត្រយ៉ង ក្នុងឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលស្ថិតមិនឆ្ងាយប៉ុន្មានពីប្រាសាទអង្គរវត្តនោះធ្លាប់មានទំនៀមធ្វើរូបតុក្កតាអំពីឈើក្រណាត់ញាត់សម្លីគហើយធ្លាប់បានសម្ដែងជូនអ្នកស្រុកមើលម្ដងម្កាលផងដែរ ប៉ុន្តែ មិនញឹកញាប់ទេ ហើយរហូតមកដល់សង្គ្រាមស៊ីវិលចាប់ផ្ដើមឡើងនៅឆ្នាំ ១៩៧០ នោះទម្រង់សិល្បៈនេះក៏បាត់បង់សូន្យតែម្ដង ជាប្រការគួរឲ្យសោកស្ដាយបំផុត រហូតមកដល់សព្វថ្ងៃនេះ។

ពត៌មានស្ដីពីសិល្បៈតុក្កតា ដែលសម្ដែងជាទស្សនីយភាពដោយមានអ្នកដឹកមានវង់តន្ត្រីប្រគំជូន និងមានពាក្យចរចារបៀបជាល្ខោនបែបនេះ យើងខ្ញុំអ្នកកត់ត្រា ក៏ធ្លាប់បានមើលផងដែរ កាលនៅពីតូចក្នុងពិធីបុណ្យបញ្ចុះសីមាវត្តដែលអ្នកធ្វើរូបតុក្កតាទាំងនោះមកពីខេត្តកំពង់ឆ្នាំង។ គាត់ធ្វើរូបតុក្កតាដែលរួមជាទិដ្ឋភាពភូមិស្ថានស្រុកស្រែចម្ការ បង្ហាញពីទេសភាព និងសកម្មភាពក្នុងភូមិស្រុកដែលមានវត្តអារាម មានវាលស្រែ មានដើមត្នោត ឥន្ទ្របុស្ស៊ី ប៊ីងត្រពាំងមានព្រះសង្ឃនិមន្តបិណ្ឌបាត្រ មានដូនចាស់រាប់បាត្រព្រះសង្ឃ នារីៗជាដូស្ទូងស្រូវ មានគោ ក្របីស៊ីស្មៅក្នុងវាលស្រែ មានមាន់បណ្ដើរកូន និងកូនក្មេងតូចៗលេងល្បែងផ្សេងៗ ឬបក្សីទំលើចុងឈើជាដើម ដែលគេរៀបចំដាក់តាំងនៅលើតុ ឬគ្រែយ៉ាងធំ (របៀបតាំងតុ ឬតាំងពិព័រណ៍) ហើយរូបភាពទាំងនោះ ចងភ្ជាប់ដោយខ្សែដែលអាចឲ្យធ្វើសកម្មភាពបានៗ ប៉ុន្តែចលនាទាំងនោះ ជាចលនាច្រំដែលៗដូចជាព្រះសង្ឃបើកគម្របបាត្រ យាយចាស់រាប់បាត្ររួចដកដៃមកវិញ ទើបព្រះសង្ឃគ្របបាត្រ នារីៗឱនស្ទូងរួចងើប (ឱនងើបៗ) សត្វគោក្របីឱនស៊ីស្មៅរួចងើបក្បាលមើលព្រះសង្ឃ សត្វស្លាបលើចុងឈើទទះស្លាបរួចដាក់ស្លាបមកវិញ សត្វ

www.elibraryofcambodia.org

មាន់ឱនចឹកចំណីជាដើម ។ល។ ហើយខ្សែចំណងរូបទាំងអស់នេះ ត្រូវចងភ្ជាប់ទៅនឹងខ្សែមេមួយ (តាមបច្ចេកទេសរបស់គេ) រួចចងភ្ជាប់ទៅនឹងច្រវាក់កង់ ដែលអាចវៃបាន ។ ហើយកាលណាគេវៃច្រវាក់កង់នោះទៅ រូបទាំងអស់ដូចរៀបរាប់ខាងលើនេះធ្វើសកម្មភាពច្រំដែលបែបនេះជារៀងរហូត គឺអាស្រ័យដោយសកម្មភាពច្រំដែលៗរបៀបជាម៉ាស៊ីន ដូច្នេះហើយទើបអ្នកមើលមួយចំនួនក្នុងសម័យនោះនិយមហៅតុក្កតានោះថា ជា «**ល្ខោនយន្ត**» ។

មួយចំណែកទៀតនៅក្នុងចន្លោះឆ្នាំ ១៩៨៥-៩០ យើងខ្ញុំអ្នកកត់ត្រាក៏បានជួបនឹងកសិករម្នាក់មកពីខេត្តកំពង់ចាម ដែលចេះធ្វើរូបតុក្កតាអំពីឈើ ហើយបានសុំឲ្យលោកធ្វើរូបទាំងនោះមួយចំនួនដាក់តាំង នៅរានហាលកណ្ដាលវាលមុខផ្ទះ ព្រោះរូបតុក្កតាទាំងនោះត្រូវការទីវាល ត្រូវការខ្យល់ដើម្បីជំរុញឲ្យមានចលនាបាន ។ រូបទាំងនោះមានរូបយក្ស និងស្វាកាន់ដំបងច្បាំងគ្នា រូបបុរសកិនស្រូវ និងត្បាល់កិន រូបនារីបុកស្រូវ នារីអុំអង្រែជាដើម ដែលសុទ្ធតែធ្វើអំពីឈើ ហើយមានសម្លៀកបំពាក់តាមតួអង្គយក្ស ស្វា ឬកសិករខ្មែរ ។ រូបទាំងនេះត្រូវវាយបញ្ឈរ ជាប់លើរនងឈើមួយយ៉ាងវែងមាំ ហើយដៃដែលមានសន្លាក់តភ្ជាប់គ្នាពីដើមដៃទៅកំភួនដៃ ឬអន្ទើដទៃទៀត ដែលចង់ឲ្យធ្វើចលនាបាននោះ ត្រូវចង និងសរសៃអំបោះភ្ជាប់ទៅនឹងស្លឹកត្នោតមួយសន្លឹកធំស្អាតល្អ ហើយខាងចុងនៃស្លឹកត្នោតម្ខាងទៀតក៏ចងដោយអំបោះដូចគ្នា រួចទាញយកអំបោះនោះទៅចងព្យួរបញ្ឈរនឹងរនងឈើមួយទៀត ដែលដាក់ពីខាងលើស្របគ្នានឹងរនង ដែលវាយរូបតុក្កតាភ្ជាប់នោះដោយលៃខ្សែឲ្យធូរល្មម ដើម្បីឲ្យខ្យល់បក់មកប៉ះស្លឹកត្នោត ស្លឹកត្នោតកម្រើករួចទាញរូបតុក្កតាទាំងនោះឲ្យមានចលនាឡើងៗ សូមបញ្ជាក់ថា រូបនីមួយៗប្រើខ្សែនិងស្លឹកត្នោតមួយដាច់ៗពីគ្នាៗ បើខ្យល់បក់មកខ្សោយ នោះចលនានៃរូបតុក្កតានោះក៏រង្គើលៗទៅតាមកម្លាំងខ្យល់ ប៉ុន្តែពេលណាដែលមានខ្យល់បក់មកខ្លាំងចលនានៃរូបទាំងនោះកាន់តែញាប់ណែនឡើងៗផងដែរ ។ ឯចលនានោះវិញ គឺជា

www.elibraryofcambodia.org

ចលនាច្រាំងផ្សេងៗ ដូចជាយក្ស ស្វា រាយដំបង (ដូចក្នុងឈុតល្ខោនបាសាក់) ឬសេះឈ្មោកខាំព្រញត្បាល់ក៏និរូបដើបមកវិញវិលៗ

ក្រៅពីនេះ នៅទូទាំងប្រទេសយើង សង្កេតឃើញមានរូបតុក្កតាផ្សេងទៀតខ្លះដែរ ប៉ុន្តែជារូបដែលមិនសូវមានចលនារស់រវើកទេ ដូចជារូបព្រះឥន្ទ្រ ឬទេវតាជិះដំរី ឬជិះសេះរួមផ្សំ និងការប្រើរំសេវឲ្យលាន់ ឬសំឡេងផងដែលគេច្រើនប្រើជាធ្មួនក្នុងពិធីបូជាសពព្រះគ្រូចៅអធិការជាដើម ឬបើមិនដូច្នោះទេ ជារូបតុក្កតានឹងថ្កល់គ្មានចលនាកម្រើកបាន ដែលច្រើនមានរូបភាពយកតាមលំនាំរបាំក្បាច់បុរាណខ្មែរ ក្នុងសម្លៀកបំពាក់តាមតួអង្គនាយរោង តួអង្គនាងយក្ស និងស្វាជាដើមដែលភាគច្រើន ច្រើនជារូបដាក់តាំងលម្អនៅតាមហាងលក់វត្ថុអនុស្សាវរីយ៍នានាតែប៉ុណ្ណោះៗ

និយាយជារួម បើគិតមកដល់ពេលនេះ យើងអាចនិយាយបានថា នៅក្នុងសង្គមកម្ពុជាទាំងមូល មានសេសសល់ទម្រង់ល្ខោនតុក្កតានេះយ៉ាងតិចតួចបំផុត ឬក៏អាចនិយាយថា គ្មានល្ខោនតុក្កតាសោះក៏ថាបានៗ ផ្ទុយទៅវិញមកដល់កាលវេលាដូចគ្នានេះដែរ យើងសង្កេតឃើញសិល្បៈល្ខោនតុក្កតា ក៏ដូចជាគំនូរជីវចលមានការរីកចម្រើនយ៉ាងខ្លាំងបំផុតនៅក្នុងពិភពលោកយើងនេះ ព្រោះមានប្រទេសជាច្រើនទាំងនៅអឺរ៉ុប អាមេរិក អាហ្វ្រិក ឬតំបន់ដទៃទៀត មានទម្រង់សិល្បៈនេះយ៉ាងសម្បូរបែប ហើយជាទីពេញនិយមបំផុតពីគ្រប់ស្រទាប់ទស្សនិកជន ពិសេសពីកុមារក្នុងគ្រប់ប្រទេស រហូតដល់ប្រទេសជឿនលឿនខ្លះបង្កើតជាវិទ្យាស្ថានអន្តរជាតិសិល្បៈតុក្កតា (Institut International de Marionettes) ដូចជានៅស្ត្រាស្បួរ (Strasbourg) ប្រទេសបារាំង ដែលមាននិស្សិតចម្រុះជាតិសាសន៍ទៅសិក្សារៀនសូត្រ ហើយខ្ញុំជាអ្នកកត់ត្រា ក៏ធ្លាប់បានទៅធ្វើទស្សនកិច្ចផងដែរៗ

ចំណែកនៅក្នុងទ្វីបអាស៊ីទាំងមូល ឬប្រទេសជិតខាងយើងនេះវិញមានប្រទេសជាច្រើនដែលមានល្ខោនតុក្កតា ដូចជាប្រទេសចិន ជប៉ុន ឥណ្ឌា ឥណ្ឌូណេស៊ី ភូមា

ថៃ ឬដូចប្រទេសវៀតណាម ដែលមានតុក្កតាសម្តែងក្នុងទឹកដ៏ល្បីល្បាញជាមោទនភាពដ៏អស្ចារ្យរបស់ជាតិគេ។

ផ្ទុយទៅវិញជាប្រការគួរឲ្យខ្មាស់អៀន ប្រទេសកម្ពុជាដែលមានប្រវត្តិជាក់លាក់ ជាប្រទេសដែលធ្លាប់មានសិល្បៈតុក្កតារាប់ពាន់ឆ្នាំមកហើយ (នៅតាមប្រាសាទទេវស្ថាននានា) បែរជាគ្មានទម្រង់សិល្បៈតុក្កតានេះទៅវិញ ក្នុងពេលបច្ចុប្បន្ននេះ។

ការពោលពាក្យខាងក្រោយនេះ មិនមែនបានសេចក្តីថា យើងបញ្ជាក់អំពីគំនិតទុទ្ទិដ្ឋិទេ ប៉ុន្តែផ្ទុយទៅវិញ គឺជាកម្លាំងជំរុញឲ្យយើងរាល់គ្នាជាជនជាតិខ្មែរប្រឹងត្រិះរិះពិចារណារកគ្រប់វិធី ដើម្បីបង្កលក្ខណៈងាយស្រួល ឬផ្តល់លទ្ធភាពគ្រប់គ្រាន់សមរម្យដល់មនុស្សខ្មែរ ដែលមានទេពកោសល្យច្នៃប្រឌិត ពិសេសដល់អតីតនិស្សិតរបស់យើង ដែលធ្លាប់បានសិក្សារៀនសូត្រវិជ្ជានេះឲ្យគ្នាមានចិត្តក្លាហានសប្បាយរីករាយក្នុងការធ្វើស្នាដៃ ដើម្បីបម្រើជាតិមាតុភូមិរបស់យើង។

ធ្វើយ៉ាងនេះបាន យើងសង្ឃឹមថា សិល្បៈល្ខោនតុក្កតានឹងរស់ឡើងវិញក្នុងរូបភាពជាខ្មែររួមចំណែក នៅក្នុងការបង្កការសប្បាយរីករាយឲ្យសង្គមខ្មែរផងរួមចំណែកក្នុងការអប់រំកសាងធនធានមនុស្សខ្មែរផង និងរួមចំណែកក្នុងការលើកកម្ពស់សីលធម៌សង្គមខ្មែរ ដោយមានប្រសិទ្ធភាពជាក់ជាមិនខានក្នុងកាលអនាគត៕

www.elibraryofcambodia.org

# ៤-ល្ខោនខោល បុភាណ៊ី




www.elibraryofcambodia.org

# ប្រវត្តិល្ខោនខោល ឬកំណើត

ពាក្យថាខោល ឬល្ខោនខោល បើតាមសន្និដ្ឋានរបស់សម្តេច ព្រះសង្ឃរាជ ជួន ណាត ដែលបានកត់ទុកក្នុងវចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយ ពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩៦៧ ត្រង់ទំព័រ ១០២ថា ខោល គឺជាពួកល្ខោនប្រុស **«រឿងរាមកេរ្តិ៍»**។

ចំពោះលោក ហ្សក សឺដេស (George Coedès) វិញ បើតាមប្រសាសន៍របស់លោកដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានស្រង់យកមកចុះក្នុងកម្រងសិក្សាកថា Annale de l' URBA N° 1 បោះពុម្ពឆ្នាំ ១៩៦៧ ត្រង់ទំព័រ ១៥៧ ថា Le mot Khol serait celui que les Cambodgiens emploient pour désigner une variété des grands singes។

ដូច្នេះសម្រាប់លោកសឺដេស ល្ខោនខោល គឺជា **«ល្ខោនរបាំស្វា»**។ ចំណែកអ្នកឧកញ៉ា ឆេពពិជូរ ក្រសេមគន្ថបណ្ឌិតវិញ នៅក្នុងទស្សនាវដ្តី កម្ពុជសុរិយា លេខ ៣ ខែ មីនា ឆ្នាំ១៩៤៨ លោកបានពោលថា «ចំណែកល្ខោនខោលនោះ គេកំណត់លេងចំពោះតែរឿងដែលទាក់ទាម ដោយរឿងព្រះជាម្ចាស់គឺព្រះឥសូរ ព្រះនារាយណ៍ ដែលជាព្រះក្នុងសេយ្យសាស្ត្រ គឺលេងរឿងអវតារ **«បែងភាគ»** របស់ព្រះជាម្ចាស់ដូចជារឿងរាមកេរ្តិ៍ **«រាមាយណៈ»** សឹងជាប្រវត្តិរបស់ព្រះជាម្ចាស់នោះដើម្បីប្រកាសកិត្តិគុណសេចក្តីខ្លាំងពូកែ និងក្លាហានរបស់ព្រះជាម្ចាស់ និងអ្នកដែលព្រះជាម្ចាស់បានបែងភាគឲ្យមកកើត ដូចយ៉ាងព្រះរាមតាមក្បួនថា លេងរឿងដូច្នេះជាហេតុឲ្យកើតមង្គលសួស្តីដល់អ្នកលេង និងជាទីប្រោសប្រាណរបស់ព្រះជាម្ចាស់ ទើបគេនិយមលេងមកដល់ឥឡូវនេះ។

ឯពាក្យខោលក្នុងជីវភាពប្រជាជនកម្ពុជាវិញ គេនិយមប្រើពាក្យនេះសម្រាប់សម្គាល់គោ ឬក្របីដែលមានស្នែងខ្លី ហើយខុបចុះក្រោម ឬក៏សម្គាល់សត្វស្វាកន្ទុយខ្លី ឬបើមិនដូច្នោះទេបើកាលណាគេនិយាយថា ធ្វើអ្វីមួយខោលតែម្តងនោះ មានសេចក្តីថាធ្វើអ្វីមួយនោះ គឺធ្វើដោយឥតបានព្រាងទុក ឬគិតទុកជាមុនឡើយ

www.elibraryofcambodia.org

ពោលគឺគិតឃើញក្លាម ឬជួបក្លាមធ្វើក្លាមតែម្តងៗ

សម្តីរបស់លោកអ្នកប្រាជ្ញបណ្ឌិត និងការនិយមរបស់ប្រជាជនកម្ពុជាក្នុងការសម្គាល់ខោល ឬល្ខោនខោលនេះមានអត្ថន័យសមរម្យល្អណាស់ ព្រោះបើយើងពិនិត្យមើលទម្រង់ល្ខោនខោល ដែលសេសសល់សព្វថ្ងៃនេះ យើងឃើញថាល្ខោនខោល គឺជាល្ខោនពាក់មុខអ្នករាំធ្វើកាយវិការឥតព្រាងទុកជាមុនដើម្បីត្រាប់ពាក្យសម្តីរបស់អ្នកពោល ដែលជាអ្នកមានតួនាទីដឹកនាំរឿង និងរៀបរាប់រឿងៗ ទម្រង់នេះសម្តែងបានតែរឿងរាមកេរ្តិ៍មួយគត់ ដែលជារឿងពោរពេញទៅដោយតួអង្គយក្ស ហើយនិងស្វាៗ ឯការសម្តែងវិញ គឺធ្វើឡើងក្នុងពិធីត្រុស្តិ៍សង្រ្កាន្ត គឺពិធីផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី រាំដើម្បីបំបាត់ឧបទ្រពចង្រៃនៃឆ្នាំចាស់ ហើយសុំទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិទាំងអស់ ជួយប្រទានសព្ទសាធុការពរសេចក្តីសុខចម្រើនសិរីសួស្តីជ័យមង្គល សុំឲ្យបានប្រកបនឹងសុខសុភមង្គល និងសម្បូរុងរឿងក្នុងជីវភាពជាប្រចាំរបស់ប្រជាជនកម្ពុជា និងមានពេលខ្លះពេលដែលស្រុកទេសជួបវិបត្តិគ្រោះរាំងស្ងួត គេក៏រាំល្ខោនខោលដើម្បីសុំទឹកភ្លៀងផងដែរ ម្យ៉ាងទៀតទម្រង់ល្ខោនខោលនេះ ជាទម្រង់ដែលមានសុទ្ធតែសិល្បករប្រុសៗជាអ្នករាំ សូម្បីតែតួអង្គស្រីដូចជាតួនាងសីតា នាងមណ្ឌោគិរី នាងបុញ្ញកាយ ឬនាងសុវណ្ណមច្ឆាក៏ដោយៗ

ទម្រង់ល្ខោននេះបានបន្សល់នូវចម្ងល់ដ៏យូរលង់មួយនៅក្នុងអារម្មណ៍របស់ប្រជាជនកម្ពុជាៗ គេច្រើនចោទសួរថា តើមកពីហេតុអ្វី បានជាចាស់បុរាណខ្មែរយកសិល្បករប្រុសមកឲ្យដើរជាតួស្រីដូច្នេះ?

ចំពោះសំណួរខាងលើនេះ យើងមិនឃើញមានចម្លើយណាធ្វើយបានច្បាស់លាស់ ឬក៏កត់ត្រាទុកជាលាយលក្ខណ៍អក្សរទេៗ ប៉ុន្តែជាទូទៅយើងសង្កេតឃើញមានមតិពីរដែលទាក់ទិនទៅនឹងសំណួរនេះហើយបានក្លាយទៅជាការន័យមនិយាយបន្តគ្នាតាំងពីយូរណាស់មកហើយ រហូតដល់សព្វថ្ងៃនេះៗ

www.elibraryofcambodia.org

មតិទី ១ នោះបាននិយាយថា ហេតុដែលនាំឲ្យមានទម្រង់ល្ខោនមួយ ដែលមានសុទ្ធតែសិល្បករប្រុស ជាអ្នករាំនោះគឺកើតឡើងដោយសារមានវិបត្តិខាងសាសនានៅប្រទេសកម្ពុជា ពិសេសក្នុងកាលវេលាដែលមានទំនាស់សាសនារវាងព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។

ពួកស្រីរបាំនៃល្ខោនក្បាច់បុរាណ ឬល្ខោនព្រះរាជទ្រព្យដែលក្នុងសម័យអង្គរគេហៅថា **«រមាំ»** មានដើមកំណើតតាំងពីមុនការចាប់បដិសន្ធិនៃលទ្ធិទេវរាជ «Culte du Dieu Roi» ដោយព្រះបាទជ័យវរ្ម័នទី ២ ក្នុងអំឡុងឆ្នាំ ៨០២ ទៅទៀត ហើយពេលដែលខ្មែរគោរពលទ្ធិទេវរាជ គេនិយមហៅស្រីរបាំទាំងនោះថា **«ទេវទាសី»** ជាស្រីរបាំនៃព្រះវិហារខាងព្រហ្មញ្ញសាសនា រួចបន្តតួនាទីជាស្រីរបាំនៃព្រះវិហារខាងព្រះពុទ្ធសាសនាមហាយាន ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២១៨) ដូចមានឯកសារខ្លះអាចឲ្យយើងដឹងថា ក្នុងពេលនោះនៅប្រាសាទតាព្រហ្មមានស្រីរបាំចំនួន ៦១៥ នាក់ និងនៅប្រាសាទព្រះខ័ន ស្រីរបាំមានចំនួនរហូតដល់ទៅ ១.០០០ នាក់ឯណោះ។

ក្រុមរបាំទាំងនោះមានតួនាទីសំខាន់ណាស់ គឺមានភារកិច្ចចម្លងពាក្យបណ្ដឹង ពាក្យបន់ស្រន់ ពាក្យឧទ្ទិសទាំងឡាយ ពីឋានមនុស្សលោកទៅឋានព្រះ គឺឋានសួគ៌ ឋានត្រៃត្រិង្ស ហើយនាំនាំនូវសព្ទសាធុការពរពីឋានសួគ៌ ចុះមកប្រោះព្រំដល់ឋានមនុស្សលោកវិញ។ អ្នកទាំងនោះសុទ្ធតែជាស្រីបរិសុទ្ធ មិនមានប្រឡាក់ប្រឡូសអ្វីនឹងគ្រឿងមន្ទិលសៅហ្មង ទាំងខាងផ្លូវកាយវាចាចិត្តតាមបែបមនុស្សសាមញ្ញឡើយ។ លុះមកដល់ពេលប្រទេសជាតិជួបវិបត្តិខាងសាសនា ពិសេសក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៨ (១២៤៣-១២៩៥)? ដែលមានប្រតិកម្មយ៉ាងខ្លាំងក្លារបស់អ្នកកាន់ព្រហ្មញ្ញសាសនាសិវៈនិយម ពួកនេះបានកោសលុបរូប ឬបំផ្លាញព្រះពុទ្ធសាសនាបដិមាផ្សេងៗជាច្រើននៅប្រាសាទបាយ័ន និងទីដទៃទៀត។ មិនត្រឹមតែប៉ុណ្ណោះទេ ដើម្បីប្រឆាំងនឹងព្រះពុទ្ធសាសនា ពួកអ្នកកាន់អំណាចមាន

www.elibraryofcambodia.org

មន្ត្រីធំៗក្នុងព្រះបរមរាជវាំង បានបង្ហុំរួមរស់ស្នេហាជាមួយស្រីរបាំ «ពួកទេវទាសី» ក្បត់ទំនៀមមុន ហើយប្រហែលជាចាប់តាំងពីពេលនោះមកហើយ ដែលគេឃើញមានការនិយម របស់ពួកមន្ត្រីក្នុងព្រះបរមរាជវាំងដណ្តើម យកស្រីរបាំធ្វើភរិយារបស់ខ្លួនៗ គេឃើញមានសេសសល់ជាក់ស្តែង ក្នុងសង្គមកម្ពុជា រហូតមកដល់ពេលមុនសង្គ្រាមឆ្នាំ ១៩៧០ ផុះឡើងបន្តិចៗ

អាស្រ័យដោយការមិនពេញចិត្តនឹងអំពើទាំងនោះ គ្រូរបាំបុរាណធំៗ នៃជំនាន់អង្គរនោះដែលជាអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា ហើយសុទ្ធតែជាអ្នកដែលបានខិតខំចំណាយអស់កម្លាំងកាយ កម្លាំងប្រាជ្ញា និងទេពកោសល្យរបស់អាត្មាខ្លួន បង្ហាត់បង្ហាញ អប់រំសិល្បការិនីរបាំឲ្យបានល្អ បានល្បីដើម្បីបម្រើព្រះពុទ្ធសាសនាទៅតាមសទ្ធាជ្រះថ្លារបស់ខ្លួន ក៏បានដកខ្លួនថយរត់គេចទៅជ្រករស់នៅជាមួយប្រជារាស្ត្រជាពុទ្ធសាសនិក ពិសេសគឺយកអារាមខាងពុទ្ធសាសនាជាបង្អែក ហើយបង្កើតទម្រង់ល្ខោនថ្មីមួយប្រភេទទៀត ដែលមានសុទ្ធតែប្រុសៗជាអ្នករាំ ដើម្បីចៀសវាងកុំឲ្យអ្នកកាន់អំណាចទាំងឡាយ បំផ្លាញសិល្បៈរបស់ខ្លួនបានទៀតៗ

ការអធិប្បាយខាងលើនេះ គឺជាហេតុផលនានាដែលមតិទី ១ បានលើកមកសំអាង ដើម្បីបញ្ជាក់អំពីការកកើតនៃទម្រង់ល្ខោនប្រុស ដែលចេញមកពីប្រភពតែមួយ គឺចេញពីល្ខោនក្បាច់បុរាណខ្មែរ ឬល្ខោនព្រះរាជទ្រព្យ ដែលមានសុទ្ធតែសិល្បការិនីជាអ្នករាំ សូម្បីតែតួអង្គប្រុសក៏ដោយនោះៗ

រីឯមតិទី ២ វិញ ដើម្បីឆ្លើយតបទៅនឹងចម្ងល់ដែលថា តើហេតុអ្វីបានជាចាស់បុរាណខ្មែរយកសិល្បករប្រុសៗឲ្យរាំជាតួស្រី នៅក្នុងទម្រង់ល្ខោនពាក់មុខដូច្នេះ? ឬក៏និយាយអំពីដើមកំណើតនៃល្ខោនខោលនោះ? គេតែងតែលើកយកវិបត្តិនៃព្រះរាជវង្សស្តេចខ្មែរ ពិសេសគឺការប្តូររាជវង្ស ពីវង្សវរ្ម័ន មកវង្សព្រះបាទត្រសក់ផ្អែមធ្វើជាទីសំអាងៗ

មុនពេលដែលព្រះបាទត្រសក់ផ្អែម បានឡើងសោយរាជ្យ ប្រទេសកម្ពុជា

www.elibraryofcambodia.org

បានជួបវិបត្តិសាសនាមួយយ៉ាងធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យស្ដេចផែនដី និងមន្ត្រីធំៗដែលកាន់ព្រហ្មញ្ញសាសនា និងប្រជានុរាស្ត្រទូទៅដែលនិយមគោរពព្រះពុទ្ធសាសនាឃ្លាតឆ្ងាយពីគ្នាៗ តាត្រសក់ផ្អែមជាកសិករ និងជាពុទ្ធសាសនិកម្នាក់មានប្រជាប្រិយភាពធំធេង ក្នុងចំណោមប្រជារាស្ត្រ ព្រោះគាត់ជាមនុស្សស្លូតបូត ហើយឆ្លាតវាងវៃផងៗ ក្នុងការសម្រាកពីមុខរបរចិញ្ចឹមជីវិត តាត្រសក់ផ្អែម តែងតែនាំអ្នកស្រុកលេងមហោស្រពនានា ដែលនាំឲ្យកេរ្តិ៍ឈ្មោះរបស់គាត់កាន់តែល្បី និងមានអ្នកស្រុកជិតឆ្ងាយគោរពស្រឡាញ់គាត់យ៉ាងច្រើនទៀតផងៗ ថ្ងៃមួយដោយឃើញថា ភោគផលកសិកម្មរបស់គាត់បានផលល្អ តាត្រសក់ផ្អែមក៏បេះត្រសក់របស់ខ្លួនយកទៅថ្វាយព្រះរាជា និងបាននាំមហោស្រព គឺល្ខោនរបាំនានាទៅសម្ដែងថ្វាយស្ដេចផែនដីទៀតផងៗ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យនឹងត្រសក់ ដែលមានរសជាតិផ្អែមឆ្ងាញ់ពិសេសរបស់គាត់ណាស់ ហើយក៏ទ្រង់ចេញព្រះរាជបញ្ជាហាមមិនឲ្យតាត្រសក់ផ្អែមបេះត្រសក់យកទៅលក់ដូរ ឬក៏ឲ្យទៅអ្នកណាម្នាក់ឡើយៗ មិនតែប៉ុណ្ណោះដើម្បីរក្សាចម្ការត្រសក់នេះ ព្រះរាជាបានប្រទានលំពែងមួយដែលស្វូះឡើង ដោយថ្មកាយសិទ្ធិ គឺជាលំពែងដ៏មានឫទ្ធិដល់តាត្រសក់ផ្អែមៗ ដើម្បីសាកល្បងថា តើតាត្រសក់ផ្អែមមានកក្តីភាពចំពោះបន្ទូលរបស់ព្រះអង្គឬក៏អត់? យប់មួយនោះព្រះអង្គទ្រង់គង់លើសេះជាជំនិះ ហើយទ្រង់នាំទាំងពលសេនាឯទៀតទៅឃ្លាំមើល រួចលបលួចចូលទៅក្នុងចម្ការត្រសក់ៗ

គាប់ជួនពេលនោះតាត្រសក់ផ្អែម កំពុងតែមើលមហោស្រព ស្រាប់តែក្រឡេកទៅឃើញមនុស្សលួចចូលក្នុងចម្ការ គាត់នឹកគិតថាជាចោរ ក៏លើកលំពែងឡើង ហើយពួយទៅក្នុងចម្ការត្រង់កន្លែងដែលមនុស្សលបចូលនោះៗ លំពែងបានហោះទៅចាក់ត្រូវចំព្រះរាជាសុគតក្នុងពេលនោះទៅៗ ដោយព្រះរាជាអង្គនោះគ្មានព្រះរាជបុត្រ ស្នងរាជបន្តពីព្រះអង្គ ពួកសេនាបតីមន្ត្រីទាំងពួង ក៏លើកតាត្រសក់ផ្អែមឲ្យឡើងសោយរាជ្យៗ

www.elibraryofcambodia.org

ដោយសារដើមកំណើតរបស់ព្រះអង្គជាតិជាកសិករ និងជាពុទ្ធសាសនិកចូលចិត្តពលកម្ម ស្រឡាញ់ធម្មជាតិ ស្រណោះស្រណោកជីវភាពស្រែចម្ការ ដែលព្រះអង្គធ្លាប់បានគតព្រួសពូកល់ថ្ងៃ ក្នុងពេលបានឡើងសោយរាជ្យ ព្រះបាទត្រសក់ផ្អែមបានចាត់ចែងឲ្យសិល្បករ ជំនិតរបស់ព្រះអង្គច្នៃប្រឌិតបង្កើតស្នាដៃសិល្បៈដែលមានភាពស្វាហាប់ ហើយលើកយករឿងរាមកេរ្តិ៍ ដែលជារឿងមានប្រជាប្រិយភាពធំធេងក្នុងសង្គមខ្មែរ ទាំងក្នុងចំណោមអ្នកកាន់ព្រហ្មញ្ញសាសនា ទាំងអ្នកកាន់ព្រះពុទ្ធសាសនា ទាំងអ្នកមានជំនឿទៅលើ អារក្ខអ្នកតា ដែលជាជំនឿរបស់ខ្មែរដើម យកមកសម្ដែងៗ គឺចាប់ពីពេលនោះមក ដែលល្ខោនខោល ឬល្ខោនពាក់មុខដែលមានសុទ្ធតែសិល្បករប្រុសៗជាអ្នករាំបានចាប់កំណើតឡើងៗ

ដូចខ្ញុំបាទបានជម្រាបបញ្ជាក់ខាងលើម្ដងរួចមកហើយថា រឿងរ៉ាវទាំងពីរដែលទាក់ទិន និងប្រកពកំណើតល្ខោនខោល យើងសង្កេតឃើញមិនមានឯកសារណាកត់ត្រាឲ្យបានច្បាស់លាស់ជាកស្តុតាងទេ ប៉ុន្តែវាជារឿងនិយាយតៗគ្នា ពីជំនាន់មួយទៅជំនាន់មួយទៀតតាមការនិយមរបស់ប្រជារាស្ត្រខ្មែរតែប៉ុណ្ណោះៗ

ម្យ៉ាងទៀត ទម្រង់ល្ខោនប្រុសនេះមិនមែនមាននៅតែប្រទេសកម្ពុជាយើងនេះទេៗ យើងសង្កេតឃើញមាននៅក្នុងប្រទេសនានាជាច្រើនដែលធ្លាប់មានអារ្យធម៌ដ៏ចំណាស់ និងរីកចម្រើនដូចជាប្រទេសឥណ្ឌា និងជប៉ុនជាដើមៗ ទម្រង់ល្ខោនប្រុសដែលល្បីល្បាញជាងគេនៅប្រទេសឥណ្ឌា មានឈ្មោះថា កាថាកាលី «KATHAKALI» ដែលមានអាយុរាប់ពាន់ឆ្នាំមកហើយៗ ចំណែកនៅប្រទេសជប៉ុនវិញ ទម្រង់ល្ខោនកាប៊ូគី «KABUKI» ជប៉ុន ក៏មានសុទ្ធតែសិល្បករប្រុសៗជាអ្នករាំ ហើយក៏មានអាយុច្រើនសតវត្សរ៍មកហើយដែរ?

ចំពោះកាលបរិច្ឆេទពិតប្រាកដ នៃដើមកំណើតរបស់ល្ខោនខោលវិញនោះវារឹតតែជាការស្មុគស្មាញណាស់ទៅទៀត សម្រាប់យើងជាអ្នកសិក្សាស្រាវជ្រាវ ដ្បិតប្រទេសកម្ពុជា ជាប្រទេសបានជួបនូវផលវិបាក ដោយសារសង្គ្រាមបំផ្លាញជាតិ

www.elibraryofcambodia.org

ច្រើនជំនាន់រាប់មិនអស់ៗ គ្រប់សង្គ្រាមដែលបានកកើតឡើង សុទ្ធតែបានបំផ្លាញវប្បធម៌ជាតិ តាមរយៈការបំផ្លាញឯកសារ បំផ្លាញបេតិកភណ្ឌ លួចយកសម្បត្តិវប្បធម៌ជាតិកម្ពុជា និងមានការកាប់សម្លាប់សិល្បករ ដែលជាឯកសាររស់របស់ជាតិខ្មែរជាដើមៗ

ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏នៅមានចំណុចពិសេសខ្លះ ដែលធ្វើឲ្យអ្នកស្រាវជ្រាវចាប់អារម្មណ៍យ៉ាងខ្លាំង នោះគឺល្ខោនខោល សម្តែងបានតែរឿងរាមកេរ្តិ៍មួយគត់ៗ ធ្វងតាមចំណាប់អារម្មណ៍លើចំណុចនេះ ហើយយោងទៅលើឯកសារដែលសេសសល់ច្រើនបន្តិស្តីពីរឿងរាមកេរ្តិ៍នៅប្រទេសកម្ពុជានោះយើងសូមសាកល្បងវិភាគ ដើម្បីបំភ្លឺពីកាលបរិច្ឆេទនៃទម្រង់ល្ខោនខោលនេះដូចតទៅ ៖

រឿងរាមកេរ្តិ៍ជារឿងមួយ ដែលមានចំណាស់ជាងគេ ហើយមានប្រជាប្រិយភាពបំផុតនៅប្រទេសកម្ពុជាៗ បើតាមឯកសាររបស់ព្រះតេជព្រះគុណ ចាប៉ី ទាត់ ក្នុងសៀវភៅព្រះពុទ្ធសាសនានៅប្រទេសខ្មែរ ព្រះអង្គបានមានសង្ឃដីកាថា ព្រហ្មញ្ញសាសនា ក៏ដូចជាពុទ្ធសាសនាដែរ បានហូរចូលមកដល់ជ្រោយសុវណ្ណភូមិ **«ប្រទេសកម្ពុជា»** តាំងពី ៣០៩ ឆ្នាំមុន គ.ស មកម្ល៉េះៗ ចុះបើព្រហ្មញ្ញសាសនាហូរចូលមក តើរឿងរាមាយណៈ ដែលជារឿងផ្សព្វផ្សាយពីឥទ្ធិពលព្រហ្មញ្ញសាសនា អាចហូរចូលមកក្នុងពេលនោះដែរឬទេ ? ឬក៏ហូរចូលមកក្នុងពេលដែល ព្រាហ្ម កៅណ្ឌិន្យ ចូលមកច្បាំងរួចរៀបអភិសេកជាមួយព្រះនាងនាគី **«សោមា»** **«ព្រះថោង និងនាងនាគ»**? ឬក៏ហូរចូលមកក្រោយពេលនោះ ប៉ុន្តែមុនសម័យអង្គរ ?

សព្វថ្ងៃ គេសង្កេតឃើញមានសំណល់រឿងរាមកេរ្តិ៍ **«រាមាយណៈ»** ជាច្រើននៅស្ទើរតែគ្រប់ទម្រង់នៃទម្រង់សិល្បៈខ្មែរដូចជា ៖

## ១-សិល្បៈចម្លាក់

- រូបចម្លាក់នៅប្រាសាទកោះកេរ សាងក្នុងដើមសតវត្សរ៍ទី ១០ «**អន្ទើត្តៈៗ នៃ**

www.elibraryofcambodia.org

**រឿងរាមកេរ្តិ៍»**

- ប្រាសាទបន្ទាយស្រី កណ្តាលសតវត្សរ៍ទី ១០ «**អន្ទើខ្លះៗនៃរឿង រាមកេរ្តិ៍**»
- ប្រាសាទបាពួន ដើមសតវត្សរ៍ទី ១១ «**អន្ទើខ្លះៗនៃរឿងរាមកេរ្តិ៍**»
- និងប្រាសាទអង្គរវត្ត សាងក្នុងអំឡុងឆ្នាំ១១១៣-១១៥២ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ នៅប្រាសាទនេះ រឿងរាមកេរ្តិ៍ ត្រូវបានគេឆ្លាក់នៅច្រើនកន្លែងខុសៗគ្នា ដូចជានៅទ្វារខាងលិច ជ្រុងខាងត្បូង ទ្វារខាងលិចជ្រុងខាងជើងផ្ទាំងខាងលិចជាដើមៗ ឯសាច់រឿងរាមកេរ្តិ៍វិញ គេសង្កេតឃើញមានច្រើនអន្ទើតាំងពីព្រះរាមទទួលជ័យជម្នះ ក្នុងការប្រឡងលើកធ្នូ រាពណ៍ចាប់នាងសីតា ចម្បាំងរវាងព្រះរាម និងសម្ព័ន្ធមិត្តស្វា ទល់នឹងពួករាពណ៍ និងអសុរឯទៀតជាសម្ព័ន្ធមិត្ត រហូតដល់ឆាកស្តីពីនាង «**សីតាលុយភ្លើង**» ដើម្បីបញ្ជាក់ពីការស្មោះត្រង់របស់នាងចំពោះស្វាមី ថ្វីត្បិតតែក្រុងរាពណ៍បានចាប់យកនាងទៅក្រុងលង្កា អស់កាលយ៉ាងយូរក៏ដោយ និងអន្ទើផ្សេងពីនេះច្រើនទៀតៗ ប៉ុន្តែ ប្រការដែលគួរឲ្យសោកស្តាយបំផុតនោះគឺ រហូតមកដល់ថ្ងៃនេះរូបចម្លាក់មួយចំនួនកំពុងទទួលគ្រោះអាសន្ន ពីសំណល់នៃសង្គ្រាម និងមួយចំនួនទៀតកំពុងតែទទួលការគំរាមកំហែងពីគ្រោះធម្មជាតិ ដូចជាអន្ទើដែលបង្ហាញពីកត្តីភាពរបស់នាងសីតាចំពោះព្រះរាម «**សីតាលុយភ្លើង**» ដែលពេលនេះយើងមើលស្ទើរតែលែងស្គាល់ទៅហើយ ព្រោះចម្លាក់នេះត្រូវពុកផុយរបេះជ្រុះដោយសារទឹកភ្លៀងដែលហូរតាមដំបូលចុះមកៗ

## ២-សិល្បៈនិទានរឿង

ជាទំនៀមទម្លាប់ពីបរមបុរាណរបស់ប្រជាជនកម្ពុជា ក្នុងការនិទានរឿងរាមកេរ្តិ៍នៅប្រទេសកម្ពុជាមានសិល្បករជំនាញពីរនាក់ត្រូវគេស្គាល់ជាទូទៅគឺ លោកតាគ្រុឌ ដែលមានដើមកំណើតនៅខេត្តកំពង់ចាម មានក្រាំងរឿងរាមកេរ្តិ៍ ពិសេស

www.elibraryofcambodia.org

របស់គាត់ មានកម្រាស់ហួតដល់ទៅកន្ទះម៉ែត្របណ្ដោយដាគមួយម៉ែត្រ ប៉ុន្ដែក្រាំងនេះត្រូវបានគេបូជាជាមួយសាកសពរបស់គាត់ ក្នុងពេលដែលគាត់អនិច្ចកម្មទៅ នៅភូមិកំណើតរបស់គាត់ៗ សិល្បករចំណានម្នាក់ទៀត គឺតាចត់មានដើមកំណើតនៅខេត្តសៀមរាប អ្នកទាំងពីរនាក់សុទ្ធតែមានសំនួនវោហារពីរោះរណ្ដំណែងណងពូកែខាងនិទានរឿងរាមកេរ្ដិ៍ មានការឆ្លាតវាងវៃច្នៃប្រឌិតរឿងទៅតាមលក្ខណៈពិសេសនៃសង្គមខ្មែរ ដូចជាអន្ទើហនុមានក្ចាល់ ទាញរោមដើងព្រះរាម ឬហនុមានដុតក្រុងលង្កាជាដើម ប្រកបដោយកាយវិការរស់រវើកធ្វើឱ្យអ្នកស្ដាប់ស្ងួនអារម្មណ៍ ផុះសំណើចយ៉ាងខ្លាំងខ្ទរខ្ទារ តាមការនិទានរបស់គាត់ៗ

## ៣– ខាងសិល្បៈវិចិត្រកម្ម

សំណល់ខាងសិល្បៈវិចិត្រកម្មផ្នែកគំនូរបុរាណ មានគំនូររឿងរាមកេរ្ដិ៍ មួយចប់នៅក្នុងថែវវត្តព្រះកែវមរកត ក្នុងបរិវេណព្រះបរមរាជវាំងនៅរាជធានីភ្នំពេញ និងមានអន្ទើរឿងរាមកេរ្ដិ៍ខ្លះទៀតនៅតាមវិហារនានា ដូចជាវិហារវត្តព្រះរាជបូណ៌ក្នុងទីរួមខេត្តសៀមរាបជាដើមៗ

## ៤– ខាងទម្រង់សិល្បៈទស្សនីយភាព

ខាងផ្នែកសិល្បៈទស្សនីយភាព យើងសង្កេតឃើញមានទម្រង់បី ដែលសម្ដែងរឿងរាមកេរ្ដិ៍ ហូតមកទល់សព្វថ្ងៃនេះគឺ÷

ក–ល្ខោនក្បាច់បុរាណ ដែលមានសុទ្ធតែសិល្បការិនីជាអ្នករាំ សូម្បីតែតួព្រះរាម ឬព្រះលក្ស្មណ៍ក៏ដោយ ហើយអាចសម្ដែងរឿងរាមកេរ្ដិ៍ផង និងរឿងឯទៀតៗផងដូចជារឿងព្រះជិនវង្ស ទិព្វសង្វារ ព្រះវេស្សន្ដរ ក្រៃថោង ព្រះចន្ទគោរពជាដើមៗលៗ

ខ–ល្ខោនស្រមោល ស្បែកធំដែលជាប្រភេទសិល្បៈសក្ការៈសម្ដែង បានតែ

www.elibraryofcambodia.org

រឿងភាមកេរ្តិ៍មួយគត់ មិនមានសម្តែងរឿងផ្សេងទៀតឡើយ។
គ-ល្ខោនខោល ដែលជាល្ខោនពាក់មុខ ហើយមានសុទ្ធតែប្រុសៗជាអ្នកកាំសម្តែងបានតែរឿងរាមកេរ្តិ៍មួយគត់ ដូចជាល្ខោនស្រមោលស្បែកធំដែរ។

## ៤-ឯកសារសំណេរ

ក្រៅពីទម្រង់សិល្បៈខាងលើ យើងនៅមានសំណល់ឯកសារខាងសំណេរ ដូចជាឯកសាររបស់អ្នកអគ្គមហាសេនាបតី ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយ ហើយដែលត្រូវបានគេជ្រើសរើសយកមកបញ្ចូល ក្នុងកម្មវិធីសិក្សាតាំងពីជំនាន់សង្គមរាស្ត្រនិយមមកម្ល៉េះ។

បើតាមឯកសារនេះ យើងឃើញថា រឿងរាមកេរ្តិ៍របស់ខ្មែរមានរហូតដល់ទៅ ៨០ ខ្សែឯណោះ។ ប៉ុន្តែឯកសារដែលបានរកឃើញ និងយកមកបោះពុម្ពផ្សាយ មានចំនួនតែ ១៦ ខ្សែប៉ុណ្ណោះ គឺពីខ្សែ ០១ ដល់ខ្សែ ១០ និងពីខ្សែ ៧៥ ដល់ខ្សែ ៨០ គឺបាត់ចំនួន៦៤ខ្សែទៀតមិនទាន់រកឃើញ។ បើយើងពិនិត្យមើលវិធីនិពន្ធក្នុងសៀវភៅទាំង ១៦ ខ្សែនោះយើងឃើញថារបៀបនិពន្ធមិនមែនសរសេរបែបប្រលោមលោកធម្មតាឡើយ។ ផ្ទុយទៅវិញយើងឃើញជារបៀបកាត់តង់ឆាកល្ខោន ដោយកាត់សាច់រឿងជាដុំៗ ជាអង្គៗបន្តបន្ទាប់គ្នា។ មានពាក្យពេចន៍ដែលយើងសង្កេតឃើញគាត់ច្រើន ជាកំណាព្យបទកាកគតិ បទព្រហ្មគីតិ បទពំនោល និងបទពាក្យ៦ជាដើមៗល។ សម្រាប់ឲ្យអ្នកពោល និងសិល្បករអ្នកសម្តែង សម្តែងបានងាយស្រួលទៅវិញ។

មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងអត្ថបទជាច្រើននៃសៀវភៅទាំង ១៦ ខ្សែនោះមានពាក្យខ្លះបញ្ជាក់ពីការដឹកនាំរឿង បង្ហាញបទពោល និងមានឈ្មោះបទភ្លេងយ៉ាងច្រើនទៀតផង។ ក្នុងចំណោមបទទាំងនោះ មានបទមួយចំនួនធំដែលយើងខ្ញុំពុំស្គាល់ ព្រោះការសិក្សាខាងផ្នែកតន្ត្រីនៅរកឈ្មោះពុំទាន់ឃើញអស់នៅ

www.elibraryofcambodia.org

ឡើយៗ ដូច្នេះយើងខ្ញុំសូមលើកយក តែបទមួយចំនួនដែលយើងស្គាល់ឈ្មោះ យល់ពីសារៈសំខាន់របស់បទ សម្រាប់ប្រើក្នុងល្ខោន ហើយដែលប្រជាជនកម្ពុជា និយមប្រើរហូតដល់សព្វថ្ងៃ និងបទខ្លះទៀតដែលយើងយល់ថា គ្រាន់តែជាការផ្លាស់ឈ្មោះបន្តិចបន្តួច ទៅតាមកាលវេលាដ៏យូរលង់តែប៉ុណ្ណោះដូចជា÷

**១-បទស្តេចលីលា** ខ្សែ ០១ ទំព័រ ០១ ជាពញាដើរ ខ្សែ ៧៦ ទំព័រ ៩ ហើយដែលសព្វថ្ងៃមានអ្នកខ្លះហៅផ្សាជីនតាមភាសាថៃ ដែលបកប្រែយកពីឈ្មោះដើមរបស់ខ្មែរទៅ និងអ្នកខ្លះហៅថាស្តេចយាងៗ

**២-បទដំណាក** ខ្សែ ០១ ទំព័រ ៤៧ ជាបណ្តក ខ្សែ ៣ ទំព័រ ២៣ ជាបណ្តក ខ្សែ ៤ ទំព័រ ២១ ជាកែវណាក ខ្សែ ៦ ទំព័រ ២២ ជាបិនណាក ខ្សែ ៩ ទំព័រ ១៥ ជាដំណាក ខ្សែ ៩ ទំព័រ ៣២ ជាបទក្រៅណាក ខ្សែ ៧៦ ទំព័រ ៣៣ ឈ្មោះក្រៅណាកនេះត្រូវបានគេប្រើរហូតមកដល់សព្វថ្ងៃនេះៗ

**៣-បទឆាន** ខ្សែ ៧៥ ទំព័រ ៣ ប្រហែលជាបទជើតឆាន ដែលយើងប្រើសព្វថ្ងៃ

**៤-បទទ្រង់គ្រឿង** ខ្សែ ៧៥ ទំព័រ ០១ ប្រហែលជាបទខមទ្រង់គ្រឿងដែលខ្មែរប្រើសព្វថ្ងៃ ?

**៥-បទស្តេចលា** ខ្សែ ០១ ទំព័រ ៣២ រហូតដល់ខ្សែ ១០ ទំព័រ ២៤ បទនេះប្រហែលជាបទលា ដែលមានប្រើរហូតដល់សព្វថ្ងៃ ព្រោះក្នុងឯកសារនេះកន្លែងខ្លះបទឱតសរសេរជាស្តេចឱតក៏មានៗ

**៦-បទស្ទឹងថង** ខ្សែ ៧៥ ទំព័រ ៣៨ បទនេះប្រហែលជាបទ សម៉ិនថងសព្វថ្ងៃៗ

**៧-បទពញាសោក** ខ្សែ ៧៥ ទំព័រ ៣៩ បទនេះសព្វថ្ងៃអ្នកខ្លះហៅផ្សាសុ តាមភាសាថៃដែលបកពីឈ្មោះដើមរបស់ខ្មែរទៅ និងអ្នកខ្លះទៀតនិយមហៅបទមន្ត្រីសោកាក៏មានៗ

**៨-បទថយ៉ីយ** ខ្សែ ៧៥ ទំព័រ ៤៣ គឺបទតាយ៉ីយ ដែលមានប្រើសព្វថ្ងៃៗ

**៩-បទក្តុម** ខ្សែ ៧៥ ទំព័រ ១ រហូតដល់ខ្សែ ៧៩ ឃើញប្រើឈ្មោះដដែល បទ

www.elibraryofcambodia.org

នេះគឺបទក្តុំ ឬក្តុម ឬ ខ្ទុំដែលជាឈ្មោះនិយមប្រើសព្វថ្ងៃ

**១០-បទប្រះ:** ខ្សែ ១ ទំព័រ ១០ រហូតដល់ខ្សែ ១០ ឃើញប្រើឈ្មោះដដែលៗ ចាប់ពីខ្សែ ៧៥ ទំព័រ ៦ ដល់ខ្សែ ៨០ ឃើញប្ដូរមកប្រើ ឈ្មោះ ត្រះវិញ បទនេះគឺបទត្រាក់ដែលមានប្រើសព្វថ្ងៃ

**១១-បទឱត់** ខ្សែ ១ ទំព័រ ២៤ រហូតដល់ខ្សែទី ៨០ ប្រើឈ្មោះដដែលៗ បទនេះគឺបទអួតដែលគេនិយមប្រើសព្វថ្ងៃ

**១២-បទស្មើ** ខ្សែ ៧៥ ទំព័រ ១៥ រហូតដល់ខ្សែ ៨០ ឃើញប្រើ ឈ្មោះដដែលៗ បទនេះគឺបទស្មើ ដែលប្រើសព្វថ្ងៃ

**១៣-បទយានី** ខ្សែ ៧៧ ទំព័រ ៤៨ រហូតដល់សព្វថ្ងៃប្រើឈ្មោះដដែលៗ

**១៤-បទដួងព្រះធាតុ** ខ្សែ ៧៦ ទំព័រ ៤៦ រហូតដល់សព្វថ្ងៃ ប្រើ ឈ្មោះ ដួង ព្រះធាតុដដែល ប៉ុន្តែមានអ្នកខ្លះនិយមហៅដួងប៉ាងថាត តាមភាសាថៃ ដែលបានមកពីឈ្មោះដើមរបស់ខ្មែរៗ

**១៥-បទជុំព្រៃ** ខ្សែ ៧៥ ទំព័រ ៣ រហូតដល់ខ្សែបញ្ចប់មានឈ្មោះ បទជុំព្រៃដដែលៗ ហើយសព្វថ្ងៃឈ្មោះនេះក៏គ្មានដោះដូរអ្វីដែរ គឺឈ្មោះបទជុំព្រៃដដែលៗ

**១៦-បទពិលាប** ខ្សែ ២ ទំព័រ ២២ រហូតដល់ខ្សែក្រោយៗ ហើយសព្វថ្ងៃនេះបទនេះ ក៏មានឈ្មោះបទពិលាបដដែលគ្មានផ្លាស់ប្ដូរអ្វីទេៗ

**១៧-បទប្រគំ** ខ្សែ ១ ទំព័រ ៣២ដល់ខ្សែចុងបញ្ចប់ឃើញប្រើដដែល ហើយសព្វថ្ងៃនេះបទនេះមានឈ្មោះប្រគំដដែលគ្មានផ្លាស់ប្ដូរអ្វីទេៗ

**១៨-បទឆា** ខ្សែ ៧៥ ទំព័រ ១ រហូតដល់ខ្សែក្រោយៗ ហើយសព្វថ្ងៃក៏នៅតែប្រើឈ្មោះបទឆា ដដែលគ្មានប្រែប្រួលឡើយៗ

**១៩-បទដើតឈើង** ខ្សែ ៤ ទំព័រ ២៤ និងទំព័រ ៣០ រហូតមកដល់សព្វថ្ងៃនេះក៏នៅតែប្រើឈ្មោះបទដើតឈើងដដែលៗ

www.elibraryofcambodia.org

**២០-បទជើត** ពីខ្សែ ១ រហូតដល់ខ្សែចុងក្រោយឈ្មោះដដែល ហើយសព្វថ្ងៃឈ្មោះបទនេះ ក៏ត្រូវគេរក្សាទុកដដែលគ្មានការផ្លាស់ប្តូរអ្វីទាំងអស់ៗ

តាមរយៈការរៀបរាប់បទភ្លេងទាំងឡាយខាងលើនេះ និងមានឈ្មោះបទភ្លេងជាច្រើនទៀត តាំងពីខ្សែ ១ ដល់ខ្សែ ៨០ ដែលយើងពុំទាន់អាចសម្គាល់ឲ្យបានច្បាស់លាស់នោះ របៀបកាត់កងឆាកដោយចែកសាច់រឿងជាឈុតៗបន្តគ្នា និងកំណាព្យជាពាក្យពោលផ្សេងៗ ព្រមដោយពាក្យជាកំណត់ចំណាំនៃការដឹកនាំរឿងផងនោះ យើងជឿថាឯកសារសំណេរនេះគឺប្រាកដជារឿងល្ខោន «Pièce de théâtre» មិនមែនជារឿងប្រលោមលោក ឬក៏អត្ថបទប្រភេទដទៃទៀតឡើយ សមតាមការសន្និដ្ឋាន របស់លោកសាស្ត្រាចារ្យ អ្នកស្រាវជ្រាវផ្នែកអក្សរសិល្ប៍ខ្មែរ ដែលថា អត្ថបទរឿងរាមកេរ្តិ៍នេះជានាដកថាមែនៗ

ចុះបើឯកសារនេះជាអត្ថបទរឿងល្ខោនមែននោះ តើជាអត្ថបទរបស់ទម្រង់ល្ខោនណាមួយ ?

ដោយយោលទៅលើការនិយមរបស់ប្រជាជនកម្ពុជា ក្នុងការប្រើវិធីសាស្ត្រ បែបបុរាណ ក្នុងការបន្តស្នាដៃពីជំនាន់មួយទៅជំនាន់មួយទៀត ដោយបង្រៀនឲ្យទន្ទេញចាំមាត់ ឬក៏និយាយប្រាប់តៗគ្នាពីឪពុកទៅកូន ពីគ្រូទៅសិស្ស និងដោយផ្អែកទៅលើភាពជាក់ស្តែង ដែលមានសេសសល់រហូតដល់សព្វថ្ងៃនេះ នោះគេឃើញទម្រង់ល្ខោនបីគឺ ល្ខោនស្រមោល ល្ខោនពាក់មុខ និងល្ខោនក្បាច់បុរាណ ដែលសម្តែងរឿងរាមកេរ្តិ៍ ដូចយើងខ្ញុំបានជម្រាបពីខាងលើម្តងមកហើយៗ

ប៉ុន្តែ បើយើងលើកយកបច្ចេកទេសសម្តែង មកពិនិត្យឲ្យបានហ្មត់ចត់នោះ យើងឃើញថា ក្នុងទម្រង់ទាំងបីដូចជម្រាបខាងលើ ឯកសាររឿងល្ខោននេះមិនមែនសម្រាប់ល្ខោនក្បាច់បុរាណទេ ព្រោះល្ខោនក្បាច់បុរាណ ជាល្ខោនដែលយកចម្រៀងជាក្រុម « Choeur » ជាមធ្យោបាយជូនដំណើរសាច់រឿង និងជូនកាយវិការអ្នករាំ ដែលត្រូវហាត់យ៉ាងហ្មត់ចត់ជាមុន រហូតដល់ចាំស្ទាត់ ស្ទើរតែក្លាយជាស្វ័យប្រវត្តិ មិនមានប្រើបទពំនោល ដូចជាល្ខោនស្រមោល «ស្បែកធំ» ឬល្ខោន

www.elibraryofcambodia.org

ខោលឡើយ ផ្ទុយទៅវិញ អត្ថបទសំណេរនេះមានពាក្យពោលយ៉ាងច្រើនដែល ពីក្នុងខ្សែ ១ រហូតខ្សែ ១០ ប្រើពាក្យថាសំណារួចពីខ្សែ ៧៥ ដល់ ៨០ ឃើញប្រើជាបទកាយ ឬនិយាយបទកាយ ដូច្នេះអត្ថបទល្ខោនរឿងរាមកេរ្តិ៍នេះ បើមិនសម្រាប់ល្ខោនស្រមោលស្បែកធំទេ មានតែល្ខោនខោលប៉ុណ្ណោះ ព្រោះទម្រង់ទាំងពីរមានប្រើពំនោលដូចគ្នា ឯរបៀបប្រើបទភ្លេងពណ៌ពាទ្យទៀតសោត ក៏ប្រហាក់ប្រហែលគ្នាដែរ។

ប៉ុន្តែបើយើងពិនិត្យទៅលើកំណត់ចំណាំ ដែលបញ្ជាក់ពីការដឹកនាំរឿងវិញ ដូចជាពាក្យថា ៖

-ដើតឈើងហើយពោល ខ្សែ ៤ ទំព័រ ៣០ ដែលបញ្ជាក់ឲ្យដឹងថា ភ្លេងត្រូវលេងបទដើតឈើង កាលណាអ្នកភ្លេងលេងចប់ហើយ នោះអ្នកពោលត្រូវពោលបន្ត ឬពាក្យថា ល្បងកាន់ហើយដើតជំហានធំ ខ្សែ ៤ ទំព័រ ៥។

-បងន្ទូវយកមេទៅបន្តាញបុណ្យ ហើយមេដឹងគុណ ញញឹមញញែមរកបង។

-ទពីក្រោមប្រះខ្លួនហោង រាពណ៍ឱបហោះផ្សង អាណាថកណ្តាលហោស៍។

ពាក្យនេះបញ្ជាក់ពីការសម្តែង និងការដឹកនាំរឿង គឺតួរាពណ៍ដែលត្រូវចាប់នាងសីតា ត្រូវធ្វើកាយវិការជាចាប់ ឬប៉ះនាងដោយលឺបល ញញើតញញើម រួចហើយឈានជំហានធំ ដើម្បីងកថយ ដូចជាភ្ញាក់ រួចចូលចាប់នាងម្តងទៀត ចាប់បានហើយ «**ឱបហោះយកទៅ**»។ ការដឹកនាំរឿងរបៀបនេះ យើងសង្កេតឃើញត្រូវបានគេថែរក្សាហូតមកដល់សព្វថ្ងៃ ទោះក្នុងល្ខោនក្បាច់បុរាណក៏មាន ទោះក្នុងទម្រង់ល្ខោនខោលក៏មាន។

ឬពាក្យថា ព្រះលក្ស្មណ៍វ័ណ្ឌមាលា ខ្សែ ៥ ទំព័រ ៣៥

-ផងណោះព្រះលក្ស្មណ៍នរបតី ដាលដោះរួសខ្ញី គំវ័ណ្ឌមាលា សុក្រីព។

-ក្រាបថ្វាយបង្គំ សូមពរដើត ស្រេចហើយសុក្រីព ក៏ហោះរឹង ថ្កានពាលី។

អន្ទើនេះ បើយោងតាមពាក្យកំណត់នៃការដឹកនាំរឿងខាងលើ ឃើញថាព្រះ

www.elibraryofcambodia.org

លក្ខណ៍ទ្រង់បំពាក់កម្រងផ្កាឲ្យសុគ្រីព ដែលត្រូវចេញច្បាំង នឹងពាលីជាបងប្អូនរបស់ខ្លួន ដែលមានរូបដូចគ្នាបេះបិទម្ដងទៀត ដើម្បីឲ្យព្រះរាមអាចចំណាំបានថា ណាជាសុគ្រីព ណាជាពាលី នឹងអាលផ្លែងសរព្រហ្មាស សម្លាប់ពាលីឲ្យបានតាមបំណងរបស់សុគ្រីព។

ដោយពិចារណាទៅលើកំណត់ចំណាំនៃការដឹកនាំរឿង ដែលមានក្នុង ឯកសារល្ខោនរឿងរាមកេរ្តិ៍នេះ និងដោយផ្អែកទៅលើបទពិសោធនៃការសម្ដែងល្ខោនខោល ឬស្បែកធំដែលមានសព្វថ្ងៃផងនោះ យើងជឿថា សំណេរនេះមិនមែនសម្រាប់ទម្រង់ល្ខោនស្រមោលស្បែកធំទេ ព្រោះពាក្យទាំងអស់ជាពាក្យដែលបញ្ជាក់អំពីសកម្មភាពរបស់តួអង្គ ដែលមានជីវិតពិតទៅលើឆាក ដែលអាចធ្វើកាយវិការយ៉ាងរស់រវើកដូចជា រាពណ៍ចាប់នាងសីតាដោយញរញើតញរញើប រួចឱបនាងហោះយកទៅ ឬក៏តួព្រះលក្ខណ៍ត្រូវបំពាក់កម្រងផ្កាឲ្យសុគ្រីពជាដើម។

តាមរយៈការសិក្សាមកដល់ចំណុចនេះ យើងមានជំនឿជឿជាក់ថា ឯកសារល្ខោនរឿងរាមកេរ្តិ៍នេះ គឺជាសំណល់របស់ទម្រង់ល្ខោនខោល យ៉ាងពិតប្រាកដ មិនមែនទម្រង់ណាក្រៅពីនេះឡើយ។

ម្យ៉ាងទៀត បើផ្អែកទៅលើប្រសាសន៍របស់លោកសាស្រ្តាចារ្យ ឈុំ ថ្លៃង ក៏ដូចជាអស់លោកសាស្រ្តាចារ្យ អ្នកស្រាវជ្រាវផ្នែកអក្សរសិល្ប៍ខ្មែរច្រើនទៀតដែលតែងតែពោលថា ស្នាដៃរឿងរាមកេរ្តិ៍ត្រូវបាននិពន្ធឡើង ដោយអ្នកនិពន្ធមិនស្គាល់ឈ្មោះពីរនាក់ខុសគ្នាពីខ្សែ ០១ ដល់ខ្សែ ១០ មានអ្នកនិពន្ធម្នាក់ និងពីខ្សែ៧៥ ដល់ខ្សែ ៨០ ជាស្នាដៃដែលសរសេរដោយអ្នកនិពន្ធម្នាក់ផ្សេងទៀត។ ហើយរឿងរាមកេរ្តិ៍នេះ ត្រូវតាក់តែងឡើងមួយកំណាត់ ប្រហែលជាក្នុងរយៈពេលមុនពេលដែលប្រទេសខ្មែរមានវិបត្តិសាសនា គឺទំនាស់រវាងអ្នកកាន់ព្រហ្មញ្ញសាសនា មួយនឹងអ្នកកាន់ព្រះពុទ្ធសាសនា និងមួយកំណាត់ក្រោយទៀត ត្រូវរៀបរៀងក្រោយពេលមានវិបត្តិ ពោលគឺក្នុងភាគចុងក្រោយនៃសម័យអង្គរ។

www.elibraryofcambodia.org

មតិអស់លោកសាស្ត្រាចារ្យ អ្នកស្រាវជ្រាវផ្នែកអក្សរសិល្ប៍ខ្មែរ ខាងលើនេះ ហាក់ស្របគ្នានឹងមតិពីខាងដើម ដែលជាពាក្យដំណាលតៗគ្នា ដែលលើកយកវិបត្តិទំនាស់សាសនា ក្នុងរដ្ឋកាលព្រះបាទជ័យវរ្ម័នទី ៨ និងវិបត្តិរាជវង្ស គឺការប្ដូររាជវង្សពីវង្សវរ្ម័ន មកវង្សតាត្រសក់ផ្អែម មកពន្យល់ដើម្បីជាហេតុ បញ្ជាក់អំពីការកកើតឡើងនៃទម្រង់ល្ខោនប្រុសនោះៗ

មួយចំណែកទៀត បើយើងសាកល្បងពិនិត្យមើលរូបចម្លាក់លើជញ្ជាំងប្រាសាទអង្គរ និងរូបភាពនៃល្ខោនខោល ដែលសេសសល់ដល់យើងសព្វថ្ងៃដូចជារូបមេទ័ពស្វា និងពលស្វា មេទ័ពយក្ស ឬក៏ចលនាច្បាំងគ្នារវាងទ័ពស្វា និងទ័ពយក្សយើងសង្កេតឃើញថា មានលក្ខណៈដូចគ្នាស្ទើរតែទាំងអស់ ដែលជាហេតុនាំឲ្យយើងខ្ញុំមានគំនិតយល់ស្របថា ការសន្និដ្ឋាន ឬក៏គំនិតរបស់អស់លោកអ្នកប្រាជ្ញអ្នកស្រាវជ្រាវខាងលើ ស្ដីអំពីកាលបរិច្ឆេទកំណើតនៃទម្រង់ល្ខោនខោល ឬល្ខោនប្រុសនេះជាការសមរម្យណាស់ៗ

ឯចំណុចដ៏វិសេសវិសាលមួយទៀតនោះ គឺការរកឃើញទម្រង់ល្ខោនមួយឈ្មោះថាភាណី «Bhanni» នៅក្នុងសិលាចារឹក K- ៩៩ នា សតវត្សរ៍ទី ១០ៗ ភ្នំ ឬរមាំភាណី «Rmam Bhani» អ្នករាំភាណី សុទ្ធតែជាសិល្បករប្រុសៗ និងត្នោងភាណី «Thmon Bhani» គឺតន្ត្រីករប្រគំ គ្រឿងដំសម្រាប់ល្ខោនភាណីក៏សុទ្ធតែប្រុសៗដែរៗ

ពាក្យភាណីនេះ ជាភាសាសំស្ក្រឹត និងបាលីមកពីពាក្យថាភាណៈៗ បើតាមវចនានុក្រមខ្មែរត្រង់ទំព័រ ៨១៨ នោះបានអធិប្បាយថា ភាណៈ ន. (បា) ដំណើរពេលការនិយាយការប្រាប់ការសូត្រៗ

ម្យ៉ាងទៀតយើងក៏ឃើញមានទំនៀមមួយទៀត ដែលព្រះរាជវង្សានុវង្សនៃក្សត្រខ្មែរទ្រង់បានថែរក្សាទុកយ៉ាងល្អខ្ជាប់ខ្ជួន តាំងពីយូរលង់មក ហើយរហូតមកដល់សព្វថ្ងៃនោះ គឺពិធីសូត្រភាណយក្ស នៅក្នុងបរិវេណព្រះបរមរាជវាំងៗ ពិធីនេះបានត្រូវក្រុមបារគូព្រាហ្មណ៍បុរោហិត«ផ្នែកព្រហ្មញ្ញសាសនា» និងព្រះសង្ឃ

www.elibraryofcambodia.org

«ផ្នែកខាងព្រះពុទ្ធសាសនា» ប្រារព្ធធ្វើឡើងក្នុងរយៈកាលប៉ុន្មានថ្ងៃប៉ុណ្ណោះ មុនពេលដែលពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិកម្ពុជាចូលមកដល់។ ពិធីនេះធ្វើឡើងដើម្បីកម្ចាត់ឧបទ្រពចង្រៃនៃឆ្នាំចាស់ ហើយសុំសិរីសួស្តី សុភមង្គលនៃឆ្នាំថ្មី មានដល់ព្រះនគរ និងប្រជារាស្ត្រកម្ពុជា ដែលគេច្រើនតែហៅថា ពិធីរំដោះគ្រោះព្រះនគរ។

ក្នុងឆ្នាំ ១៩៩៦ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គក៏បានប្រារព្ធពិធី សូត្រភាណយក្ស ឬពិធីរំដោះគ្រោះព្រះនគរនេះយ៉ាងអធិកអធម ក្នុងព្រះបរមរាជវាំងរាជធានីភ្នំពេញ ហើយបានផ្សព្វផ្សាយតាមទូរទស្សន៍ជាញឹកញាប់ទៀតផង។

ម្យ៉ាងទៀត ពិតមែនតែមានរយៈកាលខុសគ្នាដល់ទៅរាប់ពាន់ឆ្នាំនេះ បើយើងគិតពីសម័យអង្គរមកដល់សព្វថ្ងៃ ប៉ុន្តែបើយើងពិនិត្យមើលឲ្យជិតដល់ទូវលក្ខណៈពិសេសរបស់ល្ខោនខោលដែលមានសព្វថ្ងៃ ទាំងការពោល ឬការសូត្រ ទាំងសិល្បករសុទ្ធតែប្រុសៗ និងកាលវេលាដ៏ពិសេសបំផុត សម្រាប់ទម្រង់សិល្បៈល្ខោននេះសម្តែងគឺក្នុងពិធីចូលឆ្នាំថ្មី (ជាពេលវេលាសំខាន់បំផុតអាក់ខានសម្តែងមិនបានក្នុងឆ្នាំនីមួយៗនោះ) គួបផ្សំជាមួយនឹងទំនៀមទម្លាប់ប្រពៃណី ពិធីសូត្រភាណយក្សនោះ យើងមានជំនឿជឿជាក់ថា ល្ខោនភាណីដែលមានចារក្នុងសិលាចារឹកក្នុងសម័យអង្គរនោះ ប្រាកដជាល្ខោនខោល ដែលយើងនិយមប្រើសព្វថ្ងៃនេះហើយ។

ចំពោះបញ្ហាល្ខោនភាណី ឬល្ខោនខោលនេះ នៅក្នុងសៀវភៅ Music and Dance in Ancient Cambodia as evidenced by old Khmer Epigraphy លោកស្រី ពៅ សាវរស់ បានធ្វើការសិក្សា និងពន្យល់យ៉ាងក្បោះក្បាយ ដូចតទៅនេះ៖

> ពាក្យ «ភាណី» ដែលមានន័យដើមជាភាសាសំស្ក្រឹតថា «ការសម្តែងនាដកម្មលាយនឹងការពោល»។ នៅក្នុង សិលាចារឹក K-270 (IC IV, 70: 16) គេឃើញមានពាក្យថា ទឹម ដ្ងួន «អ្នកលេងភ្លេង»។ ដូច្នេះ វាត្រូវបាន បង្ហាញដោយបុព្វបុរស

www.elibraryofcambodia.org

របស់យើងយ៉ាងពិតថា «វាគឺជាប្រភេទនៃឧបករណ៍តន្ត្រីមួយប្រភេទ» ដែលស្ថិតនៅឆ្ងាយពីការចាប់អារម្មណ៍។ នៅក្នុងសតវត្សរ៍ទី១០ សិលាចារឹកលេខ c.k-99 (IC VI, 110 (n))8 យើងបានឃើញពាក្យ រ្វាដ កាណី «រាំ . . .» បង្កើតឡើងដោយមនុស្សប្រុសបីនាក់។ ប្រសិនបើយើងធ្វើការស្វែងយល់ទៅ គឺ «អ្នករាំមានអមដោយ ការលេងភ្លេង» ដែលវាគួរតែជាករណីមួយនៃពាក្យបន្ទរដែលចាត់ទុកថាជាវប្បធម៌ខ្មែរ ពីព្រោះវាមិនមានរបាំណា ដែលធ្វើឡើងដោយមិនមានការប្រគំភ្លេងដោយប្រភេទខ្លះនៃឧបករណ៍តន្ត្រីនោះទេ។ ចាប់តាំងពីដឹងថាពាក្យ កាណី មិនមែនមានន័យថា រឹម។ គិតថា យើងគួរតែធ្វើការភ្ជាប់វាជាមួយនឹងពាក្យ កណ ដែលជាពាក្យសំស្ក្រឹត «ការពោល ដែលជាបែបមួយនៃការសម្តែងល្ខោនកម្រានូបែបប្រែងកថាដែលនិទានដោយអ្នកពោលមួយរូប»។ នៅត្រង់ចំណុចមួយនេះ វានិយាយនឹកទៅដល់ប្រភេទល្ខោនបែបប្រពៃណីរបស់យើងវិញ ដែលមានរួមបញ្ចូលនូវការពោល ដូចជា ល្ខោនយីកេ ដែលជាប្រភេទនៃល្ខោនដែលនិយាយពីរឿងសាសនា និងរឿងជាច្រើននៃល្ខោនរបស់យើងស្តីពីរឿង រាមាយណៈ ហើយដែលពេលបច្ចុប្បន្ននេះហៅថា ល្ខោនខោល។ ក្រុមនៃល្ខោនខោល កើតឡើងដោយមានសុទ្ធតែ បុរសទាំងអស់ដោយរួមទាំងតួសម្តែងអ្នកប្រគំតន្ត្រី និងអ្នកពោល។ ទំនុកភ្លេងត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការបញ្ចេញជាចង្វាក់កាព្យខុសៗគ្នា ហើយដែលពេញដោយសំឡេងនៃស្គរដៃយ៉ាំ ដែលអមនឹងការពោល។ វាមានការ គាប់ជួនដែលថាពាក្យរ្វាដនិង រ្វាដ បុរាណ គឺសំដៅទៅលើ អ្នកភាយស្គរដៃយ៉ាំ និងអ្នក អ្នករបាំ ល្ខោនកាណីដែលជាបុព្វបុរសនៃល្ខោនខោលសម័យទំនើបរបស់យើង។

៥

*បើល្ខោនកាណី ឬល្ខោនខោលដែល (ប្រជាពលរដ្ឋខ្មែរខ្លះទៅសព្វថ្ងៃនិយមហៅ) ឬល្ខោនពាមកេរ្តិ៍ដែល (អ្នកចាត់ដំបន់ខ្លះនិយមហៅ) ឬល្ខោនយក្សរាំ (តាម*

www.elibraryofcambodia.org

ការនិយមរបស់ប្រជាកស្ត្រខ្មែរនៅកម្ពុជាក្រោម សម្រាប់សម្គាល់ទម្រង់ល្ខោនពាក់មុខនេះ) ត្រូវបានបុព្វបុរសជូនតាកម្ពុជា កត់ត្រាទុកក្នុងសិលាចារឹកលេខ K-៩៩ នាសតវត្សរ៍ទី ១០ និងក្នុងសិលាចារឹកលេខ K-២៧០ នោះយើងមានជំនឿយ៉ាងមុតមាំថា ទម្រង់ល្ខោនភាណី ឬខោលនេះ ប្រាកដជាបានយកយានកំណើតនៅលើទឹកដី នៃមាតុភូមិកម្ពុជានេះតាំងពីយូរអង្វែងមុនសតវត្សរ៍ទី ១០ មិនខាន ។

www.elibraryofcambodia.org

# ៦-ល្ខោនយីកេ



## ប្រវត្តិសិល្បៈយីកេ

យីកេ គឺជាទម្រង់ល្ខោនច្រៀងកំប្លែបបុរាណមួយបែប ដែលប្រហែលជាបានយកឈ្មោះតាមឧបករណ៍តន្ត្រីមួយប្រភេទគឺ «**ស្គរយីកេ**» ជាប្រភេទស្គរដែលមានវិជ្ជមាត្រ «**មុខស្គរ**» ធំជាង «**កម្រាស់ស្គរ**»ៗ

ជាទូទៅ នៅគ្រប់ក្រុមសិល្បៈយីកេទាំងអស់សុទ្ធតែមានប្រើស្គរនេះដូចគ្នា ពោលគឺស្គរនេះជាឧបករណ៍តន្ត្រីចម្បងរបស់វង់យីកេ ហើយមានចំនួនតិច ឬច្រើនពីពីរដល់ដប់បីស្គរតាមទំហំក្រុមសិល្បៈ និងធនធាននៃក្រុមសិល្បៈយីកេ

www.elibraryofcambodia.org

និមួយៗ

ក្រៅពីស្គរយីកេ ដែលជាឧបករណ៍ចម្បងក្នុងវង់ ក្រុមសិល្បៈយីកេ នៅមានប្រើឧបករណ៍តន្ត្រីមួយទៀត គឺទ្រអ៊ូចំហៀង ដើម្បីបើកបទចម្រៀង និងជាមធ្យោបាយកែសំឡេងឱ្យអ្នកចម្រៀងទាំងអ្នកបន្ទរ និងអ្នកចម្រៀងទោល (solo) ច្រៀងត្រូវសំឡេងគ្នាផងៗ នៅមានឧបករណ៍ស្រឡៃមួយទៀតដែលសម្រាប់ប្រើផ្លុំតែបទមួយ គឺបទដើតនៅក្នុងពិធីហោមរោងយីកេប៉ុណ្ណោះ (ឯក្រុមខ្លះមានប្រើឧបករណ៍ក្រាប់បន្ថែមទៀតសម្រាប់ពេលឡុក)ៗ

ឯរបៀបសម្ដែងវិញ សិល្បករយីកេ មានស្រីមានប្រុសច្រៀងរាំ និងនិយាយខ្លួនឯង ថែមដោយពាក្យពេលនៃគ្រូធំរបស់វង់ល្ខោនដើម្បីកាត់កងឆាក និងរៀបរាប់សាច់រឿងផងៗ

ការតុបតែងលម្អកាយនៃស្រីអ្នករាំ ហោមរោងមានពាក់របៃលម្អក្បាល ឬពាក់មកុដក្រុមខ្លះមានពាក់ក្រូចកផងៗ តួឯកស្រីប្រុស យក្ស ស្វា និងឥសីច្រើនយកតាមលំនាំល្ខោនក្បាច់បុរាណខ្មែរ តែគ្រឿងមិនមែនជាគ្រឿងល្អប្រណីតឡើយផ្ទុយទៅវិញគឺមានលក្ខណៈស្រេចម្ការៗ

តួពាក់មុខដូចជាយក្ស ឥសី ស្វា បើកាលណាត្រូវការនិយាយ គេបង្អើបមុខ (Masque) រុញឡើងលើក្បាលរួចទើបនិយាយៗ

ចំពោះប្រភពនៃសិល្បៈយីកេ និងកាលបរិច្ឆេទរបស់ទម្រង់នេះនៅលើទឹកដីខ្មែរវិញ មានមតិយល់ខុសៗគ្នាជាច្រើន ÷

-មតិខ្លះយល់ថា យីកេប្រហែលជាមានដើមកំណើតនៅឥណ្ឌូនេស៊ី ហើយត្រូវបានព្រះបាទជ័យវរ្ម័នទី ២ ចម្លងយកមកក្នុងពេលដែលព្រះអង្គយាងត្រឡប់មកពីប្រទេសនេះវិញៗ

-មតិខ្លះទៀតយល់ថា យីកេប្រហែលជាមានដើមកំណើតនៅម៉ាឡេស៊ី នៅទីនោះទម្រង់សិល្បៈនេះមានឈ្មោះថា យីកេ ហើយឆ្លងចូលមកប្រទេសថៃមុន

www.elibraryofcambodia.org

ឈ្មោះដាលីកេ រួចហូរចូលមកដល់ប្រទេសកម្ពុជាត្រូវប្តូរឈ្មោះជាយីកេតាមឈ្មោះដើមវិញៗ ប៉ុន្តែក្រោយពីការសិក្សាពិនិត្យ អំពីលក្ខណៈពិសេសនៃទម្រង់សិល្បៈនេះពិសេសលើឧបករណ៍តន្ត្រីយីកេនៅប្រទេសថៃ និងយីកេនៅប្រទេសកម្ពុជានេះវិញ យើងឃើញថាមតិខាងលើនេះ មិនសូវសមហេតុផលទាល់តែសោះៗ ព្រោះលីកេថៃប្រើឧបករណ៍ភ្លេងពិណពាទ្យឯយីកេខ្មែរប្រើស្គរយីកេ ដែលជាលក្ខណៈពិសេសរបស់ទម្រង់នេះ ហើយឧបករណ៍តន្ត្រីទាំងពីរប្រភេទនេះគឺខុសដាច់ស្រឡះពីគ្នាតែម្តងៗ

ប៉ុន្តែមតិមួយជាចុងក្រោយ បានផ្តោតទៅលើបងប្អូនជនជាតិចាម និងប្រទេសចម្ប៉ា ដែលស្ថិតនៅត្រង់តំបន់ប្រទេសវៀតណាមកណ្តាលសព្វថ្ងៃហើយជាប្រទេសដែលមានព្រំប្រទល់ជាប់គ្នានឹងប្រទេសកម្ពុជា និងធ្លាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត ដូចជាទំនាក់ទំនងជាញាតិសាលោហិត ឬមិត្តភក្តិ និងទំនាក់ទំនងក្នុងលក្ខណៈអាក្រក់គ្រោតគ្រាត មានជម្លោះទាស់ទែង ឬសង្គ្រាមរវាងគ្នានិងគ្នា ជាដើមដូចជា ÷

-ទំនាក់ទំនងមិត្តរវាងព្រះថោង (ស្តេចខ្មែរ) និងព្រះអសុចៃរាជ (ស្តេចចាម) សតវត្សរ៍ទី ១ (ក្នុងរឿងព្រះថោងនាងនាគ)ៗ

-ទំនាក់ទំនងរបស់ព្រះបាទហ្វាន់ស៊ីយុន ដ៏ជិតស្និទ្ធបំផុតជាមួយចម្ប៉ានាពាក់កណ្តាលសតវត្សរ៍ទី ៣ រហូតដល់គេយល់ថា ប្រហែលព្រះអង្គបានពង្រីកអធិរាជភាពរបស់ព្រះអង្គលើនគរចម្ប៉ាទៀតផងៗ

-ទំនាក់ទំនងរបស់ព្រះបាទឦសានវរ្ម័ន (៦១៥-៦៣៨) ដែលបានរៀបអភិសេកបុត្រីព្រះអង្គ ព្រះនាមសរៈកានី (ជារកាទិ) ជាមួយព្រះអង្គម្ចាស់មួយអង្គនៃនគរចម្ប៉ា ដែលបានបុត្រមួយព្រះអង្គទ្រង់ឡើងគ្រងរាជ្យនៅចម្ប៉ាព្រះនាមវិក្រន្តាៗ

www.elibraryofcambodia.org

-ព្រឹត្តិការណ៍ឆ្នាំ ១១៧៧ ដែលចាមវាយបែកក្រុងអង្គរ

-ព្រឹត្តិការណ៍ទាំងឡាយ ដែលកើតមានរវាងខ្មែរ និងចាមក្នុង រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២១៨) ព្រមទាំងតឹកតាំងជាក់ស្តែងមួយចំនួនទៀត ដែល មានសេសសល់ផ្តល់សព្វថ្ងៃដូចជា (បងប្អូនចាមប្រើស្គរយីកេនេះសម្រាប់ពិធីមង្គលផ្សេងៗ និងសាសនាៗ ជនជាតិចាមអង្គុយដំកង់ជារង្វង់មូល វាយស្គរស្វូត្រធម៌ ដែលមានលក្ខណៈដូចគ្នានឹងទម្រង់សិល្បៈយីកេពីកាតខាងដើមដែលជាសិល្បៈល្ខោន សម្តែងអាចឲ្យអ្នកមើលទស្សនាបានពីគ្រប់ជ្រុងៗ

-បទធម៌សូត្ររបស់បងប្អូនចាមមួយចំនួន គឺជាបទចម្រៀង ដែលសិល្បៈយីកេប្រើសព្វថ្ងៃមានបទ ម៉ារីយ៉ែងជាដើមៗ

៤

ក្នុងពិធីហែក្បួនព្យុហយាត្រានៅរាជធានីភ្នំពេញ ឬនៅសៀមរាប អង្គរ (ក្នុងសម័យសង្គមរាស្ត្រនិយម) គេឃើញបងប្អូន ចាមចូលរួមហែ ក្នុងក្បួនដោយប្រើស្គរយីកេចំនួន ៤០ ទៅ ៦០ ស្គរ និងមានច្រៀងបទសាមសេជាកស្តុតាងផងនោះ ទើបក្រុមអ្នកសិក្សាស្រាវជ្រាវសន្និដ្ឋានថា សិល្បៈយីកេនេះជាមរតករបស់បងប្អូនជនជាតិចាមនៃនគរចម្ប៉ា ហើយត្រូវបានប្រជាជនខ្មែរអ្នកស្រែចម្ការចម្លងយកបកប្រែហែលតាំងពីសម័យ នគរភ្នំ (សតវត្សរ៍ទី ១ និងសតវត្សរ៍ទី ៦) សម័យចេនឡា (សតវត្សរ៍ទី ៧ សតវត្សរ៍ទី ៨) មិនខានៗ ហើយពីមួយថ្ងៃទៅមួយថ្ងៃ តួបផ្សំដោយគំនិតច្នៃប្រឌិតរបស់ដូនតាខ្មែរផងសិល្បៈយីកេ ឬល្ខោនយីកេនេះបានវិវឌ្ឍន៍ទិតកែកែលក្ខណៈពិសេសជាខ្មែរ និងប្រជាប្រិយភាពធំធេងក្នុងសង្គមខ្មែររហូតអាចសម្តែងរឿងជាតកនានា រឿងប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ ឬរឿងទាំងឡាយដែលចោទ និងដោះស្រាយពីបញ្ហាសង្គមខ្មែរ ឬមនុស្សខ្មែរថែមទៀតផងៗ

នៅប្រទេសកម្ពុជាក្នុងសម័យសង្គមរាស្ត្រនិយម យើងសង្កេតឃើញមានក្រុមសិល្បៈយីកេជាច្រើន នៅតាមខេត្តនានា ដូចជាខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់

www.elibraryofcambodia.org

ចាម ខេត្តសៀមរាប ខេត្តកណ្ដាល ។ល។ ហើយភាគច្រើនក្រុមសិល្បៈយីកេ ទាំងនោះ មានលក្ខណៈជាសិល្បៈមហាជន ពោលគឺក្រៅពីការថែរក្សាការពារដោយក្ដីស្រឡាញ់របស់ប្រជាជនមហាជននោះ នៅគ្រប់ពេលសម្ដែង គឺគ្រូល្ខោន ឬអ្នកដឹកនាំរឿងគ្រាន់តែនិយាយសាច់រឿងប្រាប់ដោយត្រួសៗតែប៉ុណ្ណោះ ហើយសិល្បករអ្នកសម្ដែង ទាំងស្រីទាំងប្រុស ក៏ចាប់សម្ដែងដោយប្រើកាយវិការ ពាក្យសម្ដីនិយាយ ឬច្រៀងឥតព្រាងទុក ទៅតាមការយល់ដឹងរបស់ខ្លួន ដែលពេលខ្លះអន្ទើខ្លះ នាំឲ្យទស្សនិកជនមើលឃើញនូវចំណុចមិនសូវរៀបរយដូចជា ដាក់ស្ដែងឆាកខ្លះកំពុងបង្ហាញពីសាច់រឿងកម្សត់លន្លង់លន្លោច ស្រាប់តែមានតួកំប្លែងចេញមកសម្ដែងកាត់ ធ្វើឲ្យអ្នកមើលផុះសំណើចហួសចិត្តទៅវិញក៏មាន។

រហូតមកដល់ឆ្នាំ១៩៦៥ ពេលដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈត្រូវបង្កើតឡើងទម្រង់សិល្បៈយីកេ ក៏ដូចជាទម្រង់ល្ខោនដទៃទៀតដែរ ត្រូវបានសាកលវិទ្យាល័យចាត់ឲ្យមានក្រុមចុះធ្វើការសិក្សាស្រាវជ្រាវ ដោយរក្សាទុកនូវធាតុដើមរបស់ទម្រង់សិល្បៈនីមួយៗនោះ ឲ្យស្ថិតក្នុងដៃប្រជាជនមហាជនដដែលៗ ចំណែកខាងសាកលវិទ្យាល័យ រៀបចំឲ្យមានការវិវឌ្ឍរីកចម្រើនមួយជំហាន ពោលគឺសាកលវិទ្យាល័យចាប់ផ្ដើមធ្វើឲ្យមានការ «**រៀបរយ**» ដោយរឿងដែលត្រូវសម្ដែង គឺត្រូវសរសេរជារឿងល្ខោនឲ្យហ្មត់ចត់មានពាក្យសម្ដីនិយាយ ឬច្រៀងសិល្បករត្រូវទន្ទេញចាំស្ទាត់ជាមុន និងមានការដឹកនាំរឿង «Mise en scène» ត្រឹមត្រូវថែមទៀតផង។

ស្ថិតក្នុងស្មារតីចង់ធ្វើឲ្យមានការអភិវឌ្ឍរីកចម្រើនដោយប្រុងប្រយ័ត្ននេះ ហើយដែលទម្រង់សិល្បៈយីកេ ត្រូវបានរក្សាបានធាតុដើមទាំងស្រុង មិនឲ្យធ្លាយឬក្លាយ ហើយទម្រង់នេះកាន់តែទទួលបានការនិយមខ្លាំងឡើងៗ ពីគ្រប់ស្រទាប់ប្រជាជន អ្នកស្រែចម្ការអ្នកផ្សារ អ្នកទីក្រុង និងបញ្ញវន្តគ្រប់លំដាប់ថ្នាក់ទៀតផង។ ដោយពេលនោះទម្រង់សិល្បៈយីកេ បានលើកយករឿង «**អនក្ខរកម្ម**» ដែលបង្ហាញ

www.elibraryofcambodia.org

ពីទោស នៃការមិនចេះអក្សរមកសម្តែងជាលើកដំបូងៗ រួចបន្ទាប់មកបានលើកយករឿងទុំទាវ ដែលកើតមានក្នុងប្រវត្តិសាស្ត្រជាតិកម្ពុជា នាសម័យលង្វែក (ហើយដែលរៀបរៀងដោយលោក ឆេង ផុន លោក ពេជ្រ ទុំក្រវិលនិងលោក ចណ្ឌ ស៊ុនហេង) មកសម្តែងដោយបានទទួលជោគជ័យយ៉ាងធំធេងៗចាប់ពីពេលនោះមក យីកេរឿងទុំទាវបានចូលរួមសម្តែងក្នុងមហាស្រពអន្តរជាតិនានា ជាញឹកញាប់ដូចជា នៅប្រទេសម៉ាឡេស៊ី សិង្ហបុរី និងហ្វីលីពីនជាដើមៗ

សូមបញ្ជាក់ថា យីកេរឿងទុំទាវប្រហែលជារឿងល្ខោនខ្មែរមួយ ដែលបានសម្តែងច្រើនលើកជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្នុងទសវត្សរ៍ឆ្នាំ ៦០ ទសវត្សរ៍ឆ្នាំ៧០ ក៏ដូចជាពេលក្រោយមកទៀត រហូតមកដល់សព្វថ្ងៃនេះដែរ ៕

www.elibraryofcambodia.org

## ៧-ល្ខោនចាសាក់។



www.elibraryofcambodia.org

# ប្រវត្តិប្រភពសិល្បៈល្ខោនបាសាក់

ទម្រង់សិល្បៈទស្សនីយភាពខ្មែរ បានយោងយកឈ្មោះក្នុងលក្ខណៈខុសៗប្លែកគ្នាជាច្រើនៗ ទម្រង់ខ្លះបានយកឈ្មោះចេញអំពីឧបករណ៍តន្ត្រី ឬវង់តន្ត្រីណាមួយដូចជាល្ខោនយីកេ ឬល្ខោនមហោរីជាដើមៗ ប៉ុន្តែទម្រង់ខ្លះទៀតបានយកឈ្មោះពីសិល្បករ ដែលមានប្រជាប្រិយភាពខ្លាំងលើសលប់ដូចជាសិល្បៈចម្រៀងអាយ៉ៃៗ

ចំណែកល្ខោនបាសាក់វិញ ក៏មិនខុសពីទម្រង់ដទៃទៀតប៉ុន្មានដែរ ប៉ុន្តែបានយកឈ្មោះរបស់ខ្លួន ពីទីកន្លែងកំណើតនៃទម្រង់សិល្បៈនេះបានរីកចម្រើនទៅវិញ ពោលគឺល្ខោនបាសាក់ មានដើមកំណើតនៅស្រុកបាសាក់ ខេត្តឃ្លាំង ទល់មុខព្រះត្រពាំងកម្ពុជាក្រោមៗ ទឹកដីកម្ពុជាក្រោមនេះ ត្រូវបានពួកអាណានិគមនិយមបារាំងកាត់ទៅឲ្យយួននៅឆ្នាំ១៩៤៩ បច្ចុប្បន្នស្ថិតនៅ **«ភាគខាងត្បូងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសព្វថ្ងៃ»**ៗ បាសាក់ជាឈ្មោះទន្លេមួយ ដែលជាខ្នែងមួយនៃទន្លេមេគង្គ ហើយប្រសប់គ្នានៅភ្នំពេញ **«ចតុមុខ»**ៗ ទន្លេនេះបានហូរកាត់ទៅទិសខាងត្បូង ចាក់ទៅក្នុងឈូងសមុទ្រចិន គឺនៅលើដងទន្លេនេះហើយដែលជាទីតាំងនៃស្រុកបាសាក់-ខេត្តឃ្លាំង ទល់មុខនឹងខេត្តព្រះត្រពាំង ដែលល្ខោនបាសាក់បានចាប់កំណើតឡើងៗ តំបន់នេះ ក៏ដូចជាតំបន់ដទៃទៀតដែលមានប្រជាជនខ្មែររស់នៅច្រើន ជាតំបន់មានអារ្យធម៌ និងមានកេរដំណែលវប្បធម៌ខ្មែរ ពីបរមបុរាណច្រើន ដូចជាប្រាសាទ ស្រះបុរាណ វត្តអារាម តន្ត្រីច្រើនវង់និងល្ខោនច្រើនប្រភេទដូចជាល្ខោនយីកេ និងល្ខោនយក្សរាំជាដើមៗលៗ

តាមព័ត៌មានដែលយើងទទួលបាន ល្ខោនបាសាក់ ដែលយើងស្គាល់សព្វថ្ងៃនេះ មានប្រភពមកពីល្ខោនទ្រើងឃោក ហើយបានរីកចម្រើនឡើងដោយស្នាដៃបញ្ញវន្តមួយក្រុម ដែលមានចំណេះជ្រៅជ្រះខាងអក្សរសិល្ប៍ និងសាសនាក្រោមការដឹកនាំរបស់អតីតចៅអធិការវត្តខ្សាច់កណ្តាល **«បាសាក់ព្រះត្រពាំង»** កម្ពុជាក្រោមឈ្មោះលោកគ្រូ សួរ ក្រោយពីពេលសឹកមក គោលបំណងថែរក្សាជំរុញលើក

www.elibraryofcambodia.org

តម្លៃវប្បធម៌ជាតិរបស់ខ្លួន លោកគ្រូ ស្គរ ក៏បានប្រមែប្រមូលអ្នកសិក្សាពីបួស «**បណ្ឌិត**» ដូចគ្នា ព្រមដោយកូនសិស្សកូនគណ ពុទ្ធបរិស័ទផ្សេងៗទៀតបង្កើតជាល្ខោនមួយវង់ៗ ប៉ុន្តែដោយកាលណោះនៅមានកង្វះខាតខាងផ្នែកសម្ភារៈ និងឆាក ល្ខោននេះ ត្រូវគេនាំគ្នាសម្ដែង ដោយផ្ទាល់ដីក្នុងពេងដែលសង់ឡើងដោយប្រក់ប្លកាប់មែកឈើយកមកគ្របប្រហាក់ប្រហែលគ្នានឹងទ្រើងដែលគេដាំឃ្លោក ទើបអ្នកស្រុកគេនិយមនាំគ្នាហៅល្ខោននេះថា ល្ខោនទ្រើងឃ្លោកៗ ល្ខោនទ្រើងឃ្លោកនេះក៏មានវត្តមានរហូតដល់អំឡុងឆ្នាំ ១៩៥៣ ប៉ុន្តែក្រោយនោះបន្តិចផង នៅផាយក្រុងភ្នំពេញ និងជនបទនានា។

អ្នកខ្លះនិយមហៅល្ខោនទ្រើងឃ្លោកនេះថាជា «**យូរកើរ្ត**» វិញ។ ពាក្យយូរកើរ្តនេះជាពាក្យដ៏មានតម្លៃសម្រាប់បញ្ជាក់ថា ទម្រង់សិល្បៈនេះគឺជាមរតកតាំងពីយូរលង់មកហើយរបស់ជនជាតិខ្មែរយើង ហើយឈ្មោះនេះបានត្រូវបងប្អូនខ្មែរកម្ពុជាក្រោមប្រើប្រាស់រហូតមកដល់សព្វថ្ងៃ សម្រាប់សម្គាល់ទម្រង់ល្ខោនមួយ ដែលខ្មែរនៅកម្ពុជាយើងសព្វថ្ងៃ និយមហៅថាល្ខោនបាសាក់នេះឯង។

ល្ខោនទ្រើងឃ្លោក បានពង្រីកប្រជាប្រិយភាពរបស់ខ្លួនយ៉ាងឆាប់រហ័សព្រោះអ្នកសម្ដែងសុទ្ធតែជាអ្នកពូកែខាងអក្សរសិល្ប៍ ពូកែប្រើពាក្យសម្ដី ជាកំណាព្យកាព្យឃ្លោង ពូកែការសម្ដែងដោយឥតព្រាងទុក ជាហេតុនាំឲ្យទស្សនិកជនមានការកោតសរសើរ និងចូលចិត្តក្រៃលែងៗ មិនតែប៉ុណ្ណោះ ល្ខោននេះបានទៅជាកម្មវត្ថុនៃការប្រលងប្រជែងជាមួយនឹងល្ខោន «**កៃល្បៀងវៀតណាម**» ហើយក៏បានជះឥទ្ធិពលលើគ្នាទៅវិញទៅមកៗ ក្រោយមក ក្នុងការដែលជនជាតិចិនមួយចំនួនធំជាអ្នកភៀសខ្លួនអំពីសង្គ្រាមនៅស្រុកចិន ពិសេសក្នុងរយៈពេលនៃការបះបោរ-របស់ពួកម៉ាន់ជូ(Manchu) បានហូរច្រាលមកតាមសមុទ្រ បានចូលមកបោះទីតាំងនៅតំបន់កូសាំងស៊ីននេះរស់នៅលាយឡំជាមួយប្រជាជនខ្មែរ និងប្រជាជនវៀតណាមៗ

www.elibraryofcambodia.org

ក្នុងពេលដែលហូរចុះមកជនជាតិចិនទាំងនោះ បាននាំយកនូវទំនៀមទម្លាប់ប្រពៃណី និងសិល្បៈផ្សេងៗដូចជា «**ល្ខោនហ៊ី**» ជាដើមមកជាមួយផងៗ ទាំងល្ខោនទ្រើងឃ្លោកខ្មែរ ទាំងល្ខោនកៃលឿងវៀតណាម ទាំងល្ខោនហ៊ីចិន បានប្រលងប្រជែងទំប្រឹងបញ្ចេញឥទ្ធិពលរៀងៗខ្លួន ដណ្ដើមយកប្រជាប្រិយភាពស្រួបយកចំណាប់ និងចំណូលចិត្តទស្សនិកជនក្នុងតំបន់នោះៗ ទីបំផុតល្ខោនហ៊ីចិនបានទទួលជោគជ័យធំធំធេងៗ ឃើញហេតុផលយ៉ាងនេះ ដើម្បីទាមទារប្រជាប្រិយភាពក្នុងចំណោមទស្សនិកជនចម្រុះជាតិសាសន៍នោះ អ្នកដឹកនាំល្ខោនទ្រើងឃ្លោក បានបម្លងយកចំណុចសំខាន់ៗខ្លះ ពីល្ខោនហ៊ីចិនដែលខ្លួនយល់ថាមានសារៈសំខាន់សម្រាប់ល្ខោនខ្លួនៗ ចាប់ពីពេលនោះមក ល្ខោនទ្រើងឃ្លោក បានទទួលប្រជាប្រិយភាពធំធេងក្នុងតំបន់កូសាំងស៊ីននេះ ព្រោះពេលនោះទាំងអ្នកដឹកនាំវង់ល្ខោនទាំងសិល្បករ អ្នកសម្ដែងមានការឆ្លាតវាងវៃណាស់ នៅទីណាកន្លែងណាដែលមានប្រជាជនខ្មែរជាអ្នកមើលភាគច្រើន គេតែងនាំគ្នាសម្ដែងជាភាសាខ្មែរសុទ្ធកន្លែងណាដែលមានប្រជាជនវៀតណាមមើលច្រើន ការសម្ដែងតែងឆ្លុកគ្នាជាពីរភាសាគឺខ្មែរផងវៀតណាមផង ផ្ទុយទៅវិញកន្លែងណាដែលមានប្រជាជនចិនមើលច្រើន គេតែងនិយាយ និងច្រៀងភាសាខ្មែរផង និងភាសាចិនផង សម្រួបខ្លួនទៅតាមលក្ខណៈភូមិសាស្ត្រ ទឹកដី និងប្រជាជននៅតាមតំបន់ៗ

ចំពោះប្រវត្តិដែលល្ខោនទ្រើងឃ្លោក ឬយូរគេក្តីជាមរតក ដែលបានចាប់កំណើតនៅកម្ពុជាក្រោម ហើយបានត្រូវគេប្ដូរឈ្មោះមកជាល្ខោនបាសាក់នៅកម្ពុជាយើងសព្វថ្ងៃនេះ នោះគឺមានដំណើររឿងដូចតទៅនេះ ÷

នៅក្នុងអំឡុងឆ្នាំ ១៩២០ មានបងប្អូនពីរនាក់ បងឈ្មោះ លី កាញ់ និងប្អូនឈ្មោះ លី សួន និងមានដើមកំណើតកើតជានៅស្រុកបាសាក់ដែនដីកម្ពុជាក្រោម។ លី កាញ៉ ជាបងបានចាកចេញពីស្រុកកំណើតរបស់ខ្លួន ដើម្បីទៅរស់នៅប្រទេសបារាំង។ ក្រោយមក ដោយការខំប្រឹងប្រែងរកទទួលទានមានបាន លី កាញ់ ក៏

www.elibraryofcambodia.org

ក្លាយជាអ្នកមានទ្រព្យសម្បត្តិ ធនធានបង្គួរនៅប្រទេសបារាំង។

ថ្ងៃមួយ លី សួន ជាប្អូនផ្ញើសំបុត្រទៅសួរសុខទុក្ខ លី កាញ់ ជាបង ហើយក៏បានសុំប្រាក់មួយចំនួនពីបង ដើម្បីប្រកបរបរជំនួញជួញដូរ នៅឯស្រុកកំណើតរបស់ខ្លួន។ លី កាញ់ ក្នុងទឹកចិត្តអាណិតប្អូនក្នុងទឹកចិត្តស្រណោះស្រណោក ស្រុកកំណើតជាទីរលឹករបស់ខ្លួន និងក្នុងស្មារតីចង់ថែរក្សាវប្បធម៌ ពណ៌សម្បុរជាតិរបស់ខ្លួន ដែលស្ថិតក្នុងមជ្ឈដ្ឋានចម្រុះជាតិសាសន៍ឲ្យគង់វង្ស ក៏បានផ្ញើប្រាក់មកឲ្យ លី សួន ជាប្អូន ហើយបានសរសេរសំបុត្រប្រាប់ថា សុំប្អូនកុំធ្វើជំនួញជួញដូរអ្វីក្រៅឲ្យសោះ លុយដែលបងផ្ញើឲ្យនេះ សុំប្អូនគិតយ៉ាងណាជួយពង្រីក និងថែរក្សាសិល្បៈយូរកេ្ត ដែលមានកំណើតនៅឃ្លាំង នៅព្រះត្រពាំង ហើយដែលយើងបានមើលទាំងអស់គ្នាជាញឹកញាប់កាលនៅពីតូចៗ នោះឲ្យគង់វង្សផង។

ដោយសារបណ្តាំ និងជំនួយពី លី កាញ់ ជាបង លី សួន ក៏ក្លាយទៅជាថៅកែល្ខោនបាសាក់ ដ៏ល្បីល្បាញដំបូងគេបង្អស់ ដែលទស្សនិកជននិយមហៅឈ្មោះគាត់ថា ថៅកែ «ឆាគ្រួន»។

*ក្នុងឆ្នាំ១៩៣០ ក្នុងពេលដែលទម្រង់នេះរីកចម្រើននៅកម្ពុជាក្រោម* **«វៀតណាមខាងត្បូង»** *ថៅកែក្រុមល្ខោនឈ្មោះលោកឆាត្រួង នេះ បាននាំក្រុមសិល្បៈល្ខោនរបស់ខ្លួនមកសម្តែងធ្វើអាជីវកម្មនៅភ្នំពេញ និងខេត្តនានាក្នុងប្រទេសកម្ពុជា។ ដំណើរបេសកកម្មទី ១ របស់ក្រុមល្ខោនលោក ឆាត្រួង ដែលបានមកសម្តែងនៅប្រទេសកម្ពុជា មិនសូវទទួលបានជោគជ័យទេ មូលហេតុមកពីទម្រង់ល្ខោននេះត្រូវប្រលងប្រជែងជាមួយទម្រង់ដទៃទៀត ដែលមានយ៉ាងសម្បូរបែបនៅកម្ពុជាភាគកណ្តាល ដូចជាល្ខោនបាមោជ្ជទ័យ* **«១៩២០-១៩៤០»** *និងល្ខោនមហោរី ដែលកើតមានជាយូរលង់មកហើយៗ ពិតមែនតែលើកទី ១ នេះល្ខោនបាសាក់ បានទទួលបរាជ័យ ប៉ុន្តែពេលនោះសិល្បករល្ខោនបាសាក់ បានហាត់*

www.elibraryofcambodia.org

រៀន និងស្រូបយកនូវចំណេះថ្មីៗ មួយចំនួនពីទម្រង់ល្ខោននៅភ្នំពេញ ដូចជាភ្លេងមហោរី ឬចម្រៀងមហោរីជាដើម មុនពេលត្រឡប់ទៅស្រុកវិញ។

ក្រោយពីពេលហាត់រៀន និងបានសម្ដែងច្រើនលើកច្រើនសារ ដោយបញ្ចូលបច្ចេកទេសថ្មីៗ មួយចំនួនផង ល្ខោននេះបានទទួលជោគជ័យ កាន់តែធំធេងនៅតំបន់កូសាំងស៊ីន។ បន្ទាប់ពីនោះមក លោក ធាត្រួង ក៏នាំក្រុមរបស់គាត់តាមទូកប៉ុកចាយ ដែលមានគ្រឿងប្រដាប់ដំឡើងឆាក និងសម្ភារៈតុបតែងលម្អផ្សេងៗគឺឆាកចល័ត ដែលដំឡើងលើគោកក៏បាន ឬដំឡើងលើទូកក៏បាន ហើយនាំក្រុមសិល្បៈនេះមកសម្ដែងនៅរាជធានីភ្នំពេញ និងខេត្តឯទៀតជាលើកទី ២។ លើកនេះល្ខោន លោក ធាត្រួង បានទទួលជោគជ័យយ៉ាងធំធេង ក្នុងការប្រកួតប្រជែងជាមួយល្ខោនបាមាដូទ័យ និងល្ខោនមហោរីនៅភ្នំពេញ និងតំបន់ដទៃទៀតនៅប្រទេសកម្ពុជា ពិសេសគឺខេត្តតាមមាត់ទន្លេៗ ល្ខោនលោក ធាត្រួង នេះស្រូបយកទស្សនិកជនយ៉ាងច្រើនគគ្រឹកគគ្រេង ហើយបានធ្វើឲ្យល្ខោនបាមាដូទ័យនិងល្ខោនមហោរីធ្លាក់ក្នុងវិបត្តិដ៏ធ្ងន់ធ្ងរ បាត់បង់ប្រជាប្រិយភាព ហើយចំនួនទស្សនិកជនចេះតែថយចុះជាលំដាប់ៗ ដោយសារមធ្យោបាយសម្ដែងថ្មី រហ័សរហួនស្វាហាប់ ការតុបតែងលម្អឆាក សម្លៀកបំពាក់ ការលាបមុខ ឬគូរមុខដ៏ល្អ (កន្លែងខ្លះទទួលឥទ្ធិពលពីហ៊ីចិន) ទាំងល្បិចហោះហើរ ក៏ប៉ិនប្រសប់ ពិសេសសំនៀងជើងទាំងសម្ដីនិយាយ ទាំងចម្រៀងរបស់ខ្មែរ បាសាក់ស្រទន់ពីរោះ ហើយពាក្យសម្ដីប្រកបដោយអត្ថន័យខ្លឹមសារល្អ ព្រោះអ្នកសម្ដែងភាគច្រើន ច្រើនជាអ្នកមានចំណេះជ្រៅជ្រះខាងអក្សរសិល្ប៍ និងសាសនាផង ធ្វើឲ្យទស្សនិកជននៅកម្ពុជាកណ្ដាលនេះ ជក់ចិត្តជិតអារម្មណ៍យ៉ាងខ្លាំង រហូតដល់គេនាំគ្នាហៅ ឬឲ្យឈ្មោះទម្រង់ល្ខោននេះថាជា «**ល្ខោនបាសាក់**» ដោយយកទីកន្លែងកំណើតនៃទម្រង់សិល្បៈនេះកែចម្រើន ? មកដាក់ឈ្មោះឲ្យទម្រង់ល្ខោននេះតែម្ដងៗ គឺចាប់ពីពេលនោះមកហើយដែលល្ខោនទ្រើងឃ្លោក ឬយូរគេក៏ប្រែឈ្មោះជាល្ខោនបាសាក់ ដែល

www.elibraryofcambodia.org

យើងស្គាល់ និងបានឃើញរហូតដល់សព្វថ្ងៃនេះ។

ដោយមូលហេតុសេដ្ឋកិច្ច ក្នុងបំណងយកទម្រង់សិល្បៈធ្វើជំនួញ ពួកចៅកែជាច្រើននាក់នៃវង់ល្ខោននៅភ្នំពេញ បានរកវិធីធ្វើឲ្យវង់ល្ខោន លោក ឆា ត្រួង ធ្លាក់ចូលក្នុងវិបត្តិ រលាយក្រុម ហើយការសម្ដែងចុះខ្សោយ ដោយប្រើទឹកលុយទិញ ដោយលួចលាក់នូវសិល្បករពូកែៗ គ្រូល្ខោនពូកែៗ ដើម្បីឲ្យបែកខ្ចាយចេញពីវង់ល្ខោនលោកចៅកែ ឆា ត្រួង ដើម្បីចូលមក ផ្ដល់ចំណេះ និងបម្រើនៅក្នុងក្រុមសិល្បៈរបស់ខ្លួនវិញៗ វង់សិល្បៈល្ខោនបាសាក់របស់លោក ឆា ត្រួង បានជួបប្រទះនឹងវិបត្តិយ៉ាងធំមែន ព្រោះគ្រូធំៗ ដូចជាលោក ត្រូ ខ្មៅ លោក ត្រូ ខ្វា និងមិត្តភក្តិមួយចំនួនដទៃទៀតបានចាកចេញពីក្រុមលោក ឆា ត្រួង ហើយចូលទៅបង្កាត់ចំណេះល្ខោនបាសាក់ទាំងផ្នែកតន្ត្រី ទាំងហ្វូន ទាំងចម្រៀង ទាំងការសម្ដែង ដោយឥតព្រាងទុក ដល់ក្រុមដទៃទៀតៗ ប្រហែលជាចាប់ពីឆ្នាំ ១៩៣៧ នៅរាជធានីភ្នំពេញគេឃើញមានក្រុម និងរោងល្ខោនបាសាក់ជាច្រើនដូចជា រោងមួយនៅផ្សារកាប់គោៗ ខាងលិចរោងនេះមិនឆ្ងាយប៉ុន្មានមានរោងមួយទៀត សង់អំពីឈើដែលគេនិយមឲ្យឈ្មោះថារោងឈើៗ ខាងលិចរោងទី ២ មិនឆ្ងាយប៉ុន្មានមានរោងល្ខោនបាសាក់មួយទៀតសង់អំពីថ្ម ដែលគេនិយមឲ្យឈ្មោះថា រោងស្ពានកូនកាត់ ឬរោងថ្ម **«នៅកន្លែងវិមានឯករាជ្យសព្វថ្ងៃ»** ដឹកនាំដោយអ្នកស្រី ម៉ិះ ញ៉ោៗ រោងមួយទៀតនៅខាងលិចវាំង ជ្រុងខាងត្បូងដែលគេនិយមហៅថារោងសយសន្ធានៗ មួយទៀតរោងផ្សារស្ទួនចាស់ ឬរោងល្ខោនក្ដឹត នៅចំមុខវត្តបទុមវតីៗ រោងផ្សារស៊ីឡឹបដែលដឹកនាំដោយអ្នកម្នាងម្នាក់នៃព្រះរាជា ស៊ីសុវត្ថិមុនីវង្ស គឺអ្នកម្នាងឃុន តាត ឬឃុនព្រះម៉ែ ជាជំបុច្ឆលក្ខណ៍ យិន តាតៗ រោងមួយទៀតនៅតាខ្មៅខេត្តកណ្ដាលៗ ក្រោយពីនោះមក ទើបគេឃើញមានរោងដទៃទៀតជាច្រើនដូចជា រោងគីឡូលេខ ៦ រោងទួលទំពូងនៅចែងខាងជើងវត្តទួលទំពូងសព្វថ្ងៃ រោងទួលគោករោងបាក់ស្រែង និងអ្នកស្រី អ៊ុង ហ៊ង **«នៅម្តុំរោងភាពយន្តចេន

www.elibraryofcambodia.org

ឡ» សព្វថ្ងៃៗពេជផ្កាដេប៉ូ និងពេជដទៃទៀតសម្តែងល្ខោនបាសាក់ជាប្រចាំ ឯពេជភាពយន្តល្ខោនគឹមសឺជនៅខាងលិចផ្សារកណ្តាល និងពេជគឹមគុជនៅខាងត្បូងឈាងខាងលិចផ្សារថ្មីក៏មានសម្តែងល្ខោនបាសាក់ម្តងម្កាលដែរៗគឺចាប់ពីពេលនោះមកហើយ ដែលល្ខោនបាសាក់ចាប់សាយភាយខ្លាំងមែនទែននៅប្រទេសកម្ពុជា តាមរយៈការធ្វើសកម្មភាពទៅមកសម្តែងចុះឡើងៗគ្រប់ទីកន្លែង ហើយមានក្រុមខ្លះបានទៅបោះទីតាំងនៅខេត្ត និងស្រុកនានាបានទៅបង្រៀន និងកសាងក្រុមជាច្រើនតាមមូលដ្ឋានផ្សេងៗគ្នា

ខាងលើនេះជាប្រវត្តិរបស់ល្ខោនបាសាក់ ដែលយើងទទួលពីគ្រូចាស់ៗ និងមិត្តភក្តិខ្មែរមួយចំនួន ដែលស្ថិតនៅភាគខាងត្បូងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសព្វថ្ងៃ អមដោយឯកសារសេរសេរបន្តិចបន្តួច ដែលសេសសល់ពីមុនមក ។ យើងជឿជាក់ថាប្រវត្តិនេះ ប្រាកដជាមិនទាន់បានសុក្រឹត និងលម្អិតនៅឡើយទេ ប៉ុន្តែទោះជាយ៉ាងណាក៏ពអាចជាមូលដ្ឋាន សម្រាប់ពិចារណាខ្លះរបស់បណ្តាអ្នកស្រាវជ្រាវ អ្នកសិក្សាល្ខោន អ្នកស្រលាញ់អក្សរសិល្ប៍ ហើយនិងប្រជាជនមហាជនដែលស្រលាញ់សិល្បៈ វប្បធម៌របស់ប្រជាជនកម្ពុជាយើង ដើម្បីទុកជាទុនមូលដ្ឋានក្នុងការស្វែងយល់តម្លៃពិត រូបពិត ខ្លឹមសារពិត ទម្រង់ពិត និងលក្ខណៈបែបពិតទាំងឡាយនៃទម្រង់ល្ខោនខ្មែរៗ

ម្យ៉ាងទៀត ខ្ញុំបាទក៏សុំជម្រាបផងដែរថា ក្រោយពីពេលដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈត្រូវបានបង្កើតឡើងឆ្នាំ១៩៦៥ ទម្រង់ល្ខោនបាសាក់ក៏ដូចជាទម្រង់សិល្បៈឯទៀតជាច្រើនដែរ ត្រូវបានសាកលវិទ្យាល័យចាត់ឲ្យមានក្រុមចុះធ្វើការសិក្សាស្រាវជ្រាវរៀនសូត្រពីលោកគ្រូ អ្នកគ្រូ សិល្បករអ្នកជំនាញធំៗ ដូចជាលោកតា សាំង សារុជ អ្នកស្រី ចេច ម៉ាច លោកគ្រូ ពៅ លោកគ្រូ ឈាង លោកគ្រូ សាមិត ជាដើមៗលៗ មិនតែប៉ុណ្ណោះ សាកលវិទ្យាល័យបានអញ្ជើញលោកគ្រូ ឪតាឡៅ ដែលមានទេពកោសល្យអាចសម្តែងជាតួឯក ជាតួយក្ស ឬជាតួកមក

បរទេស និងជាគ្រូប្រចាំនៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រថែមទៀតផង។

ក្រោយពីបានសិក្សារៀនសូត្រភ្លេង ចម្រៀងក្បាច់ហួនបាសាក់ និងរបៀបសម្ដែងបានត្រឹមត្រូវ ហើយក្រុមនិស្សិតផ្នែកល្ខោនបាសាក់ ក្នុងស្មារតីរក្សាទម្រង់មិនឲ្យឃ្លាតឆ្ងាយប្រាសចាកភាពដើម និងដោយមានជំនួយពីគ្រូចាស់ៗ ក៏សាកល្បងដំឡើងរឿងមួយចំនួន ដោយរឿងដែលត្រូវសម្ដែង ត្រូវសរសេរជារឿងល្ខោនដែលមានពាក្យសម្ដីត្រឹមត្រូវ ហើយដែលត្រូវឲ្យសិល្បករអ្នកសម្ដែងទន្ទេញចាំយ៉ាងស្ទាត់ជាមុន ព្រមដោយមានការដឹកនាំរឿងត្រឹមត្រូវផង ពោលគឺធ្វើឲ្យមានលក្ខណៈ **«រៀបរយ»** នៅក្នុងការសម្ដែងដោយរក្សាអន្ទើបរិយាកាស សប្បាយរីករាយ ឬកម្សត់ព្រាត់ប្រាស ឬក៏អន្ទើកំប្លុកកំប្លែងទៅតាមដំណើរនៃសាច់រឿងមិនឲ្យរំខានគ្នាឡើយ។

ក្នុងការសាកល្បងធ្វើឲ្យមានលក្ខណៈ **«រៀបរយ»** សម្រាប់ទម្រង់ល្ខោនបាសាក់នេះ ក្រោយពីបានសម្ដែងនៅទូទាំងប្រទេសជាញឹកញាប់ ឃើញថាបានលទ្ធផលគួរជាទីពេញចិត្ត ដ្បិតយើងអាចទាក់ទាញបាន ឬតម្រូវបាននូវទឹកចិត្តរបស់ទស្សនិកជនគ្រប់មជ្ឈដ្ឋាន គឺអ្នកស្រែចម្ការ អ្នកផ្សារ សិស្ស និស្សិត បញ្ញវន្តជាច្រើនផង។

ចំណែកឯក្រុមសិល្បៈល្ខោនបាសាក់នៅតាមរោងនានាក្នុងទូទាំងប្រទេស គឺនៅរក្សារបៀបសម្ដែងបែបបុរាណដូចមុន ពោលគឺរបៀបសម្ដែងដោយឥតព្រាងទុកដដែល។

www.elibraryofcambodia.org

# ៨-ល្ខោនមហោរី



www.elibraryofcambodia.org

## ប្រវត្តិល្ខោនមហោរី

ល្ខោនមហោរី គឺជាទម្រង់ល្ខោនច្រៀង រាំបែបបុរាណនៅប្រទេសកម្ពុជា។ ពាក្យថា មហោរីនេះ គឺជាឈ្មោះវង់តន្ត្រីមួយរបស់ជនជាតិខ្មែរយើង ដែលជាប្រភេទតន្ត្រីសំឡេងស្រាល សម្រាប់ប្រគុំកំដរបរិយាកាស សប្បាយរីករាយក្នុងពិធីជួបជុំកែកម្សាន្តនានា មានពិធីជប់លៀង ឬពិធីបុណ្យតាមគ្រួសារ ពិធីបុណ្យក្នុងស្រុកភូមិ ឬឱកាសលំហែពីការងារជាដើម។

បើតាមការសិក្សាស្រាវជ្រាវរបស់ក្រុមអ្នកស្រាវជ្រាវផ្នែកតូរ្យតន្ត្រីបានឲ្យដឹងថា វង់តន្ត្រីមហោរីនេះមានអាយុច្រើនសតវត្សរ៍ណាស់មកហើយ នៅក្នុងប្រទេសកម្ពុជាយើងនេះ ហើយពាក្យមហោរីនេះអាចក្លាយមកពីពាក្យសំស្ក្រឹតថា មនោហារ (ប្រុស) ឬមនោហារី (ស្រី) ដែលសុទ្ធតែជាអ្នកបម្រើដំណាប់ព្រះទ័យខាងប្រគុំតន្ត្រី និងចម្រៀងថ្វាយព្រះអាទិទេព នៅក្នុងប្រាសាទនានា ដែលគេឃើញមានចារនៅក្នុងសិលាចារឹកជាច្រើន តាំងពីពេលមិនទាន់កសាងប្រាសាទអង្គរវត្តមកម៉្លេះ។

ចំណុចគួរឲ្យគត់សម្គាល់មួយគឺពាក្យថា មនោហារ- រី -រីកា «ដែលគួរឲ្យជក់ចិត្ត ជិតអារម្មណ៍ ពីរោះ គួរឲ្យចង់ស្តាប់ និងចង់គយគន់»។ ឈ្មោះសិល្បៈករដ៏មានប្រជាប្រិយភាពមិនត្រូវបានគេគត់ត្រាទុកក្នុងសម័យទំនើបនេះឡើយ។ ទោះជាយ៉ាងណា ក្រោយសម័យអង្គរពាក្យធម្មតាមួយត្រូវបានគេរក្សាទុក គឺទម្រង់មនោហារី សរសេរកាត់មកជា «មហោរី» ដើម្បីសម្គាល់ពីប្រភេទតន្ត្រីព្រះរាជទ្រព្យ ដ៏គួរឲ្យរីករាយ ទន់ភ្លន់ រំភើប សម្រាប់កម្សាន្តសប្បាយនាពេលឈប់សម្រាក។ មហោរី ដែលពីមុនមកត្រូវបានប្រើសម្រាប់កម្សាន្តសម្រាប់ក្រុមរាជវង្សបន្តិចម្តងៗបានរំកិលខ្លួនចេញពីរាជវាំង និងរាជដំណាក់ផ្សេងៗទៀតដើម្បីចូលខ្លួនមកបម្រើប្រជារាស្ត្រសាមញ្ញ ឲ្យមានភាពសប្បាយរីករាយរហូតដល់បច្ចុប្បន្ន។

អ្វីទាំងអស់ខាងលើនេះ បានរៀបរាប់អំពីប្រពៃណី មកជាហូរហែរនៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេស ដែលគ្មានការបែងចែករពងធម្មជាតិ និង

www.elibraryofcambodia.org

អភិធម្មជាតិ រោងសាសនា និងអភិនិហា និងរោងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ព្រមទាំងជាទីដែលមនុស្សគួរជាទីគោរពតែងតែមានកន្លែងសម្រាប់បង្ហាញសម្ផស្ស និងសេចក្តីស្រឡាញ់ ក្នុងទម្រង់ដែលគេមិនអាចឃើញបានទោះបីជាឥឡូវ ឬពីមុនក៏ដោយៗ

ចំណែកខាងល្ខោនមហោរីវិញ ដែលជាទម្រង់ល្ខោនមួយបែប ដែលមានសិល្បករចម្រុះស្រី-ប្រុស រាំផង ច្រៀងផង និយាយផង ក្នុងពេលសម្តែង និងដោយសារទម្រង់នេះពឹងផ្អែកទាំងស្រុង លើវង់តន្ត្រីមហោរីពោល គឺយកវង់តន្ត្រី និងចម្រៀងមហោរីកប់ពេយបទ ជាមធ្យោបាយគ្រឹះរបស់ខ្លួន ក្នុងការសម្តែងនោះ ទើបទស្សនិកជនហៅឈ្មោះនេះថា ល្ខោនមហោរីរហូតមកៗ

បើតាមប្រសាសន៍គ្រូល្ខោនចាស់ៗនៅប្រទេសខ្មែរបានពោលថា ល្ខោនមហោរីនេះក៏មានកំណើតតាំងពីច្រើនសតវត្សរ៍មកហើយដែរ ប៉ុន្តែទម្រង់នេះក៏ដូចជាទម្រង់សិល្បៈឯទៀតខ្លះ បានជួបវិបត្តិរេរោយ ចុះទៅតាមដំណើរវិវឌ្ឍន៍ដ៏ពិបាកនៃប្រវត្តិសាស្ត្រជាតិកម្ពុជា ក្នុងដំណាក់កាលខ្លះៗ ដោយឡែកចាប់ពីអំឡុងឆ្នាំ១៩២៩ ឬ ១៩៣០ មក ល្ខោនមហោរី ក៏ដូចជាទម្រង់ល្ខោនខ្លះទៀតដែលមាននៅតាមរោងនានា នៅរាជធានីភ្នំពេញនេះ បានជួបវិបត្តិជាបន្តបន្ទាប់ៗ ដោយក្នុងកាលៈទេសៈនោះ ល្ខោនមហោរីត្រូវប្រឈមមុខជាមួយនឹងល្ខោនបាសាក់ៗ ក្នុងគ្រោះវិបត្តិនេះ ពីមួយថ្ងៃទៅមួយថ្ងៃទម្រង់ល្ខោនមហោរី កាន់តែសាបរលាបទៅៗ រហូតស្ទើរបាត់រូបតែម្តងៗ

ប៉ុន្តែ ក្នុងអំឡុងឆ្នាំ ១៩៦៥-៦៦ លោកសាស្ត្រាចារ្យ មាស គគា លោកសាស្ត្រាចារ្យចេង ផុន លោកសាស្ត្រាចារ្យ ប៉ុលសំអឿន ដែលសុទ្ធជាសាស្ត្រាខាងវិជ្ជាល្ខោន បានលើកយកអន្ទើមួយនៃរឿងថ្នាំ ដែលនិពន្ធដោយសាស្ត្រាចារ្យហង់ ជួនហាក់ មករៀបរៀងជាល្ខោនមហោរី ដែលរួមសម្តែងដោយលោកឈង ធត (ពេជ្រ ជុំក្រាវ៉ុល) និងអ្នកស្រី អ៊ុំ មណ្ណាៗ

www.elibraryofcambodia.org

គឺដោយសារមេរៀនដ៏តូច និងមានសារៈសំខាន់នេះហើយ ដែលល្ខោនមហោរីបានចាប់កំណើតជាថ្មីឡើងវិញ ហើយបង្ហាញខ្លួននៅចំពោះមុខភ្នែកទស្សនិកជនជាតិ និងអន្តរជាតិ សារជាថ្មីដោយអ្នកនិពន្ធបន្តវេនបានធ្វើការសិក្សាស្រាវជ្រាវបន្ថែម ហើយបាននិពន្ធ និងរៀបរៀងរឿងជាច្រើន ក្នុងរូបភាពទម្រង់ល្ខោនមហោរី នេះមានជាអាទិ៍÷

- រឿងវិប្បដិសារីនៃព្រានព្រៃ និពន្ធដោយលោក (ពេជ្រ ជុំត្រាវ៉ុល)
- រឿងប្រហែសបាត់ប្រយ័ត្នគង់ និពន្ធដោយលោក (ពេជ្រ ជុំត្រាវ៉ុល)
- រឿងមិនខ្វះទេអ្នកស្រលាញ់យុត្តិធម៌ និពន្ធដោយលោក (ពេជ្រ ជុំត្រាវ៉ុល)
- រឿងតេមិយកុមារ រៀបរៀងដោយលោក (ពេជ្រ ជុំត្រាវ៉ុល)
- រឿងសុវណ្ណសាម រៀបរៀងដោយលោក (ពេជ្រ ជុំត្រាវ៉ុល)

ព្រមទាំងមានរឿងខ្លះៗទៀត ដែលជាស្នាដៃរបស់មិត្តភក្តិលោកក្នុងជំនាន់នោះផងៗ

គេសង្កេតឃើញមានវត្តមានទម្រង់ល្ខោនមហោរីនេះ រហូតដល់រយៈកាលសង្គ្រាមស៊ីវិលដ៏កាចសាហាវនាឆ្នាំ ១៩៧០ បានចាប់ផ្តើមឡើង ឬក្រោយពេលនោះបន្តិចផងនៅរាជធានីភ្នំពេញៗ ឥឡូវនេះវិញ (២០០៣) គេបានជួបប្រទះ ឬទស្សនាទម្រង់ល្ខោននេះដោយកម្រ ពោលគឺទម្រង់ល្ខោនមហោរីនេះ ក៏កំពុងតែត្រូវគំរាមកំហែង ធ្វើដំណើរទៅរកផ្លូវបាត់បង់ផងដែរ ៕

# ៩-ល្ខោនតាំណាព្យ



www.elibraryofcambodia.org

## ប្រវត្តិល្ខោនកាំណាព្យ

ល្ខោនកំណាព្យ គឺជាទម្រង់ល្ខោនមួយនៅកម្ពុជា ហើយទម្រង់នេះ ទើបតែកើតឡើងជារូបរាងច្បាស់លាស់នៅក្នុងសង្គមកម្ពុជានេះប្រហែល ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស (១៩២៧-១៩៤០) ប៉ុណ្ណោះឯង។

បើតាមព័ត៌មានដែលយើងទទួលបាន រហូតមកដល់អំឡុងឆ្នាំ ១៩៣០ ឬក្រោយនោះបន្តិច គឺពេលដែលល្ខោនបាសាក់បានធ្វើឲ្យទស្សនិកជន ជាទូទៅចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមិនត្រឹមតែទស្សនិកជនធម្មតាប៉ុណ្ណោះទេ ដែលជក់ចិត្តជិតអារម្មណ៍នឹងល្ខោនមកពីតំបន់បាសាក់នេះ សូម្បីតែអ្នកនិពន្ធ ឬអ្នកដឹកនាំរឿងល្ខោនតាមរោងនានានៅក្រុងភ្នំពេញ ដូចជារោងថ្មស្ពានកូនកាត់ជាដើម ក៏រំភើបអារម្មណ៍ណាស់ដែរ។

ក្នុងគោលបំណងជំរុញក្រុមល្ខោនខ្លួនឲ្យឡើងទៅរកកម្រិតខ្ពស់មួយ ដើម្បីប្រណាំងប្រជែងជាមួយល្ខោនបាសាក់ ដែលបានទទួលជោគជ័យធំធេងក្នុងពេលនោះ អ្នកនិពន្ធទាំងនេះបានសាកល្បងនាំគ្នាសរសេររឿងល្ខោន ជាកំណាព្យសុទ្ធយកមកសម្តែង។ ប៉ុន្តែរឿងល្ខោនបែបនេះ មិនសូវទទួលបានជោគជ័យទេ ព្រោះការនិយាយឆ្លងឆ្លើយ ជាកំណាព្យកាព្យឃ្លោងសុទ្ធយ៉ាងនេះហាក់ដូចជាខ្ពស់ផុតពីកម្រិតយល់ដឹង ឬចំណង់ចំណូលចិត្តរបស់ទស្សនិកជនសាមញ្ញធម្មតា (ទស្សនិកជនភាគច្រើន)។

ពិតមែនតែមិនសូវទទួលបានជោគជ័យធំធេងមែន តែទម្រង់ល្ខោនកំណាព្យនេះបានធ្វើដំណើរទៅមុខសន្សឹមៗ ដោយមានការគាំទ្រ ពីទស្សនិកជនមួយចំនួនធំដែរ ពិសេសគឺក្នុងចំណោមបញ្ញាជននានា។ រហូតមកដល់ពេលដែលសាលាល្ខោនជាតិ បានត្រូវបើកទ្វារឡើងនៅឆ្នាំ ១៩៥៩ គេសង្កេតឃើញមានអត្ថបទល្ខោនកំណាព្យកាន់តែមានកម្រិតខ្ពស់ឡើង ដូចជារឿងដើមធ្លករក្សាជាតិជាដើមដែលនិពន្ធជាកំណាព្យដ៏ល្អ (មិនមែនគ្រាន់តែជាកំណាព្យសម្រាប់អានទេ ប៉ុន្តែជា

www.elibraryofcambodia.org

ប្រភេទកំណាព្យសម្រាប់និយាយ) មានសម្ផស្ស និងសោភ័ណគួរឲ្យគាត់សរសើរៗ

ឆ្នាំ១៩៦៥ ពេលដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានកើតឡើង មុខវិជ្ជាកំណាព្យ ត្រូវបានដាក់ឲ្យសិក្សារៀនសូត្រ ទាំងរបៀបសរសេរ ទាំងរបៀបសូត្រ នៅក្នុងកម្មវិធីរបស់មហាវិទ្យាល័យសិល្បៈនាដសាស្រ្តៗ ប្រវត្តិកំណាព្យមានដូចតទៅនេះ ៖

-បើយើងពឹងផ្អែកលើបទភ្លេង និងទំនុកច្រៀង នៃវង់ភ្លេងអារក្ខ ដែលក្រុមអ្នកស្រាវជ្រាវតន្ត្រីខ្មែរយល់ថា ជាវង់ភ្លេងខ្មែរដែលកើតមុនគេ ដូចគ្នានឹង **«គ្រឿងដំតន្ត្រីគងកាប់ក្របីរបស់បងប្អូនជនជាតិ»** ដែរនោះ ជាតន្ត្រីសម្រាប់ប្រើពិធីផ្សេងៗបូជា អារក្ខ អ្នកតា ដែលជាជំនឿរបស់ខ្មែរដើម ហើយដែលកើតមានតាំងពីមុនសម័យ ដែលព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាហូរចូលមកកម្ពុជា «៣០៩ ឆ្នាំមុន គ.ស» ម្ល៉េះៗ

-ម្យ៉ាងទៀត បើយើងពឹងផ្អែកលើទំនុកច្រៀង បទភ្លេងនៃវង់ភ្លេងប្រពៃណី (ភ្លេងការ)ដែលក្រុមអ្នកស្រាវជ្រាវយល់ថា កើតមានតាំងពីសតវត្សរ៍ទី ១ នៃគ្រិស្តសករាជ គឺក្នុងពេលដែលរៀបអាពាហ៍ពិពាហ៍ព្រះថោង និងនាងនាគ (ហ៊ុនទៀន និងនាងលីវយី ឬព្រាហ្មណកៅណ្ឌិន្យ និងព្រះនាងសោមាកូនព្រះចន្ទ) ហើយដែលមានបទមួយចំនួនទាក់ទងនឹងប្រវត្តិសាស្រ្ត ដូចជាបទព្រះថោង បទនាងនាគ បទនាគព័ន្ធ ជាដើមៗលៗ យើងឃើញថាកំណាព្យដែលកើតមានមុនគេ គឺបទមេបួន ដែលក្នុងមួយល្បះខណ្ឌមាន ៤ ឃ្លា ក្នុងមួយឃ្លាមាន ៤ ព្យាង្គស្មើគ្នាៗ

រហូតមកដល់ចុងសតវត្សរ៍ទី ៦ ដើមសម័យចេនឡា ទើបយើងឃើញមានមរតកកំណាព្យមួយបទទៀត កើតឡើងឈ្មោះបទបថ្យាវត្ត គឺមួយល្បះមាន ៤ ឃ្លា ហើយក្នុងមួយឃ្លាមាន ៨ ព្យាង្គ ប៉ុន្តែការចាប់ចុងចួនមិនដូច បទពាក្យ ៨ ដែលកើត

www.elibraryofcambodia.org

សម័យក្រោយៗ

នៅក្នុងរឿងកាមកេរ្តិ៍ ពីខ្សែ ១ ដល់ខ្សែ ១០ ដែលកើតមាននៅសម័យអង្គរ គេឃើញមានទម្រង់កំណាព្យ ៥ បទ ទៀតកើតឡើងគឺ **បទកាកគតិ** ដែលក្នុងមួយល្បះខណ្ឌមាន ៧ ឃ្លា និងក្នុងមួយឃ្លាមាន ៤ ព្យាង្គស្មើគ្នាៗ

- **បទព្រហ្មគីតិ** មួយល្បះមាន ៤ ឃ្លា-ឃ្លាទី ១ មាន ៥ ព្យាង្គ ឃ្លាទី ២ មាន ៦ ព្យាង្គ ឃ្លាទី ៣ មាន ៥ ព្យាង្គ និងឃ្លាទី ៤ មាន ៦ ព្យាង្គៗ
- **បទពំនោល** ក្នុងមួយល្បះមាន ៣ ឃ្លាៗ ឃ្លាទី ១ មាន ៦ ព្យាង្គ ឃ្លាទី ២ មាន ៤ ព្យាង្គ និងឃ្លាទី ៣ មាន ៦ព្យាង្គៗ
- **បទបន្ទោលកាក** មួយល្បះមាន ៤ ឃ្លា ឃ្លាទី ១ មាន ៤ ព្យាង្គ ឃ្លាទី ២ មាន ៦ ព្យាង្គ ឃ្លាទី ៣ មាន ៤ ព្យាង្គឃ្លាទី ៤ មាន ៦ ព្យាង្គៗ
- **បទភុជង្គលីលា** មួយល្បះមាន ៣ ឃ្លា : ឃ្លាទី ១ មាន-៦ ព្យាង្គ ឃ្លាទី ២ និងទី ៣ មាន ៤ ព្យាង្គៗ

ទម្រង់កំណាព្យទាំង ៥ ខាងលើ មានតាំងពីសម័យអង្គរមកម្ល៉េះ ប៉ុន្តែគេពុំទាន់ឃើញប្រើឈ្មោះនៅឡើយៗ រហូតមកដល់សតវត្សរ៍ទី ១៥ ឆ្នាំ «១៤៩៨» ក្នុងល្បើក **អង្គរវត្ត-អ្នកបាំង** ទើបកំណាព្យដដែលនេះ មានប្រើឈ្មោះជាកាកគតិ ព្រហ្មគីតិ ពំនោល បន្ទោលកាក និងភុជង្គលីលាៗ

នៅក្នុងរឿងកាមកេរ្តិ៍ ពីខ្សែ ៧៥ ដល់ ៨០ ដែលជាស្នាដៃបន្ត ហើយដែលអ្នកស្រាវជ្រាវអក្សរសាស្ត្រជាតិយល់ថា ជាស្នាដៃកើតក្រោយសម័យអង្គរ ឬក៏ក្រោយពេលជ្រួលច្របល់ចលាចល ព្រោះសៀមលុកលុយក្រុងអង្គរនោះ គេឃើញមានកំណាព្យថ្មីមួយទៀត គឺបទពាក្យ ៦ ដែលក្នុងមួយល្បះមាន ៤ ឃ្លា ក្នុងមួយឃ្លាមាន ៦ ព្យាង្គស្មើគ្នាៗ

មកដល់សម័យចតុមុខ ចាប់ពីពេលដែលព្រះចៅពញាយ៉ាត ប្តូររាជធានីពីអង្គរមកតាំងនៅស្រីសន្ធរ រួចមកភ្នំពេញ និងការផ្លាស់ប្តូរទីក្រុង ចុះឡើងពីភ្នំពេញ

www.elibraryofcambodia.org

ទៅលំនាំកំពីលំនាំកទៅឧត្តុង្គ និងកន្ទួងផងទៃជាច្រើនទៀតរហូតដល់សម័យព្រះបាទនរោត្តមបូរទីក្រុងឧត្តុង្គមកភ្នំពេញដល់សព្វថ្ងៃនេះ គេឃើញមានកំណាព្យជាច្រើនទៀតបានកើតឡើង

- បទពាក្យ ៧
- បទពាក្យ ៨
- បទពាក្យ ៩
- បទពាក្យ ១០
- បទពាក្យ ១១

ហើយមានបទច្រើនទៀត ដែលមានរបៀបសរសេរបំភ្លៃចេញពីបទទាំងឡាយខាងក្រោយនេះដូចជា៖

| | | |
|---|---|---|
| បទនរោ | បទក ខ | បទអក្សរលេន |
| បទអក្សរសន្ធាស | បទកន្តែបលោតស្ទាក់ពេជ្រ | |
| បទកន្តែបលោតផ្ចាត់ខ្មៅ | | បទនាគបរិព័ន្ធ |
| បទនាគគៀវក្រវាត់ | បទនាគរាជប្តូរបុទ្ធ | បទគោព័ន្ធស្នឹង |
| បទសិង្ហតោលេងកន្ទុយ | បទមាំងដើរព្រៃ | បទផ្កាឈូករីក |
| បទក្របចក្រវាល | បទម្ភូរខ្វាក់កែវ | បទឆត្របីជាន់ |
| បទលេកយោលយារ | បទលេកខ្ទប់ច្រាំង | បទសហភ |
| បទវិវិធមាលី | បទពស់លេបកន្ទុយ | បទថយក្រោយចូលព្រែក |
| បទសត្វកាងស្ទាប | បទមាំងបើកបាស | បទទន្សាយ ទឹសទាស |
| បទមាន់ទឹកបណ្តើរកូន | បទសារថីទាញរថ | បទអើយរ៉ា |
| បទត្រឡាចឡើងច្រើង | បទសុក្រទិនវិសាល | បទសោរទិនវិសាល |
| បទយត្តិភង្គ | បទសបាត់សប៉ុង | បទដាប់ទង |
| បទត្រីពិធពន្ធ | បទសឡាបលួន | បទវង្សវិចិត្រ |

www.elibraryofcambodia.org

និងព្រះចន្ទបាំងឆត្រៗ

## សង្ខេប

មុនគេ ១-បទមេបួន

សម័យមុនអង្គរ ២-បទថ្យាវត្ត

សម័យអង្គរ ៣-បទកាកគតិ

៤-បទព្រហ្មគីតិ

៥-បទពំនោល

៦-បទបន្ទោលកាក

៧-បទភុជង្គលីលា

សម័យចុងក្រោយអង្គរ ៨-បទពាក្យ ៦

សម័យចតុមុខ ៩-បទពាក្យ ៧

១០-បទពាក្យ ៨ ១១-បទពាក្យ៩ ១២-បទពាក្យ១០

១៣-បទពាក្យ ១១ ១៤-បទ ក ខ ១៥-បទនមោ

១៦-បទអក្សរល្បួន ១៧-អក្សរសង្វាស

១៨-បទកង្កែបលោតកណ្ដាលស្រះ ១៩-កង្កែបលោតលើគោក

២០-កង្កែបលោតស្ទាក់ពេជ្រ ២១-កង្កែបលោតផ្ទាត់ខ្ទាំ

២២-នាគបរិព័ន្ធ ២៣-នាគគៀរក្រពត់ ២៤-នាគកាជវែប្ងឫទ្ធិ

២៥-គោព័ន្ធស្ទឹង ២៦-សិង្ហគោលេងកន្ទុយ ២៧-មាន់ដើរព្រៃ

២៨-ផ្កាឈូករីក ២៩-ក្របចក្រពាឡ ៣០-ម្កុរខ្នាក់កែវ

៣១-ឆត្របីជាន់ ៣២-លេកយោលយារ ៣៣-លេកខ្ទប់ច្រាំង

៣៤-សហភ ៣៥-វិវិធមាលី ៣៦-ពស់លេបកន្ទុយ

៣៧-សត្វកាងស្លាប ៣៨-ថយក្រោយចូលព្រែក ៣៩-មាន់បើកបាស

www.elibraryofcambodia.org

៤០-ទន្សាយទីសទាស ៤១-មាន់ទឹកបណ្ដើរកូន ៤២-សារថីទាញរថ
៤៣-អើយពាំ ៤៤-សុក្រទិនវិសាល ៤៥-សៅរ៍ទិនវិសាល
៤៦-ត្រឡាចឡើងច្រើន ៤៧-យក្ខិកក្ដី ៤៨-ដាប់ទង
៤៩-សបាត់សបឹង ៥០-ត្រីពិធពន្ធ ៥១-សឡាបលូន
៥២-វង្សវិចិត្រ ៥៣-ព្រះចន្ទបាំងធត្រៗ

## ទំនាក់ទំនងរវាងកំណាព្យ និងទម្រង់សិល្បៈដទៃទៀត

បើយើងសង្កេត មើលស្នាដៃផ្នែកអក្សរសាស្ត្រ ដែលបុព្វបុរស ដូនតាយើងបាន បន្សល់ទុកដល់យើងសព្វថ្ងៃនេះ យើងនឹងឃើញភ្លាមថា ភាគច្រើនសុទ្ធតែ កំណាព្យកាព្យឃ្លោង ដូចជារឿងរាមកេរ្តិ៍ ទុំទាវ ទិព្វសន្ធារ កាកី ច្បាប់ប្រុសច្បាប់ ស្រី ច្បាប់កេរ្តិ៍កាល ច្បាប់ក្រម ល្បើកផុច និងត្រី ។ល។ នេះជាសក្ខីភាពបញ្ជាក់ អំពីវិធីសាស្ត្រអប់រំបែបបុរាណរបស់ដូនតាយើង ដែលយករូបភាពកំណាព្យ **«ពីរោះ ត្រចៀក»** ជាមធ្យោបាយ ដើម្បីងាយស្រួលបញ្ចូលខ្លឹមសារនៃការអប់រំទូន្មាន ទាំងឡាយ ដែលលោកចង់បានឲ្យទាក់ជាប់ក្នុងសតិអារម្មណ៍ របស់កុលបុត្រ កុលធីតាខ្លួនៗ

នៅក្នុងសង្គមកម្ពុជាយើង កំណាព្យមានឥទ្ធិពលធំណាស់ៗ ក្រៅពីការរស់ និង បំពេញតួនាទីដោយឯកឯង (ស្មូត្រ ឬសូត្រកំណាព្យ) កំណាព្យបានជះឥទ្ធិពលនិង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត ជាមួយនឹងទម្រង់សិល្បៈដទៃទៀតរបស់ខ្មែរ យើងដូចជា ភ្លេងអារក្ខ ភ្លេងប្រពៃណី «ភ្លេងការ» របាំប្រពៃណី របាំបុរាណ ល្ខោនស្រមោល (ស្បែកធំ-ស្បែកតូច) ល្ខោនខោល (ល្ខោនពាក់មុខ) យីកេ អាយ៉ៃ ល្ខោនមហោរី ល្ខោនបាសាក់ អាយ៉ៃ ចាប៉ីៗល។

ទម្រង់សិល្បៈទាំងអស់នេះ ត្រូវការកំណាព្យជាចាំបាច់ សម្រាប់ជួយកម្រិត ទម្រង់ ជួយលើកសម្ផស្ស និងសោភ័ណរបស់ខ្លួនៗ

www.elibraryofcambodia.org

ចំពោះអ្នកសិក្សាទម្រង់សិល្បៈខ្មែរវិញ កំណាព្យក៏ជាកត្តាមួយសំខាន់ក្នុងកត្តាច្រើនទៀត ដែលជួយបញ្ជាក់អំពីចំណាស់ និងទម្រង់សិល្បៈនីមួយៗ ផ្ទុយទៅវិញទម្រង់សិល្បៈដទៃទៀត ក៏បានជះឥទ្ធិពលធំធេងដែរ សម្រាប់បញ្ជាក់អំពីចំណាស់នៃកំណាព្យនីមួយៗរបស់យើង។ ដូច្នេះ បើចង់សិក្សាកំណាព្យខ្មែរគួរសិក្សាពីទម្រង់សិល្បៈខ្មែរដទៃទៀតផង ហើយបើចង់សិក្សាពីទម្រង់សិល្បៈដទៃទៀតមិនអាចបោះបង់ចោលកំណាព្យបានដែរ។

ឯរបៀបសូត្រវិញ ក៏មានច្រើនបែបទៅតាមលក្ខណៈបទកំណាព្យនីមួយៗ និងតាមមនោសញ្ចេតនាខុសៗគ្នា ដែលយោងទៅតាមអត្ថន័យ របស់អត្ថបទកំណាព្យនីមួយៗកំណត់ឲ្យ។ គឺចាប់ពីនោះមក ហើយដែលអ្នកនិពន្ធ និងអ្នកដឹកនាំរឿងល្ខោន បានបញ្ចូលមធ្យោបាយថ្មី គឺការសូត្រកំណាព្យនេះទៅក្នុងទម្រង់ល្ខោនកំណាព្យដែលពីពេលមុនច្រើនមានតែត្រឹមពាក្យសម្តីនិយាយសុទ្ធនោះ ហើយមានបន្ថែមសំឡេងឧបករណ៍តន្ត្រីទោល មួយចំនួនដូចជា ខ្សែជៀវ ខ្លុយ ឬទ្រ ប្រគំកំដរ ឬប្រគំជូនការសូត្រកំណាព្យ ក្នុងសាច់រឿងនោះថែមទៀតផង។

ឯរឿងដែលធ្លាប់លើកយកមកសម្តែង មានច្រើន ដូចជារឿងកាកី ច្រើនតែស្រង់យកអន្ទើ នាងកាកីត្រូវមានទោសបណ្តែតពោងពាយ ដែលមានការតុបតែងលម្អឆាក ដោយយកកូនគ្រែមួយតូចដាក់កង់តូចៗ ដែលអាចទាញឲ្យរអិលបន្តិចៗបាននៅលើឆាក ធ្វើជាពោងពាយឲ្យនាងកាកីជិះ ហើយនៅពីខាងមុខគ្រែនោះប្រើក្រណាត់សំពត់ពណ៌ទឹកសមុទ្រ យ៉ាងវែងរលាស់ធ្វើជារលកសមុទ្រ។ នៅលើពោងពាយកណ្តាលសមុទ្រ នាងកាកីសូត្រកំណាព្យបទព្រហ្មគីតិ (បែបទំនួញ) ទួញសោកស្តាយពីកំហុសរបស់ខ្លួន និងការភ័យខ្លាចរបស់នាង។

រឿងព្រះរាជសម្ភារ (១៦២៩-១៦៣៤) ជាព្រះរាជាខ្មែរមួយអង្គ ដែលទ្រង់ជាកវីនិពន្ធដ៏ឆ្នើម តែមានវិបត្តិក្នុងជីវិត ដោយសារទំនាស់រឿងស្នេហា ព្រោះព្រះអង្គនៅតែស្រលាញ់ព្រះអង្គម៉ែយួរចន្ទវតី ដែលជាអតីតគូផ្សំផ្គុំរបស់ព្រះអង្គពីក្មេង

www.elibraryofcambodia.org

ហើយបានក្លាយទៅជាប្រពន្ធរបស់ឪពុកមា គឺព្រះឧទ័យរួចទៅហើយ ទីបំផុតនៃទំនាស់ស្នេហានេះព្រះអង្គត្រូវទទួលគ្រោះដល់ក្ស័យព្រះជន្ម ។ ផ្ទាំងរឿងនេះច្រើនប្រើការតុបតែងលម្អឆាកបែបនិម្មិត ដូចជាយកជាងត្នោតមួយជាងតូចទៅចងភ្ជាប់នឹងក្តារកំណល់ មួយនិម្មិតដើមត្នោត) ហើយឱ្យតួអង្គព្រះរាជសម្ភារ សម្តែងមនោសញ្ចេតនា មានវិប្បដិសារីនឹកអំពើឆ្គាំឆ្គងរបស់ខ្លួន ដែលបានប្រព្រឹត្តិធ្ងន់ផុតមក រួចតោងឡើងលើដើមត្នោត ដកកាំបិតស្នៀតពីចង្កេះ កាត់កំពូលត្នោតចារបណ្តាំចុងក្រោយ ចំពោះមនុស្សជាតិទូទៅកុំឱ្យធ្វើខុសដូចព្រះអង្គទៀត។ ព្រះអង្គសូត្រកំណាព្យបទកាកគតិ **«សាធុសម្មាយ»** សូត្រជា (បែបពិលាប) លុះដល់ចប់បណ្តាំចុងក្រោយនេះ ពួកទាហានព័ទុយហ្គេ ដែលជាទាហានខាងព្រះបិតុលា (ស្តេចមា) គឺព្រះឧទ័យក៏បាញ់ព្រះអង្គ ធ្លាក់ពីលើចុងត្នោតសុគតទៅ។ល។

តាំងពីរបបប្រល័យពូជសាសន៍ បានបំផ្លាញខ្ទេចខ្ទីពីឆ្នាំ (១៩៧៥-១៩៧៩) មក ទម្រង់ល្ខោនកំណាព្យ នេះបានបាត់មុខជារៀងរហូត។

លុះមកដល់ឆ្នាំ ២០០១ ក្នុងទិវាវប្បធម៌ ៣ មេសា ទើបគណៈកម្មការស្រាវជ្រាវវប្បធម៌ ដែលមានលោក ពេជ្រ ជុំគ្រាវិល ជាប្រធានសហការជាមួយអង្គការ UNESCO បានលើកយករឿងមហាភារតយុទ្ធ ដែលជាទេវកថាបង្ហាញពីមហិទ្ធិឫទ្ធិព្រះនារាយណ៍ ដែលមានរូបចម្លាក់យ៉ាងច្រើននៅប្រាសាទអង្គរវត្ត ដែលសាងឡើងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ ហើយដែលបានរៀបរៀងជាល្ខោនកំណាព្យ និងដឹកនាំរឿងដោយលោក ចិន ជាត យកមកសម្តែងជូនភ្ញៀវជាតិ និងអន្តរជាតិ ក្នុងឱកាសនោះ ដែលធ្វើឱ្យទស្សនិកជនចាប់អារម្មណ៍យ៉ាងខ្លាំង ៕

www.elibraryofcambodia.org

# ១០-ល្ខោនពោលស្រី



www.elibraryofcambodia.org

# ប្រវត្តិល្ខោនពោលស្រី

ល្ខោនពោលស្រី គឺជាទម្រង់ល្ខោនច្រៀងរាំបុរាណមួយ ដែលមានលក្ខណៈស្រដៀងគ្នានឹងសិល្បៈល្ខោនក្បាច់បុរាណដែរ ទាំងតន្ត្រីប្រគំជូន ល្ខោនទាំងសម្លៀកបំពាក់ សំពត់អាវ ស្បៃ មកុដ ក្បាំង ប្រដាប់ដៃជើង និងអ្នកសម្តែង គឺសុទ្ធតែស្រីទាំងអស់ សូម្បីតែតួអង្គប្រុសក៏ដោយៗ

ប៉ុន្តែបើយើងពិនិត្យលើរបៀបសម្តែងវិញ យើងសង្កេតឃើញថា មានភាពខុសគ្នាឆ្ងាយពីទម្រង់ល្ខោនបុរាណខ្មែរ ឬល្ខោនព្រះរាជទ្រព្យខ្មែរ ព្រោះល្ខោនក្បាច់បុរាណខ្មែរដែលមានតួសុទ្ធតែស្រីៗ បញ្ចេញតែកាយវិការដ៏ទន់ភ្លន់ប្រណីតទៅតាមទំនុកចម្រៀងរបស់ក្រុមអ្នកច្រៀងជាពួក (Choeur) មិនមាននិយាយ ឬច្រៀងខ្លួនឯងឡើយៗ ផ្ទុយទៅវិញ នៅក្នុងទម្រង់ល្ខោនពោលស្រី ដែលក្បាច់បានយកតាមលម្នាន ល្ខោនក្បាច់បុរាណខ្មែរ ឬល្ខោនព្រះរាជទ្រព្យនោះ ក្រៅពីពាក្យពោលដែលរៀបរាប់សាច់រឿង ឬកាត់កងឆាកដោយអ្នកពោលស្រី សិល្បការី និងអ្នកសម្តែង ទាំងតួអង្គប្រុស សុទ្ធតែត្រូវរាំច្រៀង ឬនិយាយខ្លួនឯងទាំងអស់ ដែលពាក្យបច្ចេកទេសនៅក្នុងទម្រង់នេះនិយមហៅថា «ច្រៀងឯងរាំឯង»ៗ ឯតួអង្គដែលពាក់មុខដូចជាយក្ស ស្វា ឥសីៗលៗ ពេលត្រូវនិយាយ គឺត្រូវបង្អើបមុខរុញឡើងលើ ហើយនិយាយៗ លក្ខណៈនេះ យើងឃើញមានភាពដូចគ្នាបេះបិទនឹងទម្រង់សិល្បៈយីកេ ដែលសម្តែងរឿងបុរាណៗដែលមានតួយក្ស តួស្វា តួគ្រុឌជាដើមនោះៗ ឯសិល្បករប្រុសៗអាចដើរតួជាឥសីតុកកំប្លែង និងតួអង្គសត្វផ្សេងៗ ដូចជាសេះជាដើមៗ

ចំពោះប្រភពក្បាលបរិច្ឆេទកំណើត និងការវិវត្តរបស់ទម្រង់ល្ខោនពោលស្រីនេះវិញ យើងមិនទាន់បានធ្វើការសិក្សាឲ្យហ្មត់ចត់នៅឡើយទេ ប៉ុន្តែបើតាមការសង្កេតឃើញថា ទម្រង់នេះមានតែនៅក្នុងស្រុកខ្លះៗនៃខេត្តកណ្តាល ដូចជាស្រុកកៀនស្វាយ និងស្រុកខ្សាច់កណ្តាលប៉ុណ្ណោះ ហើយបើតាមព័ត៌មានខ្លះៗដែលយើង

www.elibraryofcambodia.org

បានទទួលរួចមកហើយនោះ នាំឲ្យយើងមានគំនិតជាបណ្ដោះអាសន្នថា ល្ខោនពោលស្រីនេះ គឺជាកូនបង្កើតរបស់ល្ខោនព្រះរាជទ្រព្យ។

ក-អាចកើតមានឡើងក្នុងសម័យលង្វែក ពិសេសក្នុងរជ្ជកាល ព្រះបរមខត្តិយាមហាច័ន្ទរាជា (១៥១៦-១៥៦៦) ព្រោះឯកសារមួយចំនួន បានឲ្យយើងដឹងថា ព្រះអង្គជាព្រះមហាក្សត្រប្រកបដោយកិត្យានុភាព និងមានព្រះកិត្តិយសក្រអូបនៅក្នុងប្រវត្តិសាស្ត្រជាតិកម្ពុជា។ ព្រះអង្គទ្រង់រាជ្យប្រកបដោយទសពិធរាជធម៌ ព្រះអង្គទ្រង់បានប្រមូល និងសម្រិតសម្រាំង អស់អ្នកប្រាជ្ញរាជបណ្ឌិតទាំងខាងផ្លូវលោកទាំងខាងផ្លូវធម៌ ទាំងព្រះសង្ឃ ទាំងគ្រហស្ថព្រមទាំងគម្ពីរ ដីកា ក្រាំងសាស្ត្រា ឯកសារទាំងអស់ទុកជាគ្រឹះព្រះនគរ ហើយទ្រង់បានលើកតម្កើងការកសាងវប្បធម៌ជាតិមានចាត់ឲ្យហាត់ល្ខោនប្រុស ល្ខោនស្រី ចម្រៀង តូរ្យតន្ត្រីសព្វបែបយ៉ាងសម្រាប់ជាព្រះឥស្សរិយយសជាដើមផង។

ខ-ឬមួយល្ខោនពោលស្រីនេះអាចកើតមាននៅក្នុងរជ្ជកាលព្រះបាទ ស្រីសុរិយោពណ៌(១៦០៣-១៦១៨) ដែលទ្រង់សោយរាជ្យនៅរាជធានីលង្វែក (សព្វថ្ងៃហៅកោះនរា) ស្រុកព្រៃល្វាផ្អែម គឺស្រុកល្វាឯមដែលស្ថិតមិនឆ្ងាយប៉ុន្មាន ពីស្រុកកៀនស្វាយ ក្នុងខេត្តកណ្ដាលដែលមានក្រុមសិល្បៈល្ខោនពោលស្រីសព្វថ្ងៃនេះឯង។ ហើយឯកសារខ្លះបានរៀបរាប់បញ្ជាក់ថា សម្ដេចព្រះរាជឱង្ការព្រះស្រីសុរិយោពណ៌បរមរាជា ជាព្រះមហាក្សត្រសក្តិមួយអង្គដ៏អង់អាចក្លាហាន។ ព្រះអង្គមានមេទ័ពដ៏ខ្លាំងពូកែ គឺតេជោ មាសនិងតេជោយ៉ត ដែលជាសិស្សជំនិតរបស់លោក។ ព្រះអង្គទ្រង់សោយរាជ្យគ្រប់គ្រងរាស្ត្រប្រជាដោយយុត្តិធម៌ ហើយរៀបចំប្រទេសជាតិឲ្យបានសុខសន្តិភាព និងរីកចម្រើន។

គ-បើមិនដូច្នោះទេ ទម្រង់ល្ខោនពោលស្រីនេះអាចកើតមានក្នុង សម័យព្រះរាជសម្ភារពញាតូ (១៦២៩-១៦៣៤) ដែលជាព្រះមហាក្សត្រមួយអង្គទ្រង់ដក់

ព្រះឧទ័យក្នុងវិស័យអក្សរសាស្ត្រណាស់ ហើយដែលពីដំបូង ទ្រង់គង់នៅរាជធានីឧត្តុង្គ រួចព្រះអង្គទ្រង់យាងចេញពីរាជធានីឧត្តុង្គនេះ ទៅគង់នៅវាំងកោះឃ្លោក (សព្វថ្ងៃហៅកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល) ដើម្បីបំពេញកិច្ចខាងអក្សរសាស្ត្រដែលប្រហែលជាទ្រង់នាំទាំងក្រុម សិល្បៈល្ខោនពោលស្រីនេះមកជាមួយផង ដោយទុកកិច្ចការផែនដីថ្វាយ ព្រះឧទ័យ ជាព្រះបិតុលា គឺឪពុកមាងារជាឧបរាជឲ្យគង់នៅរាជធានី ឧត្តុង្គមើលកិច្ចការជំនួសៗ ហើយប្រហែលជាមានគ្រូល្ខោនពោលស្រីដែលសល់ពីរាជវាំងកោះឃ្លោកនោះមកហើយ ដែលមកបន្តបង្រៀនក្រុមល្ខោនពោលស្រីនៅកៀនស្វាយ ដែលយើងឃើញមានវត្តមានរហូតមកដល់ថ្ងៃនេះនោះ។
ឃ-ឬក៏អាចកើតមាននៅក្នុងរាជក្សត្រិយអង្គម៉ី (១៨៣៣-១៨៤០) ដែលគង់នៅរាជវាំង កោះស្លាកែត ជិតស្រុកកៀនស្វាយ ក្នុងខេត្តកណ្ដាល នោះឯង។

នៅភាគខាងចុងនៃសតវត្សរ៍ទី ២០ ក្នុងឆ្នាំ ១៩៧០ សង្គ្រាមស៊ីវិល ដ៏ឃោរឃៅក៏បានកើតឡើងនៅប្រទេសកម្ពុជា ទម្រង់ល្ខោនពោលស្រី ក៏ដូចជាទម្រង់សិល្បៈឯទៀតទាំងអស់របស់កម្ពុជា បានត្រូវរបបប៉ុល-ពត អៀង-សារី ប្រល័យពូជសាសន៍ រំលាយខ្ទេចក្នុងសម័យកាលរបស់គេ ១៩៧៥-១៩៧៩។

រហូតមកដល់ពាក់កណ្ដាលឆ្នាំ ១៩៩៩ គិតទៅអស់រយៈពេលជិត ២០ ឆ្នាំក្រោយពីរបបប្រល័យពូជសាសន៍ដួលរលំទៅ ដោយការខំប្រឹងប្រែងរបស់គ្រូចាស់ៗដែលសេសសល់ ភាគច្រើនជាកសិករក្រីក្រខំប្រមូលអំបែងបែកទាំងឡាយរបស់ល្ខោនពោលស្រីមកផ្គុំគ្នាគួបផ្សំ និងក្រុមអ្នកសិក្សាស្រាវជ្រាវរបស់ក្រសួងវប្បធម៌ ព្រមដោយការជួយឧបត្ថម្ភគាំទ្រទាំងសម្ភារៈ និងស្មារតី ពីអង្គការក្រៅរដ្ឋាភិបាលនានាផង ទើបទម្រង់ល្ខោនពោលស្រី បានរស់ឡើងនៅចំពោះមុខទស្សនិកជនជាតិ និងអន្តរជាតិឡើងវិញ៕

www.elibraryofcambodia.org

# ១១–ស្លោនកែន



www.elibraryofcambodia.org

# ប្រវត្តិល្ខោនគែន

ល្ខោនគែន គឺជាទម្រង់ល្ខោនច្រៀងរាំបែបបុរាណមួយ ដែលមានវត្តមានក្នុងព្រះបរមរាជវាំងរាជធានីភ្នំពេញក្នុងរាជព្រះបាទ នរោត្តម សីហនុវរ្ម័ន (១៩៤១-១៩៥៥)។

គែន គឺជាឧបករណ៍តន្ត្រីគ្រឿងផ្លុំ ដែលធ្វើពីបំពង់ឫស្សីតូចៗ បិទផ្ដាបគ្នា ជាឧបករណ៍ដើមមួយ របស់ជនជាតិអម្បូរមន-ខ្មែរ ដែលគេសង្កេតឃើញនៅសល់ក្នុងដៃខ្មែរតំបន់ភ្នំជាច្រើនមានវែង មានខ្លី ហើយឥឡូវក្លាយជាឧបករណ៍តំណាងឲ្យលក្ខណៈពិសេសរបស់ជនជាតិលាវសព្វថ្ងៃ ដែលជាជនជាតិមួយធ្លាប់រួមរស់ដោយសុខសន្តិភាព មិត្តភាព និងជាបងប្អូនជាមួយជនជាតិខ្មែរយើងតាំងពីភាគខាងចុងសម័យ **«មហាអាណាចក្រខ្មែរ»** គឺភាគខាងចុងសម័យមហានគរនោះឯង។

បើតាមព័ត៌មានដែលយើងទទួលបានពីគ្រូចាស់ៗ បានបញ្ជាក់ថា មានគ្រូល្ខោនគែនជាជនជាតិលាវ ៤ នាក់ ឈ្មោះ ឃុន សុំជីង, ឃុន ប៊ូ, ឃុន អេង និង ឃុន ផែង បានមកបង្ហាត់ល្ខោននេះដល់សិល្បការិនីខ្មែរ ក្នុងព្រះបរមរាជវាំងក្នុងអំឡុងឆ្នាំ ១៩៤៥ នៃ គ.ស។

ប៉ុន្តែបើតាមការរៀបរាប់របស់គ្រូចាស់ៗនៃក្រុមរបាំព្រះរាជទ្រព្យ ដែលធ្លាប់បានហាត់រៀន និងធ្លាប់ឃើញអំពីកិនភាគនៃទម្រង់ល្ខោននេះ យើងឃើញហាក់ដូចជាមានលក្ខណៈខុសប្លែកអំពីល្ខោនឡាំរបស់លាវ ដែលយើងឃើញសម្ដែងនៅក្រុងវៀងច័ន្ទ និងទីដទៃទៀតក្នុងប្រទេសលាវសព្វថ្ងៃ ដែលអ្នកសម្ដែងមានស្រីហានប្រុស ហើយយកឧបករណ៍គែនទៅប្រគំជាមួយនឹងវង់តន្ត្រីសម័យ។

ផ្ទុយទៅវិញ ទម្រង់ល្ខោនគែនដែលមាននៅព្រះរាជវាំងក្រុងភ្នំពេញ នេះគឺជាប្រភេទល្ខោនច្រៀងរាំបែបបុរាណមួយ ដែលអ្នកសម្ដែងសុទ្ធតែស្រីទាំងអស់ ហើយអ្នកសម្ដែងនេះត្រូវច្រៀង និងនិយាយខ្លួនឯង ដោយយកកាយវិការរបស់ល្ខោនព្រះរាជទ្រព្យជាក្បាច់បាតរបស់ខ្លួនៗ ឯឧបករណ៍ តន្ត្រីវិញមាន៖

www.elibraryofcambodia.org

-គែនចំនួន ៤ (ពីសំឡេងធំគ្រលរទៅសំឡេងតូចស្រួយ)

-រនាតឯក

-រនាតធុង

-តាខេ (ក្រពើ)

-ទ្រអ៊ូ

-ទ្រសោ

-ទ្រឆេ

-ក្រាប់

-ឈិង

-ស្គរថូនរមនា

-សុរម្ភារ

ចំណែកខាងសម្លៀកបំពាក់ និងគ្រឿងតុបតែងកាយវិញ គឺប្រើគ្រឿងតូចមានសំពត់ចងក្បិនសូត្រ ឬសម្ពុយគ្រប់ពណ៌ អាវតែកងដៃវែង ឬដៃខ្លីមានពានាក្រមា ហើយពាក់ប្រដាប់ដៃប្រដាប់ជើងគ្រប់បែប ដូចល្ខោនបុរាណដែរៗ ដូនទម្លាក់សក់ ដូនបួងសក់ លម្អដោយក្លងផ្កាផ្សេងៗទៀតផង

ជាទូទៅ មុនពេលចាប់ផ្តើមសម្តែងល្ខោនគែននេះ គេតែងនាំគ្នាធ្វើពិធីសំពះគ្រូដោយមានរណ្តាប់ផ្សេងៗ ប្រហាក់ប្រហែល និងពិធីសំពះគ្រូបាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យដែរបន្ថែមតែ ÷

-បាយដំណើប

-ប្រហុក

-ស្រា

-ចេកទុំ និងស្វាយទុំ

www.elibraryofcambodia.org

ឯបទភ្លេងពិសេសក្នុងពិធីសំពះគ្រូ មាន ៤ បទគឺ÷

-បទ ស៊ុំ

-បទតាឡិនតិន

-បទ សារ៉ាក់បូរី

-បទតាឡូតខៃ

ហើយបទសម្រាប់សម្ដែងក្នុងសាច់រឿងវិញ គាត់ច្រើនគឺខ្ចីមកពីបទភ្លេងនៃ វង់ភ្លេងមហោរីៗ ឯរឿងដែលត្រូវយកមកសម្ដែង គឺច្រើនតែលើកយកអន្ទើ ឬ ឈុតនានានៃរឿងក្រៃថោងមកសម្ដែងៗ

សូមបញ្ជាក់ថា តាំងពីដើមរៀងមក ទម្រង់ល្ខោនគែននេះ មិនសូវបានបេញ សម្ដែងឲ្យប្រជាជនមហាជនឃើញឡើយ គឺមានសម្ដែងតែក្នុងព្រះបរមរាជវាំង ដើម្បីកែកម្សាន្ត ឬពិធីបុណ្យនៃព្រះរាជវាំងប៉ុណ្ណោះ ដូច្នេះហើយទើបមានអ្នក ដែលស្គាល់ ឬចេះចាំទម្រង់នេះតិចណាស់ៗ ហើយមិនយូរប៉ុន្មានផង ទម្រង់ល្ខោន គែននេះ ក៏ត្រូវវិនាសសាបសូន្យ អាក់ខានលែងបានសម្ដែងជារឿងរហូតមក ៗ

លុះមកដល់ឆ្នាំ ២០០០ ទើបគណៈកម្មការស្រាវជ្រាវវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានលោក ពេជ្រ ជុំក្រវិល ជាប្រធាន និងដោយមានជំនួយពី អង្គការ UNESCO ផងបានអញ្ជើញគ្រូ ដែលធ្លាប់បានហាត់ល្ខោនគែននេះ នៅ ព្រះបរមរាជវាំងពីជំនាន់មុនមាន អ្នកគ្រូ ឯម ឆាយ និងអ្នកគ្រូ អ៊ុជ បូ ឲ្យមកបង្ហាត់ សិល្បការិនី ផ្នែករបាំបុរាណនៃនាយកដ្ឋានសិល្បៈ ហើយបានលើកយកអន្ទើមួយ នៃរឿងក្រៃថោងមកសម្ដែងជូនភ្ញៀវជាតិ និងអន្តរជាតិនានាក្នុងទិវាវប្បធម៌ថ្ងៃ ៣ មេសា ឆ្នាំ ២០០០ នោះនៅរោងមហោស្រពចតុមុខ ហើយទូរទស្សន៍ជាតិកម្ពុជា បានថតហើយចាក់ផ្សាយផងដែរៗ គឺចាប់ពីពេលនោះមកហើយ ដែលធ្វើឲ្យខ្មែរ បានស្គាល់ល្ខោនគែននេះឡើងវិញ ៕

www.elibraryofcambodia.org

# ១២–ល្ខោនបើកាបង




www.elibraryofcambodia.org

ប្រវត្តិល្ខោនបើកបទនេះ ខ្ញុំទទួលបានពីលោក ជា សុខុម សព្វថ្ងៃ ធ្វើការនៅមន្ទីរ វប្បធម៌ ខេត្តសៀមរាប ឪពុក-ម្តាយ លោកមាន ទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត និង ល្ខោនរបស់ ឃុន តាតរោងផ្សារស៊ីឡឹប ដែលមានទម្រង់ ល្ខោនបើកបទនេះផង

## ប្រវត្តិល្ខោនបើកបទ

ល្ខោនបើកបទនេះ អាចមានកំណើតនៅខេត្តបាត់ដំបង នៅក្នុងរជ្ជកាលព្រះបាទ អង្គអេង គ.ស ១៧៩៤។

យោងតាមឯកសារ លោក តូច ឈួង បានឲ្យដឹងថា សម្តេចចៅហ្វា បែន ដែល កាន់ត្រួតត្រាខេត្តបាត់ដំបង បានបង្កើតក្រុមសិល្បៈរបាំ និងក្រុមល្ខោនបើកបទ សម្រាប់បុណ្យទានចូលឆ្នាំ ឬទទួលភ្ញៀវជាន់ខ្ពស់ ហើយល្ខោនបើកបទ បានមាន ប្រជាប្រិយភាពយ៉ាងខ្លាំងនៅខេត្តបាត់ដំបង សៀមរាប និងកំពង់ធំៗ

ល្ខោនបើកបទនេះ បានមានជីវិតរស់នៅរហូតដល់ឆ្នាំ ១៩៦៨ ហើយត្រូវ បាត់សូន្យអស់តែម្តងក្នុងសម័យប៉ុល ពតៗ នៅសល់តែសិល្បករ ១ នាក់ និងសិល្បការិនី ១ នាក់ប៉ុណ្ណោះ ដែលជាសាក្សីក្នុងរឿងល្ខោនបើកបទៗ

## អ្នកបង្កើតល្ខោនបើកបទ

១- ចៅហ្វា បែន អ្នកបង្កើតមុនគេ នៅឆ្នាំ១៧៩៤ នៅខេត្តបាត់ដំបង

២- លើកទី ២ រៀបចំបង្កើតនៅឆ្នាំ ១៩៦០ ដោយក្រុមល្ខោនរបស់ឃុនព្រះម្នាង បុប្ផារល័ក្ខណ៍ យិន តាត នៅភ្នំពេញ

- អ្នកស្ថាបនិក ឃុនព្រះម្នាង បុប្ផារល័ក្ខណ៍ យិន តាត
- អ្នកដាក់ក្បាច់ ម៉ែ រ៉ុ (ល្ខោនព្រះរាជវាំង)
- អ្នកដាក់ក្បាច់ ម៉ែ ផាន់ (ល្ខោនផ្សារស៊ីឡឹប)
- អ្នកតុបតែងឆាក លោកឪពុក យិន

www.elibraryofcambodia.org

- អ្នកបញ្ចូលភ្លេង លោក ឃុន ឌី (ចាងហ្វាងភ្លេង)
- បង្ហាត់នាដកម្ម ម៉ែ ម៉ឹង

## អ្នកចូលរួមសម្តែង

១- លោក ជា សុខុម
២- ម៉ែ សឿម ក្រុមល្ខោនផ្កាស៊ីឡឹប
៣- ម៉ែ ផាង

## បច្ចេកទេសសម្តែង

១- តាមពាក្យសាមញ្ញគេហៅថា ល្ខោនរាំឯង ច្រៀងឯង និយាយឯង
២- សិល្បករ សិល្បការិនី ត្រូវចេះរាំក្បាច់ខ្មែរ ចេះច្រៀង ចេះលេងល្ខោន
៣- ត្រូវនៅលីវ មិនទាន់មានប្តី មិនទាន់មានប្រពន្ធ
៤- ត្រូវចេះច្រៀងបើកបទ គឺច្រៀងមុនភ្លេង ត្រូវចេះក្បាច់ខ្មែរ ៤៥០០
៥- ល្ខោនបើកបទ ខុសពីល្ខោនបាសាក់ ល្ខោនយីកេ ល្ខោនអាប៉េ ត្រង់សិល្បការិនី សិល្បករត្រូវច្រៀងមុនភ្លេង ទើបភ្លេងលេងតាមក្រោយភ្លេងពិណពាទ្យមិនអាចយកភ្លេងមហោរីមកលេងបានទេៗ
៦- ល្ខោនបើកបទ ត្រូវកាត់កងផាកតាមបែបល្ខោននិយាយ
៧- ពេលសម្តែងត្រូវរាំតាមក្បាច់ កំប៉ុន្តែមិនប្រើក្បាច់ច្រើនពេកទេ
៨- ល្ខោនបើកបទ មិនយកស្រីធ្វើតួប្រុសទេ គឺតួស្តេចត្រូវយកប្រុស តួឯកប្រុសគឺយកប្រុស
៩- ពិធីហោមរោងមុនសម្តែង គឺភ្លេងសាធុការ រួចហើយ មានរបាំក្បាច់មួយ
១០- តួយក្សប្រុស មិនគូរមុខទេ គឺតែងដូចយក្សរបាំក្បាច់សមុទ្រទឹកដោះ ៗ

www.elibraryofcambodia.org

# ១៣-ល្ខោនចាមោជ្ជជ័យ



www.elibraryofcambodia.org

## ប្រវត្តិល្ខោនបាសាក់ជ័យ ឬប្រាមោទ្យជ័យ

ល្ខោនបាមោជ្ជទ័យ ឬប្រាមោទ្យទ័យ គឺជាទម្រង់ល្ខោនច្រៀងបែបទំនើបមួយដែលបានកើតឡើងនៅដើមសតវត្សរ៍ទី ២០ នេះឯង ពិសេសគឺក្នុងរយៈពេលក្រោយសង្គ្រាមលោកលើកទី ១ (១៩១៤-១៩១៨) ហើយអ្នកខ្លះហៅទម្រង់ល្ខោននេះថា ល្ខោនបាម៉ោជ័យ តាមសំនៀងសៀមក៏មានៗ តាមពិតពាក្យបាមោជ្ជ ជាភាសាបាលី និងប្រាមោទ្យជាភាសាសំស្ក្រឹត មាន ន័យថា **«គួររីករាយ ឬរំជួលចិត្ត»** ។

ល្ខោនបាមោជ្ជទ័យ ឬល្ខោនប្រាមោទ្យទ័យដែលធ្វើឲ្យរំជួលចិត្តនេះ ពិតជាបានឧប្បត្តិកកើតឡើងនៅកម្ពុជានេះ ដោយយកលំនាំទាំងស្រុងពីល្ខោនច្រៀងបែបបស្ចិមប្រទេសអូប៉េរ៉ែត (Opérette) ពិសេសគឺពីប្រទេសបារាំង ដែលជាប្រទេសធ្វើអាណានិគម និយមលើប្រទេសខ្មែរផ្ទាល់តែម្តងៗ

បើតាមឯកសារក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បានបញ្ជាក់ឲ្យដឹងថា អ្នកសម្តែងដែលគេនិយមហៅថា **«តួកូនរាំ»** ទាំងអស់សុទ្ធតែស្រីៗ សូម្បីតែតួអង្គក្នុងរឿងនោះជាតួប្រុសក៏ដោយៗ ចំណែកខាងប្រុសៗមានមុខងារជា អ្នករៀបចំឆាក លេងភ្លេង និងដើរតួជាតួកកំប្លែងប៉ុណ្ណោះៗ

ឯតន្ត្រីជូនវង់ល្ខោននេះវិញ គឺវង់តន្ត្រីសម័យ ដែលពីមុននោះខ្មែរនិយមហៅជា ភ្លេងអរកេស្រ (Orchestre) ឬភ្លេងម៉ាទីលនោះឯងៗ ហើយក្រោយមក គេមានបញ្ចូលឧបករណ៍តន្ត្រីបុរាណខ្មែរខ្លះផងដូចជា រនាត ឃឹម តាខេ ខ្លុយ ៗលៗ សាច់បទ និងទំនុកច្រៀង គេនិពន្ធថ្មីខ្លះ និងយកបទមហោរីមកប្រើខ្លះដូចជា បទទោចយំ បទដួងចំប៉ា បទឡាវឡឹក បទសែនស្រណោះ បទចៅដកជាដើម។ ដែលអ្នកច្រៀងត្រូវច្រៀងមួយចប់សាច់បទ ទើបភ្លេងប្រគំសាច់បទនោះជាក្រោយៗ ចំណែកខាងសម្លៀកបំពាក់វិញ ច្រើនប្រើសម្លៀកបំពាក់សម័យទំនើប គឺខោឡេវអាវសឺមិះ ឬអាវធំ ស្រីសំពត់ហូល ឬកំស្លៀកបែបអឺរ៉ុប ឬបុរាណតាមសាច់រឿងនីមួយៗៗ ចំណែកខាងការតុបតែងលម្អឆាកវិញ ក៏មានលក្ខណៈទំនើបណាស់ដែរ

www.elibraryofcambodia.org

មានផ្ទាំងគំនូរតាប្លូ (Tableaux) ចងព្យួរដូចល្ខោនបាសាក់ផង ហើយមានបន្ថែម រាំងគំនូរគាត់ជារូបផ្ទះ រូបក្លោងទ្វារ រូបភ្នំ និងសម្ភារៈតុទូគ្រែ ទាំងនេះស្របទៅ តាមដំណើរនៃសាច់រឿងដែលភាគច្រើន ច្រើនតែជារឿងសម័យផង ហើយជួន កាលជារឿងរបស់បរទេសដូចជារឿងអ៊ីណាវបុស្បា (ជួ តាង សរសេរជាកាព្យ) ប្រភេទរឿងមួយពាន់មួយយប់ របស់អារ៉ាប់ ពិសេស គឺរឿងបារាំងតែម្តងៗ

ឯរបៀបសម្តែងវិញ ក្រៅពីចម្រៀងដែលជួនដោយវង់តន្ត្រីសម័យ ឬចម្រុះ ឧបករណ៍ខ្មែរខ្លះទាំងកាយវិការ ទាំងពាក្យសម្តីនិយាយ គឺមានលក្ខណៈប្រាកដ និយម ពោលគឺដូចសកម្មភាពក្នុងជីវិតធម្មតារបស់មនុស្សយើងនេះឯងៗ

ល្ខោនប្រាមោទ្យទ័យ ដែលជាល្ខោនច្រៀងបែបថ្មីទទួលឥទ្ធិពល ឬចម្លង ពីល្ខោនច្រៀង អូប៉េរ៉ែតរបស់អឺរ៉ុបមកនេះ មានអាយុកាលរស់នៅមិនបានយូរ ប៉ុន្មានឡើយក្នុងសង្គមខ្មែរ ព្រោះឯកសារក្រុមជំនុំទំនៀមទម្លាប់ខ្មែរបានបញ្ជាក់ ថា ទម្រង់នេះបានកើតឡើងប្រមាណក្នុងឆ្នាំ ១៩២០ នៃ គ.ស ហើយ ត្រូវលត់ រលាយអស់ពីកម្ពុជាទៅវិញ នៅក្នុងអំឡុងឆ្នាំ ១៩៤០ៗ មូលហេតុ គឺដោយសារ មានល្ខោនបាសាក់ ដែលឡើងមកពីស្រុកបាសាក់កម្ពុជាក្រោម មកប្រណាំង ប្រជែង ហើយទស្សនិកជនខ្មែរ ជាទូទៅក៏បែរទៅជានិយមទស្សនាល្ខោនបាសាក់ ហ៊ានខ្លាំងក្លាទៅវិញៗ

រហូតមកដល់ឆ្នាំ ២០០១ ទើបគណៈកម្មការស្រាវជ្រាវវប្បធម៌សិល្បៈរបស់ ក្រសួងវប្បធម៌ដែលមានលោក ពេជ្រ ជុំក្រវិល ជាប្រធាននឹងដោយមានជំនួយ អង្គការ UNESCO ទើបយើងអាចធ្វើឲ្យទម្រង់ល្ខោន បាមោទ្យទ័យនេះរស់ឡើង វិញបានដោយលើកយករឿងគេបគេបកូនល្អរៀបរៀងដោយ អ្នកស្រី កែវណារុំ និងដឹកនាំរឿងដោយលោក ចិន ជាត មកសម្តែងជាលើកដំបូងក្នុងទិវាវប្បធម៌ ថ្ងៃទី ៣ មេសា នៅសាល មហោស្រពចតុមុខៗ

ពិតមែនតែការសម្តែងល្ខោនបាមោទ្យទ័យរបស់យើង បានចំនួនតិចពេលក៏

www.elibraryofcambodia.org

ពិតមែន ប៉ុន្តែយើងខ្ញុំសង្ឃឹមថាមេរៀនដ៏តូច និងមានសារៈសំខាន់ដែលគណៈកម្មការស្រាវជ្រាវ និង UNESCO បានខិតខំធ្វើឲ្យរស់ឡើងវិញ និងបង្ហាញជូនទស្សនិកជនជាតិ និងអន្តរជាតិក្នុងឱកាសនេះ និងត្រូវបានសិល្បករបន្តវេនចាប់អារម្មណ៍ ហើយខិតខំការពារ ស្វែងយល់ និងពង្រីកឲ្យកាន់តែធំ និងល្អប្រសើរឡើងក្នុងកាលអនាគតជាក់ជា មិនខាន។

www.elibraryofcambodia.org

# ១៤-អាយ៉ៃ



www.elibraryofcambodia.org

# ប្រវត្តិអាយ៉ៃ

អាយ៉ៃ ជាទម្រង់សិល្បៈទស្សនីយភាពមួយ ដែលមានប្រជាប្រិយភាពធំធេងនៅប្រទេសកម្ពុជា ហើយទម្រង់សិល្បៈនេះបានឈ្មោះមកពី សិល្បករដ៏ល្បីល្បាញម្នាក់គឺ «ពូយ៉ៃ»។ ជាទម្រង់សិល្បៈចម្រៀងឆ្លងឆ្លើយ ឬជាប្រភេទសិល្បៈដេញប្រាជ្ញគ្នាដោយច្រៀងចោទ និងឆ្លើយដោះស្រាយសំណួរ ឬប្រស្នានានា ដោយសំនួនវោហាជាកំណាព្យកាព្យឃ្លោងឥតព្រាងទុក ដែលភាគច្រើន ច្រើនមានលក្ខណៈបញ្ឆិតបញ្ឆៀងបង្កើតឲ្យមានន័យពីរផ្ទុយគ្នា ឬកំប្លុកកំប្លែងថែមទៀតផង។

បើតាមប្រសាសន៍លោក ម៉េង ហ៊ុន វរសិល្បករ ដែលជាសាស្ត្រាចារ្យតន្ត្រីប្រពៃណីដ៏ល្បីល្បាញ នៅប្រទេសកម្ពុជាបានឲ្យដឹងថា សិល្បៈអាយ៉ៃមានប្រភពកំណើតចេញពីចម្រៀងប្រលែង គឺចម្រៀងឆ្លងឆ្លើយគ្នាដែលមានប្រុសម្នាក់ និងស្រីម្នាក់ឈរតម្រៀបគ្នាជាជួរទល់មុខគ្នា ទះដៃព្រមគ្នាឈូចង្វាក់ ហើយច្រៀងតគ្នាទៅវិញទៅមក ពិសេសនៅពេលលេងល្បែងប្រជាប្រិយចោលឈូង ក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរនេះឯង។ ក្រោយមកចម្រៀងប្រលែងនេះត្រូវសម្រួលដោយគំនិតច្នៃប្រឌិតរបស់បុព្វបុរសសិល្បករខ្មែរ ដែលបានបំភ្លែងឲ្យក្លាយទៅជាចម្រៀងឆ្លងឆ្លើយរវាងស្រី និងប្រុស ដែលមានវង់តន្ត្រីភ្លេងការប្រគំជូន ប៉ុន្តែវង់តន្ត្រីនេះត្រូវពង្រីកឲ្យមានឧបករណ៍ដេញ ដំ ផ្លុំ កូតជាច្រើនដូចជាទ្រខ្សែបី ឬទ្រខ្មែរ ចាប៉ីដងវែង ទ្រអ៊ូ ទ្រសោ ក្រពើ ខ្លុយ ប៉ីបបុស ស្គរដៃ ក្រាប់។ល។ ហើយ ទម្រង់ថ្មីនេះមានឈ្មោះថាភ្លេងវង់ធំ។

ចម្រៀងប្រលែង ឬភ្លេងវង់ធំនេះមានកំណើតតាំងពីយូរណាស់មកហើយ នៅប្រទេសកម្ពុជានេះ។ ប៉ុន្តែរហូតមកដល់ចុង ស.វ ទី ១៩ និង ដើម ស.វ ទី ២០ ទើបពូយ៉ៃ (១៨៧៨-១៩៥៨) ដែលមានដើមកំណើត នៅភូមិឈើនាងខ្ពស់ ឃុំព្រះពុទ្ធនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលជាសមាជិកម្នាក់សម្តែងក្នុង ក្រុមសិល្បៈភ្លេងវង់ធំមួយក្រុម នៅភូមិត្រពាំងទា ឃុំពងទឹកស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

www.elibraryofcambodia.org

(នៅខាងត្បូងផ្លូវជាតិភ្នំពេញ-កំពង់ស្ពឺ) បានធ្វើឲ្យមានព្រឹត្តិការណ៍ថ្មី សម្រាប់ទម្រង់សិល្បៈនេះឡើងៗ ដោយសារការប៉ិនប្រសប់របស់ពូយ៉ៃ ដែលជាអ្នកចម្រៀងយ៉ាងពូកែ សំឡេងពីរោះ ប្រសប់ប្រើសំនួនវោហារឥតព្រាងទុកៗ ចេះរាំផង ចេះសម្ដែងកំប្លុកកំប្លែង ព្រមទាំងចេះក្បាច់គុនផង នោះបានធ្វើឲ្យទស្សនិកជនងប់ទៅចាប់អារម្មណ៍លើរូបគាត់ រហូតដល់ក្រោយៗមក ពេលគេទៅមើលការសម្ដែងសិល្បៈក្នុងវង់ធំ ដែលមានពូយ៉ៃជាសមាជិក នោះគេតែងតែនិយាយថា ទៅមើលពូយ៉ៃ ឬទៅមើលអាយ៉ៃ (សម្រាប់ទស្សនិកជនដែលមានអាយុច្រើនជាងសិល្បករយ៉ៃ) យ៉ាងដូច្នេះទៅវិញៗ គឺដោយសារការនិយមរបស់ អ្នកស្រុកដែលប្រើពាក្យថា ទៅមើលអាយ៉ៃៗយ៉ាងដូច្នេះ ហើយដែលធ្វើឲ្យឈ្មោះពូយ៉ៃក្លាយជាឈ្មោះទម្រង់សិល្បៈចម្រៀងឆ្លងឆ្លើយ **«អាយ៉ៃ»** ជំនួសក្នុងវង់ធំជារៀងរហូតមកៗ

រហូតមកដល់សព្វថ្ងៃនេះ អាយ៉ៃនៅតែជាទម្រង់សិល្បៈដែលមានប្រជាប្រិយភាពយ៉ាងធំធេងនៅក្នុងសង្គមយើង ព្រោះជាទីចូលចិត្តទាំងប្រជាជននៅទីក្រុងផង នៅជនបទៗ ឯតន្ត្រីជូនអាយ៉ៃបច្ចុប្បន្ន ភាគច្រើនមានឧបករណ៍ ទ្រ ក្រពើ ឃឹម ខ្លុយ និងស្គរដៃ ហើយគេឃើញសិល្បៈនេះចែកជាពីរប្រភេទគឺ÷

១-អាយ៉ៃឆ្លងឆ្លើយ (ភាគច្រើនស្រីម្នាក់ប្រុសម្នាក់ ច្រៀងឆ្លង ឆ្លើយគ្នា) ជាកំណាព្យកាព្យឃ្លោងដោយឥតព្រាងទុកៗ

២-អាយ៉ៃរឿង គឺទម្រង់អាយ៉ៃដដែលដែរ ប៉ុន្តែសម្ដែងជារឿងផ្សេងៗភាគច្រើនជារឿងកំប្លុកកំប្លែង ដែលយើងអាចប្រើពាក្យសម្គាល់បណ្ដោះអាសន្នទៅតាមលក្ខណៈពិសេសក្នុងការសម្ដែងនេះថា អាយ៉ៃរឿងគឺជា ប្រភេទ **«ល្ខោនធ្វើពើ»**ៗ

សូមជម្រាបបន្ថែមថា ការសិក្សារៀនសូត្រសិល្បៈអាយ៉ៃនេះតាំងពីដើមរៀង

www.elibraryofcambodia.org

មក គឺប្រើការនិយមតាមវិធីបែបបុរាណ គឺជំរុញសិស្សរៀនពីគ្រូផ្ទាល់ដោយទន្ទេញចាំមាត់រួច ក្រោយមកទើបបំបែក បច្ចៃប្រឌិតទៅតាមនិស្ស័យរបស់ខ្លួនដែលមានបន្ថែមទៀតៗ

ប៉ុន្តែក្រោយមក ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានចាប់អារម្មណ៍ដ៏ខ្លាំងក្លាបំផុត អំពីការបាត់បង់សិល្បៈប្រជាប្រិយរបស់ជាតិ ដែលជាកេរមរតកកាត់ថ្លៃពុំបាន និងជាតំណាងឲ្យប្រាជ្ញាញាណរបស់បុព្វបុរសដូនតាខ្មែរ នោះសម្តេចនាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ជាច្រើន ហើយញឹកញាប់ ដើម្បីឲ្យអ្នកធ្វើការផ្នែកវប្បធម៌ មានការប្រុងប្រយ័ត្នខ្ពស់ ចំពោះមរតកទាំងអស់នេះៗ

គឺដោយការអនុវត្តទៅតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នេះហើយ ទើបមកដល់ឆ្នាំ ២០០០ សិល្បៈអាយ៉ៃនេះ ត្រូវបានគេលើកបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាផ្លូវការ នៅក្នុងសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ ក្រោមការគ្រប់គ្រងផ្ទាល់ របស់មហាវិទ្យាល័យសិល្បៈតូរ្យតន្ត្រីជារៀងរហូតមក ៕

www.elibraryofcambodia.org

# ១៤-ល្ខោនភ្ញៀវការ



www.elibraryofcambodia.org

ពិធីអាពាហ៍ពិពាហ៍របស់ជនជាតិខ្មែរ មានអាយុរាប់ពាន់ឆ្នាំមកហើយ ពោល គឺផ្ដើមឡើងពីដើមសតវត្សរ៍ទី១ នៃ គ.ស ដោយយកតាមលម្អានពិធីពជាភិសេក របស់ព្រះថោង និងនាងនាគ (ហ៊ុនទៀន និងព្រះនាងលីវយី) ឬ (កៅណ្ឌិន្យ និង ព្រះនាងសោមា) ជាព្រះបឋមមហាក្សត្រខ្មែរនោះឯង តាំងពីពេលនោះមករហូត ដល់សព្វថ្ងៃនេះ ខ្មែរតែងចាត់ទុកពិធីអាពាហ៍ពិពាហ៍នេះថាជា **«ពិធីមង្គល»** និង មាន **«សារៈសំខាន់បំផុត»** ក្នុងជីវិតរបស់ខ្លួន រហូតដល់គេជឿថា បានក្រាបក្បាល ដល់កន្ទេល (បានផ្ដើមរៀបការ) គឺបានសងគុណមាតាបិតា បានបំពេញកិត្តិយស គ្រួសារថែមទៀតផង ម្យ៉ាងទៀត ពិធីអាពាហ៍ពិពាហ៍មង្គលការកូនប្រុសស្រីនេះ គឺជាមធ្យោបាយដ៏ល្អប្រពៃបំផុត សម្រាប់ជាចំណងចងភ្ជាប់គូស្វាមីភរិយាឲ្យជាប់ ឋិតថេរជាមួយគ្នាផង ជាចំណងចងញាតិសន្ដានខាងប្រុស ទៅនឹងញាតិខាងស្រីផង ពិសេស គឺចងជនជាតិខ្មែរទាំងមូល ឲ្យជាប់ទៅនឹងទឹកដីនៃមាតុភូមិរបស់ខ្លួន ផងៗ ប្រហែលជាដោយការនិយមពិធីការនេះថា ជាពិធីមង្គល និងមានសារៈ សំខាន់ក្នុងជីវិតនេះហើយ ដែលជាកត្តាអនុគ្រោះរាងប្ដី និងប្រពន្ធមិនឲ្យឈ្លោះ ទាស់ទែងគ្នា ហើយមានការលែងលះគ្នាយ៉ាងតិចបំផុតនៅក្នុងសង្គមជនជាតិ ខ្មែរនេះៗ

ក្នុងពិធីមង្គលការខ្មែរ ដែលមានរាប់សតវត្សរ៍មកហើយនេះមានពិធីតូចៗជា ច្រើនក្នុងនោះដែលគេត្រូវប្រារព្ធធ្វើកាលពីដើម រហូតដល់បីថ្ងៃបីយប់ រួចក្រោយ មកបំព្រួញមកនៅត្រឹមមួយថ្ងៃមួយយប់ ហើយភាគច្រើនឥឡូវនេះ ច្រើនសង្ខេប មកនៅត្រឹមរយៈពេលមួយព្រឹកប៉ុណ្ណោះក៏មានៗ ក្នុងពិធីទាំងនោះ មានពិធីខ្លះបាន ត្រូវតន្ត្រីករ សិល្បករ បំភ្លែរបៀប ជារឿងល្ខោនដោយលើកយកប្រវត្តិនៃសាច់ រឿងដែលទាក់ទងទៅនឹងពិធីនីមួយៗនោះ មកសម្ដែងឲ្យអ្នកដែលបានចូលរួម ក្នុងពិធី ឬទស្សនិកជនបានមើលដូចជា ពិធីកាត់សក់ដែលអ្នកចម្រៀងស្រីប្រុស ត្រូវក្លែងអង្គជាតួអង្គទេវតា-ទេពធីតា បម្រើអង្គឥន្ទ្រា ឲ្យនាំយកកន្ត្រៃទិព្វក្រាស

ទិព្វមកជូនលោកមហាសម្បត្តិ ដើម្បីគាត់សក់កូនប្រុសស្រី ឲ្យកើតមាសកើតប្រាក់ទុកជាមង្គល សិរីសួស្តីដល់គូស្វាមីភរិយាថ្មីនេះផង ដែលពេលខ្លះអន្ទើទាំងនេះ ត្រូវបានសិល្បករ តន្ត្រីករសម្តែងរបៀបជាឈុតកំប្លែងធ្វើឲ្យអ្នកមើលសប្បាយរីករាយ ផ្ទុះសំណើចសើចគិលាឡើង ញ៉ាំងពិធីនេះឲ្យកាន់តែអឹកអធិកថែមទៀតផងៗ ឯពិធីខ្លះទៀតដូចជាពិធីបុកល័ក្ត ធ្វើធ្មេញបំពេញលក្ខណ៍ស្រីជាដើមក៏យ៉ាងដូច្នោះដែរ គឺសិល្បករ ឬតន្ត្រីករ ឬមិត្តភក្តិអ្នកចូលរួមក្នុងពិធីត្រូវនាំគ្នាសម្តែងជារបាំ អុំទូកទៅរកល័ក្តៗ ដល់ព្រៃហើយនាំគ្នាចូលទៅបេះល័ក្ត ប៉ុន្តែត្រូវឃ្មុំ ឬឱម៉ាល់ទិច ឬអ្នកតាម្ចាស់ទឹកម្ចាស់ដី ម្ចាស់ព្រៃភ្នំធ្វើឲ្យចុកពោះ ព្រោះមិនបានសុំការអនុញ្ញាតជាមុន (ដែលការសម្តែងភាគច្រើនមានលក្ខណៈជាត្លុកកំប្លែង)ៗ រហូតដល់ត្រូវធ្វើពិធីបញ្ជាន់អារក្ខ លៀងអ្នកតា សុំក្តីសន្តោសប្រោសប្រណីរួចសព្វគ្រប់ ទើបបេះល័ក្តបានហើយចុះអុំទូកត្រឡប់មកវិញ រួចទើបនាំគ្នាបុកល័ក្តដែលមានរូបភាពជារបាំមួយយ៉ាងពី **«របាំបុកល័ក្ត»** ដែលញ៉ាំងឲ្យពិធីអាពាហ៍ពិពាហ៍នោះសប្បាយរីករាយក្រៃលែងៗលៗ

ចំណែកឯទម្រង់ល្ខោនក្នុងការនោះវិញ គឺយើងខ្ញុំមិនចង់និយាយ អំពីពិធីទាំងឡាយដែលស្ថិតក្នុងពិធីអាពាហ៍ពិពាហ៍មង្គលការកូនប្រុសស្រី ដែលត្រូវសិល្បករលើកយកមកសម្តែងជាបែបល្ខោន ដូចបានរៀបរាប់ខាងលើនោះទេៗ ផ្ទុយទៅវិញ គឺយើងខ្ញុំចង់ជម្រាបអំពីទម្រង់ល្ខោនមួយ ដែលមានលក្ខណៈដូចជា ល្ខោនបាសាក់ ឬយីកេ ឬល្ខោនមហោរីដែរ ប៉ុន្តែជាទម្រង់ដែលពឹងផ្អែកលើវង់ភ្លេងការនិងបទភ្លេងការអាចយកបទជាគ្រឹះរបស់ខ្លួនៗ ដោយរើសយកបទភ្លេងការទាំងនោះមកសរសេរទំនុកថ្មីតម្រូវទៅតាមសាច់រឿង ឬតាមមនោសញ្ចេតនានានានៃតួអង្គដែលមានក្នុងសាច់រឿងដែលបាននិពន្ធ ឬរៀបរៀងនោះៗ ឯរបៀបសម្តែងគឺមិនខុសអ្វីពីទម្រង់សិល្បៈយីកេ ឬល្ខោនមហោរីឡើយ គឺមានសិល្បករទាំងស្រីទាំងប្រុសចម្រុះគ្នាមានចម្រៀង និងពាក្យនិយាយឆ្លងឆ្លើយ ដោយប្រើកាយវិការជា

របៀប ចម្រៀងកាយវិការ ឬល្ខោនច្រៀង ដែលមានលក្ខណៈទន់ភ្លន់ទៅតាមចង្វាក់នៃសាច់បទនីមួយៗផងៗ ឯការតុបតែងលម្អឆាក វិញក៏ដូចជាសិល្បៈយីកេ ឬល្ខោនមហោរីដូច្នេះដែរ

សូមជម្រាបថា ជាការពិតណាស់ដែលថា វង់ភ្លេងប្រពៃណី ឬភ្លេងការខ្មែរ មានអាយុច្រើនសតវត្សរ៍មកហើយមែន ប៉ុន្តែចំពោះទម្រង់ល្ខោនភ្លេងការនេះវិញ គឺទើបតែកើតមានឡើងនៅក្នុងអំឡុងឆ្នាំ ១៩៨០ ឬក្រោយនោះបន្តិចប៉ុណ្ណោះ? ពិសេសគឺក្នុងពេលដែលសិល្បករ សិល្បការិនីរបស់យើងគ្រប់មុខជំនាញ ដែលសេសសល់ពីការកាប់សម្លាប់នៃរបបប្រល័យពូជសាសន៍ប៉ុលពត ត្រូវប្រឡងយកសញ្ញាប័ត្របញ្ជាក់ការសិក្សា និងជាការរើរំពុកឡើងវិញ នូវមុខជំនាញតាមការចេះចាំរៀងខ្លួន ឬតាមចំណង់ចំណូលចិត្តរបស់ខ្លួន ដើម្បីជាកម្រិតបញ្ជាក់អំពីសមត្ថភាពសិល្បករយើងម្នាក់ៗ ក្នុងការបំពេញបែបបទចូលបម្រើការងាររបស់រដ្ឋយើង ពិសេសខាងវិស័យសិល្បៈទស្សនីយភាពនោះឯង។

ម្យ៉ាងទៀត យើងក៏សង្កេតឃើញដែរថា ច្រើនឆ្នាំកន្លងផុតមកហើយនោះ ពោលគឺមុនពេលដែលទម្រង់ល្ខោនភ្លេងការ បានកើតឡើងជារូបរាងដាច់ដោយឡែកតែឯងនេះបទភ្លេងការមួយចំនួនតូច ក៏ធ្លាប់ត្រូវទម្រង់ល្ខោនដទៃទៀតដូចជាយីកេជាដើមខ្ចីមកប្រើខ្លះៗដែរ ដូចជាក្នុងយីកេរឿងទុំទាវ យីកេរឿងម៉ាក់ថឺង ពិសេសគឺត្រង់អន្ទើមនោសញ្ចេតនា នៃតួអង្គដែលមានភាពតឹងតែងពិបាកបំផុត និងរកបទយីកេមកបំពេញឲ្យត្រូវទៅតាមមនោសញ្ចេតនានោះបាន។ ចំណុចនេះក៏ប្រហែលជាចំណុចមួយយ៉ាងសំខាន់ផងដែរ ដែលជួយជំរុញឲ្យអ្នកច្នៃប្រឌិតគិតបង្កើតជាទម្រង់ល្ខោនភ្លេងការដាច់ដោយឡែកនេះឡើងបាន។

សូមបញ្ជាក់ជូនថា ការសាកល្បងបង្កើតល្ខោនភ្លេងការ ឲ្យទៅជារូបរាងទម្រង់ល្ខោនមួយដាច់ដោយឡែកឡើង ជាដំបូងគេនោះគឺអ្នកស្រី ឈឹម វត្តី និងដោយមានការជួយជ្រោមជ្រែងពីសិល្បករ រៀមច្បងមួយចំនួនផង បានលើកយក

www.elibraryofcambodia.org

រឿងខណ្ឌស្វា ខណ្ឌស្នេហ៍មកសម្ដែងក្នុងឱកាសប្រឡងនោះឯងរួចក្រោយមក សម្ដែងជូនទស្សនិកជននៅភ្នំពេញនេះបានច្រើនលើកផងដែរ បានទទួលជោគជ័យធំធេង គួរជាទីសប្បាយរីករាយយ៉ាងក្រៃលែងៗ

ប៉ុន្តែក្រោយពីពេលនោះបន្តិច ទម្រង់ល្ខោនភ្លេងការនេះ ហាក់ត្រូវស្ថិតក្នុងសភាពស្ងប់ស្ងៀម ឬក៏ត្រូវរលត់សូន្យទៅវិញ ដោយមិនមានមូលហេតុច្បាស់លាស់ ថ្វីដ្បិតតែទម្រង់នេះ ធ្លាប់បានទទួលជោគជ័យធំធេង ទទួលការពេញចិត្តពេញថ្លើមពីទស្សនិកជនពិតមែនក៏ដោយ ។

ក្នុងការសិក្សាដើម្បីស្វែងយល់អំពីបញ្ហាស្ងប់ស្ងៀម ឬបាត់បង់ទៅវិញ នៃទម្រង់ល្ខោនភ្លេងការនេះ មានមតិអ្នកនិពន្ធ និងអ្នកដឹកនាំរឿងល្ខោនមួយចំនួនយល់ថា ការដែលយកភ្លេងការជា **«ភ្លេងសក្ការៈ ភ្លេងមង្គល»** ក្នុងជីវិតខ្មែរ មានបទរាប់រយបទ និងមានទំនុកច្រៀងច្បាស់លាស់ ហើយមានតួនាទីយ៉ាងសំខាន់ជាប់ទៅនឹងពិធីនីមួយៗ ដាច់ៗពីគ្នា ដែលបុព្វបុរសដូនតាខ្មែរបានកំណត់ទុកឱ្យមករាប់ពាន់ឆ្នាំមកហើយនោះ មកធ្វើជាទម្រង់ល្ខោនសម្រាប់តែកម្សាន្ត ដោយយកបទភ្លេងទាំងឡាយនោះមកសរសេរទំនុកថ្មី ប្រហែលជាអាចជះឥទ្ធិពលមិនល្អដល់ពិធីអាពាហ៍ពិពាហ៍មង្គលការខ្មែរជាក់ជាមិនខាន ក្នុងកាលអនាគតវែងឆ្ងាយទៅមុខ ដែលជាប្រការគួរតែជៀសវាងៗ

គឺប្រហែលជា ដោយសារមានគំនិតដូចបានពោលខាងលើនេះ ហើយទើបគ្មានអ្នកនិពន្ធណាម្នាក់បន្តស្នាដៃល្ខោនភ្លេងការនេះ ហើយទម្រង់នេះក៏ត្រូវសាបសូន្យ ឬស្ងប់ស្ងៀមទៅវិញរហូតមកដល់សព្វថ្ងៃ ៕

www.elibraryofcambodia.org

# ១៦-ល្ខោននិយាយ



www.elibraryofcambodia.org

## ប្រវត្តិល្ខោននិយាយ

បើយើងសាកល្បងពីផ្នែក ប្រយោគលើការនិទានរឿង ពិសេសរឿងរាមកេរ្តិ៍ ដែលជាប្រភេទទេវកថារៀបរាប់អំពីមហិទ្ធិឫទ្ធិព្រះរាមអវតារ ព្រះនារាយណ៍ ដែលសិល្បករតែម្នាក់ សម្តែងជាពាក្យសម្តី ធ្វើគ្រាប់ជំនួសឲ្យតួអង្គជាច្រើនក្នុងសាច់រឿង ឬ ប្រយោគទៅលើព្រះធម៌ទេសនា ប្រយោគលើទម្រង់សិល្បៈស្បែកតូចហៅអាយ៉ងដែលក្រៅពីបទភ្លេង និងទំនុកច្រៀងនៅមានពាក្យសម្តីនិយាយឆ្លើយឆ្លងគ្នាយ៉ាងច្រើនក្នុងពេលសម្តែងម្តងៗនោះ យើងអាចសន្និដ្ឋានបានថា ទម្រង់ល្ខោននិយាយមានកំណើតពីយូរលង់ណាស់មកហើយដែរនៅប្រទេសកម្ពុជានេះ ប៉ុន្តែទម្រង់នេះមិនសូវបានរីកចម្រើនឡើយ។ រហូតមកដល់អំឡុងឆ្នាំ ១៩៤៩ សាស្ត្រាចារ្យជនជាតិបារាំងដែលបង្រៀនអក្សរសិល្ប៍បារាំងនៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ពិសេសគឺសាស្ត្រាចារ្យ ហ្គីប៉ូរ៉េ (Gui Poreé) បាននាំសិស្សសម្តែងអត្ថន័យនានានៃរឿងទាំងឡាយដែលគាត់បង្រៀន ឬក៏នាំសិស្សដំឡើងរឿងខ្លីៗ មានពាក្យសម្តីនិយាយឆ្លងឆ្លើយគ្នាគួរឲ្យចាប់អារម្មណ៍ ព្រមដោយមានការដឹកនាំរឿងត្រឹមត្រូវផងហើយរឿងទាំងនេះច្រើនតែត្រូវបានគេជ្រើសរើសយកទៅសម្តែងក្នុងពិធីបុណ្យបញ្ចប់ឆ្នាំសិក្សានីមួយៗ ដែលមានពិធីចែករង្វាន់ដ៏អឺកអធិកផងនោះ ធ្វើឲ្យទស្សនិកជនខ្មែរដែលបានចូលរួមមើលការសម្តែង និងសិស្សានុសិស្សចាប់អារម្មណ៍យ៉ាងខ្លាំងៗ

ដោយហេតុយោលទៅលើទម្រង់ល្ខោនថ្មីនេះ យកការនិយាយគឺការប្រើពាក្យសម្តីនិយាយជាធំនោះ ទើបទស្សនិកជនទាំងអស់សន្មត ហៅឈ្មោះទម្រង់ល្ខោននេះថា ជាល្ខោននិយាយតាំងពីពេលនោះមក។

ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមបញ្ជូននិស្សិតខ្មែរ ឲ្យទៅរៀនមុខវិជ្ជាល្ខោននៅប្រទេសបារាំង និងប្រទេសដទៃទៀត។

www.elibraryofcambodia.org

ក្រោយពេលនោះបន្តិច ប្រមាណដល់ឆ្នាំ ១៩៥៦ ក្រសួងសិក្សាធិការជាតិ ក៏បានប្រមូលគរុសិស្ស នៃវិទ្យាស្ថានជាតិគរុកោសល្យមួយចំនួនឲ្យហាត់មុខវិជ្ជាល្ខោននិយាយនេះជាផ្លូវការឡើង ហើយរហូតមកដល់អំឡុងឆ្នាំ ១៩៥៩ ទើបក្រសួងសិក្សាធិការជាតិនេះ ចាប់ផ្តើមបើកសាលាជាតិផ្នែកល្ខោន (សាលាល្ខោនជាតិ)ដែលមានទីតាំងដំបូងនៅម្តុំវត្តភ្នំ រួចមកនៅសាលារចនា រាជធានីភ្នំពេញក្នុងគោលបំណងជំរុញមុខជំនាញល្ខោននិយាយនេះ ឲ្យរីកចម្រើនឡើងព្រមគ្នាជាមួយសាលាជាតិផ្នែកតូរ្យតន្ត្រីៗ

តាំងពីពេលដែលសាលាជាតិផ្នែកល្ខោនបានកើតឡើង (១៩៥៩) រហូតដល់ពេលបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ(១៩៦៤) មកទល់មុនពេលដែលរបបប្រល័យពូជសាសន៍ដណ្តើមឡើងកាន់អំណាចបាន យើងសង្កេតឃើញថាទម្រង់ល្ខោននិយាយនៅប្រទេសកម្ពុជាទាំងល្ខោននិយាយលើឆាកទាំងល្ខោននិយាយតាមវិទ្យុ ទាំងល្ខោននិយាយតាមទូរទស្សន៍ បានរីកចម្រើនយ៉ាងខ្លាំងក្លាៗ ក្នុងរយៈពេលនោះ យើងមានអ្នកនិពន្ធ និងអ្នកដឹកនាំរឿងល្ខោនយ៉ាងចំណាញៗដូចជា លោក ហង្ស ធុនហាក់, លោក ពៅ យូឡេង, លោក អ៊ុំ ឈឹង, លោកមាស គគា, លោកឆេង ផុន, លោកហង្ស ជួន, លោកឌួន គាង, លោកលី គឹមអួង, លោក ហួត គឹមលាង, លោក ហ៊ីង ប៊ុនថុន, លោក ប៉ុល សំអឿន, លោក ជីគសំផេង, អ្នកស្រី អ៊ូ ចាន់ថន ជាដើម ព្រមទាំងបណ្តុះបណ្តាលបានអ្នកនិពន្ធ និងអ្នកដឹកនាំរឿងល្ខោនជំនាន់ក្រោយជាច្រើននាក់ទៀតផង ដែលអាចនិពន្ធល្ខោននិយាយសម្រាប់សម្តែងលើឆាកល្ខោន និយាយសម្រាប់ទូរទស្សន៍ និងល្ខោន-និយាយសម្រាប់វិទ្យុទៀតផងៗ

ក្នុងដំណាក់កាលរីកចម្រើន របស់ទម្រង់ល្ខោននិយាយនៅប្រទេសកម្ពុជានេះសិល្បករល្ខោននិយាយ ទាំងអស់ បានដំឡើងរឿងជាច្រើនដូចជារឿង ÷

- ដើមឆ្កក្សាជាតិ
- ចំពៀនបញ្ចាំចិត្ត

www.elibraryofcambodia.org

- ល្បិចស្នេហាស្រុកស្រែ
- ពុទ្ធប្រវត្តិ
- ពុទ្ធិសែនកន្ធើ
- កុលាបប៉ៃលិន
- រឿងលោហិតតែមួយ
- ស្អីងកម្ចាយមារ
- ព្រះគោព្រះកែវ
- កូនអ្នកណា?
- ផ្កាស្រពោន
- ថៅកែចិត្តចោរ
- វង្សត្រកូលកម្សត់
- ព្រះវេស្សន្តរ
- សុវណ្ណសាម
- ប្រាង្គសិលាកញ្ញាអន្តរ
- ថ្មពាំ
- សោកណាកគ្រី
- សព្វសិទ្ធ
- រៀបចំរួងយើងៗលៗ

ហើយបានធ្វើកម្មវិធីដើរសម្ដែងជូនសិស្សានុសិស្ស និងសាធារណជនជាអ្នកទៅតាមខេត្ត-ក្រុង ស្រុកនៅទូទាំងប្រទេសជារៀងរាល់ឆ្នាំផងៗ

មិនត្រឹមតែរឿងខ្មែរ ដែលជាជាតិរបស់ខ្លួនប៉ុណ្ណោះទេ ក្រុមសិល្បករ និងសិល្បការិនី ផ្នែកល្ខោននិយាយរបស់ខ្មែរក៏មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការរំលេច និងសម្ដែងរឿងបរទេសពិសេសគឺស្នាដៃរបស់អ្នកនិពន្ធធំៗ និងល្បីល្បាញក្នុងពិភពលោកមានលោក សេក ស្ពៀរ (Shakespeare) លោក ម៉ូ លីយែរ (Molière) និងអ្នកនិពន្ធបរទេសដទៃទៀតច្រើនផងៗ ដាក់ស្ដែងក្រុមនេះបានសម្ដែងរឿង៖

- ហាំលែត (Hamlet) (Shakespeare)
- ជនកំណាញ់ក្រៅតម្រា (Molilère)
- រ៉ូម៉េអូ. ស៊ូលីយ៉េត (Shakespeare)
- ហ្សកដង់ដាំង (Molière)
- សុបិននិម្មិតនាវស្សន្តរដូវ (Shakespeare)

www.elibraryofcambodia.org

- អ្នកស្រីដែលមានកូនខ្ចី
- ស្គរធំ ផាដើម។

ប៉ុន្តែជាប្រការគួរឲ្យសោកស្តាយពន់ពេកណាស់ ទម្រង់ល្ខោនក៏ដូចទម្រង់សិល្បៈខ្មែរដទៃទៀតដែរ ត្រូវបានបេបប្រល័យពូជសាសន៍រំលាយខ្ទេច ដោយសម្លាប់អ្នកនិពន្ធអ្នកដឹកនាំរឿង និងសិល្បករ ល្ខោននិយាយ ទាំងស្រីទាំងប្រុសស្ទើរអស់គ្មានសល់ៗ

ក្រោយពីបេបប្រល័យពូជសាសន៍ដួលរលំទៅ នៅសិល្បករផ្នែកនេះ (ភាគតិចបំផុត) ដែលឆ្លងរួចពីការកាប់សម្លាប់បាននាំគ្នាខំប្រឹងប្រែង ធ្វើឲ្យទម្រង់ល្ខោននិយាយបានរស់រានមានជីវិតឡើងវិញៗ ប៉ុន្តែ តាំងពីឆ្នាំ១៩៧៩ រហូតមកដល់ ១៩៩៩ ទម្រង់ល្ខោននិយាយនៅប្រទេសកម្ពុជា នៅតែមិនទាន់មានកម្រិត (រីកចម្រើន) ដូចពេលមុនសង្គ្រាម ឆ្នាំ ១៩៧០ នៅឡើយទេ។

www.elibraryofcambodia.org

# ១៧-ល្ខោនចម្រុះ



www.elibraryofcambodia.org

## ប្រវត្តិល្ខោនចម្រុះ (Théâtre Total)

ល្ខោនចម្រុះ គឺជាឈ្មោះទម្រង់ល្ខោនថ្មីមួយ ដែលបានកកើតឡើងដើម្បីរួមចំណែកលើកកម្ពស់មោទនភាពជាតិខ្មែរ ក្នុងរយៈកាលរីកចម្រើនមួយគួរឲ្យកត់សម្គាល់នោះគឺសម័យសង្គមរាស្ត្រនិយមក្នុងទសវត្សរ៍ឆ្នាំ១៩៦០នោះឯង។ ក្នុងរយៈកាលនេះ ខ្មែរមានពេលដកដង្ហើមធូរដើមទ្រូង ដោយប្រទេសជាតិមានសុខសន្តិភាពពេញបរិបូរណ៍ ដែលជាទូទៅគេនិយមឲ្យរហស្សនាមដល់ប្រទេសជាតិកម្ពុជាថា «**កោះសន្តិភាព**»។ ប្រជារាស្ត្រខ្មែរបានរស់ដោយ សុភមង្គល សុខដុមរមនា សង្គមខ្មែរជាសង្គមប្រកបដោយសីលធម៌ខ្ពស់ ជាសង្គមមានធម៌មេត្តា ករុណា សន្តោសប្រោសប្រណី និងមានសាមគ្គីភាពល្អប្រពៃ គឺសាមគ្គីទាំងពាក្យសម្តី សាមគ្គីទាំងចិត្តនិងសាមគ្គីទាំងអំពើធ្វើឲ្យខ្មែរមានឱកាសដ៏ប្រសើរអាចកសាងជាតិមាតុភូមិរបស់ខ្លួនលើគ្រប់វិស័យ ការកសាងធនធានមនុស្សក៏បានច្រើន សេដ្ឋកិច្ចក៏រីកចម្រើនទេសចរណ៍ វប្បធម៌សិល្បៈ និងកីឡាក៏មានកម្លាំងខ្លាំងក្លា ពោលគឺក្នុងរយៈកាលនោះខ្មែរអាចសាងជាតិ ទាំងសង្គមធម៌ ទាំងវប្បធម៌ឲ្យដើរលឿនទៅមុខព្រមគ្នាក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់នៃព្រះករុណា ព្រះបាទ ឧកោត្តមសីហនុវរ្ម័នដែលកាលណោះព្រះអង្គទ្រង់គង់ជាព្រះប្រមុខរដ្ឋអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម ដែលធ្វើឲ្យកិត្តិសព្ទនៃមាតុភូមិយើងក្រអូបល្បីរន្ទឺ ពុពាសពេញតំបន់អាស៊ីអាគ្នេយ៍ទាំងមូល គួរជាទីមោទនៈក្រៃលែង។

ឯពាក្យថា ល្ខោនចម្រុះគឺជាពាក្យដែលសិល្បករខ្មែរ និងប្រជារាស្ត្រខ្មែរប្រើសម្រាប់សម្គាល់ទម្រង់ល្ខោនថ្មីនេះ ព្រោះដោយពិនិត្យឃើញថា ល្ខោនថ្មីជាទម្រង់ល្ខោនដែលបានប្រមូលនូវធាតុទម្រង់សិល្បៈឯទៀតជាច្រើន មកបូកបញ្ចូលគ្នាដូចជាមានធាតុល្ខោននិយាយយីកេបាសាក់ មានចម្រៀងសម័យ ចម្រៀង ជាពួក។ ចម្រៀងបុរាណ មានតន្ត្រីសម័យ និងតន្ត្រីបុរាណ មានរបាំព្រះរាជទ្រព្យ និងរបាំប្រពៃណីរួមផ្សំផង ហើយក្រោយៗមកទៀតមានសិល្បៈសៀកមានការបញ្ចាំង

www.elibraryofcambodia.org

ស្លាយ (Slide) បញ្ចាំងពីដេអូ ឬក៏មានភាពយន្តឯកសារចូលរួមនៅក្នុងសាច់រឿងតែម្តងបន្ថែមទៀតផងដែរ។

តាំងពីពេលកកើតមកដល់សព្វថ្ងៃ ទម្រង់ល្ខោនចម្រុះនេះ សម្តែងតែរឿងប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ ដែលមានទ្រង់ទ្រាយធំ (Grandiose) ហើយមានសិល្បករចូលរួមច្រើនរយនាក់ ឬពេលខ្លះមាន សិល្បកររាប់ពាន់នាក់ផងក៏មាន។

រឿងដំបូងដែលទម្រង់ល្ខោនចម្រុះនេះសម្តែង គឺរឿងប្រាសាទព្រះវិហារ ដែលនិពន្ធដោយលោក **ហង់ ធន់ហាក់**, លោក **ហាស គត**, លោក **ឆេង ផុន**, លោក **បណ្ឌ មូលីចណ្ឌ**, លោក **ម៉ុល សំអឿន** និងមិត្តភក្តិរបស់លោកជាច្រើនទៀត ដែលបានមុខជំនាញសិល្បៈខុសៗគ្នា រួមគ្នាកសាងឡើងដោយរៀបរាប់ពីព្រឹត្តិការណ៍បច្ចុប្បន្នភាពដ៏សំខាន់មួយ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ នោះគឺព្រឹត្តិការណ៍ដែលតុលាការអន្តរជាតិដ៏យុត្តិធម៌ នាក្រុងឡាអេ (La Haye) បានកាត់សេចក្តីដាក់កំហិតឲ្យប្រទេសថៃ ដែលជាអ្នកឈ្លានពាន ប្លន់ទឹកដី និងសម្បត្តិវប្បធម៌របស់ខ្មែរ ប្រគល់ប្រាសាទព្រះវិហារមកឲ្យខ្មែរ ដែលជាម្ចាស់ដើមវិញ។ រឿងនេះសម្តែងនៅវាលព្រះមេរុ។

ឯរឿងទី២ គឺរឿងព្រះបាទជ័យវរ្ម័នទី ៧ ដោយលើកយកដំណាក់កាលរីកចម្រើនក្នុងសម័យមហានគរ ពិសេសក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ រួចបន្តភ្ជាប់មកសម័យសង្គមរាស្ត្រនិយម ដែលជាអ្នកបន្ត មរតកដ៏ល្អប្រពៃរបស់ដូនតាពីសម័យអង្គរមក។ រឿងនេះនៅពហុកីឡាដ្ឋានជាតិអូឡាំពិក មានសិល្បកររាប់ពាន់នាក់ចូលរួម។

ប៉ុន្តែចាប់ពីឆ្នាំ ១៩៧០ មក ល្ខោនចម្រុះត្រូវបញ្ចប់ដោយសង្គ្រាមស៊ីវិលបានផ្ទុះឡើង។ មោទនភាពនៃសម័យសង្គមរាស្ត្រនិយម ក៏ប្រែក្លាយទៅជាស្រមោលអតីតកាលមួយរំពេច។ អ្នកនយោបាយជ្រុលនិយមដែលស្រលាញ់មនោគមវិជ្ជាបរទេសជាងស្រលាញ់ជាតិមាតុភូមិ បានទំលាក់សម្តែងឫទ្ធិឃោរឃៅរបស់ខ្លួន សាងក្តីអាម៉ាស់

www.elibraryofcambodia.org

សាងក្តីឈឺចាប់ សាងឈ្មោះថោកទាបឲ្យជាតិខ្មែរ នៅចំពោះមុខភ្នែកមនុស្សជាតិ ដែលធ្វើឲ្យគេស្អប់ខ្ពើមរអើម និងមាក់ងាយមាក់ថោកជាតិខ្មែរយ៉ាងក្រៃលែង ។

មកដល់ឆ្នាំ១៩៨៣ គឺ ៤ឆ្នាំ ក្រោយពីរបបប្រល័យពូជសាសន៍ដួលរលំទៅ ទើបទម្រង់សិល្បៈល្ខោនចម្រុះបានរស់ឡើងវិញដោយចាប់ផ្តើមឡើងពីរឿង **«ដំណើរជាតិកម្ពុជា»** និពន្ធដោយលោក ឆេង ផុន និងពេជ្រ ទុំក្រាវិល ដែលបានសម្តែងសម្រាប់អបអរសាទរពិធីបុណ្យជាតិផង និងសម្តែងជូនសាធារណជន ជាច្រើនលើកនៅសាលមហោស្រពទន្លេបាសាក់ និងទទួលបានភាពជោគជ័យផងដែរ។

ដោយសារការដក់ចិត្តដិតអារម្មណ៍នឹងរឿងដំណើរជាតិកម្ពុជា គណៈប្រតិភូថ្នាក់ដឹកនាំប្រទេសលាវ ដែលបានចូលរួមក្នុងពិធីបុណ្យជាតិកម្ពុជា នាសម័យនោះ ក៏បានស្នើសុំរដ្ឋាភិបាលខ្មែរ ឲ្យចាត់សិល្បករអ្នកជំនាញមួយក្រុមទៅជួយសហការជាមួយអ្នកជំនាញសិល្បៈលាវដំឡើងរឿងមួយថ្មី នៅប្រទេសលាវ។ ដោយហេតុនេះទើបនៅឆ្នាំ ១៩៨៥ រឿង **«ដំណើរជាតិលាវ»** បានកើតឡើង ដើម្បីអបអរសាទរខួបទី ១០ ទិវាបុណ្យជាតិលាវ នៅទីក្រុងវៀងច័ន្ទ។

ឆ្នាំ ១៩៨៩ រឿងមួយថ្មីទៀត ដែលមានចំណងជើងថា **លោហិតជាតិកម្ពុជា** និពន្ធដោយលោក ឆេង ផុន និងលោក ពេជ្រ ទុំក្រាវិល ត្រូវបាននិពន្ធឡើងដោយសាច់រឿងបានដកស្រង់នូវកំហុសឆ្គងទាំងឡាយ ក្នុងការដឹកនាំប្រទេសជាតិ តាំងពីសម័យបែកអង្គរ (១៣៥៣?) រហូតមកដល់សម័យបច្ចុប្បន្ន ក្នុងន័យយកអតីតកាលជាមេរៀនដល់បច្ចុប្បន្ន និងអនាគតត្រូវបានសម្តែងអបអរបុណ្យជាតិខួបទី ១០ នៅសាលមហោស្រពទន្លេ បាសាក់។

បើគិតមកដល់ឆ្នាំដែលយើងធ្វើការកត់ត្រាពីទម្រង់ល្ខោនចម្រុះ (១៩៩៩) នេះ រឿងចុងក្រោយគេបង្អស់គឺរឿង **«ជីវិតជាតិកម្ពុជា»** និពន្ធដោយលោក ពេជ្រ ទុំ–ក្រាវិល ដែលត្រូវបាននិពន្ធឡើងនៅឆ្នាំ ១៩៩៣ ដែលជាកាលវេលានៃរបត់នយោបាយមួយ ដោយសាច់រឿងបានលើកឡើងពីទំនាស់រវាងខ្មែរ និងខ្មែរពី

www.elibraryofcambodia.org

បំណងល្អរបស់អង្គការសហប្រជាជាតិ ដែលបានចំណាយជីវិតមនុស្ស ទុនជាទ្រព្យធនយ៉ាងច្រើនសន្ធឹកសន្ធាប់ (ជាង ២,០០០ លានដុល្លារ) ដើម្បីទិតទំ **«សាងទំនប់ទប់ឈាមខ្មែរឲ្យឈប់ហូរ»** និងព្រះរាជតម្រិះបង្រួបបង្រួមជាតិ ប្រកបដោយមេត្តាធម៌របស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងព្រះបា.ទ នរោត្តម សីហនុ ដែលទិតទំ **«ជូតទឹកភ្នែកខ្មែរ ជាកូនចៅ ឲ្យស្ងួតស្អាត»** ៚

# ១៨-ការនិទានរឿង



www.elibraryofcambodia.org

# ប្រវត្តិការនិទានរឿង

ក៏ដូចនៅប្រទេសជាច្រើនក្នុងពិភពលោកដែរ ការនិទានរឿងនៅប្រទេសកម្ពុជា គឺជាទំនៀមមួយ ដែលមានអាយុតាំងពីយូរលង់ណាស់មកហើយ ហើយមានប្រជាប្រិយភាពទៀតផង។

ជីតា ឬជីដូននិទានរឿងពីធម្មជាតិនៅជុំវិញខ្លួន ដូចជាប្រវត្តិភ្នំ ទន្លេ សមុទ្រ ជ្រោះជ្រងជ្រលងដងអូរ ប្រវត្តិប្រាសាទ ឬប្រវត្តិអារក្ខ អ្នកតាម្ចាស់ទឹកម្ចាស់ដី ដែលគេជឿថា មានឫទ្ធិបារមីធំធេងតែងតែបានផ្តល់ក្តីសុខចម្រុងចម្រើនដល់ប្រជានុរាស្ត្រជាកូនចៅក្នុងភូមិស្រុក ក្នុងតំបន់ ហើយមានលក្ខណៈប្លែកៗគួរឲ្យចងចាំដូចជារឿងលោកតាក្បាលប្រាំបី ដែលស្ថិតក្នុងកោះមួយតាមបណ្តោយដងទន្លេសាប ដែលអ្នកស្រុកមានជំនឿមុតមាំថា ជាអ្នកតាចាស់ស្រុកដែលតែងតាមជួយថែរក្សាកូនចៅឲ្យបានសុខសប្បាយគ្រប់ពេលវេលា ពិសេសក្នុងពេលមានគ្រោះកាសន្ន ហើយធ្លាប់មានក្រពើយ៉ាងធំជាទូក ជាជំនិះរបស់លោកតាថែមទៀតផង។

យប់មួយ លោកតាបានមកពន្យល់សប្តិ៍ អ្នកស្រុកម្នាក់ (ជារូបដែល លោកតាតែងផ្តល់ដំណឹង) ថាលោកតាបានភ្នាល់ឈ្នះបានទូកមួយ ដែលមានទំហំធំប៉ុនគ្នានឹងទូកចាស់? ហើយលោកតា និងសាកល្បងប្រណាំងទូកទាំងពីរនេះមើល ថាតើទូកចាស់ និងទូកថ្មី តើទូកមួយណាខ្លាំងជាង?(ការប្រណាំងទូក) របស់លោកតា គឺការប្រខាំ ឬប្រជល់ប្រពើ)។

រំលងពីពេលយល់សប្តិបានមួយថ្ងៃពីរ ថ្ងៃមួយពេលព្រះអាទិត្យចាប់ផ្តើមរះក្រហមព្រឿងៗនៅទិសខាងកើត ក្រពើយ៉ាងធំអស្ចារ្យពីរបានខាំគ្នា នៅខាងទន្លេធ្លុប ស្ថិតខាងកើតកោះ ដែលមានបណ្តោយប្រមាណពីរ ឬបីមួយគីឡូម៉ែត្រធ្វើឲ្យទឹកទន្លេបែកកក់ល្អក់ខ្វល់ ហើយមានរលកគ្រាំគ្រេងបោកខ្ទាលៗ ឡើងមកដល់ពាក់កណ្តាលខ្ទបដែលជាចម្ការដាំដំណាំ ៗ ក្រពើទាំងពីរនោះបោកប្រជែញប្រខាំហែកហួរ ប្រយុទ្ធគ្នាយ៉ាងអស់ទំហឹង ពេញមួយថ្ងៃតាំងពីពេលព្រឹកព្រលឹមស្រាងៗ

www.elibraryofcambodia.org

រហូតដល់ថ្ងៃជិតលិចទើបស្ងប់ស្ងាត់ៗ យប់នោះលោកតា បានមកពន្យល់សប្តិអ្នកស្រុកដដែលនោះម្តងទៀត ដោយបាននិយាយប្រាប់ថា ទូកថ្មីចាញ់ទូកចាស់របស់លោកតាហើយៗ លុះពេលព្រឹកព្រលឹមថ្ងៃស្អែកឡើង ទើបអ្នកស្រុកបានឃើញក្រពើដ៏ធំអស្ចារ្យមួយ «ប៉ុនទូកថែវ?» ស្លាប់អណ្តែតផ្ងារពោះតាមទន្លេដែលជាសន្សៀន ឬទីលានប្រជល់ក្រពើខាងមុខរោងលោកតានោះៗ

ឯរឿងទាំងឡាយដែលទាក់ទង និងសាសនាព្រាហ្មណ៍វិញដូចជា រឿងមហាភារតយុទ្ធ ឬរឿងរាមាយណៈដែលនិពន្ធដោយមហាកវីវាល្មីកិ (តាមជួន ណាត) ក្នុងអំឡុង ព.ស ៧៥០ ដើម្បីផ្សព្វផ្សាយពីឥទ្ធិពល នៃព្រហ្មញ្ញសាសនានោះ។គេជឿថាបានហូរចូលមកប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប្រទេសកម្ពុជា និងប្រទេសដទៃទៀតតាំងពីយូរលង់ណាស់មកហើយ តាមរយៈពួកព្រាហ្មណ៍ដែលមកធ្វើជំនួញជួញដូរផង និងមកផ្សាយសាសនារបស់ខ្លួននៅក្នុងតំបន់នេះផងៗ

មិនខុសពីការសាងប្រាសាទនៅប្រទេសកម្ពុជា ដែលពីដំបូងយើងរៀន ឬទទួលឥទ្ធិពលពីឥណ្ឌា ហើយក្រោយមកខ្មែរបានធ្វើឲ្យមានការវិវឌ្ឍរីកចម្រើនរហូតដល់អាចសាងប្រាសាទអង្គរវត្ត ដែលមានលក្ខណៈជាខ្មែរ ហើយបានក្លាយជាអច្ឆរិយវត្ថុក្នុងលោកនោះឡើយៗ ចំពោះការនិទានរឿង គឺពីដំបូងខ្មែរបានស្តាប់ជឿហើយទទួលយកការទេស ឬនិទានរឿងរាមយណៈរបស់ពួកព្រាហ្មណ៍ក្នុងទស្សនៈលោកធាតុឥណ្ឌាៗ ហើយក្រោយមក ពីមួយថ្ងៃទៅមួយថ្ងៃពីជំនាន់មួយទៅជំនាន់មួយទៀត ខ្មែរបានកែច្នៃរឿងរាមាយណៈរបស់ឥណ្ឌា ដោយបានបញ្ចេញបញ្ចូលបន្ថែមបន្ថយ នូវអន្ទើផ្សេងៗ ឲ្យអភិវឌ្ឍន៍មករកទស្សនៈលោកធាតុខ្មែរ រហូតដល់កើតបានជារឿងរាមកេរ្តិ៍ ដែលជាផ្ទេកនៃអក្សរសិល្ប៍ខ្មែរ ពាក្យពេចន៍នៃភាសា និងវោហារសាស្ត្រខ្មែរ ជាប្រភពមិនចេះរីងស្ងួតនៃការច្នៃប្រឌិតខាងផ្នែកតែងនិពន្ធ ខាងវិចិត្រកម្ម ខាងសិល្បៈនាដសាស្ត្រមានល្ខោនតូរ្យតន្ត្រីចម្រៀង និងរបាំយ៉ាងច្រើនសន្ធឹកសន្ធាប់ថែមទៀតផងៗ

www.elibraryofcambodia.org

ក្នុងស្មារតីធ្វើឲ្យរាមាយណៈឥណ្ឌា មានការអភិវឌ្ឍមករកពណ៌សម្បុរជាខ្មែរ ដោយផ្អែកលើលក្ខណៈភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ណាដ៏ចំណូលចិត្តរបស់ខ្លួននេះ ពោលគឺខ្មែរបាននិទាន ដោយបានបន្ថែមបន្ថយខ្លះ បានធ្វើឲ្យរឿងរាមកេរ្តិ៍ខ្មែរមានអន្លើខុសប្លែកពី រឿងរាមាយណៈឥណ្ឌាយ៉ាងច្រើន ឧទាហរណ៍ដូចជាអន្លើនាងបុញ្ញកាយ ដែលជាកូនស្រីរបស់ពិភេក ជាប្អូនបង្កើតរបស់ក្រុងរាពណ៍ ដែលបានមកសុំចុះចូលក្នុងទ័ពរបស់ព្រះរាម ហើយនាងបុញ្ញកាយនេះបានត្រូវក្រុងរាពណ៍ ជាឪពុកធំបញ្ជាឲ្យមកធ្វើចារកិច្ច ក្លែងខ្លួនជាសាកសពនាងសីតា អណ្តែតទឹកមកព្រះពន្លាព្រះរាម ក្នុងបំណងបំភាន់ឲ្យព្រះរាមយល់ច្រឡំថានាងសីតាជាមហេសីព្រះអង្គសុគតហើយ ទីបំផុតសាកសពនាងសីតា(បុញ្ញកាយក្លែង)ត្រូវហនុមាន និងពលស្វាយកទៅដុតសាកល្បង ដើម្បីឲ្យដឹងច្បាស់ថា ជាសាកសពនាងសីតា ឬមិនមែន?ៗ

ដោយទ្រាំនឹងកម្តៅភ្លើងមិនបាន នាងបុញ្ញកាយក៏បន្ទំហោះ រត់គេចទៅតាមផ្សែងតែត្រូវហនុមាន ជាមេទ័ពដ៏ឆ្លាតវាងវៃ និងក្លាហាន របស់ព្រះរាមចាប់បាន រួចយកមកធ្វើទោសសួរចម្លើយៗ ក្រោយមកព្រះរាមទ្រង់ជ្រាបថា នាងបុញ្ញកាយជាបុត្រីរបស់ពិភេកហោរា ដែលបានមកសុំជ្រកកោនជាមួយនឹងព្រះអង្គនោះ ព្រះអង្គក៏បញ្ជាឲ្យហនុមាននាំនាង ជាសម្ងាត់ទៅក្រុងលង្កាវិញ មិនឲ្យពិភេកហោរាដឹង ហើយទីបំផុត នាងបុញ្ញកាយ ក៏បានធ្លាក់ចូលក្នុងអន្ទាក់ស្នេហារបស់ហនុមាន មុនពេល ទៅដល់ក្រុងលង្កាវិញនោះៗ សុំបញ្ជាក់ថា អន្លើនាងបុញ្ញកាយក្នុងរឿងរាមកេរ្តិ៍ខ្មែរនេះ មិនឃើញមានក្នុងរឿងរាមាយណៈរបស់ឥណ្ឌាទេ ហើយយើងជឿថានៅមានអន្លើជាច្រើនទៀត ដែលមានចំណុចខុសគ្នារវាងរឿងរាមាយណៈឥណ្ឌា និងរឿងរាមកេរ្តិ៍ខ្មែរនោះៗ

មិនត្រឹមតែប៉ុណ្ណោះទេ តួអង្គព្រះរាម ដែលមនុស្សជាទូទៅជឿថា ជាអវតាររបស់ព្រះនារាយណ៍ ឬព្រះវិស្ណុនោះ ត្រូវបានខ្មែរបន្ថែមតួនាទី ជាតួអង្គព្រះពោធិ

សត្វ របស់ព្រះពុទ្ធអង្គ តាមទស្សនៈខ្មែរ ក្នុងពេលដែលខ្មែរកាន់ព្រះពុទ្ធសាសនា ថែមទៀតផង។ ក្រៅពីហៅតួអង្គព្រះរាមថា ព្រះនារាយណ៍រាមា គេនៅសម្គាល់ព្រះអង្គដោយពាក្យពន្សពុទ្ធសន្តានពុទ្ធង្កូរ សារព៌ជ្ញាញាណ ឬពាក្យព្រះពោធិសត្វ ជាកស្តុតាងបញ្ជាក់គំនិតនេះផង។ ឯគំនូរវិចិត្រកម្មរឿងរាមកេរ្តិ៍ជាច្រើនដែលគេគូរលើជញ្ជាំងព្រះវិហារ ព្រះពុទ្ធសាសនា ដូចនៅវត្តព្រះរាជបូណ៌ខេត្តសៀមរាប ឬក្នុងថែវព្រះវិហារ ព្រះកែវមរកតក្រុងភ្នំពេញ ក៏ស្ថិតនៅក្នុងស្មារតីនេះដែរម្យ៉ាងទៀត តួអង្គព្រះរាមក្នុងរឿងរាមាយណៈឥណ្ឌាពោរពេញទៅដោយលក្ខណៈទេវៈ ឯព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរ ហាក់មានលក្ខណៈជាមនុស្សសាមញ្ញយ៉ាងច្រើន ដោយព្រះរាមចេះខឹងសម្បាប្រឡាត គោតតួងចង់យកទោសហនុមាន និងអង្គទ ពេលព្រះអង្គឃើញសាកសពនាងសីតា (បុញ្ញកាយក្លែង)អណ្តែតទឹកមកដល់ព្រះពន្លាព្រះអង្គ ដោយទ្រង់ជឿថា ហេតុដែលបណ្តាលឲ្យនាងសីតាសុគត គឺដោយសារតែហនុមានបានធ្វើឲ្យក្រុងរាពណ៍ខឹង ព្រោះហនុមានបានអនុវត្តហួសបញ្ជារបស់ព្រះអង្គ រហូតដល់ធ្វើឲ្យឆេះក្រុងលង្កា។។

-ព្រះរាមចេះទួញសោកកើតទុក្ខរីងរៃ (ទ្រង់វិយោគសោយសោក រហូតដល់ដួលសន្លប់បាត់ស្មារតី ប្រែបព្រះលក្ខណ៍អនុជ ដែលត្រូវសរព្រហ្មាស របស់ឥន្ទជិត? (ក្នុងពេលដែលព្រះរាមព្រះអង្គឯងទំរាំងកសរតែដកមិនរួច)។

-ព្រះរាមចេះគួតករកុហកបោកប្រាស (ព្រះរាមចូលគោជិបញ្ឆោត នាងសីតា?)។

យើងមានជំនឿជឿជាក់ថា ទំនៀមនៃការនិទានរឿងរាមកេរ្តិ៍ ប្រាកដជាមានវត្តមានជានិច្ចតាំងពីសម័យមុនអង្គរ ក៏ដូចជាសម័យអង្គរ ដែលមានរូបចម្លាក់រឿងរាមកេរ្តិ៍យ៉ាងច្រើនសន្ធឹកសន្ធាប់លើជញ្ជាំង ឬផ្តែរប្រាសាទនានា ពិសេសប្រាសាទអង្គរវត្ត រហូតមកដល់បច្ចុប្បន្ននេះ។

ចំណែករឿងដែលទាក់ទងខាងព្រះពុទ្ធសាសនាវិញ ក៏ដូចគ្នានេះដែរ គឺត្រូវបានព្រះសង្ឃទេសនា ឬអាចារ្យលើកយករឿងទាំងឡាយដូចជាពុទ្ធប្រវត្តិ ឬរឿង

www.elibraryofcambodia.org

ជាតកផ្សេងៗ មានរឿងព្រះវេស្សន្តរ រឿងតេមិយកុមារ រឿងសុវណ្ណសាមជាដើម។ល។ មកនិទានផ្សព្វផ្សាយឲ្យពុទ្ធសាសនិកទាំងអស់បានជ្រួតជ្រាប។

ពេលខ្លះជីដូន ឬជីតានិទានប្រវត្តិវត្តនៅភូមិយើងឲ្យចៅស្តាប់ ដូចប្រវត្តិវត្តតាមាស ឬវត្តលិចស្ថិតនៅលើកោះមួយបណ្តោយតាមដងទន្លេសាប ដែលមានលក្ខណៈខុសប្លែកពីវត្តដទៃទាំងអស់ក្នុងស្រុកខ្មែរ ដោយវត្តនេះបែរមុខទៅទិសខាងលិច។ ជីដូនបានប្រាប់ចៅឲ្យដឹងថា កាលពីយូរលង់ណាស់មកហើយ ពេលដែលចាប់ផ្តើមកសាងវត្តនេះ អ្នកស្រុកនាំគ្នាកសាងដោយដាក់ព្រះអង្គធំ បែរព្រះភក្ត្រទៅទិសខាងកើតដូចវត្តឯទៀតដែរ។ ប៉ុន្តែដល់ពេលយប់ស្ងាត់មានហ្វូងដំរីដែលដឹកនាំដោយដំរីសមួយជាមេហ្វូង ឡើងមកពីព្រៃមាត់បឹងទន្លេសាបមកលើកព្រះអង្គដាក់បែរព្រះភក្ត្រទៅទិសខាងលិចវិញ។ ថ្ងៃក្រោយមក អ្នកស្រុកក៏នាំគ្នាចំប្រឹងគ្រប់លើកព្រះអង្គធំដាក់បែរព្រះភក្ត្រមកទិសខាងកើតដូចពេលមុន តែដល់ពេលយប់ ត្រូវហ្វូងដំរីមកលើកបំបែរព្រះអង្គ ដាក់ព្រះភក្ត្របែរទៅទិស ខាងលិចវិញទៀត។ ដោយមានជំនឿថា នេះជាប្រផ្នូលដែលវត្ថុសក្តិសិទ្ធ ចង់បញ្ជាក់ប្រាប់អ្នកស្រុកកល់គ្នាថា ត្រូវតែដាក់ព្រះអង្គ និងសាងព្រះវិហារ បែរមុខទៅទិសខាងលិច ទើបបានសេចក្តីសុខ ទោះ ទើបអ្នកស្រុកសម្រេច នាំគ្នាកសាងវត្តតាមាស ឬវត្តលិចនេះបែរមុខទៅទិសខាងលិច ដែលយើងអាចឃើញជាក់ស្តែងរហូតមកដល់សព្វថ្ងៃនេះ។ សូមបញ្ជាក់ថា វត្តនេះស្ថិតនៅត្រើយខាងកើតទល់មុខផ្សារកំពង់ហ្លួង ក្នុងស្រុកពញាឮ ខេត្តកណ្តាល ចម្ងាយប្រមាណ ៣៥ គ.ម ពីរាជធានីភ្នំពេញយើងនេះ។

ក្រៅពីការអធិប្បាយខាងលើ ប្រទេសកម្ពុជាមានការនិទានរឿងតាមសាលារៀនដែលគ្រូៗនាំគ្នានិយាយរឿងព្រេងនិទាន ឬរឿងគតិលោកដើម្បីឲ្យសិស្សស្តាប់ ពិសេសកុមារាកុមារីតូចៗក្នុងបំណងបង្កើតការសប្បាយរីករាយផង និងអប់រំឲ្យក្មេងៗចងចាំនូវគំនិតល្អៗផ្សេងៗផង។

www.elibraryofcambodia.org

ម្យ៉ាងទៀតយើងក៏សង្កេតឃើញផងដែរថា នៅរយៈកាលចុងក្រោយនេះ អំឡុងចន្លោះឆ្នាំ (១៩៨០-២០០០) សិល្បៈនិទានរឿងនេះមាន ការរីកចម្រើនយ៉ាងព្រោងព្រាតអស្ចារ្យ ពិសេសនៅតាមភោជនីយដ្ឋាននានា ដែលដាក់ខ្ទង់ហូបចុកកម្សាន្តសប្បាយ ហើយភាគច្រើនវាតែជារឿងកំប្លុកកំប្លែង។ ពេលខ្លះមានលក្ខណៈគ្រោតគ្រាត អាសអាភាស ចំអាសចំអួងធ្វើឲ្យអ្នកស្តាប់ហួសចិត្ត បន្តឲ្យមានការសើចហោកញ្ញៀវខ្សៀវខ្សារ សប្បាយទាំងភ្ញៀវ ទាំងអ្នកបម្រើភ្ញៀវក្នុងហាង ដែលគេនិយមឲ្យឈ្មោះរឿងទាំងអស់នោះថា «**រឿងឥតស្តេច**»? ។

# ១៩-ចម្រៀងខ្សែមួយ ឬចម្រៀងសាដៀវ



## ប្រវត្តិចម្រៀងខ្សែមួយ ឬចម្រៀងសាដៀវ

*ខ្សែមួយ ឬសាដៀវជាឧបករណ៍តន្ត្រី គ្រឿងកេះតែ្រះ ឬដេញមួយប្រភេទរបស់ខ្មែរយើង ដែលរួមផ្សំប្រកបប្រគំនៅក្នុងវង់ភ្លេងអារក្ខ ដែលគេជឿថា មានអាយុច្រើនពាន់ឆ្នាំមកហើយ ពោលគឺតាំងពីពេលមុនព្រះពុទ្ធសាសនា និងព្រហ្មញ្ញ*

www.elibraryofcambodia.org

សាសនា ហូរចូលមកតំបន់ជ្រោយសុវណ្ណភូមិយើងនេះម្ល៉េះៗ ម្យ៉ាងទៀតឧបករណ៍តន្ត្រីខ្សែមួយនេះក៏ជាឧបករណ៍មួយផ្សំ ប្រកបនៅក្នុងវង់ភ្លេងប្រពៃណីខ្មែរ «ភ្លេងការ» ដែលគេជឿថា មានអាយុកាលតាំងពីការកកើតឡើងនៃព្រះរាជវង្ស ព្រះបឋមមហាក្សត្រខ្មែរ ពិសេសគឺជាកេរដំណែលដែលចេញមកពីពិធីរាជាភិសេក **«អាពាហ៍ពិពាហ៍»** រវាងព្រះថោង និងនាងនាគ ឬកៅណ្ឌិន្យ និងព្រះនាងសោមា ឬក៏ព្រះបាទហ៊ុនទៀន និងព្រះនាងលីវយី នៅដើមសតវត្សរ៍ទី ១ នៃ គ.ស នោះឯងៗ ហើយរហូតមកដល់សព្វថ្ងៃនេះ គេសង្កេតឃើញមានរូបចម្លាក់នៃឧបករណ៍តន្ត្រីនេះនៅលើផ្តែរ ឬជញ្ជាំងប្រាសាទជាច្រើនដូច ជាប្រាសាទសម្បូរណ៍ព្រៃគុហ៍ ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទដទៃទៀតៗលៗ ឧបករណ៍តន្ត្រីនេះមានខ្សែតែមួយដែលវេញដោយសរសៃសូត្របញ្ចូលគ្នា (ឥឡូវគេប្រើខ្សែលួសជំនួសវិញ) ដាក់សណ្ដូក តាមបណ្ដោយដងយ៉ាងវែង ដែលធ្វើពីឈើរឹងហើយភាគច្រើនចេនាជា រូបក្បាលពស់ ឬនាគផង ដោយចងខ្សែនោះពីចុងដងមកចងភ្ជាប់នឹងព្រលួត ដែលនៅខាងគល់ដង (ខុសពីឧបករណ៍ចាប៉ីដែលព្រលួតសម្រាប់តែសំឡេងស្ថិតនៅខាងចុងដង) ហើយដោយមានយកសម្បកឃ្លោកទុំ (ឃ្លោកក្ដម) កាត់មួយកំណាត់មកចងភ្ជាប់ និងដងជិតព្រលួត ដោយយកផ្នែកកស្តួចនៃសម្បកឃ្លោកនោះ ទៅចងជាប់នឹងគល់ដង ដើម្បីធ្វើជាប្រអប់សំឡេងៗ ឃ្លោកដែលជាប្រអប់សំឡេងនេះមិនមានសន្ទះទេ គឺគេទុកឲ្យនៅប្រហោងដូចសម្បកឃ្លោកធម្មតា ដល់ពេលគេប្រគំ គឺគេយកសម្បកឃ្លោកនោះមកដាក់ផ្ទប់នឹងដើមទ្រូងតន្ត្រីករអ្នកប្រគំ ឬដេញឧបករណ៍ខ្សែមួយនេះដើម្បីឲ្យមានសំឡេងខ្ទរខ្ទើងៗ គេកេះ ឬត្រេះ ឬដេញឧបករណ៍មួយនេះដោយក្រចកធ្វើពីបន្ទះលោហធាតុមូរសើកនឹងនាងដៃៗ អាស្រ័យដោយឧបករណ៍នេះមានគិនភាគពិសេសយ៉ាងដូច្នេះហើយ ទើបខ្មែរយើងនិយមឲ្យឈ្មោះថា ខ្សែមួយ ឬសាដៀវយ៉ាងដូច្នេះៗ

www.elibraryofcambodia.org

ចំណែកខាងចម្រៀងខ្មែរមួយ ឬចម្រៀងសារដៀវវិញ មិនខុសអ្វីពីចម្រៀងចាប៉ីរឿង ឬចាប៉ីឆ្លងឆ្លើយឡើយ គឺជាប្រភេទចម្រៀងរៀបរាប់រឿង និងពេលខ្លះជាចម្រៀងដេញប្រាជ្ញា ចោទឆ្លើយគ្នាជាកំណាព្យកាព្យឃ្លោង ឥតព្រាងទុកយ៉ាងប៉ុនប្រសប់ ដោយអ្នកចម្រៀងខ្លួនឯងត្រូវច្រៀងផង ដេញសារដៀវខ្លួនឯងផង ឬពេលខ្លះក៏មានអ្នកដេញសារដៀវជំនួសផងក៏មានៗ

ជាភាពជាក់ស្តែង នៅក្នុងសង្គមកម្ពុជា សិល្បៈចម្រៀងខ្មែរមួយ ក៏ដូចជាសិល្បៈចម្រៀងចាប៉ីដែរ គឺជាប្រភេទសិល្បៈផ្នែកគំនិតស្ងប់ស្ងៀមមិនអាសអាភាស ប៉ុន្តែមានតួនាទីយ៉ាងសំខាន់ ក្នុងការកសាងធនធានមនុស្សខ្មែរ ទាំងឲ្យមានចំណេះដឹង ទាំងឲ្យមានចំណេះធ្វើ កសាងសីលធម៌សង្គម ជួយជំរុញឲ្យសង្គមជាតិរស់រានប្រកបដោយធម៌យោគយល់ សុខសុភមង្គលៗ គេមានជំនឿជឿជាក់ថា តាំងពីយូរលង់ណាស់មកហើយចម្រៀងសារដៀវ ឬចម្រៀងខ្មែរមួយនេះ (តិច ឬច្រើន) តែងហានវត្តមានជានិច្ច ក្នុងសង្គមជាតិកម្ពុជា ជាសិល្បៈមួយប្រភេទសម្រាប់ការអប់រំៗ

រហូតមកដល់អំឡុងចុងសតវត្សរ៍ទី ១៩ ដើមសតវត្សរ៍ទី ២០ ចម្រៀងខ្មែរមួយ ឬសារដៀវនេះបានត្រូវលេចមុខកាន់តែខ្លាំងឡើងនៅក្នុងសង្គមជាតិកម្ពុជា ដោយនៅអំឡុងពេលនោះ សង្គមបរិយាកាសនៅកម្ពុជាត្រូវប្តូរផ្លាស់យ៉ាងខ្លាំង ព្រោះអាណានិគមនិយមបារាំងបានប្រើអំណាចរំលោភទាំងកំរោល បង្ខំដាក់ប្រទេសកម្ពុជាឲ្យទៅជាប្រទេសអាណានិគមរបស់ខ្លួនចាប់ពីឆ្នាំ ១៨៨៤ (១) ដែលពីមុនពេលនេះ ប្រទេសកម្ពុជាជាប្រទេសស្ថិតក្នុងអាណាព្យាបាលរបស់ប្រទេសបារាំងនោះៗ ក្នុងកំឡុងពេល ដែលប្រទេសជាតិជួបវិបត្តិយ៉ាងច្រើនវាប៉ះពាល់ដល់គ្រប់វិស័យរបស់សង្គមជាតិ ក៏ដូចជាជីវភាពរស់នៅរបស់ប្រជារាស្ត្រទូទាំងប្រទេសៗ ពេលនោះអ្នកប្រាជ្ញប្រជាប្រិយខ្មែរម្នាក់ គឺអ្នកព្រះតិរច្ឆានភាសា អ៊ូ ហៅក្រមង៉ុយ(១៨៦៥-១៩៣៦) បានដើរទេសន៍ ឬច្រៀងដើម្បីអប់រំជនជាតិខ្មែរ នៅគ្រប់ទីតំបន់ដោយប្រើឧបករណ៍តន្ត្រីខ្មែរមួយ ឬសារដៀវនេះ (ដែលលោកនិយម

www.elibraryofcambodia.org

យកសម្បកឃ្លោកចងក្នុងបង្ខិចស្ពាយ ហើយយកដងសាដៀវនោះធ្វើជាឈើច្រត់ក្នុងពេលធ្វើដំណើរកាត់ពីទីមួយទៅទីមួយទៀត ហើយលោកអាចយកសម្បកឃ្លោកក្នុងបង្ខិចនោះផ្គុំជាមួយដងដែលជាឈើច្រត់បានជាសាដៀវភ្លាមៗក្នុងពេលដែលលោកត្រូវការ ដើម្បីបានជាឧបករណ៍តន្ត្រី ផ្ទួនចម្រៀងរបស់លោកពន្យល់ប្រជារាស្ត្រអំពីការពិបាកសព្វបែបយ៉ាង ពីការបាត់បង់ឯករាជ្យ និងសេរីភាព ពន្យល់ណែនាំប្រជារាស្ត្រឲ្យខិតខំសិក្សារៀនសូត្រ ប្រឹងប្រែងប្រកបរបរចិញ្ចឹមជីវិត ទូន្មានប្រៀនប្រដៅឲ្យមានការប្រុងប្រយ័ត្នកុំឲ្យបែកបាក់គ្នា និងឲ្យខ្មែររួបរួមសាមគ្គីគ្នាជាដើម ។ល។ ដែលធ្វើឲ្យកិត្តិនាមរបស់លោកល្បីរន្ទឺយ៉ាងក្រៃលែង។

ប៉ុន្តែជាប្រការគួរឲ្យព្រួយបារម្ភណាស់ រហូតមកដល់ពេលនេះយើងសង្កេតឃើញថាឧបករណ៍ចាប៉ីដងវែង ក៏ដូចជាឧបករណ៍ខ្សែមួយ ឬសាដៀវដែរហាក់ដូចជាមានកម្រិតស្រុតចុះយ៉ាងខ្លាំង ក្នុងការសមប្រកបនៅក្នុងវង់ភ្លេងប្រពៃណី ឬភ្លេងការខ្មែរ ពិសេសគឺនៅរាជធានីភ្នំពេញនេះតែម្តង ដោយតន្ត្រីករភាគច្រើនច្រើនតែយកឧបករណ៍តន្ត្រីផ្សេងៗដូចជាឃឹម ឬក្រពើ (តាខេ) មកជំនួសវិញ (នេះប្រហែលជាមកពីឧបករណ៍ចាប៉ីដងវែង ឬសាដៀវខ្សែមួយ នេះពិបាករៀន ? ឬក៏ដោយប្រការណាផ្សេង?)។

ម្យ៉ាងទៀត ចំណែកខាងចម្រៀងសាដៀវ ឬចម្រៀងខ្សែមួយនេះវិញ យើងអាចជួបដោយកម្រក្នុងពេលបច្ចុប្បន្ននេះ ហើយបើបានឃើញម្តងម្កាលនោះយើងសង្កេតឃើញថា ច្រើនមានអ្នកច្រៀងដោយឡែក និងអ្នកដេញឧបករណ៍ខ្សែមួយ ឬសាដៀវកំដរ ឬផ្ទួនចម្រៀងនោះដោយឡែកទៀតផង ពេលគឺមិនដូចជាចម្រៀងចាប៉ីរឿង ឬចាប៉ីឆ្លងឆ្លើយឡើយដែលរហូតមកដល់ពេលនេះ យើងសង្កេតឃើញមានសិល្បករជាច្រើននៅទូទាំងប្រទេស ហើយឯការសម្តែងជូនប្រជាជនមហាជន ទាំងនៅរាជធានីភ្នំពេញ តាមខេត្តក្រុងនានា ក៏ដូចជាការផ្សាយតាមបណ្តាញទូរទស្សន៍ជាច្រើនខ្សែ និងចេញទៅសម្តែងនៅបរទេស ដូចជា

www.elibraryofcambodia.org

ប្រទេសបារាំង ឃើញថាមានចំនួនច្រើន ព្រមដោយគុណភាពដ៏នាំញញួរដោ
ទីមោទនៈយ៉ាងក្រៃលែង ៕

www.elibraryofcambodia.org

# ២១–ចម្រៀងចាប៉ី



## ប្រវត្តិចម្រៀងចាប៉ី

ចាប៉ីជាឧបករណ៍តន្ត្រីខ្មែរបុរាណមួយប្រភេទ ដែលជាគ្រឿងដេញ ឬកេះ ឬគ្រែះ ដែលមានខ្សែពីរ ធ្វើពីសរសៃសូត្រ វេញចូលគ្នា ឬក៏ខ្សែបួន ប៉ុន្តែមានសំនៀងតែពីរទេ គឺខ្សែទី១ (ឬទី១ + ទី២) មានសំឡេងតូច ហៅថា ខ្សែឯក និងខ្សែទី២ (ឬទី៣ + ទី៤) មានសំនៀងធំដែលគេឲ្យឈ្មោះថា ខ្សែគោ សូមបញ្ជាក់ថាខ្សែចាប៉ីដែល

www.elibraryofcambodia.org

ពីដើម ច្រើនធ្វើពីសរសៃសូត្រវេញបញ្ចូលគ្នានោះ ឥឡូវនេះគេច្រើនយកខ្សែជ័រនីឡុងមកប្រើជំនួសវិញដោយដាក់សណ្តូកខ្សែនេះបណ្តោយតាមដងពីលើក្រាញ ឬគីង្គក់ស្នូកតម្រៀបលើខ្នង តាំងពីគល់រហូតដល់ព្រលួត (សម្រាប់រឹតសំឡេងឲ្យតឹង ឬធូរ) ដែលស្ថិតនៅខាងចុងចាប៉ីៗ ម្យ៉ាងដោយឧបករណ៍ចាប៉ីនេះមានដងយ៉ាងវែង ដែលភ្ជាប់ពីស្នូក ឬពីប្រអប់សំឡេង ដែលធ្វើដោយឈើដែលខ្លះមានរាងស្មើរមូល ស្មើរជ្រុង ស្នូកខ្លះមានរាងដូចស្លឹកពោធិ៍ ខ្លះមានរាងដូចផ្លែម្នាស់និងស្នូកខ្លះមានរាងដូចសីមា (សីមាដែលគេដាក់តាំងក្នុងវត្តអារាម) ហើយមានខ្នងចំនួន ១២ ធ្វើអំពីឆ្អឹងរឹងដាក់តម្រៀបលើដងវែងនោះទើបខ្មែរនិយមហៅ ឬឲ្យឈ្មោះឧបករណ៍នេះថា ចាប៉ីដងវែងៗយ៉ាងដូច្នេះៗ ឯក្រចកសម្រាប់គ្រះ ឬដេញខ្សែចាប៉ីនោះវិញ ធ្វើអំពីចំណិតស្នែងគោ ឬស្នែងក្របី ដែលចិតជាបន្ទះយ៉ាងស្តើងហើយវែងៗ

ជាបទពិសោធរបស់ជនជាតិខ្មែរ បើគេចង់ធ្វើចាប៉ីឲ្យបានល្អ ឬមានសំឡេងល្អនោះ គេត្រូវអនុវត្តធ្វើវាទៅតាមពាក្យស្លោកចាស់បុរាណ ដែលបានបញ្ជាក់ពីបទពិសោធនេះ ពីយូរលង់ណាស់មកហើយ ដោយរើសយកសាច់ឈើ ឬវត្ថុធាតុដទៃទៀតដែលមាននៅក្នុងស្រុក មកផ្គុំផ្សំគ្នាឲ្យកើត ជារូបរាងចាប៉ីឡើង ដោយយក **«ស្នូករាំង ដងក្រសាំង សន្ទះក្នុម្ព គីង្គក់ធ្នុងខ្នងប៉ង្អើង»** ហើយគេច្រើននិយមឲ្យនិម្មិតរូបទៅលើឧបករណ៍ចាប៉ីនេះថា ជាតំណាងឲ្យតួសត្វនាគ (និម្មិតអម្បូរខ្មែរ) គឺស្នូកតំណាងក្បាលនាគ ដងយ៉ាងវែងតំណាងឲ្យខ្លួននាគ ឯប្រពៃ គឺភាគខាងចុងនៃដងចាប៉ី ដែលមានរាង ង.ទន្ទ្រាំនោះ តំណាងឲ្យកន្ទុយនាគថែមទៀងផងៗ

ចាប៉ីជាឧបករណ៍មួយ ដែលប្រគំជាមួយនឹងឧបករណ៍តន្ត្រីដទៃទៀតជាច្រើនក្នុងវង់ភ្លេងអារក្ខ ដែលជាវង់ភ្លេងមានកំណើតកើតច្រើនពាន់ឆ្នាំមកហើយនៅលើទឹកដីកម្ពុជានេះ ហើយមានតួនាទីយ៉ាងសំខាន់ក្នុងពិធីនានាខាងជំនឿអារក្ខ អ្នកតាដែលជាជំនឿដើមរបស់ជនជាតិខ្មែរ ហើយដែលគេជឿថា កើតមានតាំងពីមុន

www.elibraryofcambodia.org

ពេលដែលព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាហូរចូលមកដល់តំបន់នេះម៉្លេះ។

មួយចំណែកទៀតឧបករណ៍ចាប៉ីដងវែងនេះក៏ជាឧបករណ៍សមប្រកប ប្រគំនៅក្នុងវង់ភ្លេងប្រពៃណីខ្មែរ គឺ «**ភ្លេងការ**» ដែលគេជឿថាមានកំណើតតាំងពីសតវត្សរ៍ទី ១ នៃ គ.ស ពិសេសគឺចាប់ផ្តើមពីពិធីអភិសេក (អាពាហ៍ពិពាហ៍) ព្រះថោង និងនាងនាគ (កៅណ្ឌិន្យ និងព្រះនាងសោមា ឬហ៊ុនទៀន និងនាងលីវយី) ដែលជាព្រះបឋមមហាក្សត្រខ្មែរមក ហើយដែលត្រូវជនជាតិខ្មែរប្រកាន់យកជាទំនៀមទម្លាប់ ប្រពៃណីរបស់ជាតិខ្លួនយ៉ាងខ្ជាប់ខ្ជួន និងមានសារៈសំខាន់បំផុតក្នុងជីវិតរបស់ខ្លួន មកដល់ពេលបច្ចុប្បន្ននេះ។

ចំណែកខាងចម្រៀងចាប៉ីវិញ គឺជាប្រភេទសិល្បៈចម្រៀងទោល (ច្រៀងម្នាក់ឯង) ឬក៏ជាចម្រៀងឆ្លងឆ្លើយគ្នារវាងដៃគូពីរនាក់ (ដែលជួនកាល មានសិល្បករប្រុស និងប្រុសម្នាងម្នាក់ ឬជួនកាលសិល្បករប្រុសម្នាង និងស្រីម្នាង) ច្រៀងឆ្លងឆ្លើយគ្នាមានកេះ ឬដេញចាប៉ីនេះខ្លួនឯងក៏ដេរចម្រៀង ឬជួនចម្រៀងនោះផង។

ចំពោះចម្រៀងចាប៉ីទោល ឬចម្រៀងចាប៉ីដែលច្រៀងម្នាក់ឯង ភាគច្រើនគឺច្រើនតែច្រៀងអំពីរឿងជាតក ឬរឿងនិទាន ឬរឿងប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ប្រពៃណី ប្រវត្តិភូមិស្រុក ប្រវត្តិអ្នកតាចាស់ស្រុក ម្ចាស់ទឹក ម្ចាស់ដីៗលៗ ដែលអ្នកស្រុកនិយមហៅថា «**ចាប៉ីរឿង**»។ ចាប៉ីរឿងនេះមានប្រជាប្រិយភាពណាស់នៅប្រទេសកម្ពុជា ព្រោះក្នុងពិធីបុណ្យខាងសាសនាក្តី ពិធីបុណ្យគ្រួសារតាមភូមិស្រុកក្តី ឬពិធីបុណ្យផ្សេងៗឯទៀតក្តី ពិសេស គឺនៅជនបទ គេច្រើនតែអញ្ជើញអ្នកច្រៀងចាប៉ីទៅច្រៀង ជារឿយៗនៅទីអារាម ឬក៏ក្នុងភូមិដើម្បីកំដរ ពិធីបុណ្យឲ្យបានអឹកធឹកផង បានកែកម្សាន្តផង និងជាឱកាស ឬមធ្យោបាយដ៏ល្អ ដើម្បីអប់រំទូន្មាន ប្រៀនប្រដៅកុលបុត្រកុលធីតាឲ្យមានព្រហ្មវិហារធម៌ គឺមានមេត្តា ករុណា មុទិតា ឧបេក្ខាផង ព្រមទាំងមានការទូន្មានតាំងពីការសន្រ្ទួមឥរិយាបថ ដេកដើរ

www.elibraryofcambodia.org

ឈរអង្គុយនិយាយស្ដី បង្កើតចិត្តសន្ដោសប្រោសប្រណី ចេះយោគយល់ និងជួយទុក្ខធុរៈផងគ្នា ដែលជាបច្ច័យសំខាន់ ក្នុងការរួមចំណែកកសាងសីលធម៌សង្គមជាតិឲ្យមានកម្ពស់ខ្ពស់ត្រដែតឡើង ចាកអំពើឃោរឃៅហិង្សាថែមទៀតផងៗ

អ្នកស្ដាប់ដែលភាគច្រើនអង្គុយលើកន្ទេលស្លឹកត្នោត ឬកន្ទេលចចូតក្រាលផ្ទាល់ដី ឬពេលខ្លះលើកន្ទេលក្រហមក្នុងសាលាឆាន់ ឬរោងបុណ្យ សង្រ្គួលតរិយាបថផ្ទៀងសោតាស្ដាប់នូវសំនួនពោហារ និងសំនៀងដ៏ពីរោះរបស់អ្នកចម្រៀងចាប៉ីដែលពេលខ្លះធ្វើឲ្យកើតមនោសញ្ចេតនាកម្សត់ លន្លង់លន្លោចអត់ទ្រាំ និងទប់ទឹកភ្នែកមិនបាន និងពេលខ្លះទៀតធ្វើឲ្យអ្នកស្ដាប់ផ្ទុះសំណើចសើចតឹលឡើង ទៅតាមការរៀបរាប់កំប្លុកកំប្លែងពីតួអង្គយក្ខ ឬពីកូនស្រីយក្ខ ដែលមានលក្ខណៈមិនប្រក្រតីនោះៗ

ចំណែកខាងចាប៉ីឆ្លងឆ្លើយវិញ មិនខុសអីពីសិល្បៈអាយ៉ៃឆ្លងឆ្លើយឡើយ គឺជាប្រភេទសិល្បៈដេញប្រាជ្ញាគ្នា ដោយអ្នកចម្រៀងម្នាក់ច្រៀងចោទសួរជាចំណោទជាប្រស្នាផ្សេងៗ (ល្បែងដេញប្រាជ្ញា) ហើយអ្នកច្រៀងម្នាក់ទៀត ជាអ្នកច្រៀងរៀបរាប់ឆ្លើយដោះប្រស្នានោះបំភ្លឺ ដោយប្រើពាក្យពេចន៍ជាកំណាព្យកាព្យឃ្លោងឥតព្រាងទុកជំពុំនប្រសប់ ដែលទុកឱកាសឲ្យអ្នកស្ដាប់ជាអាជ្ញាកណ្ដាល ឬអ្នកវាយតម្លៃៗ ហើយពេលខ្លះមានទាំងពាក្យលែបខាយ បន្ដុះបន្ដាប់គ្នាដើម្បីកែកម្សាន្តថែមទៀតផងៗ

ជាទូទៅ នៅក្នុងព្រះរាជពិធីចម្រើនព្រះជន្មវស្សាព្រះមហាក្សត្រ ពិធីបុណ្យតាំងតួ អុំទូក អកអំបុក សំពះព្រះខែ ដែលប្រារព្ធធ្វើនៅរាជធានីភ្នំពេញជារៀងរាល់ឆ្នាំ គេតែងសង្កេតឃើញមានវត្តមានការសម្ដែងសិល្បៈ អាយ៉ៃឆ្លងឆ្លើយ អាយ៉ៃរឿង សិល្បៈចម្រៀង ចាប៉ីរឿង ឬចាប៉ីឆ្លងឆ្លើយជានិច្ច តាំងពីយូរលង់មកហើយ រហូតដល់សព្វថ្ងៃនេះៗ

សូមបញ្ជាក់ផងដែរថា សិល្បៈចម្រៀងចាប៉ី ជាសិល្បៈប្រភេទស្មុគស្មាញខ្ពង់

www.elibraryofcambodia.org

ខ្ពស់ ជាសិល្បៈប្រភេទអប់រំហើយស៊ីជម្រៅខ្លាំងណាស់ ទៅក្នុងសន្តានចិត្តខ្មែរគ្រប់រូប ហើយក៏ជាប្រភេទសិល្បៈ ដែលមានប្រជាប្រិយភាពបំផុតផង ក្នុងចំណោមប្រជាជនមហាជន ជនជាតិខ្មែរតាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្ននេះ។

www.elibraryofcambodia.org

# ២២-សៀកខ្មែរ



www.elibraryofcambodia.org

# ប្រវត្តិសិល្បៈសៀក

សិល្បៈសៀក ជាទម្រង់សិល្បៈទស្សនីយភាពមួយប្រភេទ ដែលមានវត្តមានតាំងពីយូរលង់ណាស់មកហើយនៅប្រទេសកម្ពុជា ហើយប្រហែលត្រូវបានរីកចម្រើនយ៉ាងខ្លាំងក្លាណាស់ផង នៅក្នុងសម័យមហានគរ ព្រោះបើយើងពិនិត្យមើលរូបចម្លាក់នៅប្រាសាទបាពួន ស្ថាព្រះហស្ត ព្រះបាទឧទ័យទិត្យាវរ្ម័នទី ២ (១០៥០-១០៦៦ ឥស្វរនិយម)ៗ ប្រាសាទអង្គរវត្តស្ថាព្រះហស្តព្រះបាទសុរិយាវរ្ម័នទី ២ (១១១៣-១១៥២ វិស្ណុនិយម) និងចម្លាក់នៅលើផ្ទាំងប្រាសាទបាយ័ន ដែលជាស្ថាព្រះហស្តព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២១៨? ពុទ្ធសាសនាមហាយាន) ដែលភាគច្រើននៃចម្លាក់ប្រាសាទនេះច្រើនរៀបរាប់អំពីជីវភាពប្រចាំថ្ងៃ របស់ប្រជារាស្ត្រជាទូទៅ ឬចម្លាក់នានានៅព្រះលានជល់ដំរី ឬព្រះលានស្តេចគម្លង់ និងប្រាសាទដទៃខ្លះផងនោះ យើងឃើញមានចម្លាក់ជាច្រើន ដែលរៀបរាប់ឆ្លុះបញ្ចាំងអំពីរូបភាពសិល្បៈសៀក ក្នុងសម័យនោះដូចជាឈុតត្រែះបង្វិលកង់រទេះដោយជើងៗ ឈុតសម្តែងលំនឹងដោយមនុស្សប្រុសម្នាក់ទ្រក្មេងបីនាក់ ដោយឲ្យក្មេងពីរនាក់ឈរជើងមួយលើបាតដៃ ម្ខាងម្នាក់ និងឲ្យក្មេងម្នាក់ទៀតឈរជើងមួយដែរ លើក្បាលរបស់ខ្លួនផងៗ ឈុតមនុស្សធំម្នាក់យកអង្រែមួយ ដែលមានរាយឈើវែងទៅចុងខាងលើ ដាក់ទូលបញ្ឈរលើក្បាល ហើយឲ្យក្មេងពីរនាក់ឡើងទៅសម្តែងកាយវិការ ពត់ខ្លួនបន្តោកនៅចុងអង្រែខាងលើនេះៗ

-ឈុតរែកបាវយ៉ាងធ្ងន់ដើរស្ទូលើព្រ័ត្រ ឬខ្សែពួរដែលគេចងសន្ទឹងយ៉ាងតឹងលើបង្គោលខ្ពស់ៗ

-ឈុតជិះរទេះសេះយ៉ាងលឿន ឈរតម្រៀបជាន់លើគ្នាច្រើនជាន់ៗ

-ឈុតខាំកាំបិតវែងបញ្ឈរ រួចយកចុងកាំបិតខ្លី ដាក់បញ្ឈរត្រួតពីលើកាំបិតវែងទៀតៗ

- ឈុតបង្ហាញបច្ចេកទេសកាយសម្ព័ន្ធៗ

www.elibraryofcambodia.org

-បច្ចេកទេសរហស្សកម្ម និងមានឈុតបង្ហាញពីបច្ចេកទេសបង្ហាត់សត្វយ៉ាងច្រើនថែមទៀតផង ហើយឈ្មោះប្រាសាទសួព្រ័ត្រ ក៏ប្រហែលជាមានទំនាក់ទំនងនឹងទម្រង់សិល្បៈសៀក ក្នុងសម័យមហានគរនោះផងដែរ។

យើងមិនបានដឹងទេថា តើសិល្បៈសៀកនេះនៅសម័យអង្គរគេឲ្យឈ្មោះជាអ្វី? ប៉ុន្តែយើងគ្រាន់តែអាចប៉ាន់ស្មានបានថា ក្រោយពីអរិយធម៌មហានគររលំរលាយទៅតាំងពីក្នុងអំឡុងពាក់កណ្តាល ស.វ.ទី១៤ មក ប្រភេទសិល្បៈសៀកនេះក៏ប្រហែលជាបានវិនាសសាបសូន្យទៅផងដែរ។ ក្រោយពេលនោះនៅក្នុងសង្គមខ្មែរមានសល់តែបច្ចេកទេសរហស្សកម្មបន្តិចបន្តួច ដែលគេនិយមហៅថា ល្បែងធ្មិនភ្នែក សម្តែងដោយបុគ្គល ដែលមាននិស្ស័យពីធម្មជាតិមិនមានការរៀបចំ ឬអប់រំឡើយ ហើយដែលភាគខ្លះបានធ្វើឲ្យមនុស្សជឿថា ជាមន្តអាគមទៅវិញថែមទៀតដូចជា យកអង្ករបាចទៅកើតជាកំពីសរស់លោតព្រោងព្រាតពេញចង្អេរ ឬរើសស្លឹកឈើយកមកក្តាប់ញីនឹងបាតដៃ ធ្វើល្បិចជាសូត្រមន្តអាគមរួចផ្លុំ ហើយលាបាតដៃគេវិញ ចេញបានជាកូនសត្វកណ្តុរតូចៗ ឬអ្នកខ្លះទៀតចេះពត់ខ្លួនឲ្យទន់ភ្លន់ រហូតដល់អ្នកមើលដាក់លុយផ្ចាល់នឹងដីឲ្យអ្នកនោះពត់ផ្ងារខ្លួនឱនក្បាលមកក្រោមចន្លោះជើងខ្លួន ខាំយកលុយនោះថែមទៀតផង។ បើតាមព័ត៌មានដែលយើងទទួលបានចាប់តាំងពីសម័យបែកអង្គរ (១៣៥៣?) រហូតមកដល់ឆ្នាំ ១៩៧០ ពោលគឺពេលសង្គ្រាមស៊ីវិលដ៏កាចសាហាវ នាចុងសតវត្សរ៍ទី២០នេះបានផុះឡើង សិល្បៈសៀកខ្មែរ មិនដែលមានវត្តមានជាផ្លូវការឡើយ។

រហូតមកដល់អំឡុងឆ្នាំ១៩៨០ ឬ១៩៨១ គឺរយៈពេលមួយឆ្នាំ ឬពីរឆ្នាំក្រោយពេលដែលរបបប្រល័យពូជសាសន៍ប៉ុល ពត ដែលធ្វើឲ្យខ្មែរអោម៉ាស់បានដួលរលំទៅដោយមានជំនួយពីបរទេស ពិសេសគឺសហភាពសូវៀត និងវៀតណាមផង ពោលគឺនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ទើបក្រសួងវប្បធម៌ខ្មែរបានបង្កើតឲ្យមានក្រុមសិល្បៈសៀក ដែលបានទទួលការអប់រំរៀនសូត្របច្ចេក

www.elibraryofcambodia.org

ទេសនានាក្នុងស្រុកផង ហើយបញ្ជូននិស្សិតឲ្យទៅរៀនជំនាញសៀកនេះនៅបរទេសផង ។

គឺចាប់ពីពេលនោះមកហើយ ដែលប្រទេសខ្មែរយើងមានទម្រង់សិល្បៈសៀក និងមានសិល្បករសៀកធ្វើសកម្មភាពសម្តែងជាផ្លូវការ ទាំងក្នុងឆាកជាតិ និងឆាកអន្តរជាតិឡើងវិញ ។

www.elibraryofcambodia.org

# ស្នាដៃបោះពុម្ពសៀវភៅហើយ

១- ស្បែកធំ (បោះផ្សាយដោយ UNESCO)
២- ស្បែកធំ និងស្បែកតូច (ផ្សព្វផ្សាយដោយក្រសួងវប្បធម៌)
៣- យីកេរឿងម៉ាក់ថឺង (ផ្សព្វផ្សាយដោយក្រសួងវប្បធម៌)
៤- សិល្បៈតែងកំណាព្យ (ដោយក្រសួងវប្បធម៌ និង UNESCO)
៥- ចម្រៀងចម្រិតដៃក
៦- ដំណើរជាតិកម្ពុជា (ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ)
៧- របាំខ្មែរ (ជំនួយអង្គការ តូយូតា)
៨- ល្ខោនខោល (ជំនួយអង្គការ តូយូតា)
៩- ទស្សនីយភាពខ្មែរ (រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា)
១០- យីកេ និងល្ខោនបាសាក់ (ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ)
១១- ស្បែកពណ៌ និងស្បែកតូច (ជំនួយអង្គការ តូយូតា)
១២- ឈាមតែមួយ (អង្គការField Relief Agency)
១៣- យីកេរឿងទុំទាវ (អង្គការField Relief Agency)
១៣- ជីវិតជាតិកម្ពុជា (អង្គការField Relief Agency)
១៥- រឿងលោហិតជាតិកម្ពុជា (អង្គការField Relief Agency)

www.elibraryofcambodia.org

# ស្នាដៃរឿងល្ខោន

១- វិប្បដិសារីនៃព្រានព្រៃ (ល្ខោនមហោរី)
២- ប្រហែសបាត់ប្រយ័ត្នគង់ (ល្ខោនមហោរី)
៣- យុវវស្ត្រីខ្មែរ (ល្ខោនយីកេ)
៤- មិនខ្វះទេអ្នកស្រលាញ់យុត្តិធម៌ (ល្ខោនមហោរី)
៥- តេមិយកុមារ (ល្ខោនមហោរី)
៦- សុវណ្ណសាម (ល្ខោនមហោរី)
៧- ហង្សពិការ (ល្ខោនមហោរី)
៨- កោះសន្តិភាព (ល្ខោនបាសាក់)
៩- ទិព្វសង្វារ (ល្ខោនបាសាក់)
១០- ចៅក្រិស្នា (ល្ខោនភាពយន្ត)
១១-ករណីកិច្ចទី២ (ល្ខោននិយាយ)
១២- ដំណើរខ្មែរ (ល្ខោននិយាយ)
១៣- ដីខ្មែរឈាមខ្មែរ (ឧកញ៉ា ស៊ឹន គុយ) (ល្ខោននិយាយ)
១៤- រដ្ឋាភិបាលចម្រុះ (ល្ខោននិយាយ)
១៥- ឈាមតែមួយ (ល្ខោននិយាយ)
១៦- សម្ពស្សខ្មែរក្រោយអង្គរ (ល្ខោននិយាយ)
១៧- សិល្បៈឥតសោភ័ណ (ល្ខោននិយាយ)
១៨- ទុំទាវ (ល្ខោនយីកេ)
១៩- ម៉ាក់ថឺង (ល្ខោនយីកេ)
២០- ដំណើរជាតិកម្ពុជា (ល្ខោនចម្រុះ)
២១- ដំណើរជាតិឡាវ (ល្ខោនចម្រុះ)

www.elibraryofcambodia.org

២២- លោហិតជាតិកម្ពុជា (ល្ខោនចម្រុះ)
២៣- ជីវិតជាតិកម្ពុជា (ល្ខោនចម្រុះ)

www.elibraryofcambodia.org

# ជីវប្រវត្តិសង្ខេប



កើតថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ១៩៤៣
នៅភូមិសសី ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល ។
ជាបុត្ររបស់លោក ជួន ឈង និងអ្នកស្រី ញូង យ៉ុម
(កសិករ)

-ឆ្នាំ២០០៤ : ទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋមន្ត្រី ។

-ឆ្នាំ២០០២ : វរសិល្បករកម្ពុជា ។

-ឆ្នាំ២០០១ : វិញ្ញាបនប័ត្រ Palme Accadémique ក្រសួងអប់រំ សាធារណរដ្ឋបារាំង ។

-ឆ្នាំ២០០១ : វិញ្ញាបនប័ត្រ ព្រឹទ្ធាចារ្យ វប្បធម៌សិល្បៈ រាជបណ្ឌិតសភាកម្ពុជា ។

-ឆ្នាំ១៩៩៩ : អ្នកនិពន្ធខ្មែរទី១ ដែលទទួលពានរង្វាន់តែងនិពន្ធអាស៊ាន
-ប្រធានគណៈកម្មការស្រាវជ្រាវសិល្បៈប្រចាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

-ឆ្នាំ១៩៩៨ : អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

-ឆ្នាំ១៩៩៧-៩៨ : ធ្វើការនៅវិទ្យុអាស៊ីសេរី ក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ។

www.elibraryofcambodia.org

-ឆ្នាំ១៩៨២-៩៣ : ប្រធាននាយកដ្ឋានសិល្បៈ ក្រសួងវប្បធម៌ និងព័ត៌មាន ។ ធ្លាប់ជាជំនាញការខាងវប្បធម៌ នៅសាធារណៈរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ (ឆ្នាំ ១៩៨៤-១៩៨៥)។

-ឆ្នាំ១៩៧៩-៨១ : អនុប្រធាននាយកដ្ឋាន នៃក្រសួងវប្បធម៌ និងព័ត៌មាន។

-ឆ្នាំ១៩៧៥-៧៨: ទាសករនៅស្រុកឧដុង្គ តំបន់ ៣២ នាសម័យប្រល័យពូជសាសន៍ ប៉ុលពត ។

-ឆ្នាំ១៩៦៩-៧៥ : នាដករនៅអគ្គិរក្សមន្ទីរជាតិនៃទស្សនីយភាពនិងបង្រៀននៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ក្រុងភ្នំពេញ និងមជ្ឈមណ្ឌលវប្បធម៌ ដែលមានទីតាំងនៅខេត្តសៀមរាប ។

-ឆ្នាំ១៩៦៥-៦៧ : និស្សិតនៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

-ឆ្នាំ១៩៦៣-៦៤ : សិស្ស នៃសាលាជាតិផ្នែកល្ខោន (ល្ខោនជាតិ)

-ឆ្នាំ១៩៦០-៦៣ : សិស្សនៃវិទ្យាស្ថានជាតិគរុកោសល្យរាជធានីភ្នំពេញ ។

www.elibraryofcambodia.org

# ឯកសារពិគ្រោះ

កែវ ណារុំ, **តន្ត្រី និងជីវិតខ្មែរ**, *១៩៩៥*

ឆត្រា ប្រែមប្ញី, **ខ្មែរខម**, *១៩៧៤*

— **នគរគោកធ្លក**, *១៩៩៣*

ឆេង ផុន, **គ្រូនិងសិស្ស**, *មជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា*

— **សិល្បៈទេវៈ**, *មជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា*

ជួន ណាត (*សម្ដេចព្រះសង្ឃរាជ*), **វចនានុក្រមខ្មែរ**, *បោះពុម្ពលើកទី ៥ ដោយពុទ្ធសាសនបណ្ឌិត្យ ១៩៦៧-១៩៦៨*

— **ស្នាព្រះហស្តក្រោយបង្អស់នៃសម្ដេចព្រះមហាសុមេធាធិបតី**, *ពុទ្ធសាសនបណ្ឌិត្យ ១៩៩៣*

តូច ឈួង, **បាត់ដំបងសម័យលោកម្ចាស់**, *ក្រោមការឧបត្ថម្ភនៃមជ្ឈមណ្ឌលបូព៌ាបស្ចិម ក្រុងហូណូលូលូ រដ្ឋហាវ៉ៃ*

ត្រឹង ងា, **ប្រវត្តិសាស្ត្រខ្មែរ**, *វគ្គ១ វគ្គ២ ១៩៧៣*

ប៉ាង ខាត់ (*ព្រះតេជព្រះគុណ*) **ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ**, *ពុទ្ធសាសនបណ្ឌិត្យ*

ពិ–ប៊ុន្នីន, **រាមកេរ្តិ៍**, *ពោលដោយ តាសយ, ២០០០*

ពេជ្រ ជុំក្រាវ៉ុល, **សិល្បៈតែងកំណាព្យ**, *អាគារបោះពុម្ពផ្សាយវប្បធម៌ ឆ្នាំ១៩៨៥*

— **ស្បែកធំ**, UNESCO SEAP Cornell 1995

— **យីកេ និងបាសាក់**, *សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ១៩៩៧*

— **ល្ខោនខោល**, *មូលនិធិតូយ៉ូតាជប៉ុន ឆ្នាំ ២០០០*

— **ស្បែកពណ៌ និងស្បែកតូច**, *មូលនិធិតូយ៉ូតាជប៉ុន ឆ្នាំ ២០០០*

— **របាំខ្មែរ**, *មូលនិធិតូយ៉ូតាជប៉ុន ២០០១*

— **ចំរៀងចម្រៀងដែក**, *២០០២*

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ទៅ យុនសំរ៉ង ខ្ទៅ យ៉ាតណៃ ខ្ទៅសុខផល ខ្ទៅ វិសាល ខ្ទៅ រ៉ាមុន
ខ្ទៅ ភារាដា ខ្ទៅ ចំរើន ខ្ទៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ទៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ គីម វាសនា

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org







មានលក់ ដុំ និង រាយ

នូវសៀវភៅធម៌គ្រប់ប្រភេទ នៅ

បណ្ណាគារវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

**Buddhist Institute Book Shop**

អាស័យដ្ឋាន: អាគារថ្មីជាប់សួនច្បារ សម្តេចតេជោ **ហ៊ុន សែន**

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

Address: Adjacent to Hun Sen Park, Tonle Basak, ChamKarmon, Phnom Penh.

Tel: 016 595 427
092 253 332

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព !!!



www.elibraryofcambodia.org